# សទ្ទានុក្រម បាលី-ខ្មែរ

ស្រាវជ្រាវ និងចងក្រងដោយ

ឯកឧត្តម មិន ឃិន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងធម្មការ និង សាសនា

លេខ ០០២/១៣ ក.ធ.ស.រ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ។*

**កម្មវត្ថុ** : គោរពជូននូវ**សៀវភៅសទ្ទានុក្រមបាលី-ខ្មែរ** ចំនួន ០១ ក្បាល, **សៀវភៅភាសាបាលី** ថ្នាក់ទី១ ចំនួន ០១ ក្បាល និង**សៀវភៅពុទ្ធវិន័យ ពុទ្ធប្បវត្តិ ពុទ្ធសាសនា** ចំនួន ០១ ក្បាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា : ក្នុងស្មារតីអនុវត្តន៍អនុសាសន៍ណែនាំ ដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** លើការយកចិត្តទុកដាក់ស្រាវជ្រាវ និងចងក្រងឯកសារ តម្រា ក្បួនច្បាប់ ពិធីមង្គល និងពិធីបុណ្យផ្សេងៗ របស់ខ្មែរនោះ ចាប់តាំងពីឆ្នាំ២០១០ មក ខ្ញុំបាទបានដឹកនាំក្រុមការងារព្រឹទ្ធសាស្ត្រាចារ្យ និងព្រឹទ្ធាចារ្យ ដែលមានចំណេះដឹងជ្រៅជ្រះផ្នែកភាសាបាលី-សំស្ក្រឹត និងប្រពៃណីទំនៀមទំលាប់ខ្មែរ ធ្វើការស្រាវជ្រាវ ដើម្បីចងក្រងជាឯកសារ ទុកជាកេរ្តិ៍តំណែលរបស់ជាតិ និងសាសនា ក្នុងសម័យដឹកនាំដ៏រុងរឿងនៃសម្តេចតេជោ នាយករដ្ឋមន្ត្រី ។

ក្រោយពីបានត្រួតពិនិត្យវាយតម្លៃលក្ខណៈវិជ្ជមានពីក្រុមការងារស្រាវជ្រាវ គណៈសង្ឃនាយក និងថ្នាក់ដឹកនាំក្រសួងរួចមក ក្រសួងធម្មការ និងសាសានា បានចងក្រងចេញជាសៀវភៅសទ្ទានុក្រមបាលី-ខ្មែរ ចំនួន ០១ ក្បាល មាន ៨៧៤ ទំព័រ និងមានមេពាក្យភាសាបាលី ចំនួន ១៤,៦០១ ពាក្យ សម្រាប់ព្រះសង្ឃ សមណសិស្ស-និស្សិត និងពុទ្ធបរិស័ទបានសិក្សាស្វែងយល់បន្តទៀត ។ ជាងនេះទៅទៀត សៀវភៅសទ្ទានុក្រមបាលី-ខ្មែរនេះ ក្រសួងនឹងសហការជាមួយដៃគូអភិវឌ្ឍន៍ នឹងរៀបចំបញ្ចូលជាកម្មវិធីវចនានុក្រមអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ជាមួយប្រព័ន្ធកុំព្យូទ័រ ឱ្យមានលក្ខណៈងាយស្រួលសិក្សាស្រាវជ្រាវទៀតផង ។

ដោយឡែកនៅក្នុងវិស័យពុទ្ធិកសិក្សា ក្រសួងក៏បានរៀបចំចងក្រង និងបោះពុម្ពចេញជា **សៀវភៅ ភាសាបាលី** ថ្នាក់ទី១, **សៀវភៅពុទ្ធវិន័យ ពុទ្ធប្បវត្តិ ពុទ្ធសាសនា** ថ្នាក់ទី១ សម្រាប់ដាក់ឱ្យប្រើប្រាស់នៅតាមបណ្តាសាលាពុទ្ធិកសិក្សានៅទូទាំងព្រះរាជាណាចក្រកម្ពុជា ផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

សូម**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

22.1-13

**មិន.ឃិន**

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ-កាលប្បវត្តិ

# ៣១៣, តិវិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

# អារម្ភកថា

ព្រះពុទ្ធសាសនាគឺជាដួងព្រលឹងវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ពុទ្ធសាសនិកខ្មែរ។ ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា មានតួនាទីយ៉ាងសំខាន់ក្នុងការអប់រំផ្សព្វផ្សាយព្រះធម៌វិន័យ របស់ព្រះសម្មាសម្ពុទ្ធដល់ប្រជាពុទ្ធបរិស័ទ គ្រប់មជ្ឈដ្ឋានក្នុងការគោរពដុសខាត់កំចាត់កិលេសតណ្ហាគឺ លោភៈ ទោសៈ និងមោហៈ ដែលជាប្រភពនៃអវិជ្ជា មិនឲ្យជាប់មាននៅក្នុងខន្ធសន្តានដើម្បីទទួលបាននូវសេចក្តីសុខទាំងផ្លូវកាយ និងផ្លូវចិត្ត។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ *សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន* **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** វិស័យព្រះពុទ្ធសាសនា ពីមួយថ្ងៃទៅមួយថ្ងៃមានការវិវឌ្ឍន៍រីកចម្រើនឈានឆ្ពោះទៅមុខឥតឈប់ឈរ។

ជាអកុសល ក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យវិស័យព្រះពុទ្ធសាសនារលាយសាបសូន្យ។ ព្រះសង្ឃត្រូវបានចាប់ផ្សឹក ពុទ្ធបរិស័ទត្រូវបានគេហាមឃាត់មិនឲ្យមានជំនឿលើព្រះពុទ្ធសាសនា គម្ពីរដីកា ក្បួនខ្នាត វត្តអារាមទាំងឡាយ ត្រូវបានគេវាយបំផ្លិចបំផ្លាញកម្ទេចចោលទាំងស្រុង។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ជាថ្ងៃជ័យជំនះនៃប្រវត្តិសាស្ត្ររបស់ខ្មែរយើង ដែលមានសម្តេចទាំងបីជាប្រមុខដឹកនាំគឺ*សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម*, *សម្តេចអគ្គមហាពញាចក្រី ហេង សំរិន* និង *សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន* បានធ្វើឲ្យជីវិតរបស់ប្រជាពលរដ្ឋ ជំនឿនៃការកាន់ព្រះពុទ្ធសាសនា និងសង្គមជាតិយើងទាំងមូលបានរស់ឡើងវិញ។

ក្នុងនាមក្រសួងធម្មការ និងសាសនា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ *សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន* **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**ដែលបានផ្តល់អនុសាសន៍ប្រកបដោយអត្ថន័យដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ចំពោះក្រសួងធម្មការ និងសាសនា ដែលមានរូបខ្ញុំបាទ **មិន ឃិន ជារដ្ឋមន្ត្រី**។ ដោយគោរពតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់នេះ ក្រសួងធម្មការ និងសាសនា បានអនុវត្ត និងរៀបចំចងក្រងប្រវត្តិវត្តទូទាំងប្រទេសឡើងវិញ ទុកជាឯកសារប្រវត្តិសាស្ត្រសម្រាប់កូនខ្មែរជំនាន់ក្រោយបានសិក្សាស្រាវជ្រាវបន្ត បានរៀបចំនាទីសន្ទនាព្រះធម៌ផ្សារភ្ជាប់នឹងសង្គម សម្រាប់អប់រំផ្លូវកាយ និងផ្លូវចិត្តដល់ប្រជាពលរដ្ឋ តាមរយៈការផ្សាយនៅតាមបណ្តាវិទ្យុ ទូរទស្សន៍របស់ជាតិ និងឯកជន និងបានរៀបចំវគ្គបណ្តុះបណ្តាលតួនាទី និងភារកិច្ចអាចារ្យទូទាំងប្រទេស ក្នុងគោលបំណងដោះស្រាយវិបត្តិអាចារ្យ ក្នុងការរក្សាការពារប្រពៃណី ទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ជាតិ។ ជាទិសដៅបន្ត ក្រសួងនឹងរៀបចំវគ្គបណ្តុះបណ្តាលជូនដល់សីលវន្ត សីលវត្តី (ដូនជី តាជី) ឲ្យយល់ពីសីល សមាធិបញ្ញា ជ្រះថ្លាច្បាស់ក្នុងព្រះពុទ្ធសាសនា។ ទន្ទឹមនឹងនោះ ក្រសួងធម្មការ និងសាសនា បានខិតខំធ្វើការស្រាវជ្រាវរកគម្ពីរ ដីកា ក្បួនច្បាប់ចាស់ៗពីបុរាណ ដែលខ្លះបានបាត់បង់ និងស្ទើរតែបាត់បង់មកធ្វើការរៀបរៀង កែសម្រួល ចងក្រង និងបោះពុម្ពឡើងវិញសារជាថ្មីនេះ

ក្នុងគោលបំណងផ្សព្វផ្សាយឲ្យបានទូលំទូលាយ ក្នុងស្រទាប់សាមណសិស្ស សាមណនិស្សិត ព្រះសង្ឃទូទាំងប្រទេសដែលកំពុងសិក្សា និងបញ្ញាជនទូទៅ ដែលមានបំណងចង់សិក្សាស្វែងយល់ពីព្រះពុទ្ធសាសនា។

បច្ចុប្បន្នក្នុងឆ្នាំសិក្សា២០១១-២០១២នេះ យើងមានសាលាធម្មវិន័យចំនួន ៥១៩សាលា, ពុទ្ធិកបឋមសិក្សាចំនួន ៧៧៥សាលា, ពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន ៣៥ សាលា, ពុទ្ធិកសិក្សាមធ្យមសិក្សាទុតិយភូមិចំនួន ១៧សាលា និងសាកលវិទ្យាល័យចំនួនប្រាំកន្លែងគឺ **ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ, ពុទ្ធិកសាកលវិទ្យាល័យសីហមុនីរាជា, ពុទ្ធិកសាកលវិទ្យាល័យនៅខេត្តកំពង់ឆ្នាំង, ពុទ្ធិកសាកលវិទ្យាល័យនៅខេត្តបាត់ដំបង** និង **ពុទ្ធិកសាកលវិទ្យាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងខេត្តកំពង់ចាម**។ ជាមួយនេះ ពុទ្ធិកសិក្សាទាំងមូលមានសាមណសិស្ស-និស្សិតសរុបចំនួន ៣១.០៩២ អង្គ/នាក់កំពុងសិក្សា។

សៀវភៅ «សទ្ទានុក្រមបាលី-ខ្មែរ» គឺជាឯកសារយោងដ៏មានសារសំខាន់សម្រាប់សាមណសិស្ស-និស្សិតនិងអ្នកស្រាវជ្រាវផ្នែកភាសាខ្មែរ ដែលកើតឡើងក្រោមគំនិតផ្តួចផ្តើមឡើងដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ដើម្បីទុកជាសម្បត្តិវប្បធម៌ជាតិ សម្រាប់ព្រះសង្ឃ ប្រជាពលរដ្ឋកម្ពុជាសិក្សា និងស្វែងយល់តរៀងទៅ។

ភ្នំពេញ, ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២

រដ្ឋមន្ត្រី

មិន.ឃិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
លេខ :...៣២៣/១៧...អ.ព.ស.ជ

# និវេទនកថា

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ពិនិត្យឃើញថា នៅតាមសាលាពុទ្ធិកសិក្សានានាក្នុងព្រះរាជាណាចក្រកម្ពុជា មានការខ្វះខាតសៀវភៅ **សទ្ទានុក្រម បាលី-ខ្មែរ** ដែលបង្ករជាការលំបាកមួយយ៉ាងខ្លាំងសម្រាប់សាមណសិស្ស-និស្សិតក្នុងការរកឯកសារយោងនានាមកសិក្សា។

ដោយមើលឃើញពីការលំបាកនេះ ទើបអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបានប្រជុំពិភាក្សាជាមួយលោកសាស្ត្រាចារ្យភាសាបាលី និងបានរៀបរៀងសៀវភៅ **សទ្ទានុក្រម បាលី-ខ្មែរ** សម្រាប់ដាក់ឲ្យសិក្សានៅតាមសាលាពុទ្ធិកសិក្សានានាទូទាំងប្រទេសកម្ពុជានេះឡើង។

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិសង្ឃឹមជឿជាក់ថា លោកគ្រូដែលមានភារកិច្ចបង្រៀនមុខវិជ្ជាភាសាបាលីនៅតាមសាលាពុទ្ធិកសិក្សាជាតិទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា នឹងខិតខំយកចិត្តទុកដាក់ក្នុងការបង្រៀនសាមណសិស្ស-និស្សិតប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ និងប្រើប្រាស់សៀវភៅ **សទ្ទានុក្រម បាលី-ខ្មែរ** ជាឯកសារយោងនេះឲ្យបានត្រឹមត្រូវដើម្បីជានាឲ្យបាននូវគុណភាពនៃការសិក្សា ដែលក្រសួងធម្មការ និងសាសនា បានកំណត់រួចហើយ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១២
**ជ.អគ្គាធិការដ្ឋានពុទ្ធិកសិក្សា**
**អគ្គាធិការរង**

សង្ឃហត្ថេរោ អ៊ំ_លីមហេង

# យោបល់សាស្ត្រាចារ្យភាសាបាលី

ក្រោយពីបានទទួលសំណើរបស់ **ឯកឧត្តម មិន ឃិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឲ្យជួយពិនិត្យផ្ទៀងផ្ទាត់សៀវភៅ «**សទ្ទានុក្រមបាលី-ខ្មែរ**» ដែលអ្នកប្រាជ្ញជាន់មុនបានរៀបរៀងទុកដូចជា **បទានុក្រមបាលី អភិធានប្បទីបិកា, បទានុក្រមធម្មបទ និងធាតុសង្គ្រោះ** មកបញ្ចូលគ្នាតែមួយភាគ ដោយសមាជិក-សមាជិកានៃពុទ្ធសាសនបណ្ឌិត្យ ដើម្បីងាយស្រួលក្នុងការសិក្សាស្រាវជ្រាវរបស់សិក្ខាកាមកុលបុត្រ ។ យើងខ្ញុំទាំងអស់គ្នា ជាក្រុមសាស្ត្រាចារ្យភាសាបាលី រួមមាន៖

១. លោក **ខិត ខន**, ២. លោក **អែម ឧត្តម**, ៣. លោក **រិត សោរខឿ**, ៤. ព្រះមហា **ឃាខ សុភាព**, ៥. លោក **អ៊ុខ សុវណ្ណា** បានយកចិត្តទុកដាក់អស់ពីស្មារតីទទួលខុសត្រូវខ្ពស់ គោរពតាមសំណើ**ឯកឧត្តមរដ្ឋមន្ត្រី** ពិនិត្យផ្ទៀងផ្ទាត់រហូតបានចប់ ឃើញថាត្រឹមត្រូវល្មមប្រើការបាន ទោះបីមិនទាន់សុក្រឹតមួយរយភាគរយក៏ដោយ ។ យើងខ្ញុំយល់ឃើញថា សៀវភៅ «**សទ្ទានុក្រមបាលី-ខ្មែរ**» នេះ ទុកជាសម្បត្តិដ៏មានតម្លៃសម្រាប់កុលបុត្រសិក្សាបាលីបាន ។ ម្យ៉ាងទៀត សៀវភៅនេះចាត់ទុកជាសមិទ្ធផលដ៏ធំធេងក្នុងសម័យកាល **ឯកឧត្តម** ជារដ្ឋមន្ត្រីក្រោមការដឹកនាំ និងផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ។

ជាទីបំផុតនេះ យើងខ្ញុំជាក្រុមសាស្ត្រាចារ្យភាសាបាលី សូមលើកនូវមហាកុសលវិបុលកល្យាណ-កម្ម ដែលកើតអំពីស្នាដៃដ៏ធំធេងនេះជូនចំពោះ៖

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ព្រមទាំងបុត្រា-បុត្រី ចៅប្រុស-ចៅស្រី សូមជួបប្រសព្វតែសុភមង្គលវិបុលសុខ និទ៌ុក្ខ និភ៌យ រយវឌ្ឍនាការ គ្រប់ប្រការ កុំបីក្លាយឃ្លាតទៅជាប្រការដទៃឡើយ ។
- **ឯកឧត្តម មិន ឃិន** និង**លោកជំទាវខូន ធួន** ព្រមទាំងក្រុមគ្រួសារ សូមជួបសុខចម្រើនកើនសួស្តីសិរីខ្ពង់ខ្ពស់យសសក្តិថ្កើងថ្កានក្សេមក្សាន្តជានិច្ចនិរន្តរ៍តរៀងទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២៥៥៦=២០១២

ក្រុមសាស្ត្រាចារ្យភាសាបាលី

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៧៣១ ក.ធ.ស.ខ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបរៀង និងចងក្រងសៀវភៅសទ្ទានុក្រម បាលី-ខ្មែរ សម្រាប់ពុទ្ធិកសិក្សារបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខនស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១៥៤ អនក្របក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- យោងតាមការចាំបាច់របស់ក្រសួងធម្មការ និងសាសនា

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតគណៈកម្មការ និងអនុគណៈកម្មការស្រាវជ្រាវ, រៀបរៀង និងចងក្រងសៀវភៅ **សទ្ទានុក្រម បាលី-ខ្មែរ** សម្រាប់ប្រើប្រាស់ក្នុងអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ដែលមានសមាសភាពដូចខាងក្រោម ៖

**ក. គណៈកម្មការកណ្តាលគ្រប់គ្រងរួម**

| | | |
|---|---|---|
| ១. ឯកឧត្តម | មិន ឃិន | ប្រធាន |
| ២. សម្តេចព្រះមហាសុមេធាធិបតី | នន្ទ ង៉ែត | អនុប្រធាន |
| ៣. សម្តេចព្រះពោធិវង្ស | អំ លឹមហេង | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តម | ផ្លោក ផន | អនុប្រធាន |
| ៥. សម្តេចព្រះវនរ័ត | ណយ ច្រឹក | សមាជិក |
| ៦. សម្តេចព្រះឧត្តមវង្សា | មួង រ៉ា | សមាជិក |
| ៧. សម្តេចព្រះឧត្តមចរិយាបណ្ឌិត | ឈឹង ប៊ុនឈា | សមាជិក |

# 393, តិរិវិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីមែល : ministry religion@yahoo.com Web site : www.mocar.gov.kh

| | | |
|---|---|---|
| ៨. សម្ដេចព្រះមហាអរិយវង្ស | សៅរ៍ ចន្ទថុល្ល | សមាជិក |
| ៩. ព្រះញាណវង្ស | ឃឹម សន | សមាជិក |
| ១០. ព្រះសមេធវង្សាបណ្ឌិត | ញ៉ែម គឹមតេង | សមាជិក |
| ១១. ព្រះមហាបណ្ឌិត | ស៊ិន ស៊ី | សមាជិក |
| ១២. ព្រះទេពសត្ថា | ឃី សុវណ្ណរតនា | សមាជិក |
| ១៣. ព្រះញាណកោសល្យ | យ៉ន សេងយៀត | សមាជិក |
| ១៤. ព្រះពុទ្ធវង្ស | ជា សំអាង | សមាជិក |
| ១៥. ព្រះមហា | សឿន សាន | សមាជិក |
| ១៦. ឯកឧត្តម | ញ៉ែម វ៉ាលី | សមាជិក |
| ១៧. ឯកឧត្តម | សេង សុមុនី | សមាជិក |
| ១៨.លោកជំទាវ | កែវ សុធារី | សមាជិក |
| ១៩. លោកជំទាវ | មិន ចណ្ឌីណែត | សមាជិក |

គណៈកម្មការកណ្ដាលគ្រប់គ្រងរួម មានភារកិច្ចណែនាំ ជំរុញ ឧបត្ថម្ភ ដោះស្រាយនូវតម្រូវការផ្សេងៗសម្រាប់ដំណើរការរៀបរៀង និងចងក្រងសៀវភៅ។

**ខ. អនុគណៈកម្មការត្រួតពិនិត្យ**

| | | |
|---|---|---|
| ១. លោកព្រឹទ្ធសាស្ត្រាចារ្យ | ជិត ជន | ប្រធាន |
| ២. លោកសាស្ត្រាចារ្យ | រ៉ិត សោរង្សី | អនុប្រធាន |
| ៣. លោកព្រឹទ្ធសាស្ត្រាចារ្យ | អ៊ុំង សុវណ្ណ | សមាជិក |
| ៤. លោកព្រឹទ្ធសាស្ត្រាចារ្យ | អែម ឧត្តម | សមាជិក |
| ៥. ព្រះមហាសាស្ត្រាចារ្យ | ឃាង សុភាព | សមាជិក |

អនុគណៈកម្មការនេះមានភារកិច្ចត្រួតពិនិត្យសៀវភៅ **សទ្ទានុក្រម បាលី-ខ្មែរ** ដើម្បីធានាឲ្យបានភាពត្រឹមត្រូវនៃសៀវភៅនេះ។ អនុគណៈកម្មការនេះត្រូវធ្វើការប្រជុំគ្នានៅរាល់សប្ដាហ៍ នៅសាលសាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត រហូតដល់ចប់កិច្ចការ។

**គ. អនុគណៈកម្មការនិន្នន័យ**

| | | |
|---|---|---|
| ១. លោកស្រី | ឃិន ចំរើន | ប្រធាន |
| ២. ឯកឧត្តម | មាស សំណាង | អនុប្រធាន |
| ៣. លោក | ស សុខនី | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. អ្នកស្រី | ផាត់ ច័ន្ទមុនីរដ្ឋា | សមាជិកា |
| ៥. កញ្ញា | ហ៊ុន ច័ន្ទសុជាតា | សមាជិកា |
| ៦. លោក | ស៊ុន សូណៃ | សមាជិក |
| ៧. លោក | សោម វណ្ណៈ | សមាជិក |
| ៨. លោក | ឱម វីរៈ | សមាជិក |

| | | |
|---|---|---|
| ៩. លោក | ប្រាង ប្រិត | សមាជិក |
| ១០. លោក | អ៊ី គុណា | សមាជិក |
| ១១. លោក | អ៊ួន សំអុល | សមាជិក |

អនុគណៈកម្មការនេះមានភារកិច្ចស្រាវជ្រាវ ចងក្រង និងពិនិត្យអក្ខរាវិរុទ្ធអត្ថបទដែលបានកំណត់ទុករហូតដល់ចប់កិច្ចការ។

**ឃ. អនុគណៈកម្មការវាយតម្លៃ និងបោះពុម្ពផ្សាយ**

| | | |
|---|---|---|
| ១. ឯកឧត្តម | មិន ឃិន | ប្រធាន |
| ២. សម្តេចព្រះមហាសុមេធាធិបតី | នន្ទ ង៉ែត | អនុប្រធាន |
| ៣. សម្តេចព្រះពោធិវង្ស | អំ លឹមហេង | អនុប្រធាន |
| ៤. ឯកឧត្តម | ញ៉ែម វ៉ាលី | សមាជិក |
| ៥. លោកជំទាវ | កែវ សុធារី | សមាជិក |
| ៦. លោកជំទាវ | មិន ចណ្ឌីណែត | សមាជិក |
| ៧. លោក | ស្រេង ង៉ូវឡេង | សមាជិក |

អនុគណៈកម្មការនេះមានភារកិច្ចវាយតម្លៃ ផ្តល់យោបល់បន្ថែមដល់ស្នាដៃសៀវភៅ **សទ្ទានុក្រមបាលី-ខ្មែរ** ដែលអនុគណៈកម្មការត្រួតពិនិត្យបានធ្វើរួចរាល់ហើយប្រគល់ជូន។

**ប្រការ២:**អនុប្រធានគណៈកម្មការគ្រប់គ្រងរួម, ប្រធាន-អនុប្រធានអនុគណៈកម្មការ និងសមាជិកទាំងអស់ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធានគណៈកម្មការគ្រប់គ្រងរួម តាមពេលវេលាសមស្រប។

**ប្រការ៣:**អនុគណៈកម្មការនីមួយៗមានសិទ្ធិប្រជុំបែងចែកភារកិច្ចដល់សមាជិក ដើម្បីពង្រឹងការទទួលខុសត្រូវខ្ពស់ តាមការប្រគល់សិទ្ធិរបស់ប្រធានគណៈកម្មការគ្រប់គ្រងរួម។

**ប្រការ៤:**សេចក្តីសម្រេចនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២

រដ្ឋមន្ត្រី

**មិន.ឃិន**

**ចម្លងជូន-ជូន ៖**

- គណៈសង្ឃនាយក
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យជំទាវឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់នាយកដ្ឋាននៃក្រសួងធម្មការ និងសាសនា
  «ដើម្បីជូនជ្រាប»
- ដូចប្រការ ១ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងធម្មការ និង សាសនា

លេខ ៧៧៣៧/១២ ក.ធ.ស.ខ

## ប្រកាស

### ស្ដីពីការដាក់ឲ្យប្រើប្រាស់សៀវភៅសទ្ទានុក្រម បាលី-ខ្មែរ នៅពុទ្ធិកសិក្សាជាតិ

### រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខនស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១៥៨ អនក្របកចុះថ្ងៃទី១១ ខែកក្កដាឆ្នាំ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- យោងសេចក្ដីសម្រេចលេខ២៧១ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មការស្រាវជ្រាវ, រៀបរៀង និងចងក្រងសៀវភៅសទ្ទានុក្រមបាលី-ខ្មែរ

## សម្រេច

**ប្រការ១:** ដាក់ឲ្យប្រើប្រាស់**សទ្ទានុក្រម បាលី-ខ្មែរ** សម្រាប់ពុទ្ធិកសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២:** អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ, អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចបោះពុម្ពចែកផ្សាយសៀវភៅសទ្ទានុក្រមនេះឲ្យបានទូលំទូលាយគ្រប់ពុទ្ធិកភូមិសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣:** ប្រកាសនេះចូលជាធរមានគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២

រដ្ឋមន្ត្រី

**មិន-ឃិន**

**ចម្លងជូន-ជូន ៖**

- គណៈសង្ឃនាយក
- ខុទ្ទការល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យជំទាវឧបនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់នាយកដ្ឋាននៃក្រសួងធម្មការ និងសាសនា
  «ដើម្បីជូនជ្រាប»
- ដូចប្រការ ១ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

# ៣៧៣, តិវិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

# អក្សរសង្ខេបប្រើក្នុងសទ្ទានុក្រមបាលី-ខ្មែរ

០១- ក.ក ........................ កត្តុរូប កត្តុសាធន

០២- ក-ស ...................... ក-សកត្ថ

០៣- កា.និ ...................... ការណត្ថវាចកនិបាត

០៤- កា.ស ..................... កាលសត្តមី

០៥- កិ .......................... កិរិយា ឬកិរិយាស័ព្ទ

០៦- កិ.វិ ........................ កិរិយាវិសេសនៈ

០៧- គុ .......................... គុណ ឬគុណនាម

០៨- ដី.វិ ........................ ដីកាវិសុទ្ធិមគ្គ

០៩- ណិក-ស ................. ណិក-សកត្ថ

១០- តិ-វ ........................ តិ-វត្តមានា

១១- តុ-ប ....................... តុ-បញ្ចមី

១២- ត្ថ-ហី ...................... ត្ថ-ហីយត្តនី

១៣- ន .......................... នាម

១៤- នបុំ ......................... នបុំសកលិង្គ

១៥- និ .......................... និបាត

១៦- និ-អា ...................... និគ្គហិតអាគម

១៧- ប.សំ ...................... បកតិសំខ្យា

១៨- ប-ស ...................... បកតិសំខ្យា

១៩- បុ.និ ........................ បុច្ឆនត្ថវាចកនិបាត

២០- បុ.ស ...................... បុរិសសព្វនាម

២១- បុំ .......................... បុំលិង្គ

២២- បូ.សំ ...................... បូរណសំខ្យា

២៣- យ.វិ ........................ យោជនាវិន័យ

២៤- យ.អភិ .................... យោជនាអភិធម្មត្ថវិភាវិនី

២៥- លិ.វិ ........................ លិង្គវិបល្លាស

២៦- វិ ............................ វិគ្គហៈ

២៧- វិ.ស.និ .................... វិសេសន-សព្វនាម- និយម

២៨- វិ.ស.អ .................... គឺ វិសេសន- សព្វនាម- អនិយម

២៩- វេវ .......................... វេវចនសព្ទ

៣០- ស.ត ...................... សមាសរូប តស្សីលសាធន

៣១- ស.និ ...................... ស-និបាត

៣២- សព្វ ....................... សព្វនាម

៣៣- ស-អា........................ ស-អាគម

៣៤- សិ-វិ.......................... សិ-វិភត្តិនាម

៣៥- ស្សតិ-ភ.................... ស្សតិ-ភវិស្សន្តិ

៣៦- ស្សា-កា.................... ស្សា-កាលាតិបត្តិ

៣៧- សំ-ស...................... សំខ្យាសព្វនាម

៣៨- ហ-អា...................... ហ-អាគម

៣៩- អ ............................ អព្យយកិរិយា ឬអព្យយកិរិយាស័ព្ទ

៤០- ឥ ............................ ឥត្ថីលិង្គ

៤១- អ.ត.......................... អព្យយតទ្ធិត

៤២- អ.ន.......................... អសាធារណនាម

៤៣- អ.និ.......................... អព្យយនិបាត ឬ មោនត្ថវាចកនិបាត

៤៤- អ.វិ.......................... អដ្ឋកថាវិន័យ

៤៥- អ.ស ........................ អព្យយ- សព្វនាម

៤៦- អ.សុ ........................ អដ្ឋកថាសុត្តន្តបិដក

៤៧- ឥ.អា ........................ ឥ-អាគម

៤៨- អ-បរោ.................... អ-បរោក្ខា

៤៩- អភិ.-សុ.................... អភិធានប្បទីបិកា-សុចិ

៥០- ឯយ្យ-ស.................. ឯយ្យ-សត្តមី

៥១- ឧ-ស ........................ ឧបសគ្គ

៥២- អស.ន...................... អសាធារណនាម

៥៣- ញ្ញ-អជ្ជ..................... ញ្ញ-អជ្ជត្តនី

៥៤- ឥ-អា ........................ ឥ-អាគម

៥៥- អា.ន ........................ អាលបននាម

៥៦- អា.និ ........................ អាលបននិបាត

៥៧- អា.ឥ ........................ អា-ការន្ត ឥត្ថីលិង្គ

៥៨- អា-និ ........................ អាលបនបិបាត

៥៩- អា-ហី...................... អា-ហីយត្តនី

៦០- អា-ឥ ........................ អា-ឥត្ថីលិង្គ

< នេះសម្គាល់ថា «មកពី» ឬ «កើតមកពី»; > នេះសម្គាល់ថា «ទៅជា» ឬ «កើតទៅជា»; + នេះសម្គាល់ថា «និង» ឬ «ហើយ និង»; ដូចជា រដ្ឋាភិបាល <រដ្ឋ +អភិបាល (មើលថា រដ្ឋាភិបាល មកពី រដ្ឋ និង អភិបាល), រដ្ឋ + អភិបាល > រដ្ឋាភិបាល (មើលថា រដ្ឋ និង អភិបាល ទៅជា រដ្ឋាភិបាល) ជាដើម ។ វណ្ណយុត្តិក្រៅពីនេះ មិនបាន លើកយកមកពន្យល់ទីនេះទេ ព្រោះធ្លាប់ប្រើថ្មីកមកហើយ ។

# ក

**កកច** បុំ វណារសម្រាប់អារឈើ (ដូច **ខរ**), ដើមដងជឹងស្វាត (ដូច **ករីរ**) ។

**កកណ្ដក** បុំ សត្វបង្គួយ (ដូច **សរដ**) ។

**កកុ** បុំ. បូកគោ (ដូច **កកុធ**) ។

**កកុដ** បុំ. សត្វព្រាប (ដូច **បារេវដ**) ។

**កកុដបាទ** គុ. [កកុដ + បាទ] មានជើងដូចជាជើងនៃព្រាប, វិ. **កកុដស្ស បាទា**> **កកុដបាទា**, **កកុដបាទា ឥវ បាទា យេសំ តានិ** > **កកុដបាទានិ** ។

**កកុធ** បុំ. រាជកកុធភណ្ឌ មានព្រះខ័នជាដើម, បូកគោ (ដូច **កកុ**), ដើមអង្គ្រងស, ដើមថ្វាន់ (ដូច **អជ្ជុន**) ។

**កកុធរុក្ខ** បុំ. [កកុធ + រុក្ខ] ដើមនៃថ្វាន់, ដើមថ្វាន់ ។

**កកុសន្ធ** អ.ន. ព្រះនាមព្រះពុទ្ធ, ព្រះពុទ្ធទ្រង់ព្រះនាម **កកុសន្ធៈ** ។

**កក្ក** បុំ., នបុំ. លំអិតសម្រាប់ងូត (មានសាប៊ូជាដើម)(ដូច **នហាចុណ្ណ**) ។

**កក្កដក** បុំ. [ក + កដ + អ + ក-ស.] សត្វហាមនូវភ្លៀង (ក្ដាម ដូច **កុលីរ**), វិ. **កំ វស្សំ កដតីតិ**>**កក្កដកោ** ។

**កក្កស** គុ. [ករ + អស] អាក្រក់, ទ្រគោះ, គ្រោតគ្រាត, កាច, ខូច (ដូច **ខរ**), កំហែង (ដូច **សាហស**), មិនជាទីស្រឡាញ់ (ដូច **អប្បិយ**), វិ. **កិព្វិសំ ករោតីតិ**>**កក្កសោ** ។

**កក្ការី** ឥ. ត្រឡាច (ដូច **ឯឡាឡុក**) ។

**កក្ខល** គុ. [កក្ខ + អល] របឹង, រឹងរូស, អាក្រក់, រឹង (ដូច **កឋិន**), ។ - **តា** ឥ. ភាវៈនៃ.....នោះជា...រឹង, -រូស ។ -**កម្ម** នបុំ.កម្មដ៏រឹងរូស, អំពើដ៏អាក្រក់ ។ ប្រើជា **កក្ខឡ** ក៏បាន ។

**កក្ខិ** ធា. **ហសនេ កក្ខតិ កក្ខលោ**"សើច, ញញឹម, គ្រោតគ្រាត, រឹងរូស, រីក" ភូ. ។

**កគិ** ធា. ១-**លោលិយេ កគតិ**"ថោកទាប, ឡេមឡឹម" ភូ. ។ **កាក** បុំ.**កាកី** ឥ. "ក្អែក" សព្វជាវេវចនៈ: **កាកោ** គឺ **ធង្ខោ វាយសោ ពលិភោជី អរិដ្ឋោ**-ស. ។
២- **គតិយំ កង្គតិ**"ទៅ, ដល់, ប្រព្រឹត្តទៅ " រុ. ។

**កខិ** ធា. ១-**ហសនេ កខតិ**"សើច, ញញឹម, គ្រោធគ្រាត, រឹងរូស" ភូ. ។

២-**កង្ខាយំ កង្ខតិ កង្ខា កង្ខាយនា កង្ខាយិតត្តំ**"សង្ស័យ, ឆ្ងល់, អល់ឯក, រារែក" រុ. ។ សព្ទជាវេវចនៈ នឹង **កង្ខា** គឺ **វិមតិ វិចិកិច្ឆា កង្ខា ទ្វេឡ្ហកំ ទ្វេធាបថោ សំសយោ អនេកំសគាហោ អាសប្បនា បរិសប្បនា អបរិយោគាហនា ចិត្តស្ស ឆម្ភិតត្តំ មនោវិលេខោ**-ស. ។

៣-**ឥច្ឆាយំ កង្ខតិ អភិកង្ខតិ**" ប្រាថ្នា, ចង់បាន, គាប់ចិត្ត ស្រឡាញ់" រុ.។ អា. **ធនំ កង្ខតិ**"គេចង់បានទ្រព្យ " ។ **នាភិកង្ខាមិ មរណំ**"ខ្ញុំមិនចង់ស្លាប់ទេ"-ស.។

**កង្ក** បុំ. សត្វខ្លែងក្រហម (ដូច **លោហបិដ្ឋ**) ។

**កង្ខា** ឥ. [កង្ខ + អ + អា-ឥ.] សេចក្តីសង្ស័យ, វិ. **កង្ខនំ**>**កង្ខា** ។ (ធម្មជាតិ) ជាគ្រឿងសង្ស័យ, វិ. **កង្ខតិ ឯតាយាតិ**>**កង្ខា** ។ -**ឆេទន** នបុំ. កិរិយាកាត់នូវសេចក្តីសង្ស័យ ។

**កង្គុ** ឥ. ស្រូវថ្កៅ (ដូច **បិយង្គុ**), ដើមប្រយង្គុ (ដូច **សាមា**, **បិយង្គុ**)។

**កចវរ** បុំ. [កច + វរ + អ] សម្រាម(ដូច **កសម្ពុ**) វិ. **នានាវិធេ សង្ការេ រាសិករណវសេន កចតិ ពន្ធតីតិ**>**កចោ**, **សោ ឯត្ថ ឥច្ឆិតព្វោតិ**>**កចវរោ** ។ -**ឆឌ្ឌិក**, -**កា**, គុ. សម្រាប់ចាក់ចោលនូវសម្រាម, អ្នកចាក់ចោលនូវសម្រាម, វិ. **កចវរំ ឆឌ្ឌេតីតិ**>**កចវរឆឌ្ឌិកា** ។ -**រាសិ** បុំ. គំនរនៃសម្រាម ។

**កច្ចាន** អ.ន. [កច្ច+ណាន] ភិក្ខុជាពូជពង្សនៃកច្ចៈ (ភិក្ខុឈ្មោះកច្ចៈ), វិ. **កច្ចស្ស អបច្ចំ**>**កច្ចានោ** ។ **អបច្ច**= កូន, កូនចៅ, ជាសាធារណនាម នបុំ. ។

**កច្ចិ** បុ.និ. និបាតប្រាប់សេចក្តីសួរដណ្តឹង ប្រែថា <<ឬ, ដែរឬ, ទេឬ, ខ្លះដែរឬ >>។

**កច្ចិនុ** និ. **បញ្ហត្ថវាចក** និបាតប្រាប់អត្ថគឺការសាកសួរ ប្រែថា ឬ, ឬហ្ន៎, **កថំ**, **កឹសុ**, **ននុ**, **កឹ** ក៏ជាបញ្ហត្ថវាចកៈ ដែរ ។

**កច្ចិ** ធា. **ទិត្តិយំ កច្ចេតិ កច្ចយតិ**"ភ្លឺ, រុងរឿង, ល្អ" ចុ. ។ **កច្ចាន** បុំ. "មនុស្សល្អ" ជាឈ្មោះនៃបុព្វរសមួយ -ស. ។ **កច្ចានោ កច្ចាយនោ ភាតិយានោ**"ដែលជាប់ខ្សែស្រឡាយវង្សរបស់កច្ចៈ ឬកូនចៅនៃកច្ចៈ" ។

**កច្ឆ** បុំ., នបុំ. [កច + ឆ] (ប្រទេស)ដែលជនចង (ក្បិន, កន្ទុយក្បិន ដូច **កច្ឆពន្ធន**) វិ. **កចិយតិ ពន្ធិយតីតិ**>**កច្ឆោ**, **កច្ឆំ** ។ ចំណែកខាងក្រោមនៃដុំដៃ (ដូច **បកោដ្ឋ**) ,គ្រឿងប្រដាប់ចង្កេះស្រី គឺផែនប្រាក់ឬមាសជាដើម មានសណ្ឋានដូចស្លឹកពោធិ៍សម្រាប់ចងចង្កេះបាំងអង្គជាតិក្មេងស្រីតូចៗ (ដូច **មេខលា**), វល្លិ (ដូច **លតា**), ប្រទេសមានទឹកច្រើន ប្រទេសដែលជោកជាំទៅដោយទឹក (ដូច **អនុប**), ក្លៀក (ដូច **ពាហុមូល**) ។

**កច្ឆន្តរ** នបុំ. ទីនៅរបស់ព្រះរាជា មិនទូទៅដល់ជនទាំងពួង ។

**កច្ឆប** បុំ. [កច្ឆ + បា + ក្វិ] សត្វផឹក (នូវទឹក) តាមក្លៀក (អណ្តើក ដូច **នក្ក**), វិ. **កច្ឆេន (ឧទកំ) បិវតីតិ>កច្ឆបោ** ។ -**អណ្ឌ** នបុំ. ពងនៃអណ្តើក, ស៊ុតនៃអណ្តើក ។

**កច្ឆា** ឥ. ខ្សែដង្កន់ដំរី (ដូច **ហត្ថិមជ្ឈពន្ធន**) ។

**កច្ឆុ** នបុំ. [កស + ច្ឆុ] (រោគជាត)ជាទីអេះ (ខ្វារ, ខ្វាំ) នៃជន (រមាស់, ខ្ទើរ, រោគកម ដូច **បាម**), វិ. **កសន្តិ វិលេខន្តិ ឯត្ថាតិ>កច្ឆុ** ។ -**បរិកិណ្ណ** គុ. ដេរដាសដោយរមាស់, ស្អេកស្កះដោយរមាស់ ។ -**ចុណ្ណ** នបុំ. លំអិតនៃខ្ទើរ, ផង់នៃខ្ទើរ ។

**កចិ** ធា. **ពន្ធនេ កចតិ**"ចង, រឹត" ភូ. ។ **កញ្ចុក** បុំ. "អាវកាក់, អាវកត្រង់, ក្រោះ, សំណាកពស់", **កញ្ចុកី** បុំ. "មនុស្សបម្រើនាងខាងក្នុងគឺមនុស្សចាស់ទុំបម្រើស្រីក្នុងវាំង =**សោវិទល្ល** ។

**កជ្ជល** នបុំ. លោហធាតុ, របស់ដែលគេយកអំពីផែនដីមកស្លឲ្យកើតជាលោហៈ (ដូច **អញ្ជន**) ។

**កជ្ជិ** ធា. **ព្យថនេ កជ្ជតិ**"បៀតបៀន, កម្ចាត់បង់, ..." ភូ. ។

**កញ្ចន** នបុំ. មាស (ដូច **សត្ថុវណ្ណ**) ។ -**ថូប** [កញ្ចន + ថូប] បុំ. ស្តូបជាវិការៈនៃមាស ឬ ស្តូបដែលជនធ្វើហើយដោយមាស, វិ. **កញ្ចនស្ស វិការោ ថូបោ> កញ្ចនថូបោ, កញ្ចនេន កតោ វា ថូបោ> កញ្ចនថូបោ** ។ ប្រើជា **កាញ្ចន** ក៏មាន ។

**កញ្ចុក** បុំ. ក្រោះ (ដូច **កវច**), អាវ, ខែលស្បែក (ដូច **វារពាណ**), សំណាកពស់និងសត្វឯទៀតៗ (ដូច **និម្មោក**), របស់ចាស់ (ដូច **បុរាណ**) ។

**កញ្ចុកី** បុំ. មនុស្សចាស់ទុំ ជាបរិស័ទព្រះរាជា (ដូច **សោវិទល្ល**) ។

**កញ្ជិក** នបុំ. [ក + អញ្ជ +ឥក] ទឹកបាយ, បាយចុងអង្ករ ។ -**តេល** នបុំ. ទឹកបាយនិងប្រេង, ប្រេងដំលាយដោយទឹកបាយ ។ -**មត្ត** គុ. វត្ថុត្រឹមតែទឹកបាយ, វត្ថុត្រឹមតែទឹកបាយចុងអង្ករ ។ ទឹកជ្រក់, ជ្រក់ (ដូច **សោវីរ**) ។

**កញ្ញា** ឥ. ស្រីក្រមុំតូច (ដូច **កុមារិកា**) ។

**កដ** បុំ. សេចក្តីឈ្នះ (ដូច **ជយ**), និមិត្តនៃស្រី (ដូច **ឥត្ថីនិមិត្ត**), កន្ទេល (ដូច **កិលញ្ជ**), ថ្ពាល់ដំរី (ដូច **គណ្ឌ**) ,កិ.គុ. ធ្វើហើយ (ដូច **កត**) ។

**កដកដាយតិ** កិ. [កដកដ + អាយ + តិ-វ.] ប្រព្រឹត្តនូវសំឡេងថាកដកដៈ ។

**កដក** បុំ. ជំនីរភ្នំ, ចង្កេះភ្នំ, ជ្រោះភ្នំ (ដូច **និតម្ព**), នបុំ. កងដៃ (ដូច **វលយ**) ។

**កដច្ឆុ** បុំ. [កដ + ឆុ] វែក, ស្លាបព្រា (ដូច **ទព្វិ**)។ -**ភិក្ខា** ឥ. បាយមានវែកជាប្រមាណ, បាយមួយវែក ។ -**ភិក្ខាទានវស** បុំ. អំណាចនៃកិរិយាឲ្យនូវបាយមួយវែក ។ -**ភិក្ខាមត្តទាន** នបុំ. កិ.ឲ្យនូវវត្ថុត្រឹមតែ

បាយមួយវែក ។ -**ភិក្ខាមត្ត** គុ. វត្ថុត្រឹមតែបាយមួយវែក, វត្ថុមានបាយមានវែកមួយជាប្រមាណ ។ -**មត្ត** គុ. ត្រឹមតែមួយវែក, មានវែកមួយជាប្រមាណ ។

**កដសារក** បុំ. [កដ + សរ + ណ្មុ] កន្ទេល, កន្ទេលផែង, ថែប ។

**កដាហក** អ.ន. បុរសឈ្មោះកដាហក, ទាសៈ(ខ្ញុំ)ឈ្មោះកដាហកៈ ។ -**ជាតក** នបុំ. ជាតកគឺបណ្ឌិតកំណត់ដោយទាសៈឈ្មោះ**កដាហកៈ** ។

**កដិ** ឥ. [កដ + ឥ] (ធម្មជាតិ)ដែលគេបិទបាំងដោយវត្ថុមានសំពត់ជាដើម (ចង្កេះ, ត្រគាកដូច **សោណី**), វិ. **កដ្យតេ អាវរិយតេ វត្ថាទីហីតិ**> **កដិ** ។ -**ប្បទេស** បុំ. ប្រទេសនៃចង្កេះ, ។ -**ប្បមាណ** នបុំ. ប្រមាណនៃចង្កេះ, ប្រមាណត្រឹមចង្កេះ, គុ. មានចង្កេះជាប្រមាណ ។

**កដុ** គុ. កាច, អាក្រក់, ទ្រគោះ (ដូច **ខរ**) , មិនគួរធ្វើ (ដូច **អការិយ**), រសហឹរ (ដូច **ហឹល**)។

**កដុក** គុ. [កដ + ណ្មុ] ហឹរ, ហឹរក្តៅ, ផ្សាក្តៅ, ក្តៅផ្សា, បុំ. គ្រឿងហឹរ, គ្រឿងទេស (ដូច **ហឹល**) ។ -**ភណ្ឌ** នបុំ. ភណ្ឌៈដ៏ហឹរក្តៅ, ភណ្ឌៈដ៏ក្តៅផ្សា, គ្រឿងទេស ។ -**វិបាក** គុ. មានវិបាកដ៏ក្តៅផ្សា, មានផលដ៏ផ្សាក្តៅ ។ -**ប្បភេទន** គុ.មានប្រេងជាគ្រឿងបែកទូទៅដ៏ផ្សាក្តៅ (ចុះប្រេងដ៏ផ្សាក្តៅ) ។ -**ប្ផល** គុ. មានផលដ៏ផ្សាក្តៅ ។

**កដុកា** ឥ. រំដេង (ដូច **កដុរោហិណី**) ។

**កដុរោហិណី** ឥ. រំដេង (ដូច **កដុកា**) ។

**កដ្ឋ** នបុំ. [កាស ឬកស + ត] (ធម្មជាត)រុងរឿងដោយភ្លើង ឬ(ធម្មជាត)វិនាសដោយភ្លើង (ឈើ, ឧស ដូច **ទារុ**), វិ. **កាសតេ អគ្គិនា ទិប្បតេតិ**>**កដ្ឋំ**, **កសតិ អគ្គិនា វិនាសតីតិ វា** >**កដ្ឋំ** ។ -**កលិង្គរ** នបុំ. ឈើនិងអង្កត់ឧស ( អង្កត់ឧស) ។ -**ខណ្ឌ** នបុំ. កំណាត់នៃឈើ ។ -**អង្គរុក្ខ** បុំ. ឈើជាអវយវៈនៃឧស ។ -**ត្ថរ** គុ. ទីជាទីក្រាលដោយឈើ, កម្រាលជាវិការៈនៃឈើ ។ -**បាទុកា** ឥ. ទ្រនាប់ជើងជាវិការៈនៃឈើ, ស្បែកជើងជាវិការៈនៃឈើ ។ -**វាហនរាជ** បុំ. ស្តេចព្រះនាម**កដ្ឋវាហនៈ**។ -**ហត្ថី** បុំ. ដំរីជាវិការៈនៃឈើ, វិ. **កដ្ឋស្ស វិការោ ហត្ថី**> **កដ្ឋហត្ថី** ។ ដំរីដែលគេធ្វើហើយដោយឈើ, វិ. **កដ្ឋេន បកតោ ហត្ថី**>**កដ្ឋហត្ថី** ។ -**ហារិកា** ឥ. [ហរ +ណ្មុ+ឥ-អា+អា-ឥ] អ្នកនាំទៅនូវឈើ, អ្នកនាំទៅនូវឧស, វិ. **កដ្ឋានិ ហរតីតិ**>**កដ្ឋហារិកា** ។ -**ហារិយជាតក** នបុំ. ជាតកគឺបណ្ឌិតកំណត់ហើយដោយបុគ្គលអ្នកនាំទៅនូវឧស ។ គុ. លំបាក (ដូច **កិច្ឆ**), សាំញ៉ាំ (ដូច **គហណ**), ភ្លូវ (ដូច **កសិត**) ។

**កដ្ឋិស្ស** នបុំ. កម្រាលគេធ្វើដោយសូត្រ និងអម្បោះសំបកឈើឈ្មោះ **កដ្ឋិស្ស**

ប៉ាក់ដោយរតនៈផង ។

**កដិ** ធា. **ខស្សាវរណេ គតិយញ្ច កដតិ**"ហាមភ្លៀង, រាំងភ្លៀង, បិទបាំង, ទៅ, ដល់" ភូ. **កដ** បុំ. "យោនីនៃស្ត្រី, ជ័យជំនះ, ប្រេងដំរី, ថ្ពាល់ដំរី, ។ **បាកដ** គុ. "ប្រាកដ, ច្បាស់លាស់" (ប+កដ-សូចិ) ។ **កដក, -កំ** បុំ. នបុំ. "ជំនីរភ្នំ, ចង្កេះភ្នំ, ជ្រោះ, កងដៃ" ។ **កដិ** ឥ. "ចង្កេះ, ត្រគាក" វិ. **កដ្យតេ អាចរីយតេ ចត្តាធីហីតិ កដិ** (សូចិ) ។ **កដុក** បុំ. "រំដេង" គុ. ហឹរ, ផ្សា, មិនគួរ, អាក្រក់, កាច, ខុស" ។

**កថិត** គុ. ឆ្អិន, ចាស់ក្លា (ដូច **និប្បក្ក**) ។

**កថិន** គុ. រឹង (ដូច **កក្ខឡ**) ។

**កថិ** ធា. **កិច្ឆជីវនេ កថតិ កថោ**"រស់នៅដោយលំបាក" ភូ. ។ **កថិនោ** គុ. "រឹង, លំបាក, គ្រោតគ្រាត" (កថ+ឥន សូចិ) ។

**កឌ្ឍន្ត** គុ. [កឌ្ឍ + អ + អន្ត] កាលទាញទៅ, កាលយឺត, កាលកន្ត្រាក់ ។

**កឌ្ឍិ** កិ. [កឌ្ឍ + អ + ឦ-អជ្ជ.] ទាញហើយ, យឺតហើយ, កន្ត្រាក់ហើយ ។

**កឌ្ឍិតុំ** អ. [កឌ្ឍ + ឥ-អា + តុំ] ដើម្បីទាយទៅ, ដើម្បីយឺត, ដើម្បីកន្ត្រាក់ ។

**កឌ្ឍ** ធា. **អាកឌ្ឍនេ កឌ្ឍតិ អាកឌ្ឍតិ បរិកឌ្ឍតិ និក្កឌ្ឍតិ**"ទាញ, អូស, កញ្ឆក់, កន្ត្រាក់" ភូ. ។

**កណ** បុំ. កុណ្ឌាក (កុន្ទក់) ដូច (**ធញ្ញគ្គ, កុណ្ឌក**), គុ. តូច, តិច, ល្អិត, ឆ្មារ (ដូច **អណុ, សុខុម** ) ។

**កណយ** បុំ. ច្បូក (ដូច **ភិន្ទិវាឡ**) ។

**កណិកា** ឥ. ដើមភក្តី (ដូច **អគ្គិមន្ថ**) ។

**កណិការ** បុំ. [កណ + ករ + ណ] ឈើកណិការ, ផ្កាកណិការ, ដើមកណិការ (ដូច **មុទុប្បល**) (វិ. **អគន្ធបុប្ផតាយ អត្តានំ កណិដ្ឋំ ករោតីតិ**> **កណិការោ**) ។ -**បុប្ផរាសិ** បុំ. គំនរនៃផ្កាកណិការ ។

**កណេរុ** បុំ. [កណ + ឥរុ ] ដំរី, ដំរីឈ្មោល (ដូច **គជ**) ន័យខ្លះថា ឥ. មេដំរី (ដូច **ហត្ថិនី**) ។ -**មិដ្ឋ** នបុំ. ខ្នងនៃដំរី, ខាងក្រោយនៃដំរី ។

**កណេរុកា** ឥ. [កណ + ឥរុ + ក-ស. + អា-ឥ.] មេដំរី (ដូច **ហត្ថិនី**)។ ប្រើជា **ករេណុកា**ក៏មាន។

**កណ្ដក** បុំ. សត្រូវ (ដូច**សបត្ត**), បន្លា, ព្រឺរោម (ដូច **លោមហំសន**), សត្វខ្ទីង (ដូច **គណិ**។

**កណ្ដកីផល** បុំ. ដើមខ្នុរ(ខ្នុល) (ដូច **បនស**) ។

**កណ្ឋក** អ.ន. សេះឈ្មោះ**កណ្ឋកៈ** ។

**កណ្ឋតូសា** ឥ. គ្រឿងប្រដាប់ ក (ដូច **គីវេយ្យ**) ។

**កណ្ឋ** បុំ. ក (ដូច **សិរោធរា**) ។

**កណ្ឋិ** ធា. **សោកេ កណ្ឋេតិ កណ្ឋាយតិ**"ស្ងួតចិត្ត, សោកស្រណោះ សង្រេង

សង្រែ" ចុ.។

**កណ្ឌ** នបុំ. [កណ + ឌ] វត្ថុជាគ្រឿងដែលជនបាញ់ទៅ (ព្រួញ, កូនសរ ដូច **សរ, ឧសុ**), វិ. **កណិយតេ ខិបិយតេ ឯតេនាតិ>កណ្ឌំ** ។ កំណាត់ឈើ, ឈើច្រត់ (ដូច **ទណ្ឌ**), កណ្ឌ(ដូច **វគ្គ**) ឧ. **ឥតិសន្ធិ កប្បេ បឋមោ កណ្ឌោ** ។ បុំ. ដើម, ទង (ដូច **នាឡ**) ។

**កណ្ឌរា** ឥ. សរសៃធំ (ដូច **មហាសិរា**) ។

**កណ្ឌុ** ឥ. រោគរមាស់ (ដូច **កណ្ឌុតិ**) ។

**កណ្ឌុតិ** ឥ. រោគរមាស់ (ដូច **កណ្ឌូយា,កណ្ឌុ**) ។

**កណ្ឌុវណដ្ឋាន** នបុំ. [**កណ្ឌុវណ** + **ឋាន**] ទីជាទីអេះ, ទីជាទីតាំងនៃកិ. អេះ (ខ្លះថា ទីមានដំបៅដ៏រមាស់), **កណ្ឌុវណ**<**កណ្ឌុ** + **យុ**, ផ្លាស់អនៃកណ្ឌ > ឧវ, ផ្លាស់យុ >អន >អណ។

**កណ្ឌុវន្តី** គុ. [កណ្ឌ >កណ្ឌុវ + អន្ត + ឦ] កាលអេះ, កាលខ្វាំ ។

**កណ្ឌុវន** នបុំ. រោគរមាស់ (ដូច **ខជ្ជុ**) ។

**កណ្ឌូយា** ឥ. រោគរមាស់ (ដូច **កណ្ឌុ**) ។

**កណ្ឌិ** ធា. **ឆេទនេ កណ្ឌេតិ កណ្ឌយតិ**"កាត់, បែងចេញ" ចុ. ។ **កណ្ឌ** បុំ. "វគ្គ, កណ្ឌ" **កណ្ឌុតិ កណ្ឌូ កណ្ឌូយា** ឥ. **កណ្ឌូវនំ** នបុំ. រមាស់ដោយអ្វី រោល កន្ទួល ។ **កណ្ឌរា** ឥ. =**មហាសិរា** "សរសៃធំ" ។ **កណ្ឌូយតិ** កិ. "អេះ, ខ្វារ" (បា. អ.) ។

**កណ្ណ** បុំ. នបុំ [ករ+ណ] (អវយវៈ)ជាគ្រឿងស្តាប់ ឬឮនៃជន (ត្រចៀកដូច **សវន**, **សទ្ទគ្គហ** ឬស្លឹកត្រចៀក), វិ. **កណ្ណតិ សុណាតិ ឯតាយាតិ**> **កណ្ណោ** ។ កន្លែងខ្លះប្រែថា <<មុំ, ជាយ, ជ្រៀង, ទីបំផុត, (ដូច **កោដិ**)។ -**ចូឡិកា** ឥ. គុម្ពនៃត្រចៀក, គល់នៃត្រចៀក ។ -**នាសា** ឥ. ត្រចៀកនិងច្រមុះ។ -**ចិដ្ឋ** ឥ. ខ្ទង់នៃត្រចៀក ។ -**មូល** នបុំ. ប្រទេសជាទីតាំងនៃត្រចៀក, ជិតនៃត្រចៀក, គល់នៃត្រចៀក ។ -**វិជ្ឈនមង្គលាទិ** គុ. (**មង្គល**) មានមង្គលជាទីចោះនូវត្រចៀកជាដើម, មានមង្គលគឺបុគ្គលគប្បីធ្វើក្នុងកាលជាទីចោះនូវត្រចៀកជាដើម ។ -**វិជ្ឈនមង្គល** នបុំ. មង្គលជាទីចោះនូវត្រចៀក។ -**សក្ខលិ** ឥ. គុម្ពនៃត្រចៀក ។ -**សោត** នបុំ. ប្រហោងនៃត្រចៀក, រន្ធនៃត្រចៀក ។

**កណ្ណជលូកា** ឥ. សត្វខ្លឹស, ក្អែប (ដូច **សតបទី**) ។

**កណ្ណធារ** បុំ. នាយទូក, នាយសំពៅ (ដូច **នាវិក**) ។

**កណ្ណបូរ** បុំ. គ្រឿងប្រដាប់ត្រចៀក (ដូច **កណ្ណិកា**) ។

**កណ្ណមុណ្ឌ** បុំ. ឈ្មោះមហាស្រះមួយក្នុងព្រៃហិមពាន្ត ។

**កណ្ណវិភូសន** នបុំ. គ្រឿងប្រដាប់ត្រចៀក (ដូច **កណ្ណិកា**) ។

**កណ្ណវេធន** នបុំ. ការ, ទំហូ គ្រឿងប្រដាប់ត្រចៀក (ដូច **កុណ្ឌល**) ។

**កណ្ណិកា** ឥ. [កណ្ណ + ណិក] ហោជាង, ជហ្វា, កំពូលផ្ទះ, ជហ្វាផ្ទះ (ដូច **កូដ**, **ឃរកូដ**), គ្រឿងប្រដាប់ត្រចៀក (ដូច **កណ្ណវិភូសន**, **កណ្ណភូសា**), ស្រោមនៃគ្រាប់ឈូក (ដូច **ពីជកោស**) ។ -**មណ្ឌល** នបុំ. មណ្ឌលនៃហោជាង ។ -**រុក្ខ** បុំ. ឈើសម្រាប់ធ្វើនូវហោជាង ។ -**ពន្ធ** គុ. ដែលបុគ្គលចងឲ្យជាចង្កោម, ជាប់គ្នាដោយចង្កោម ។ -**អារោបន-ទិវស** បុំ, នបុំ. ថ្ងៃជាទីលើកនូវហោជាង ។

**កណ្ណិការ** បុំ [កណ្ណ + ករ + ណ] ឈើកណិការ, ផ្កាកណិការ (វិ. ចូរមើល <<**កណិការ**>>) ។ -**បុប្ផទាមសទិស** គុ. ប្រាកដស្មើដោយកម្រង (ចង្កោម, ភួង) នៃផ្កាកណិការ ។ -**បុប្ផបទុមបុប្ផាទិ** គុ. (ផ្កា) មានផ្កានៃកណិការនិងផ្កានៃឈូកជាដើម ។

**កណ្ណេជប** បុំ. អ្នកខ្សិបខ្សៀវ, អ្នកសឹកសៀត, អ្នកញុះញង់ (ដូច **បិសុណ**)។

**កណ្ណ** ធា. **សវនេ កណ្ណេតិ កណ្ណយតិ**"ស្តាប់, ឮ" ចុ.។ **កណ្ណ** បុំ. "ត្រចៀក, មុម, ជ្រុង" ។

**កណ្ដក** បុំ. បន្លា, ឈើមានបន្លា, ។ -**ឧទ្ធរណ** នបុំ.កិ.ដកឡើងនូវបន្លា ។

**កល្យាណ** នបុំ. [កល + យាណ] (គុណជាត)ដែលជនគួររាប់ (សេចក្តីល្អ, លម្អ, ពីរោះ, ជាទីពេញចិត្ត), វិ. **កលិតព្វំ សំខ្យាតព្វន្តិ**>**កល្យាណំ** ។ -**កម្ម** នបុំ. កម្មមានគុណគឺបណ្ឌិតគប្បីរាប់, កម្មដ៏ល្អ ។ -**អជ្ឈា-សយ** គុ. អ្នកមានអធ្យាស្រ័យមានគុណគឺបុគ្គលគប្បីរាប់, អ្នកមានអធ្យាស្រ័យល្អ, ។ -**ធម្ម** គុ. មានធម៌មានគុណគឺបុគ្គលគប្បីរាប់, មានធម៌ដ៏ល្អ ។ - **បាបក** គុ. មានអំពើល្អ និងអំពើអាក្រក់ ។ - **មិត្ត** បុំ. មិត្រល្អ, កល្យាណមិត្រ ។

**កណ្ហ** គុ. ន. [កសឬកុ + ណ្ហ] ខ្មៅ, ពណ៌ខ្មៅ (ដូច **កាឡ**), បុំ. ព្រះនារាយណ៍ (ដូច **វាសុទេវ**, **ចក្កបាណិ**), មារ (ដូច **អន្តក**, **នមុចិ**), គោឈ្មោះ **កណ្ហៈ**, នបុំ. បាប (ដូច **អកុសល**) ។ -**ឧសភជាតក** នបុំ. ជាតកគឺបណ្ឌិតកំណត់ដោយគោឧសភឈ្មោះកណ្ហៈ ។

**កណ្ហវណ្តា** ឥ. ដើមច្រនៀង (ដូច **បាដលី**) ។

**កណ្ហវត្តនី** ឥ. ភ្លើង (ដូច **វាយុសខ**) ។

**កណ្ហាជិនា-សទិស** គុ. [កណ្ហាជិនា+សទិស] ប្រាកដស្មើដោយកុមារីឈ្មោះ**កណ្ហាជិនា** ។

**កណ** ធា. ១-**សទ្ទេ កណតិ កាណោ**"ចេញសំឡេង, ពោល" ភូ. ។
២- **និម្មិលេ កាណេតិ កាណយតិ**"ធ្មេច, បិទភ្នែក, ខ្វាក់" ចុ. ។ **កាណ** បុំ."មនុស្សខ្វាក់"។ ប៉ុន្តែក្នុង **អដ្ឋកថា**ពន្យល់ថា ខ្វាក់តែម្ខាងប្រើសព្ទថា "**កាណ**" បើខ្វាក់ទាំងសងខាងប្រើសព្ទថា **អន្ធ** វិញ ។

**កត** គុ. [ករ + ត] គឺ.....ធ្វើហើយ, វិ. **ករិយិត្ថាតិ>កតោ**, **កតា**, **កតំ** ។ -**ឧបដ្ឋាននិស្សន្ទ** បុំ. វិបាកជាគ្រឿងហូរចេញនៃកិ.បម្រើគឺ....ធ្វើហើយ, អានិសង្សនៃកិ.បម្រើគឺ.....ធ្វើហើយ ។ -**កម្មវស** បុំ. អំណាចនៃកម្មគឺ......ធ្វើហើយ ។ -**កម្ម** នបុំ. កម្មគឺ....ធ្វើហើយ, គុ. មានកម្មគឺ....ធ្វើហើយ, មានកម្មធ្វើហើយ ។ -**កល្យាណ** គុ. មានកម្មគឺបណ្ឌិតគប្បីរាប់ធ្វើហើយ, មានអំពើដ៏ល្អធ្វើហើយ ។ -**កិច្ច** គុ. មានកិច្ចធ្វើហើយ ។ -**កិរិយា** ឥ. កិរិយាគឺ.....ធ្វើហើយ ។ -**គន្ធបរិ-ភណ្ឌ** គុ. មានកិ.ប្រោះព្រំដោយវត្ថុមានក្លិនធ្វើហើយ ។ -**ចិត្តក** គុ. មានវិចិត្រធ្វើហើយ, មានកម្មដ៏វិចិត្រគឺ....ធ្វើហើយ ។ -**ចិត្តកម្ម** គុ. មានកម្មដ៏វិចិត្រគឺ...ធ្វើហើយ, មានគំនូរធ្វើហើយ ។ -**ដ្ឋាន** នបុំ. ទីនៃ....គឺ.......ធ្វើហើយ ។ -**ត្ត** នបុំ. ភាវៈនៃ..... ជា.....គឺ....ធ្វើហើយ ។ -**ទាន** នបុំ. ទានគឺ...ធ្វើហើយ ។ -**និយាម** បុំ. ហេតុជាគ្រឿងកំណត់នៃ......ធ្វើហើយ, ទំនងនៃ.....គឺ.....ធ្វើហើយ ។ -**ប្បច្ចុគ្គមន** គុ. មានកិ.ក្រោកទទួលធ្វើហើយ, វិ. **កតំ បច្ចុគ្គមនំ យេន សោ>កតប្បច្ចុគ្គមនោ**។ -**ប្បដិសម្មោទន** គុ. មានសេចក្តីរីករាយព្រមចំពោះធ្វើហើយ ។ -**បត្តបុដ** គុ. មានសំបុក (កញ្ចប់) នៃស្លឹកគឺ...ធ្វើហើយ ។ -**បរិច្ចាគ** បុំ. កិ.លះបង់គឺ...ធ្វើហើយ, គុ. មានការបរិច្ចាគធ្វើហើយ ។ -**បាតរាស** គុ. មានភោជនគឺបុគ្គលគប្បីស៊ីក្នុងវេលាព្រឹកធ្វើហើយ, វិ. **បាតោ អសិតព្វន្តិ>បាតរាសំ**, **កតំ បាតរាសំ យេន សោ>កតបាតរាសោ** ។ -**បាបកម្មវស** បុំ. អំណាចនៃបាបកម្មគឺ....ធ្វើហើយ ។ -**បាបកម្ម** នបុំ. កម្មដ៏លាមកគឺ....ធ្វើហើយ, គុ. មានកម្មដ៏លាមកធ្វើហើយ ។ -**បុញ្ញកម្ម** នបុំ. មានបុញ្ញកម្ម (កម្មគឺបុណ្យ) ធ្វើហើយ ។ -**បុញ្ញ** គុ. អ្នកមានបុណ្យធ្វើហើយ ។ -**បុព្វ** គុ. គឺ....ធ្លាប់ធ្វើហើយ ។ -**ភត្តកិច្ច** គុ. អ្នកមានកិច្ចដោយភត្តធ្វើហើយ, អ្នកមានភត្តកិច្ចធ្វើហើយ វិ. **ភត្តេន កិច្ចំ>ភត្តកិច្ចំ**, **កតំ ភត្តកិច្ចំ យេន សោ>កតភត្តកិច្ចោ** ។ -**ភាវ** បុំ. ភាវៈនៃ...នោះជា....គឺ...ធ្វើហើយ ។ -**មង្គល** គុ. អ្នកមានមង្គលធ្វើហើយ, នបុំ. មង្គលគឺ...ធ្វើហើយ ។ -**វត្ត** នបុំ. វត្តគឺ...ធ្វើហើយ ។ -**វេទី** បុំ. អ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយ, អ្នកសម្តែងនូវឧបការៈដែលអ្នកដទៃធ្វើហើយ, វិ. **កតំ ឧបការំ វិទតីតិ> កតវេទី** ។ -**សក្ការសម្មាន** គុ. អ្នកមានសក្ការៈនិងសម្មានៈ (សេចក្តីរាប់អាន) ធ្វើហើយ ។ - **សក្ការ** បុំ. សក្ការៈគឺ...ធ្វើហើយ, គុ. អ្នកមានសក្ការៈធ្វើហើយ ។ -**សន្នាហ** គុ. អ្នកមានវត្ថុជាគ្រឿងចងព្រមហើយ, អ្នកមានវត្ថុជាគ្រឿងស៊កសៀតធ្វើហើយ ។ -**សព្វកិច្ច** គុ. អ្នកមានកិច្ចទាំងពួងធ្វើហើយ ។ -**សរីរប្បដិជគ្គន** គុ. អ្នកមានកិរិយាជម្រះនូវ

សរីរៈធ្វើហើយ។ -**សមណធម្ម** គុ. អ្នកមានសមណធម៌ធ្វើហើយ ។ -**សស្ស** នបុំ. សំទូងគឺ...ធ្វើហើយ ។

**កតក** បុំ. ឈ្មោះឈើម្យ៉ាង ដីកាប្រាប់ថា **ឧទកប្បសាទនផល** ឈើមានផ្លែញ៉ាំងទឹកឲ្យថ្លា (ដើមពោន),គុ. របស់ប្លម, កាឡៃ (ដូច **កិត្តិម**) ។

**កតម** វិ.ស.អ. [កឹ + តម >កតម] ណា, ណាមួយ, ណាខ្លះ, អ្វី, ដូចម្តេច... ។

**កតមាល** បុំ. ដើមរាជព្រឹក្ស (ដូច **រាជរុក្ខ**) ។

**កតរ** វិ.ស.អ. [កឹ + តរ >កតរ] ណា, ណាមួយ, ណាខ្លះ, អ្វី, ដូចម្តេច... ។ -**កុល** នបុំ. ត្រកូលណា ។ -**ថេរ** បុំ. ព្រះថេរៈអង្គណា ។ -**ទានរសរតិ** ឥ. ទាននិងរសនិងសេចក្តីត្រេកអរអ្វី ។ -**ធីតា** ឥ. ធីតាណា, ធីតានៃជនណា ។ -**នគរ** នបុំ. នគរណា ។ -**ប្បច្ចយ** បុំ. បច្ច័យអ្វី ។ -**សក្ក** បុំ. សក្យៈណា ។

**កតហត្ថ** គុ. អ្នកមានថ្វីដៃ, អ្នកឆ្លៀវឆ្លាស, អ្នកជំនាញ (ដូច **កុសល**) ។

**កតាកត** គុ. [កត + អកត] គឺ....ធ្វើហើយនិងមិនធ្វើហើយ ។ -**វិញ្ញានក** បុំ. អ្នកដឹងច្បាស់នូវកម្មដែលបុគ្គលធ្វើហើយនិងមិនធ្វើហើយ, វិ. **ក-តាកតំ វិជានាតីតិ**> **កតាកតវិញ្ញានកោ** ។

**កតាធិការ** គុ. [កត + អធិការ] មានអធិការៈធ្វើហើយ, មានកុសលគឺបុគ្គលគប្បីធ្វើដ៏ក្រៃលែងធ្វើហើយ, មានកិ.កសាងធ្វើហើយ ។

**កតាបរាធ** បុំ. [កត + អបរាធ] សេចក្តីខុសគឺ...ធ្វើហើយ, កំហុសគឺ...ធ្វើហើយ, គុ. មានកំហុសធ្វើហើយ ។

**កតាភិនិហារ** គុ. [កត + អភិនិហារ] អ្នកមានអភិនិហារធ្វើហើយ, អ្នកមានធម៌ជាគ្រឿងនាំចេញដើម្បីគុណដ៏ក្រៃលែងធ្វើហើយ, វិ. **កតោ អភិនិ-ហារោ យេន សោ**>**កតាភិនិហារោ** ។

**កតាភិយោគភាវ** បុំ. [កត + អភិយោគ + ភាវ] ភាវៈនៃ.....អ្នកមានព្យាយាមជាគ្រឿងប្រកបដ៏ក្រៃ លែងធ្វើហើយ, វិ. **អភិយុញ្ជតិ ឯតេនាតិ**>**អភិ-យោគោ, កតោ អភិយោគោ យេន សោ**>**កតាភិយោគោ, កតាភិយោគស្ស ភាវោ**> **កតាភិ-យោគភាវោ** ។

**កតិ** និ. ប៉ុន្មាន, ចំនួនប៉ុន្មាន ។ -**វស្ស** គុ. មានវស្សាប៉ុន្មាន, ប៉ុន្មានវស្សា, ។

**កតិកា** ឥ. [កតិ + ណិក] សញ្ញាដែលកើតអំពីការធ្វើ (សេចក្តីប្តេជ្ញា, ពាក្យប្តេជ្ញា), វិ. **ករណំ**>**កតិ, កតិយា( សញ្ញា ) ជាតា** >**កតិកា** ។

**កតិបយ** គុ. [កតិ + បិ>កតិបយ] ពីរបី, ពីរបីនាក់, ពីរបីរូប ។

**កតិបាហ** នបុំ. [កតិបិ + អហ] ថ្ងៃពីរបី, ពីរបីថ្ងៃ ។ -**អច្ចយ** បុំ. កាលជាទីប្រព្រឹត្តកន្លងទៅនៃថ្ងៃពីរបី, កាលជាទីប្រព្រឹត្តកន្លងទៅអស់ពីរបីថ្ងៃ ។

**កតុ** បុំ. យញ្ញ, ការបូជា (ដូច **យញ្ញ**) ។

**កតុបាសន** គុ. [កត + ឧបាសន] មានការបាញ់នូវកូនសរស្ទាត់ហើយ, -ថ្នឹកហើយ

(ខ្លះថា មានគ្រឿងក្រោះធ្វើហើយ), វិ. **កតំ ឧបាសនំ យេហិ តេ**> **កតុបាសនា** ។

**កតោកាស** គុ. [កត + ឱកាស] អ្នកមានឱកាសធ្វើហើយ, អ្នកមានឱកាសគឺ....ធ្វើហើយ ។

**កតោបការ** គុ. [កត + ឧបការ] អ្នកមានឧបការៈធ្វើហើយ ។

**កត្តព្វ** គុ. [ករ + តព្វ] គឺ...គប្បីធ្វើ-គួរធ្វើ, -ត្រូវធ្វើ ។ -**កម្ម** នបុំ. កម្មគឺបុគ្គលគប្បីធ្វើ ។ -**កិច្ច** នបុំ. កិច្ចគឺ...គប្បីធ្វើ ។ -**បរិហារ** គុ. វត្ថុជាគ្រឿងរក្សាគឺ...គប្បីធ្វើ, (វត្ថុជាគ្រឿងនាំទៅជុំវិញគឺអ្នកទាំងឡាយគប្បីធ្វើ) ។ -**យុត្តក** គុ. គួរគឺ...គប្បីធ្វើ ។ -**រូប** គុ. មានរូបគឺ....គប្បីធ្វើ, មានសភាពគឺ...គប្បីធ្វើ ។ -**វត្ថុ** នបុំ. វត្ថុគឺ...គប្បីធ្វើ ។ -**សិប្ប** នបុំ. សិល្បៈ (សិល្បសាស្ត្រ) គឺ...គប្បីធ្វើ ។

**កត្តរ** គុ. [កត្តរ + អ] ចាស់, គ្រាំគ្រា (វិ. **កត្តរយតីតិ**>**កត្តរោ**) ។ -**យដ្ឋិ** ឥ. ឈើច្រត់ចាស់, ឈើច្រត់នៃបុគ្គលចាស់ ។ -**សុប្ប** នបុំ. ចង្អេរចាស់ ។- **យដ្ឋិ** ឥ.ឈើច្រត់មនុស្សចាស់ (ដូច **អាលម្ពនទណ្ឌ**) ។

**កត្តរិយគ្គ** នបុំ. [កត្តរិយ + អគ្គ] ចុងនៃកន្ត្រៃ ។

**កត្តរិ** ធា. **សេថិល្លេ កត្តរេតិ កត្តរយតិ**"ស្រាល..." ចុ. ។ **កត្តរ** បុំ. =**ជិណ្ណ**=**មហល្លក** មនុស្សចាស់, **កត្តរទណ្ឌ** បុំ. "ឈើច្រត់" ឈើមនុស្សចាស់, **កត្តរសុប្ប** នបុំ. ចង្អេរចាស់, កន្ទាំងចាស់" ។

**កត្តា** បុំ. [ករ + តុ] អ្នកធ្វើ, វិ. **ករោតីតិ**>**កត្តា** ។

**កត្តិកា** ឥ. ឈ្មោះផ្កាយឫក្សម្បាំង ។

**កត្តិក** បុំ. ខែកត្តិក, ខែប្រកបដោយកត្តិកាឫក្ស ។

**កត្តុកម្យតាឆន្ទវស** បុំ. [**កត្តុកម្យតា**+ **ឆន្ទ**+ **វស**] អំណាចនៃឆន្ទៈ (សេចក្ដីពេញចិត្ត) គឺភារៈនៃបុគ្គលអ្នកប្រាថ្នាដើម្បីធ្វើ (**កត្តុកម្យតា**<កត្តុកាម+ណ្យ+តា, វិ. **កត្តុំ កាមេតីតិ**>**កត្តុកមោ**, **កត្តុកាមស្ស ភាវោ**>**កត្តុកម្យំ**, **កត្តុកម្យំ ឯវ**> **កត្តុកម្យតា**) ។

**កត្តុកាម** គុ. [កត្តុំ + កម + ណ] អ្នកប្រាថ្នាដើម្បីធ្វើ, អ្នកចង់ដើម្បីធ្វើ, វិ. **កត្តុំ កាមេតីតិ**> **កត្តុកាមោ** ។

**កត្ថ** អ.ស. **ក្វត្ថវាចក** និបាតប្រាប់អត្ថគឺ ក្នុង ណា, ក្នុងដូចម្ដេច ប្រែថា ក្នុងទីណា, ក្នុងដូចម្ដេច ជាដើម, **កុហិញ្ចនំ**, **កុហឹ**, **កុត្រ**, **កុត្ថ**, **កហំ**, **ក្វ** ក៏ជា**ក្វត្ថវាចក** ដែរ ។

**កត្ថចិ** អ.ស. [កឹ + ត្ថ + ចិ] ក្នុងទីណា, ក្នុងទីដូចម្ដេច ។

**កត្ថនា** ឥ. ការពណ៌នា, សេចក្ដីសរសើរ (ដូច **វណ្ណនា**) ។

**កត្ថវាសិក** គុ. [កត្ថ + វស + ណិក] អ្នកនៅក្នុងទីណា ។

**កត្ថូរិកា** ឥ. ដើមឈ្មុស (ដូច **មិគមទ**) ។

**កត្ថិ** ធា. **សិលាឃាយំ កត្ថតិ វិកត្ថតិ កត្ថនា វិកត្ថនា កត្ថី វិកត្ថី**" សរសើរ, ស្ញើច" ភូ. ។ សូមជ្រាបថា សព្ទណាមាន **វិ** នាំមុខគឺ សម្ដែងអាការៈច្រើនឡើង ក្រៃលែងឡើង ឧ. **ពហុម្បិ សោ វិកត្ថេយ្យ** "គេគប្បីស្ញើចច្រើន" ។ **ឥធេកច្ចោ កត្ថី ហោតិ វិកត្ថី**"ក្នុងលោកនេះ មនុស្សខ្លះ ជាអ្នកសរសើរ សរសើរក្រៃលែង" ស. ។

**កត្វា** អ. [ករ + ត្វា] ធ្វើ, ធ្វើហើយ ។

**កតិ** ធា. ១-**សុត្តជននេ កន្តតិ**"បង្កើតសូត្រ, រវៃ" រុ. អា. **សុត្តំ កន្តតិ** "រវៃ អំបោះ, ការអំបោះ"។

២- **ឆេទនេ កន្តតិ វិកន្តតិ កន្តនំ ឧក្កន្តិត្វា ឧក្កច្ច**"កាត់, វះ, ពន្លះ, រុ. ។ **អយោកន្ត**"កាត់ដែក" ។ **សល្លកត្តោ=សល្លវេជ្ជោ**" ពេទ្យវះកាត់" -**ស**. ។ អា. **សល្លកត្តោ មហាវីរោ** "ព្រះមហាវីរៈ ជាអ្នកកាត់កិលេសដូចកូនសរ" ។ **មានោ អជ្ជ វិកន្តឹសុ**"កុំកាត់ (រូបកាយ) នៃយើងទ. ក្នុងថ្ងៃនេះ" ។ **ឧក្កច្ច** អព្យ. អា. **បិដ្ឋិមំសានិ អត្តនោ សាមំ ឧក្កច្ច ខាទសិ**"ឯងខ្វេះសាច់ខ្នងរបស់ខ្លួនទំពាស៊ី ដោយខ្លួនឯង" <**ឧក្កច្ច=ឧក្កន្តិត្វា=ឆិន្ទិត្វា**> -**ស**. ។

**កថញ្ចិ** និ. **កិច្ឆត្ថវាចក** និបាតប្រាប់អត្ថគឺ លំបាក, ខ្វចចិត្ត ។

**កថន** នបុំ. [កថ + យុ] កិ.ពោល, កិ. សម្ដែង,...វិ. **កថិយតេ**>**កថនំ** ។ ជាទីពោល, វិ. **កថេតិ ឯតស្មិន្តិ**>**កថនំ** ។ - **កាល** បុំ. កាលជាទីពោល ។ - **ភយ** នបុំ. ភ័យ (សេចក្ដីខ្លាច) អំពីកិ.ពោល ។

**កថយមាន** គុ. [កថ + ណយ + មាន] កាលពោល, កំពុងពោល ។

**កថយិត្វា** កិ. [កថ + ណយ + ត្វ-ហី.,ចុះត-អា.] ពោលហើយ ។

**កថយឹសុ** កិ. [កថ + ណយ + ឧំ-អជ្ជ.] ពោលហើយ, សម្ដែងហើយ,.......។

**កថា** ឥ [កថ + អ + អា-ឥ.] វាចាជាគ្រឿងពោល, វិ. **កថេតិ ឯតាយាតិ**> **កថា** ។ វាចាដែលជនពោល (ពាក្យ, សម្ដី), វិ. **កថិយតីតិ**>**កថា** ។ -**ទោស** បុំ. ទោសនៃវាចាជាគ្រឿងពោល ។ -**បបញ្ច** បុំ. កាលដ៏យឺតយូរព្រោះវាចាជាគ្រឿងពោល, ដំណើរយឺតយូរព្រោះវាចាជាគ្រឿងពោល ។ -**បរិយោសាន** នបុំ. កាលជាទីបំផុតជុំវិញនៃកថា, កាលជាទីចប់នៃវាចាជាគ្រឿងពោល ។ -**បវត្តិ** ឥ. កិ.ប្រព្រឹត្តទៅនៃវាចាជាគ្រឿងពោល ។ -**វត្ថុ** នបុំ. កថាវត្ថុ, វត្ថុ (រឿង) នៃវាចាជាគ្រឿងពោល ។ -**សទ្ទ** បុំ. សំឡេងនៃវាចាជាគ្រឿងពោល, សូរនៃ... ។ -**សមុដ្ឋាបនវត្ត** នបុំ. វត្តគឺកិ.ញុំាំងវាចាជាគ្រឿងពោលឲ្យតាំងឡើងព្រម, វិ. **កថំ សមុដ្ឋាបិយតេតិ**>**កថាសមុដ្ឋាបនំ**, **កថា-សមុដ្ឋាបនំ ឯវ វត្តំ**>**កថាសមុដ្ឋាបនវត្តំ** ។ -**សល្លាប** បុំ. កិ.

ចរចាដោយវាចាជាគ្រឿងពោល, ការនិយាយឆ្លើយឆ្លងដោយសម្ដី (**សល្លាប**<សំ + លប + ណ), វិ. **សល្លបនំ**>**សល្លាបោ**, **កថាយ សល្លាបោ**>**កថាសល្លាបោ** ។ ប្រពន្ធកថាសាស្ត្រ ។

**កថាន** នបុំ. ឈ្មោះសំខ្យាម្យ៉ាងដាក់លេខ ១ មានពិន្ទុ ១២៦ គឺមួយរយសែនបទុម ។

**កថាបេតុំ** អ. [កថ+ណាបេ+តុំ] ដើម្បីញ៉ាំង...ឲ្យពោល, វីកិ.ញ៉ាំង...ឲ្យសម្ដែង ។

**កថាបេត្វា** អ. [កថ + ណាបេ + ត្វា] ញ៉ាំង...ឲ្យសម្ដែងហើយ ។

**កថាបេថ** កិ. [កថ + ណាបេ + ថ-ប.] ចូរញ៉ាំង...ឲ្យពោល ។

**កថាបេសុំ** កិ. [កថ + ណាបេ + ឧំ-អជ្ជ., ចុះស-អា.] ញ៉ាំង...ឲ្យពោលហើយ ។

**កថាបេស្សាមិ** កិ. [កថ + ណាបេ + ស្សាមិ-ភ.] នឹងញ៉ាំង...ឲ្យពោល ។

**កថំកថា** ឥ. សេចក្ដីសង្ស័យ (ដូច **សន្ទេហ**) ។

**កថិត** គុ. [កថ + ឥ-អា. + ត] គឺ...ពោលហើយ(ដូច **ឧទិរិត**) ។ -**កថា** ឥ. វាចាជាគ្រឿងពោលគឺ...ពោលហើយ ។ -**ការណ** នបុំ. ហេតុនៃ... គឺ...ពោលហើយ ។ -**កាល** បុំ. កាលនៃ...គឺ...ពោលហើយ ។ -**ត្ត** នបុំ. ភាវៈនៃពាក្យនោះជាពាក្យគឺ....ពោលហើយ ។ -**ធម្ម** បុំ. ធម៌គឺ... សម្ដែងហើយ ។ -**និយាម** បុំ. ទំនងនៃពាក្យគឺ....ពោលហើយ ។ -**ភាវ** បុំ. ភាវៈនៃពាក្យនោះជាពាក្យគឺ...ពោលហើយ ។ -**វត្ត** នបុំ. វត្តគឺ...ពោលហើយ, វត្តគឺ...ពោលហើយ, វត្តគឺ...ប្រាប់ហើយ ។

**កថិយមាន** គុ. [កថ + ឥ-អា + យ + មាន] គឺ...កាលពោល, គឺ...កំពុងពោល ។

**កថេតព្វ** គុ. [កថ + ណេ + តព្វ] គឺ...គប្បីពោល, គឺ..ត្រូវពោល ។ -**យុត្តក** គុ. គួរគឺ...គប្បីពោល ។

**កថេតិ** កិ. [កថ + អ (ឯ)+ តិ-វ.] ពោល, សម្ដែង, ប្រាប់, និយាយ, ស្ដី, ថា ។

**កថេតុំ** អ. [កថ + អ + តុំ] ដើម្បីពោល, វីកិ.ពោល ។

**កថេត្វា** អ. [កថ + អ + ត្វា] ពោលហើយ, សម្ដែងហើយ ។

**កថេន្ត** គុ. [កថ + អ + អន្ត] កាលពោល, កាលសម្ដែង ។

**កថេន្តិ** កិ. [កថ + អ + អន្តិ-វ.] ពោល, សម្ដែង ។

**កថេន្តី** គុ. [កថ + អន្ត + ឦ] កាលពោល, កាលសម្ដែង ។

**កថេយ្យ** កិ. [កថ + អ + ឯយ្យ-ស] គប្បីពោល, គប្បីសម្ដែង ។

**កថេសិ** កិ. [កថ + អ + ឦ-អជ្ជ, ចុះស-អា] ពោលហើយ, សម្ដែងហើយ ។

**កថេស្សតិ** កិ. [កថ + អ + ស្សតិ-ភ] នឹងពោល, នឹងសម្ដែង ។

**កថេហិ** កិ. [កថ + អ + ហិ-ប] ចូរពោល, ចូរសម្ដែង ។

**កថំ** បុ.និ. ដោយប្រការដូចម្ដេច, ដូចម្ដេច, អ្វី, យ៉ាងណា ។ -**កថា** ឥ. វាចាជាគ្រឿងពោលថាដូចម្ដេច, វិ. **កថំ កថេតិ ឯតេនាតិ>កថំកថា** ។ -**ភូត** គុ. កើតហើយយ៉ាងណា, កើតហើយដូចម្ដេច ។ -**រូប** គុ. មានសភាពយ៉ាងណា, មានសភាពដូចម្ដេច, មានអ្វីជារូប ។

**កថំ** អ.ត. [កឹ + ថំ] វិប្រការដូចម្ដេច, នូវប្រការដូចម្ដេច, ដោយប្រការដូចម្ដេច ។ ល ។

**កថំ** និ. **បញ្ហត្ថវាចក** និបាតប្រាប់អត្ថគឺ សាកសួរ ប្រែថា ដោយប្រការដូចម្ដេច, **កឹសុ**, **ននុ**, **កច្ចិនុ**, **កឹ** ក៏ជា**បញ្ហត្ថវាចក** ដែរ ។

**កថិ** ធា. ១-**កថនេ វាក្យបពន្ធនេ ច កថេតិ កថយតិ កថេត្វា កថិតោ កថេតុំ**"ពោល, ថ្លែង, សម្ដែង, អធិប្បាយ, និពន្ធ, ចងក្រង" ចុ. ។ **សាកច្ឆតិ** កិ. "ចរចាគ្នា, សាកសួរគ្នា" =**សហ កថយតិ** ។ ឥ. **សាកច្ឆា** ។ **កថា** ឥ. "ពាក្យពោល, ពាក្យអធិប្បាយ, អត្ថបទ, សេចក្ដីដែលតែងឡើង ឬ និពន្ធឡើង" ។ **បរិកថា** ឥ. "ការនិយាយស្ទាក់, ពាក្យនិយាយស្ទាត់" ។ **អដ្ឋកថា** ឥ. =**អត្ថសំវណ្ណនា** "អធិប្បាយពន្យល់សេចក្ដី, សេចក្ដីពន្យល់ន័យ" វិ. **អត្ថោ កថីយតិ ឯតាយាតិ អដ្ឋកថា**(**ថទន្តជៈ>ឋ**មុទ្ធជៈវិញ) -ស. ។
២- **និប្បាកេ កថតិ**"ឆ្អិន, ទុំ, ចាស់" ភូ. ។ **កថិត** កិ. គុ. "ឆ្អិនហើយ" (កថិ+ត មានរូប ២ គឺ **កថិត កឋិត** សូចិ) ។
៣- **ហឹសាយំ កថតិ**"បៀតបៀន" ភូ. ។
៤ **កោដិល្លេ កន្ថតិ**"វៀច, កោង, ង" រុ. ។

**កទម្ព** បុំ. ដើម **កទម្ព** ឬ **ក្ទម្ព**(ដូច **នីប**), ហ្វូង, ប្រជុំ, ពួក (ដូច **ចយ**) ។

**កទម្ពក** នបុំ. ហ្វូង, ប្រជុំ, ពួក (ដូច **ម្ភូត**) ។

**កទម្ពបុប្ផ** នបុំ. [កទម្ព + បុប្ផ] ផ្កានៃឈើកទម្ព, ផ្កាកទម្ព ។

**កទរិយ** គុ. [កទរ+ឥយ] (បុគ្គល) អ្នកមានសេចក្ដីកំណាញ់,រឹង(ដូច **ថទ្ធមច្ឆរី**), វិ.**កទរំ យស្ស អត្ថីតិ>កទរិយោ** ។

**កទរ** បុំ. ដើមពពេល (ដូច **សោមវក្ក**) ។

**កទលិគព្ភសទិស** គុ. [កទលិ + គព្ភ + សទិស] ប្រាកដស្មើដោយបណ្ដូលនៃចេក, ប្រហែលដោយត្រួយនៃចេក ។

**កទលិបណ្ណ** នបុំ. [កទលិ + បណ្ណ] ស្លឹកនៃចេក ។

**កទលិបត្ត** នបុំ. [កទលិ + បត្ត] ស្លឹកនៃចេក ។

**កទលិមិគ** បុំ. ម្រឹគឈ្មុស, ម្រឹគស្មាន់ (ដូច **កទលី**) ។

**កទលី** ឥ. ទង់ (ដូច **កេតន**, **បតាកា**), ចេក (ដូច **មោច**), ម្រឹគឈ្មុស (ដូច **កទលិមិគ**) ។

**កទា** កា.ស. [កឹ+ទា, កឹ>ក] ក្នុងពេលណា, អង្កាល់, ពីអង្កាល់ ។ **កទាត្ថវាចក**

និបាតប្រាប់អត្ថគឺក្នុងកាលណា, ក្នុងកាលដូចម្ដេច, **កុទាចនំ** ក៏ជា **កទាត្ថវាចក** ដែរ។

**កទាចិ** កា.ស. **អនិយតត្ថវាចក** និបាតប្រាប់អត្ថគឺមិនទៀង ប្រែថា ក្នុងកាលខ្លះ, ជួនកាលក៏, **ជាតុ** ក៏ជាអនិយតត្ថវាចក ដែរ ។

**កទ្ទមពហុល** គុ. [កទ្ទម + ពហុល] ច្រើនដោយភក់, មានភក់ដ៏ច្រើន ។

**កទ្ទមលេបនាការ** គុ. [កទ្ទម + លេបន + អាការ] អាការៈគឺកិ.លាបដោយភក់ ។

**កទ្ទ** ធា. **កុច្ឆិសទ្ទេ កទ្ទតិ**"ចេញសំឡេងគួរខ្ពើម" ភូ. ។ **កទ្ទម** បុំ. "ភក់, ល្បាប់" ។

**កទិ** ធា. ១-**អវ្ហានេ រោទនេ ច កន្ទតិ បក្កន្ទតិ កន្ទន្តោ កន្ទិតំ** "ហៅ, យំ, កន្ទក់កន្ទេញ" រុ.។

២- **វេលម្ពេ កន្ទិតិ**"ឈោង, តោង, យុរយារ" រុ. ។

**កនកមយ** គុ. [កនក+មយ] ជាវិការៈនៃមាស, វិ. **កនកស្ស វិការោ>កនកមយំ** ។ សម្រេចហើយដោយមាស, វិ. **កនកេន និប្ផន្នំ>កនកមយំ** ។

**កនកវិមាន** នបុំ. [កនក + វិមាន] វិមានជាវិការៈនៃមាស, វិមានដែលបុញ្ញកម្មធ្វើហើយដោយមាស, វិ. **កនកមយំ វិមានំ>កនកវិមានំ** ។

**កនក** នបុំ. មាស (ដូច **ជាតរូប**) ។

**កនិដ្ឋ** គុ. [យុវ > កន + ឥដ្ឋ] ក្មេងដោយវិសេស , ឬ ក្មេងជាង, តូចក្រៃពេក (ប្អូន **អនុជ**, ប្អូនតូច, ប្អូនពៅ ដូច **អត្យប្ប**), កម្លោះក្រៃពេក (ដូច **អតិយុវ**) វិ. **អយញ្ច យុវា អយញ្ច យុវា អយមិមេសំ វិសេសេន យុវាតិ>កនិដ្ឋោ** ។ -**កុដុម្ពិក** បុំ. កុដុម្ពិកៈ ឬ កុដុម្ពីក៏ជាប្អូន ។ -**កុមារ** បុំ. កុមារជាប្អូន ។ -**ធីតា** ឥ. ធីតាជាប្អូន ។ -**បុត្ត** បុំ. កូនជាប្អូន, កូនតូចជាង, កូននៃប្អូន (កូនពៅ) ។

-**ភគិនី** ឥ. ប្អូនស្រី ។ -**ភាតា** បុំ. ប្អូនប្រុស, បងប្អូនប្រុស ។

**កនិដ្ឋា** ឥ. ម្រាមកូនដៃ, ម្រាមទី ៥ ។

**កនិយ** គុ. ប្អូន (ដូច **អនុជ**), តូចក្រៃពេក (ដូច **អតប្ប**), កម្លោះក្រៃពេក (ដូច **អតិយុវ**) ។

**កនីនិកា** ឥ. កែវភ្នែក, ប្រស្រីភ្នែក (ដូច **នេត្តតារា**) ។

**កនុយិ** ធា. **សទ្ទេ កនុយតិ កនុតវា** "ចេញសំឡេង ពោល" ភូ. (កនុយិ+ភវន្តុ) ។

**កន្ត** គុ. [កម + ត] គឺបុគ្គលគប្បីប្រាថ្នា, -ត្រេកអរ, ជាទីត្រេកអរ ។

**កន្តតិ** កិ. [កត + ឬកន្ត + អ + តិ.វ] កាត់, លះ, ពុះ, ច្រៀក, រវៃ ។

**កន្តន្ត** គុ. [កន្ត + អន្ត] កាលរវៃ, កំពុងរវៃ,.......។

**កន្តន** នបុំ. ការកាត់ (ដូច **ឆេទន**) ។

**កន្តា** ឥ. ស្រី (ដូច **សុន្ទរី,ថី**) ។

**កន្ត** បុំ.ឬគុ. ប្ដី (ដូច **បិយ**) គុ. ល្អ, ជាទីគាប់ចិត្ត (ដូច **មនោរម**) ។

**កន្តារ** បុំ. [កំ + តរ + ណ] ផ្លូវជាទីញុំាងទឹកឲ្យឆ្លង (ផ្លូវឆ្ងាយ, ផ្លូវលំបាក ដូច **ទុគ្គ**, **ទុគ្គម**, ផ្លូវឆ្ងាយដាច់ស្រយាល, ផ្លូវដែលត្រូវយកទឹកទៅជាមួយផង), ព្រៃ (ដូច **វន**), វិ. **កំ តារេន្តិ ឯត្ថាតិ**>**កន្តារោ** ។ -**អទ្ធាន** នបុំ. ផ្លូវឆ្ងាយជាទីញុំាងទឹកឲ្យឆ្លង, ផ្លូវឆ្ងាយដាច់ស្រយាល, ផ្លូវឆ្ងាយគឺកន្តារៈ ។

**កន្តិ** គុ. ល្អ (ដូច **សោភ**) ឥ. សេចក្តីប្រាថ្នា (ដូច **ឥច្ឆា**), អំណាច (ដូច **វស**), រស្មី (ដូច **ជុតិ**) ។

**កន្តិត** គុ. កាត់, ដក, ច្រូត (ដូច **សញ្ឆិន្ន**) ។

**កន្តិត្វា** អ. [កន្ត+ឥ-អា.+ត្វា] កាត់ហើយ, លះហើយ, មុតហើយ, រវៃហើយ ។

**កន្តិមត្ត** បុំ. គ្រាន់តែសេចក្តីត្រេកអរ, សេចក្តីប្រាថ្នា, សព្ទនេះជាអត្ថនៃ **វិក្កម** សព្ទ ។

**កន្ទតំ** គុ. [កន្ទន្ត + នំ-វិ., ផ្លាស់ន្ត + នំ >តំ] កំពុងយំ, កំពុងទ្រហោយំ, កំពុងកន្ទក់កន្ទេញ។

**កន្ទថ** កិ. [កទ + ឬ កន្ទ + អ + ថ-វ.] រមែងយំ, ទ្រហោយំ, កន្ទក់កន្ទេញ ។

**កន្ទន្ត** គុ. [កទ + អន្ត] កាលកន្ទក់កន្ទេញ,......។

**កន្ទម** បុំ. ភក់ (ដូច **ចិក្ខល្ល**) ។

**កន្ទរ** បុំ.ឥ. [ក+ទរ+អ] ប្រទេសដែលទឹកហូរច្រោះ (ជ្រោះ, ជ្រោះភ្នំ, ច្រកភ្នំ ដូច **ទរី**), វិ. **កេន ឧទកេន ទរិយតិ បទាលិយតីតិ**>**កន្ទរោ**, -**រា** ។

**កន្ទសិ** កិ. [កទ + អ + សិ-វ.] កន្ទក់កន្ទេញ, រអ៊ូរទាំ...... ។

**កន្ទិត្វា** អ. [កទ + ឥ-អា.+ ត្វា] កន្ទក់កន្ទេញហើយ, រអ៊ូរទាំហើយ,...... ។

**កន្ទិត** គុ. កន្ទក់កន្ទេញ, យំ (ដូច **រោទិតំ**) ។

**កន្ទីសុ** កិ. [កទ + អ + ឱំ-អជ្ជ., ចុះនិ-អា.] កន្ទក់កន្ទេញហើយ,..... ។

**កន្ទុក** បុំ. សីដ៏ហើយដោយស្បែក, កូនឃ្លីស្បែក (ដូច **គេណ្ឌុក**) ។

**កន្ទេយ្យុំ** កិ. [កទ + អ + ឯយ្យុំ-ស., ចុះនិ-អា.] គប្បីកន្ទក់កន្ទេញ,... ។

**កន្ទ** បុំ. មើម (ដូច **ករហាដ**) ។

**កន្ធរា** ឥ. ក (ដូច **គីវា**) ។

**កន្ធិ** ធា. **សាតច្ចនិរន្តរតាយំ កន្ធេតិ កន្ធយតិ**"ជាប់ត, ស្មើ, ជានិច្ច, ជានិរន្តរ៍" ចុ. ។

**កន** ធា. **ទិត្តិកន្តីសុ កនតិ**"រុងរឿង, ល្អ, ប្រាថ្នា, ត្រូវចិត្ត, ស្រឡាញ់" ភូ. ។ **កញ្ញា** ឥ. "ស្រីក្រមុំ, នាងកញ្ញា" =**យោព្វនិត្ថី**, វិ. **កនីយតិ កាមីយតិ អភិបត្ថីយតិ បុរិសេហីតិ កញ្ញា** (កនិ+យ>កន្យ>កញ្ញា) មួយយ៉ាងទៀត **កំ =បុរិសំ, ញាបេតិ តោសេតីតិ កញ្ញា** (ក+ញបិ+ក្វិ+អា) **សូចិ.** ។ **កនកំ** នបុំ. "មាស" សព្ទជាវេវចនៈ នៃ **កនកំ** គឺ **សុវ-ណ្ណំ ហេមំ កនកំ កញ្ចនំ ជាតរូបំ ហាដកំ តបនីយំ វណ្ណំ**

**ជម្ពូនទំ សិង្គិកំ ចាមីករំ** -ស. ។

**កបណ** គុ. [កប + យុ] មនុស្សដែលគេគប្បីអាណិត(កំព្រា, មនុស្សកំព្រា, អ្នកកម្សត់, អ្នកទ័លក្រ ដូច **ទឡិទ្ទ** ឬ **ទលិទ្ទ**), វិ. **កបិតព្វោ ករុណាយិតព្វោតិ**>**កបណោ** ។ ន័យខ្លះថា ៖ មនុស្សមានដៃគួរខ្ពើម, វិ. **កុច្ឆិតោ បណោ យស្ស សោ** > **កបណោ** ។ -**ជន** បុំ. ជនកំព្រា ។ -**អទ្ធិកវណិព្វកយាចក** បុំ. ជនកំព្រា និងជនអ្នកដំណើរ និងវណិព្វកៈ និងយាចក, ជនកំព្រា និងជនអ្នកដើរទៅកាន់ផ្លូវឆ្ងាយ និងជនអ្នកពណ៌នាហើយទើបសូមនិងជនអ្នកសូម ។

**កបល្ល** នបុំ. [ក + បាល + អ] អំបែង (ដូច **កបាល**) ។ -**បាតិ** ឥ. ភាជនៈគឺអំបែង ។ -**បូវបណ្ណារ** បុំ. ញកនៃនំអំបែង, ញកជាទីចាក់ចោលនូវនំអំបែង ។ -**ខណ្ឌាទិភាវ** បុំ. ភាវៈនៃវត្ថុមានចំណែកនៃអំបែងជាដើម ។ -**ហត្ថ** គុ. មានអំបែងក្នុងដៃ, វិ. **កបាលំ ហត្ថេ យស្ស សោ** >**កបាលហត្ថោ** ។

**កបាល** បុំ. រលាក្បាល (ដូច **សិរសដ្ឋិ**), អំបែងឆ្នាំងជាដើម (ដូច **ឃដាទិសកល**) ។

**កបិ** បុំ. [កប+ឥ] សត្វតែងកម្រើកញាប់ញ័រ (ស្វា ដូច **វលីមុខ**), វិ. **កម្បតិ ចលតីតិ**> **កបិ** ។ -**កច្ឆុ** បុំ. ខ្ញែរ (ដូច **ទុផស្ស**) ។

**កបិដ្ឋ** បុំ. ដើមក្វិដ្ឋ, ខ្វិដ្ឋ (ដូច **កវិដ្ឋ**) ។

**កបិល** គុ. [កព > កប + ឥល] ពណ៌ក្រហម, គោក្រហម, គោមានសម្បុរក្រហម, អ.ន. ត្រីឈ្មោះកបិលៈ, ភិក្ខុឈ្មោះកបិលៈ, ។ -**មច្ឆ** បុំ. ត្រីឈ្មោះកបិលៈ ។ -**វត្ថុនគរ** នបុំ. ក្រុងឈ្មោះកបិលព័ស្តុ ។ -**វត្ថុប្បវេសនាទិ** គុ. (កាល) មានកាលជាទីចូលទៅកាន់ក្រុងឈ្មោះកបិលព័ស្តុជាដើម ។ -**វត្ថុបុរ** នបុំ. បុរី (ក្រុង) ឈ្មោះកបិលវត្ថុ ។ -**វត្ថុវាសិក** គុ. អ្នកនៅក្នុងក្រុងឈ្មោះកបិលព័ស្តុ, វិ. **កបិលវត្ថុម្ហិ វសតីតិ**>**កបិលវត្ថុវាសី**, **កបិលវត្ថុវាសី ឯវ**> **កបិលវត្ថុវាសិកោ** ។ -**វត្ថុសាមន្ត** គុ. ទីជិតនៃក្រុងឈ្មោះកបិលព័ស្តុ ។ សម្បុរខៀវលឿង, សម្បុរឆ្នាត់, ដំដែង (ដូច **កឡារ**) ។

**កបិលវត្ថុ** នបុំ. ឈ្មោះទីក្រុងមួយ ក្នុងដែនសក្ក ឥណ្ឌៀ ។

**កបិលា** ឥ. ដើមនាងនួន (ដូច **សីសបា**) ។

**កបិសីស** បុំ. សសរទ្វា, មេទ្វារ, ស៊ុមទ្វារ (ដូច **អគ្គឡត្ថម្ភ**) ។

**កបីតន** បុំ. ដើមក្រសាំង (ដូច **គទ្ទភណ្ឌ**) ។

**កបោណិ** បុំ. ដុំដៃ (ដូច **កប្បរ**) ។

**កបោត** បុំ. សត្វលលក, សត្វព្រាប (ដូច **បារាវត**) ។

**កបោតក** បុំ. [កប + ឧត + ក-ស.] ព្រាប, សត្វព្រាប, សត្វលលក ។ -**វណ្ណ** គុ. មានសម្បុរដូចជាសម្បុរនៃសត្វព្រាប ។

**កបោល** បុំ. ថ្ពាល់ (ដូច **គណ្ឌ**), រលោក្បាល (ដូច **កប្បរ**) ។

**កប្ប** អ.ន. តាបសឈ្មោះកប្បៈ ។

**កប្ប** បុំ. **កប្ប** សព្វប្រព្រឹត្តទៅក្នុងអត្ថគឺ **កាល** ឧ. **យេន សុទំ និច្ចកប្បំ វិហរាមិ** ដូច្នេះជាដើម, យុគ យុគមាន៤ គឺ **កតយុគ** ១ **តេតាយុគ** ១ **ទ្វាបរយុគ** ១ **កលិយុគ** ១, **លេស** (គួរ) ឧ. **អត្ថិ កប្បោ និបជ្ជិតុំ** ដូច្នេះជាដើម, **បញ្ញត្តិ** (ឈ្មោះ) ឧ. **ឥច្ចាយស្មា កប្បោ** ដូច្នេះជាដើម, **បរមាយុ** (កំណត់អាយុ) ឧ. **អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា** ដូច្នេះជាដើម, **សទិស** ឧ. **សត្ថុកប្បេន វត ភិរ ភោ សាវកេន សទ្ធឹ មន្តយមានា ន ជានិម្ហា** ដូច្នេះជាដើម, **សមណវោហារ** (ពាក្យសមគួរដល់សមណ) ឧ. **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ដូច្នេះជាដើម, **កប្បពិន្ទុ** (វិនយកម្មម្យ៉ាង) ឧ. **កប្បកតេន អកប្បកតំ សំសិព្វិតំ ហោតិ** ដូច្នេះជាដើម, **សមន្តត្ត** (ទីជុំវិញ) ឧ.**កេវលកប្បំ ជេតវនំ ឱភាសេត្វា** ដូច្នេះជាដើម, **អន្តរកប្ប** ឧ. **អាបាយិកោ នេរយិកោ កប្បដ្ឋោ សង្ឃភេទកោ កប្បំ និរយម្ហិ បច្ចតិ** ដូច្នេះជាដើម, **អសំខេយ្យកប្ប** ឧ. **អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ** ដូច្នេះជាដើម, **មហាកប្ប** ឧ. **ចត្តារិមានិ ភិក្ខវេ កប្បស្ស អសំខេយ្យានិ** ដូច្នេះជាដើម, **តក្ក**(ត្រិះរិះ) ឧ. **នេក្ខម្មសំកប្បោ អព្យាបាទសំកប្បោ** ដូច្នេះជាដើម, **វិធិ** (ចាត់ចែង) ឧ. **មោរោ វាសមកប្បយិ ចីវរេ វិកប្បំ អាបជ្ជេយ្យ** ដូច្នេះជាដើម, **អភិសទ្ទហន**(ជឿស៊ប់, ជឿខ្លាំង, ជឿមាំ) ឧ, **សទ្ធា សទ្ទហនា ឱកប្បនា អភិប្បសាទោ ឱកប្បនីយមេតំ ភោតោ គោតមស្ស យថាតំ អរហតោ សម្មាសម្ពុទ្ធស្ស** ដូច្នេះជាដើម, **ឆេទន**(ការកាត់, កោរ) ឧ, **អលំកតោ កប្បិតកេសមស្សុ** ដូច្នេះជាដើម, **វិកប្ប**(ខ្លះ, បានខ្លះដែរ, ក៏បានដែរ) ឧ, **កប្បតិ ទ្វង្គុលកប្បោ** ដូច្នេះជាដើម, **វិនិយោគ** (មិនប្រាសចេញ, សម្រេច) ឧ, **ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ** ដូច្នេះជាដើម, **តណ្ហាទិដ្ឋិ** ឧ, **ន កប្បយន្តិ ន បុរក្ខរោន្តិ ធម្មាបិ តេ ន សម្បច្ឆិតា សេ ន ព្រាហ្មណោ សីលវតេន នេយ្យោ បារង្គតោ ន ច បច្ចេតិ តាទី** ដូច្នេះជាដើម, ឈ្មោះ**វេទង្គ** ឬ **វេទាង្គ** សាស្ត្រម្យ៉ាង គឺអង្គនៃវេទម្យ៉ាង, របស់ដែលខ្វះបន្តិចបន្តួច (ដូច **កិញ្ចិទូនក**) ។

**កប្បក** បុំ. [កប្ប + ណ្វុ] អ្នកកោរកាត់នូវសក់, ជាងកាត់សក់, ខ្មាន់ព្រះកេស (ដូច **នហាបិត**), វិ. **កប្បតិ កេសេ ឆិន្ទតីតិ>កប្បកោ** ។ -**អន្តេវាសិក** បុំ. អន្តេវាសិក (សិស្ស) ឈ្មោះ **កប្បកៈ** ។ -**វេស** បុំ. ភេទនៃខ្មាន់ប្រកេស ។

**កប្បកោដិ** ឥ. [កប្ប+កោដិ] កោដិនៃកប្ប ។ -**សហស្ស** នបុំ. ពាន់នៃកោដិនៃកប្ប។

**កប្បក្ខយ** បុំ. ការអស់ទៅ ឬវិនាសទៅនៃកប្ប (ដូច **សំវដ្ដ**) ។

**កប្បជ** បុំ. សំពត់ប្រឡាក់ (ដូច **នន្តក**) ។

**កប្បដ្ឋិតិក** គុ. [កប្ប + ឋិតិ + ណិក ឬក-ស. ] មានកិ.តាំងនៅអស់កប្ប, ប្រកប ក្នុងកិ.តាំងនៅអស់កប្ប ។

**កប្បតិ** កិ. [កប ឬកប្ប + អ + តិ-វ.] សម្រេច, គួរ, ចិញ្ចឹម ។

**កប្បន** នបុំ. ការកាត់ (ដូច **កន្តន**), ការត្រិះរិះ (ដូច **វិកប្ប**), ការរៀបចំនូវពាហនៈមានដំរីជាដើម (ដូច **សជ្ជន**), ការតែង, ការប្រដាប់, សព្ទនេះជាអត្ថនៃ **សជ្ជន** សព្ទ បុំ. គ្រឿងតែងដំរី ។

**កប្បពិន្ទុ** នបុំ. ពិន្ទុចីវរ(យកវត្ថុមានពណ៌ខ្មៅជាដើមទៅវង់ចីវរជាគ្រឿងសម្គាល់) ។

**កប្បរជន្នុកាទិ** គុ. [កប្បរ+ជន្នុក+អាទិ] (អវយវៈ) មានដុំដៃនិងក្បាលជង្គង់ជាដើម ។

**កប្បរុក្ខ** បុំ. [កប្ប + រុក្ខ] ដើមកល្បព្រឹក្ស, ឈើញុំាងសេចក្ដីប្រាថ្នាឲ្យសម្រេច, ឈើដ៏តាំងនៅអស់កប្ប (ដូច **សន្តាន**) ។

**កប្បរ** បុំ. ដុំដៃ (ដូច **កបោណិ**), រលាក្បាល (ដូច **កបោល** ឬ**កបាល**) ។

**កប្បវិនាសក** គុ. [កប្ប + វិ + នស + ណ្វុ] ដែលញុំាងកប្បឲ្យវិនាស (ភ្លើងប្រល័យកល្ប), វិ. **កប្បំ វិនាសេតីតិ** >**កប្បវិនាសកោ** ។

**កប្បសត** នបុំ. [កប្ប+សត] រយនៃកប្ប ។ -**សហស្ស** សែននៃកប្ប ។ -**បរិយោ-សាន** នបុំ. កាលជាទីបំផុតនៃសែននៃកប្ប ។ -**សហស្សាធិក** គុ. [កប្បសតសហស្ស + អធិក] គុ. ដ៏ក្រៃលែងដោយសែននៃកប្ប ។ -**បូរិតបារមី** គុ. មានបារមីបំពេញហើយអស់សែននៃកប្ប ។ -**មត្ថក** នបុំ. ទីបំផុតនៃសែននៃកប្ប ។

**កប្បាសដ្ឋិកភាវ** បុំ. [កប្បាស + អដ្ឋិក + ភាវ] ភាវៈនៃ.....ជាគ្រាប់នៃកប្បាស ។

**កប្បាសិក** គុ. ដ៏ដេរដាសដោយដើមកប្បាស, គឺបុគ្គលកំណត់ហើយដោយដើមកប្បាស ។ -**វនសណ្ឌ** [កប្បាសិក+វន+សណ្ឌ] បុំ. ដងនៃព្រៃដ៏ដេរដាសដោយដើមកប្បាស, ដងនៃព្រៃគឺបុគ្គលកំណត់ហើយដោយដើមកប្បាស ។

**កប្បាសិក** គុ. (សំពត់)កើតអំពីកប្បាស ។

**កប្បាសី** ឥ. ដើមពទ្រា (ពុទ្រា ) (ដូច **ពទរា**) ។

**កប្បិត** គុ. ដែលគេតែងគ្រឿងប្រដាប់រួចហើយ (ដូច **សជ្ជិត**) ។

**កប្បិយ** គុ. [កប្ប + ណ្យ + ឥ-អា] វត្ថុដែលបុគ្គលគប្បីសម្រេច, ជារបស់គួរ, ដ៏សមគួរ ។ -**ការកសាមណេរសទិស** គុ. ប្រាកដស្មើដោយសាមណេរអ្នកធ្វើនូវវត្ថុឲ្យជារបស់គួរ, ឬអ្នកធ្វើនូវកប្បិយៈ ។ -**ការក** បុំ. នបុំ. អ្នកធ្វើនូវវត្ថុឲ្យជារបស់គួរ, អ្នកធ្វើនូវកប្បិយៈ, វិ. **កប្បិយំ ករោតីតិ**>**កប្បិយការកោ** ។ -**កណ្ឌ** នបុំ.

ភណ្ឌៈដ៏គួរ, ភណ្ឌៈជាកប្បិយៈ ។ -**ភូមិ** ឥ. ផែនដីជាកប្បិយ, ផែនដីដ៏សមគួរ, ទីដ៏គួរ។ -**មំស** នបុំ. សាច់ជាកប្បិយៈ, សាច់ដ៏គួរ, ។

**កប្បុរ** នបុំ. កប្បូរ (ដូច **ឃនសារ**) ។

**កប្បេតិ** កិ. [កប្ប + អ + តិ-វ.] សម្រេច, គួរ, ចិញ្ចឹម,....។

**កប្បេតុ** កិ. [កប្ប + អ + តុ-ប.] ចូរកាប់, ចូរក្របែល,... ។

**កប្បេន្ត** គុ. [កប្ប + អ + អន្ត] កាលសម្រេច, កាលចិញ្ចឹម, កាលកាប់,... ។

**កប្បេយ្យំ** កិ. [កប្ប + អ + ឯយ្យំ-ស.] គប្បីសម្រេច, -កាប់, -កាត់, -ក្របែល ។

**កប្បេសិ** កិ. [កប្ប+អ+ឦ-អជ្ជ., ចុះស-អា.] សម្រេចហើយ, ចិញ្ចឹមហើយ, ... ។

**កប្ប** ធា. ១-**វិតក្កវិធិច្ឆេទនេសុ កប្បេតិ កប្បយតិ សង្កប្បេតិ កប្បេន្តោ កប្បិតោ កប្បោ**"នឹកគិត, ត្រិះរិះ, ធ្វើ, កំណត់, កោរកាត់" ចុ. ។ **កប្ប**ធាតុនេះមានឧបសគ្គនាំមុខខ្លះ មិនមានខ្លះ ប្រែបានច្រើនយ៉ាង ៖១/ ត្រិះរិះ =**វិតក្កោ** អា. **នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ** ។ ២/ ធ្វើឲ្យក្រៃលែង, ទុកដាក់ = **អធិកវិធានំ** អា. **ចីវរេបិ វិកប្បំ អាបជ្ជេយ្យ** ។ ៣/ ប្រៀប, ដូច, ស្មើ, ប្រាកដស្មើ =**បដិភាគោ=សទិសោ** អា. **សត្ថុកប្បេន វត ភោ សាវកេន សទ្ធឹ មន្តយមានា ន ជានិម្ហា** ។ ៤/ ឈ្មោះ, នាមដែលតែងតាំង = **បញ្ញត្តិ** អា. **ឥច្ចាយស្មា កប្បោ** ។ ៥/ កាល, វេលា, សម័យ =**កាលោ** អា. **យេន សុទំ និច្ចកប្បំ វិហរាមិ** ។ ៦/ អាយុវែង, អាយុយឺនយូរ របស់មនុស្សនោះ =″**បរមាយុ**" អា. **អាកង្ខមានោ អានន្ទ តថាគតោ កប្បំ តិដ្ឋេយ្យ កប្បាវសេសំ វា** ។ ៧/ ជុំវិញ = **សមន្តភាវោ** អា. **កេវលកប្បំ វេឡុវនំ ឱភាសេត្វា** ។ ៨/ ពោល, ប្រាប់, និយាយ =**វោហារោ** អា. **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ។ ៩/ ជឿ, ចុះចិត្តស៊ប់ =**អភិសទ្ទហនំ=សទ្ធា**, អា. **សទ្ធា សទ្ទហនា ឱកប្បនា អភិប្បសាទោ** ។ ១០/ កាត់, កោរ =**ឆេទនំ** អា. **អលង្កតោ កប្បិតកេសមស្សុ** ។ ១១/ បង្កើនផល, សម្រេចផល, ផ្តល់ផល = **វិនិយោគោ** អា. **ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតុ** ។ ១២/ **វិនយកម្ម**, ធ្វើ ឬ ប្រព្រឹត្តតាមច្បាប់បញ្ញត្ត =**វិនយកិរិយា** អា. **កប្បកតេន អកប្បកតំ សំសិព្វិតំ ហោតិ** ។ ១៣/ លេស, ហេតុបន្តិចបន្តួច =**លេសោ**, អា. **អត្ថិ កប្បោ និបជ្ជិតុំ ហន្ទាហំ និបជ្ជាមិ** ។ ១៤/ កប្បជាចន្លោះ, **អន្តរកប្ប=អន្តរកប្បោ** អា. **អាបាយិកោ នេរយិកោ កប្បដ្ឋោ សង្ឃភេទកោ កប្បំ និរយម្ហិ តិដ្ឋតិ** ។ ១៥/ តណ្ហា, ទិដ្ឋិ, កិលេស, សេចក្តីអាក្រក់ = **តណ្ហា**, អា. **តណ្ហាកប្បោ ទិដ្ឋិកប្បោ** ។ ១៦/ **អសំខេយ្យកប្ប**"កប្បដែលរាប់មិន

អស់" អា. **អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ** ។ ១៧/ មហាកប្ប, កប្បធំ =**មហាកប្បោ** អា. **ចត្តារិមានិ ភិក្ខវេ កប្បស្ស អសំខេយ្យានិ** ។ ១៨/ កំណត់, ប្រមាណ, វាស់, សម្គាល់ =**វិកប្បោ** អា. **កប្បតិ ទ្វង្គុលកប្បោ**-ស. ។ **សង្កប្បោ** បុំ. **សង្កប្បនំ** នបុំ. "សេចក្ដីត្រិះរិះ, នឹក, គិត, ពិចារណា" ។ **វិកប្បោ** បុំ. "ការកំណត់, ប្រមាណ, វាស់, ផ្ញើទុក, តម្កល់ទុក" ។ **កប្បក** បុំ. "ជាងកាត់សក់" (កប្ប+ណ្វុ)។

២-**វិធិម្ហិ កិរិយាយញ្ច កប្បេតិ កប្បយតិ កប្បោ កប្បេន្តោ**" សម្រេច, ចាត់ចែង, រៀបចំ, ធ្វើ" ចុ. ។ អា. **សីហសេយ្យំ កប្បេតិ**" សម្រេចនូវ **សីហសេយ្យា**" (=ផ្ទំ ដូចសត្វសីហ), **មោរោ វាសមកប្បយិ**"ក្ងោក បានរៀបចំទីនៅ" -ស. ។

៣- **គតិយំ កប្បេតិ កប្បយតិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ចុ. ។

**កបិ** ធា. ១-**ករុណាយំ កបតិ**"ករុណា, ជួយទុក្ខ, អាណិត, អាសូរ" ភូ. ។ **កបតិ**= **ករុណាយតិ**-ស. ។ **កបណ** បុំ. "មនុស្សដែលគួរឲ្យអាសូរ" =**ករុណាយិតព្វោ** -ស. ។ **កាបញ្ញំ** ភ.ន. =**កបនតាវោ**" សេចក្ដីអាណិតអាសូរ" -ស. ។

២- **អវកម្បនេ កបេតិ កបយតិ**"អនុគ្រោះ, អាណិតអាសូរ, ករុណា" ចុ. ។

៣- **ហឹសាគន្ធោលគន្ធេសុ កប្បតិ**"បៀតបៀន, ក្លិនក្រអូបដូចក្រវាញ" ទិ. **កប្បូរ** បុំ. "កាប៊ូ" ។

៤- **សាមត្ថិយេ កប្បតិ** "អាច, អាចមាន, គួរ, សមគួរ" ទិ. ភូ. ។ អា. **ឥទំ អម្ហាកំ កប្បតិ**"នេះសមគួរដល់យើង ទ.″, **កប្បតិ ទ្វង្គុលកប្បោ**" ប្រមាណព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ក៏គួរ" -ស. ។

**កពន្ធ** បុំ.,នបុំ [កុ + អន្ធ] សាកសព, សាកអសុភកំបុតក្បាល (ដូច**កលេវរ**) ។

**កពរ** គុ. [កុ + អល, អល>អរ + អ] ពពាល ។ -**គាវីសទិស** គុ. ប្រាកដស្មើដោយមេគោពពាល, ដូចជាមេគោពពាល ។ -**គោរូប** នបុំ. រូបនៃគោពពាល ។ -**ច្ឆាយ** គុ. មានស្រមោលពពាល, មានម្លប់ប៉ើងរើង, មានស្រមោលរង្វើល ។

**កពរមណី** ឥ. កែវពព្រុះ, កែវភ្នែកឆ្មា (ដូច **មសារគល្ល**) ។

**កពល** បុំ. [កុ + អល + អ] ពំនូត, ពំនូតបាយ (ដូច **អាលោប**), (វិ. **កេន តោយេន ពលមស្សាតិ**>**កពលោ**) ។ ប្រើជា **កពឡោ** ក៏បាន ។

**កព្វ** ធា. **គតិយំ កព្វតិ**"ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។

**កមណ្ឌលុ** ឥ. **កុណ្ឌីទឹក** (កុន្ទីទឹក), ភាជនៈម្យ៉ាងសម្រាប់ដាក់ទឹក (ដូច **កុណ្ឌិកា**) ។

**កមណ្ឌលូទក** នបុំ. [កមណ្ឌលុ+ឧទក] ទឹកក្នុងកុណ្ឌី ។ (**កមណ្ឌលុ**<កមណ្ឌ+លា+ឧ) វត្ថុកាន់យកនូវភារៈនៃទឹកថ្លា (កុណ្ឌី), វិ. **កស្ស ជលស្ស មណ្ឌោ បសន្នភាវោ**> **កមណ្ឌោ**, **តំ លាតីតិ**>**កមណ្ឌលុ** ។

**កមលាសន** បុំ. ព្រះព្រហ្ម (ដូច **លោកេស**) ។

**កមល** នបុំ. ផ្កាឈូក (ដូច **បទុម**) ។

**កមិត** គុ. អ្នកប្រាថ្នា, អ្នកស្រឡាញ់ (ដូច **កាមុក**) ។

**កមុក** បុំ. ដើមស្លា (ដូច **បូគ**) ។

**កម** បុំ. លំដាប់, បែប, ក្បួន (ដូច **អនុបុព្វី**) ។

**កម្បតិ** កិ. [កម្ប + អ + តិ-វ.] កក្រើក, ញាប់ញ័រ ។

**កម្បនាការប្បត្ត** គុ. [កម្បន + អាការ + បត្ត] ដល់ហើយនូវអាការគឺកិ.កម្រើក, -កក្រើក, -ញាប់ញ័រ ។

**កម្បន** បុំ. ការកក្រើក, ញាប់ញ័រ (ដូច **ចលន**) ។

**កម្បមាន** គុ. [កម្ប + មាន] កាលញាប់ញ័រ, កំពុងញាប់ញ័រ ។ -**សរីរ** គុ. មានសរីរៈកំពុងញាប់ញ័រ ។

**កម្បិ** កិ. [កម្ប + អ + ឦ-អជ្ជ.] កក្រើកហើយ, ញាប់ញ័រហើយ, ។

**កម្បិត** គុ. កក្រើក, ញាប់ញ័រ (ដូច **ធុត**) ។

**កម្បេតុំ** អ. [កម្ប + ណេ + តុំ] ដើម្បីញាប់ញ័រ...ឲ្យកក្រើក,... ។

**កម្បេត្វា** អ. [កម្ប + ណេ + ត្វា] ញុំាង...ឲ្យកក្រើកហើយ ។

**កម្ប** ធា. **កម្បនចលនេសុ កម្បតិ** "ញាប់ញ័រ, រន្ធត់, កម្រើករព្វយ" ភូ. ។ **អនុកម្បោ** បុំ. **អវកម្បនំ** នបុំ. "សេចក្ដីអាណិត, ការអនុគ្រោះ" ។ ការិត. **កម្បេតិ កម្បយតិ** អា. **ឥទម្បិ ទុតិយំ សល្លំ កម្បេតិ ហទយំ មម** "កូនសរទីពីរនេះ ញុំាងបេះដូងខ្ញុំឲ្យញាប់ញ័រ"-ស. ។

**កម្ពល** បុំ. [កម + អល, ចុះព-អា.] សំពត់ដែលជនគប្បីប្រាថ្នា (សំពត់កម្ពល), វិ. **កមនីយោតិ**>**កម្ពលោ** ។ -**កូដាគារ** នបុំ. កូដាគារគឺបុគ្គលបិទបាំងដោយសំពត់កម្ពល, ផ្ទះគឺបុគ្គលសង្គ្រោះដោយកំពូលដែលបុគ្គលពាសដោយសំពត់កម្ពល, ផ្ទះប្រកបសង្គ្រោះដោយកំពូលគឺបុគ្គលពាលដោយសំពត់កម្ពល ។ - **អត្ថិក** គុ. អ្នកមានសេចក្ដីត្រូវការដោយសំពត់កម្ពល, វិ. **កម្ពលេន អត្ថោ**> **កម្ពលត្ថោ**, **សោ យេសមត្ថីតិ**>**កម្ពលត្ថិកា** ។ -**ទាយកតិស្ស** អ.ន. សាមណេរឈ្មោះកម្ពលទាយកតិស្សៈ ឬសាមណេរឈ្មោះតិស្សៈអ្នកឲ្យនូវសំពត់កម្ពល ។ -**បាទុកា** ឥ. ស្បែកជើងជាវិការៈនៃសំពត់កម្ពល ។ -**សហស្សភាវ** បុំ. ភារៈនៃសំពត់កម្ពលមានពាន់ជាប្រមាណ, ភារៈនៃពាន់នៃសំពត់កម្ពល ។

**កម្ពល** បុំ. នបុំ. សំពត់ធ្វើដោយរោមសត្វ, ឈ្មោះនាគដែលនៅជើងភ្នំមេរុ ។

**កម្ពុ** បុំ. នបុំ. មាស (ដូច **ហរី**, **សុវណ្ណ**), ស័ង្ខ, ខ្យងស័ង្ខ (ដូច **សំខ**), កងដៃ (ដូច **វលយ**) ។

**កម្ពុគីវា** ឥ. កល្អប្រហែលស្គរសម្ភោរដំហើយដោយមាស ឬក៏មានផ្នត់បីជាន់នេះជាលក្ខណៈនៃមហាបុរស ។

**កម្ពោជ** បុំ. ឈ្មោះដែនឬជនបទមួយ ក្នុងប្រទេសឥណ្ឌៀ ។

**កម្ម** នបុំ. [ករ + រម្ម] កិច្ចដែលជនធ្វើ ឬ កិច្ចដែលជនត្រូវធ្វើ (កម្ម, អំពើដូច **កិរិយ**), វិ. **ករិយតេតិ>កម្មំ**, **ភាតព្វន្តិ វា>កម្មំ** ។ **-ករណ** នបុំ. កម្មករណ៍, កិ.ធ្វើនូវកម្ម, ទោសជាតជាគ្រឿងធ្វើនូវកម្ម ។ **-ករ** បុំ. កម្មករ, ជនអ្នកធ្វើនូវការងារ, វិ. **កម្មំ ករោតីតិ>កម្មករោ** ។ **-កិលិដ្ឋ** គុ. កម្មដ៏សៅហ្មង, សេចក្តីសៅហ្មងនៃកម្ម, សេចក្តីសៅហ្មងព្រោះកម្ម ។ **-កុព្វ** គុ. អ្នកធ្វើនូវកម្ម ។ **-តប្បន** នបុំ. សេចក្តី ក្តៅក្រហាយព្រោះកម្ម ។ **-ប្បច្ចវេក្ខណាវស** បុំ. អំណាចនៃកិ.ឃើញចុះចំពោះនូវកម្ម, អំណាចនៃកិ.ពិចារណានូវកម្ម ។ **-បថ** បុំ. កម្មបថ, កម្មជាគន្លង, គន្លងគឺកម្ម, ផ្លូវនៃកម្ម ។ **-ផលសម្ពន្ធ** គុ. ដែលជាប់ព្រមដោយកម្មនិងផលនៃកម្ម, ដែលជាប់ព្រមដោយផលនៃកម្ម, ដែលទាក់ទងដោយផលនៃកម្ម, ។ **-ពល** នបុំ. កម្លាំងនៃកម្ម ។ **-មោទន** នបុំ. សេចក្តីត្រេកអរព្រោះកម្ម ។ **-វិបាក** បុំ. វិបាកនៃកម្ម, ផលនៃកម្ម ។ **-វិសុទ្ធិ** ឥ. កម្មជាគ្រឿងស្អាតដោយវិសេស, សេចក្តីស្អាតដោយវិសេសនៃកម្ម ឬ ព្រោះកម្ម, សេចក្តីបរិសុទ្ធនៃកម្ម ។ **-សន្និចយ** បុំ. ការសន្សំព្រមនូវកម្ម, កិ.សន្សំព្រមនូវកម្ម (**សន្និចយ**<សំ+និ+ចិ+អ) ។ **-សរិក្ខក** គុ. ប្រាកដស្មើដោយកម្ម, ប្រហែលដោយកម្ម (**សរិក្ខក**<សមាន >ស, ទិស >រិក្ខ+ ណ្ហ), វិ. **សមានមិវ នំ បស្សតីតិ>សរិក្ខកោ**, ម្យ៉ាងទៀត គឺបុគ្គលគប្បីឃើញស្មើ, វិ. **សមានំ ទដ្ឋព្វោតិ> សរិក្ខកោ** ។ **-សោចន** នបុំ. សេចក្តីសោកព្រោះកម្ម, សេចក្តីសោកស្តាយព្រោះកម្ម ។

**កម្មករ** បុំ. អ្នកធ្វើការស៊ីឈ្នួល, កូនឈ្នួល (ដូច **ភតក**) ។

**កម្មជវាត** បុំ. [កម្មជ + វាត] ខ្យល់ដែលកើតអំពីកម្ម (ខ្យល់កម្មជវាត), វិ. **កម្មុនា ជាតា វាតា>កម្មជវាតា** ។

**កម្មដ្ឋាន** នបុំ. [កម្ម+ឋាន] កម្មដ្ឋាន, អារម្មណ៍ជាទីតាំងនៃកម្ម, វិ. **តិដ្ឋតិ ឯត្ថាតិ> ឋានំ**, **កម្មស្ស ឋានំ>កម្មដ្ឋានំ** ។ - **ភាវនា** ឥ. ភាវនាដែលប្រព្រឹត្តទៅក្នុងកម្មដ្ឋាន, វិ. **កម្មដ្ឋានេ បវត្តា ភាវនា>កម្មដ្ឋានភាវនា** ។ គុណជាតិជាគ្រឿងញ៉ាំងកម្មដ្ឋានឲ្យចម្រើន, វិ. **កម្មដ្ឋានំ ភាវេតិ ឯតាយាតិ>កម្មដ្ឋានភាវនា** ។ កិ.ចម្រើននូវកម្មដ្ឋាន, កិ.ញ៉ាំងកម្មដ្ឋានឲ្យកើត, វិ. **កម្មដ្ឋានស្ស ភាវនា> កម្មដ្ឋានភាវនា** ។ - **មនសិការ** បុំ. ការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន ។ **-សីស**

នបុំ. ធម៌ជាប្រធាននៃកម្មដ្ឋាន ។ -**អភិមុខ** គុ. មានមុខឆ្ពោះទៅកាន់កម្មដ្ឋាន, មានមុខបែរទៅរកកម្មដ្ឋាន ។

**កម្មនីយ** គុ. [កម្ម + អនីយ] គួរនូវកម្ម, គួរដល់កម្ម, គួរដល់ការងារ ។

**កម្មន្ត** បុំ. [កម្ម + អន្ត-ស.] ការងារ, វិ.**កម្មំ ឯវ>កម្មន្តោ**។ -**កិរិយា** ឥ. កិ.ធ្វើនូវការងារ ។

**កម្មាទិ** គុ. (វដ្ត)មានកម្មវដ្តជាដើម, សព្ទនេះជាអត្ថនៃ **វដ្ដ** សព្ទ ។

**កម្មាធិដ្ឋាយិក** គុ. [កម្ម+អធិដ្ឋាយិក] អ្នកតាំងទុកនូវកម្ម, អ្នកតាំងទុកនូវការងារ (អ្នកចាត់ការ), វិ. **កម្មំ អធិដ្ឋាតីតិ>កម្មាធិដ្ឋាយី**, **កម្មាធិដ្ឋាយី ឯវ>កម្មាធិដ្ឋាយិកោ** ។

**កម្មានុរូប** គុ. [កម្ម + អនុរូប] ដ៏សមគួរដល់កម្ម, ដ៏សមគួរដល់ការងារ ។

**កម្មារ** បុំ. [កំ + មរ + ណ] ជនអ្នកញ៉ាំងទឹកឲ្យស្លាប់ (ជាង, ជាងមាស ឬ ជាងប្រាក់, ជាងដំ, ជាងលោហៈ ដូច **លោហការក**) វិ. **កំ មារេតីតិ>កម្មារោ** ។ -**កុល** នបុំ. ត្រកូលនៃជាងមាស ឬ ត្រកូលនៃជាងប្រាក់។

**កម្មារភណ្ឌភេទ** បុំ. ប្រភេទនៃភណ្ឌរបស់ជាងដំ, សព្ទនេះជាអត្ថនៃ **មុដ្ឋិ** សព្ទ ។

**កម្មាសបូវ** បុំ. [កម្មាស+បូវ] នំគឺបុគ្គលធ្វើហើយដោយសណ្តែក, នំសណ្តែក, នំកម្មាស, (ជាឈ្មោះនំមួយប្រភេទដែលគេប្រើក្នុងប្រទេសឥណ្ឌា) ។

**កម្មាស** បុំ. សម្បុរពពាល, ពព្រុះ, សម្បុរដូចកនៃសត្វតាវៅ (ដូច **សពល**) ។

**កមិ** ធា. ១-**បទវិក្ខេបេ កមតិ ចង្កមតិ**"ឈានទៅ, ដើរទៅ, បោះជំហានទៅ, ចូលទៅ" ភូ.។ ការិត, **និក្ខាមេតិ** ។ អា. **នាស្ស កាយេ អគ្គិ វា វិសំ វា សត្ថំ វា កមតិ**"ភ្លើងក្តី ថ្នាំពិសពុលក្តី សស្ត្រាវុធក្តី មិនចូលទៅក្នុងរូបកាយនៃបុគ្គលមានមេត្តាចិត្តនោះទេ" -ស. ។ **អតិក្កមតិ**"កន្លង, ប្រព្រឹត្តកន្លង, ល្មើស" ន. **អតិក្កមោ**(អតិ+កមិ)។ **អភិក្កមតិ**"ឈានទៅមុខ, កន្លងទៅមុខ, រុកទៅមុខ, ចម្រើនឡើង (ជំងឺ)" ន. **អភិក្កមោ**(អភិ+កមិ) ។ **បដិក្កមតិ**"ត្រឡប់ក្រោយ, ថយក្រោយ, ស្រាកស្រាន្ត (ជំងឺ)" ន. **បដិក្កមោ**(បដិ+កមិ) ។ **បក្កមតិ**" ជៀសចេញ, ថយចេញ, ងាកចេញ, ដើរចេញទៅ" កិគុ. **បក្កន្តោ** (ប+កមិ+ត) **បក្កមន្តោ** (ប+កមិ+អន្ត) ។ **បរក្កមតិ** "ប្រឹងប្រែង, ខិតខំ, ព្យាយាម" ន. **បរក្កមោ** (បរ+កមិ)។ **វិក្កមតិ**"ឈានទៅយ៉ាងសង្ហា, ដើរទៅយ៉ាងអង់អាច" ន. **វិក្កមោ** (វិ+កមិ) ។ **អភិនិក្ខមតិ** ឬ **អភិនិក្ខមតិ**"ចេញទៅក្រៅលែង, ចេញចាកកាម, ចេញបួស" ន. **អភិនិក្ខមោ អភិនិក្ខមនំ**(អភិ+និ+កមិ) ។ **សង្កមតិ**"ទៅព្រម, ទៅដោយប្រពៃ,..." ន. **សង្កន្តិ សង្កមោ**(សំ+កម) ។ **ឧបសង្កមតិ**"ចូលទៅ, ចូលទៅរក, ចូលទៅគាល់, ចូលទៅជួប" ន. **ឧបសង្កមនំ**(ឧប+សំ+កមិ) ។

២-**ឥច្ឆាកន្តីសុ កាមេតិ កាមយតិ**"ប្រាថ្នា, ចង់បាន, ស្រឡាញ់" ចុ. ។ រូបដទៃ **កន្តិ និកន្តិ កាមនា កាមយមានោ កាមេន្តោ** ។ **កាមោ** បុំ. មានពីរយ៉ាងគឺ **កិលេសកាមោ** បានដល់ តណ្ហា រាគៈ ជាដើមមួយ, **វត្ថុកាមោ** បានដល់ រូបសំឡេង ក្លិន រស សម្ផស្ស មួយ ។ **អភិក្កន្តំ** គុ. ប្រែបានច្រើន ៖

១/ កន្លងហួសទៅ, អស់ទៅ =**ខយោ** ឧ. **អភិក្កន្តា ភន្តេ រត្តិ** "រាត្រីកន្លងផុតហើយ ព្រះអង្គ (ភ្លឺស្វាង)" ។

២/ ល្អ, ស្អាត, ឆើតឆាយ = **សុន្ទរោ** ឧ. **អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច**"បុគ្គលនេះល្អឆើតឆាយ ទាំងប្រណីតជាងបុគ្គលទាំង ៤ នាក់នេះ" ។

៣/ ល្អ, ផូរផង់ =**អភិរូបោ** ឧ. **អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា**"មានពណ៌ល្អផូរផង់ ញុំាង ទិសទ. ទាំងអស់ឲ្យភ្លឺច្រាល " (ឱ+ភាស+ ណយ+អន្ត+ សិ) ។

៤/ ត្រេកអរខ្លាំង ត្រេកអរក្រៃពេក, ពីរោះ =**អព្ភានុមោទនា** ឧ. **អភិក្កន្តំ ភន្តេ**"ព្រះអង្គដ៏ចម្រើន សេចក្ដីត្រេកអរក្រៃពេក, ពីរោះពេក" -ស. ។ **កន្តា** ឥ. "ស្រី, នាង" ដែលប្រុសប្រាថ្នា ឬ ស្រឡាញ់ (កមិ+ត+អា) ។

**កយវិក្កយិក** បុំ. អ្នកជំនួញ (ដូច **សត្ថវាហ**) ។

**កយិក** នុំ. អ្នកទិញ (ដូច **កាយិក**) ។

**កយិរតិ** កិ. [ករ + យិរ + តិ-វ.] ធ្វើ ។

**កយិរមាន** គុ. [ករ + យិរ + មាន] កាលធ្វើ, កំពុងធ្វើ ។

**កយិរា** កិ. [ករ + យិរ + ឯយ្យ-ស.] គប្បីធ្វើ ។

**កយិរាថ** កិ. [ករ + យិរ + ឯយ្យាថ-ស.] គប្បីធ្វើ ។

**ករ** បុំ. គ្រឿងបូជា, អាករ (ដូច **ពលិ**), ដៃ (ដូច **ហត្ថ**), រស្មី (ដូច **អំសុ**) ។

**ករកា** ឥ. ព្រិល, ភ្លៀងធ្លាក់ទឹកកកចុះមក ទឹកកកនោះហៅថាព្រិល (ដូច **ឃនោបល**, **មេឃបាសាណ**),ធម្មក្រក, កុណ្ឌីទឹក (ដូច **កុណ្ឌិកា**) ។

**ករក** បុំ. ដើមទទឹម (ដូច **ទាលិម**) ។

**ករគ្គ** នបុំ. ចុងប្រមោយដំរី (ដូច **ចោក្ខុរ**) ។

**ករជ** បុំ. [ក+រជ] ធូលីប្រព្រឹត្តទៅក្នុងសរីរៈ ,ក្រចក (ដូច **នខ**), វិ. **កេ សរីរេ បវត្តោ រជោ>ករជោ** ។-**កាយ** បុំ. [ករជ + កាយ] ករជកាយ, កាយដែលកើតអំពីធូលីប្រព្រឹត្តទៅក្នុងសរីរៈ, វិ. **ករជេន សម្ភូតោ កាយោ>ករជកាយោ** ។ យ.វិ.។

**ករញ្ជ** បុំ. ដើមទន្លា (ដូច **នត្តមាល**) ។

**ករណ** នបុំ. [ករ + យុ] កិ.ធ្វើ( ដូច **ក្រិយា**), វិ. **ករិយតេតិ**>**ករណំ** ។ ជាទីធ្វើ, វិ. **ករោតិ ឯតស្មិន្តិ**>**ករណំ**។ ជាគ្រឿងធ្វើ, ជាហេតុធ្វើ, វិ. **ករោតិ ឯតានាតិ**>**ករណំ** ។ -**ក្ខណ** បុំ. ខណៈនៃកិ.ធ្វើ, ខណៈជាទីធ្វើ ។ -**សម្បត្តិជនិតសុខវិនិគ្គតមធុរោឡារវចនលាវណ្ណយុត្ត** គុ. អ្នកប្រកបដោយសេចក្ដីក្បោះក្បាយនៃពាក្យដ៏ពីរោះក្រៃលែង ដែលចេញទៅហើយដោយស្រួលជាពាក្យគឺករណសម្បត្តិឲ្យកើតហើយ, អ្នកប្រកបហើយដោយពាក្យដ៏ក្បោះក្បាយពីរោះក្រៃលែង ដែលចេញទៅដោយងាយជាពាក្យញុំាងករណសម្បត្តិឲ្យកើតហើយ ។ ការសម្រេច (ដូច **សាធកតម**), ខ្លួន (ដូច **គត្ត**), ឥន្ទ្រិយមានចក្ខុជាដើម ។

**ករណីយ** គុ. [ករ + អនីយ] គឺ....គប្បីធ្វើ, វិ. **កាតព្វន្តិ** >**ករណីយំ** ។ នបុំ. អំពើដែលគួរធ្វើ (ដូច **កិច្ច**) ។

**ករណុត្តរិយករណ** នបុំ. [ករណ + ឧត្តរិយ + ករណ] កិ.ធ្វើឲ្យក្រៃលែងជាងកិ.ធ្វើ, កិ.ធ្វើឲ្យចម្រើនក្រៃលែងជាងកិ.ធ្វើ, - ជាងអំពើ ។

**ករណ្ឌកកណ្ណិកា** ឥ. [ករណ្ឌក + កណ្ណិកា] ចំពួយនៃដប, ចំពួយនៃខ្ចូច, ចំពួយនៃកំប៉ុក, ចំពួយនៃកំសៀវ ។

**ករណ្ឌ** បុំ. ប្រអប់ (ដូច **ចង្កោដក**) ។

**ករបាលិកា** ឥ. ខែលសម្រាប់ការពារដៃ (ដូច **ឥល្លី**) ។

**ករបុដ** បុំ. ក្រពុំម្រាម, ក្រពុំដៃ (ដូច **អញ្ជលិ**) ។

**ករភ** បុំ. ប្រទេសជាចន្លោះនៃកដៃនិងកូនដៃ, សត្វអូដ្ឋ (ដូច **ឱដ្ឋ**) ។

**ករភូសា** ឥ. គ្រឿងប្រដាប់ដៃ (ដូច **កង្កណ**) ។

**ករមន្ទ** បុំ. ដើមក្រចកខ្លែង (ដូច **សុសេន**) ។

**ករមរ** បុំ. [ករ + មរ + អ] ជនអ្នកស្លាប់ក្នុងដៃនៃសត្រូវ, ជនអ្នកត្រូវស្លាប់ដោយដៃនៃសត្រូវ (មនុស្សឈ្លើយសឹក ដូច **ពន្ទិ**), វិ. **សត្តូនំ ករេ ហត្ថេ មតោតិ**>**ករមរោ**, **សត្តូនំ ករេន ហត្ថេន មរេយ្យាតិ**>**ករមរោ** ។ -**អានីត** គុ.ដែលគេនាំមកជាឈ្លើយ (ទាស ,ខ្ញុំ) ។

**ករវីក** បុំ. ឈ្មោះភ្នំមួយក្នុងចំណោមភ្នំសត្តបរិភណ្ឌ, សត្វករវិក ។

**ករវីរ** បុំ. ដើមន្ទួនស្រីទេស (ដូច **អស្សមារក**) ។

**ករសាខា** ឥ. ម្រាមដៃ (ដូច **អង្គុលិ**) ។

**ករស្សុ** កិ. [ករ + អ + ស្សុ-ប.] ចូរធ្វើ ។

**ករហាដ** នបុំ. មើម (ដូច **កន្ទ**) ។

**ករិ** កិ. [ករ + អ + ឦ-អជ្ជ.] ធ្វើហើយ ។

**ករិត្ថ** កិ. [ករ + អ + ឥ-អា.+ ត្ថ-ហី.] ធ្វើហើយ ។

**ករិត្វាន** អ. [ករ + ឥ-អា. + ត្វាន] ធ្វើហើយ, លុះធ្វើហើយ ។

**ករិសាបណា** បុំ. កហាបណៈ (ដូច **កហាបណា**) ។

**ករិស្សតិ** កិ. [ករ + អ + ឥ-អា.+ស្សតិ-ភ.] នឹងធ្វើ ។

**ករីរ** បុំ. ដើមដងដឹង, ស្វាត (ដូច **ករកច**) ។

**ករីស** បុំ. ន- [ករ+ឦស] (អាហារវត្ថុ)ដែលជនធ្វើ, -បន្ទោបង់ (ករីស, អាហារចាស់, បុំ. ឧច្ចារៈ, លាមក, គូថ ដូច **វច្ច**, **គូថ** ), វិ. **ករិយតីតិ> ករីសំ** ។ មួយ ករីសចំនួនបួនអម្ពណ ឬ អម្មណ ។

**ករីសុ** កិ. [ករ + អ + ឦ-អជ្ជ.] ធ្វើហើយ ។

**ករុណា** ឥ. [កិរ + យុ + ឥ-អា., ករ + ឧណា + អា-ឥ.] (ធម្មជាតិ)នាំបង់នូវទុក្ខនៃបុគ្គលដទៃ ឬ(ធម្មជាតិ)បំផ្លាញនូវទុក្ខនៃបុគ្គលដទៃ (សេចក្តីអាណិត ដូច **អនុទ្ទយា**), វិ. **កិរតិ វិក្ខិបតីតិ >ករុណា**, **ករោតិ បរទុក្ខំ វិនាសេតីតិ វា >ករុណា** ។ល។ - **ភាវនា** ឥ. គុណជាតិញ៉ាំងករុណាឲ្យចម្រើន, វិ. **ករុណំ ភាវេតីតិ> ករុណា-ភាវនា** ។ -ភាវនាប្រកបដោយករុណា, វិ. **ករុណាយ សម្ប-យុត្តា ភាវនា >ករុណាភាវនា** ។ កិ.ចម្រើននូវករុណា ឬកិ. ញ៉ាំងករុណាឲ្យចម្រើន ។ - **ចេតសមុស្សាហិតមានស** គុ. មានចិត្តគឺកម្លាំងនៃករុណាឲ្យខ្មីឃ្មាតហើយ ។ - **សហគត** គុ. ទៅមួយអន្លើដោយករុណា, ប្រព្រឹត្តទៅមួយអន្លើដោយករុណា, ប្រកបដោយករុណា ។

**ករុណ** គុ. (សភាវ)ញ៉ាំងសេចក្តីសោកឲ្យចម្រើនឡើង (ជារសនៃរបាំម្យ៉ាងដែលគួរឲ្យយំសោក) ។

**ករេ** កិ. [ករ + អ + ឯយ្យ-ស., លុបយ្យ] គប្បីធ្វើ, ត្រូវធ្វើ ។

**ករេយ្យ** កិ. [ករ + អ + ឯយ្យ-ស.] គប្បីធ្វើ ។

**ករេរិ** បុំ. ដើមថ្ងាន់ (ដូច **វរណា**) ។

**ករោតិ** កិ. [ករ + ឱ + តិ-វ.] ធ្វើ, រមែងធ្វើ ។

**ករោន្តិ** កិ. [ករ + ឱ + អន្តិ-វ.] ធ្វើ, រមែងធ្វើ ។

**ករោន្តី** គុ. [ករ + ឱ + អន្ត + ឦ] កំពុងធ្វើ, កាលធ្វើ ។

**ករោន្តុ** កិ. [ករ + ឱ + អន្តុ-ប.] ចូរធ្វើ, សូមធ្វើ ។

**ករោហិ** កិ. [ករ + ឱ + ហិ-ប.] ចូរធ្វើ, សូមធ្វើ ។

**ករ** ធា. ១-**ករណេ ករោតិ កយិរតិ កុព្វតិ ក្រុព្វតិ** កម្ម. **ករីយតិ ករិយ្យតិ កយិរតិ** ការិត. **ការេតិ ការយតិ ការាបេតិ ការាបយតិ កតោ កុរុមានោ ករោន្តោ កុព្វន្តោ, ករណំ កិរិយា ក្រិយា កត្តា** ។ល។ "ធ្វើ, សាង, សង់, បំពេញ, ប្រតិបត្តិ, បង្កើត, សរសេរ, តែង, ស្លៀកពាក់..." ឥ. ។ **កយិរតិ** ប្រព្រឹត្តទៅបានទាំង ២ វាចកគឺ

កត្តុ. កម្ម. ។ **កត្តុ**.ឧ. **បុរិសោ កម្មំ ករិយតិ** ។ **កម្ម**.ឧ. **កុដិ មេ ករិយតិ អទេសិតវត្ថុកា**"កុដិមានវត្ថុមិនទាន់សម្តែង គឺខ្ញុំធ្វើ ឬខ្ញុំធ្វើកុដិមានទីដែលសង្ឃមិនទាន់សម្តែងហើយ" ។ កត្តុ. **យិរ** បច្ច័យ កម្ម. **យ** បច្ច័យ **វណ្ណវិបរិយាយ** គឺបង្វិលត្រឡប់អក្សរ យ រ -ស. ។ **ការណា** នបុំ. "ហេតុ, ការណ៍" ធ្វើផល, វិ. **អត្តនោ ផលំ ករោតីតិ ការណំ** -ស.។

**ករ**ធាតុប្រកបចូលអព្យយបច្ច័យមានរូបដូចតទៅនេះ **កាតុំ កត្តុំ កាតវេ ការេតុំ កត្វា កត្វាន កាតូន ករិត្វា កច្ច អធិកច្ច បដិកច្ច ករីយ ករីយាន បុរក្ខិត្វា ករិត្វាន** ។ល។ -ស.។ អា. **បទក្ខិ-ណំ កច្ច**"ធ្វើប្រទក្សិណហើយ" =**បទក្ខិណំ កត្វា** ។ **អធិកច្ច** ធ្វើក្រៃលែង =**អធិកំ កត្វា** មិនប្រើ **អធិកិច្ច** ទេ ។ **បដិកច្ច**"ធ្វើឲ្យហើយស្រេច, រៀបចំទុកជាមុន, ប្រុងប្រៀបទុកមុនឲ្យហើយ" (បដិ+ករ+ត្វា) ច្រើនប្រកបចូលនឹង **ឯវ**ស័ព្ទ អា. -**ហន្ទាហំ បដិកច្ចេវ វីរិយំ អារភាមិ**... ។ **កុព្វតិ**(ករ+ឱ ផ្លាស់ អ នៃ ករ ជា ឧ ផ្លាស់ ឱ ជា វ >ព លុប រ ចេញបំបែកដូចនេះ៖ វត្ត. **កុព្វតិ កុព្វន្តិ កុព្វសិ កុព្វថ, កុព្វាមិ កុព្វាម កុព្វតេ កុព្វន្តេ កុព្វសេ កុព្វវ្ហេ កុព្វេ កុព្វម្ហេ** ។ល។

២- **ករណោ បករោតិ បករោ បកតិ** "ធ្វើ, និពន្ធ, តែង, ចងក្រង, របៀបរៀង" ត.ន. **បករណំ** នបុំ. "គម្ពីរ, បករណ៍" ។ **ឧបករោតិ**" ទំនុកបម្រុង, គាំទ្រ, ..." ន. **ឧបការោ ឧបករណំ** ។ **បដិករោតិ** "ធ្វើតបត, ធ្វើប្រាស, បង្ការ, តប" ន. **បដិករណំ បដិការោ** ។ **បរិករោតិ**"ធ្វើជុំវិញ, (ប្រើប្រាស់,) ... ន. **បរិក្ខារោ**បុំ. ប្រែបាន ៣ យ៉ាង ៖១/ ស្នាមភ្លោះ, គូ =**បរិវារោ** ឧ. **នគរបរិក្ខារេហិ សុបរិ-ក្ខិត្តំ** ។ ២/ គ្រឿងប្រដាប់, **អលង្ការ=អលង្ការោ** ឧ. **រថោ សេតបរិក្ខារោ** ។ ៣/ គ្រឿងប្រើប្រាស់របស់បព្វជិត =**សម្ភារោ** ឧ. **បព្វ-ជិតេន ជីវិតបរិក្ខារា សមុទានេតព្វា** ។ **បដិសង្ខរោតិ**" ជួសជុល, ធ្វើឲ្យឡើងវិញ" ន. **បដិសង្ខរណំ** (បដិ+សំ+ករ)។ល។

**កល** បុំ. [កល + អ] សភាវៈគឺបុគ្គលគប្បីរាប់ (ចំណិត), វិ. **កលិតព្វោ សំខ្យាយិតព្វោតិ** >**កលោ** ។

**កលង្ក** បុំ. គ្រឿងកំណត់, គ្រឿងសម្គាល់, ស្នាម (ដូច **អង្ក**), សេចក្តីតិះដៀល (ដូច **អបវាទ**) ។

**កលទិ** ធា. **អវ្ហានរោទនេសុ កលន្ទតិ**"ហៅ, យំ" រុ. ។ **កលន្ទក** បុំ. "កង្ហែន, កំប្រុក" ។

**កលន្ទក** បុំ. សត្វកង្ហែន, កំប្រុក (ដូច **កាឡកា**) ។ -**និវាប** [កលន្ទក + និវាប] កលន្ទកនិវា-បដ្ឋាន, ប្រទេសជាទីឲ្យនូវចំណីដល់សត្វកង្ហែន ។

**កលភ** បុំ. ដំរីស្ទាវ (ដូច **ភឹក**) ។

**កលម្ពក** បុំ. ត្រកួន (ដូច **ភម្ពក**) ។

**កលល** នបុំ. [កល + អល] ភក់ ។ -**មក្ខិតបាទ** គុ. មានជើងប្រឡាក់ហើយដោយភក់, មានជើងគឺភក់ប្រឡាក់ហើយ ។ -**មក្ខិត** គុ. ប្រឡាក់ហើយដោយភក់, គឺភក់ប្រឡាក់ហើយ ។ **កលលរូប** គឺរូបដែលកកើតជាដំបូង, ភក់ (ដូច **ជម្ពាល**) ។

**កលវិង្ក** បុំ. ចាបស្រុក (ដូច **ចដក**) ។

**កលស** បុំ. ក្អម (ដូច **កុម្ភ**) ។

**កលហ** បុំ. [កល + ហ] វាទៈជាទីបៀតបៀននូវគ្នានិងគ្នា ឬវាទៈជាទីចាក់ដោតនូវគ្នានិងគ្នា (ការឈ្លោះ, ជម្លោះ សេចក្តីឈ្លោះ, ទាស់ទែង, ប្រកាន់ផ្សេងគ្នា ដូច វិគ្គហ), វិ. **កលតិ ហឹសតិ អញ្ញមញ្ញំ អស្មិន្តិ** >**កលហោ ។** - **វូបសមន នបុំ. កិ.ចូល**ទៅរម្ងាប់នូវជម្លោះ, កិ. ញុំាងជម្លោះឲ្យចូលទៅរម្ងាប់។ - **វូបសមនវត្ថុ** នបុំ. រឿងនៃកិ. ចូលទៅរម្ងាប់នូវជម្លោះ, រឿងនៃកិ.ញុំាងជម្លោះឲ្យចូលទៅរម្ងាប់ ។ - **សង្ខាត** គុ. ពោលគឺជម្លោះ, គឺបណ្ឌិតរាប់ព្រមហើយថាជម្លោះ ។

**កលហល** បុំ. កោលាហល, សំឡេងចៀវចារៀវ, សំឡេងខ្លាំង (ដូច **កោលាហល**) ។

**កលហិ** ធា. **កុច្ឆនេ កលហតិ**"គួរខ្ពើម, ឈ្លោះ, ទាស់" ភូ. ។ **កលហ** បុំ. "ជម្លោះ, ការទាស់ទែង, វិវាទ" ។

**កលា** ឥ. ចំណែកទី ១៦ , របស់ដែលគេបែងចែកជា ១៦ ចំណែក ហើយគេយកតែមួយចំណែកមកនិយាយ (ដូច **អំស**), សិល្បៈដែលមកក្នុងនាដកសាស្ត្រ, ចំណែកទី ១៦ នៃព្រះចន្ទ ។

**កលាប** បុំ. [កល+បា+អ] សភាវៈរក្សាទុកនូវអវយវៈ (កណ្តាប់, បាច់, សំណុំ), វិ. **កលំ អវយវំ បាតិ រក្ខតីតិ** >**កលាបោ** ។ -**អគ្គ** គុ. ទានដ៏ថ្មោងគឺបុគ្គលគប្បីឲ្យក្នុងកាលជាទីធ្វើនូវកណ្តាប់ ។ -**អាទិ** គុ. (កាល) មានកាលជាទីធ្វើនូវកណ្តាប់ជាដើម ។ កន្ទុយក្ងោក (ដូច **សិខណ្ឌ**, **បិញ្ឆ**), បំពង់សរ (ដូច **តុណីរ**, **ពាណធិ**), ហ្វូង, ប្រជុំ, ពួក, បាច់ (ដូច **និករ**, **គុម្ព**) ។

**កលាបី** បុំ. សត្វក្ងោក (ដូច **មោរ**) ។

**កលាពុរាជភូត** គុ. [កលាពុរាជ + ភូត] កើតជាស្តេចឈ្មោះកលាពុ, ជាស្តេចឈ្មោះកលាពុកើតហើយ ។

**កលិ** បុំ. [កល+ឥ] ទោស, បាប, កំហុស, ទោសកំហុស, ចាញ់ (ដូច **បរាជយ**) ។

**កលិកា** ឥ. ផ្កាឈើជិតនឹងរីក, ផ្កាឬផ្លែឈើដែលចម្រើន (ដូច **កោរក**) ។

**កលិង្គរ** បុំ., នបុំ. [ក + ឥំគ + អរ, ចុះល-អា] ឈើដែលឃ្លាតទៅដោយខ្យល់ (ឧស, អង្កត់ឧស), វិ. **កេន វាតេន ឥង្គតិ អបគច្ឆតីតិ** >**កលិង្គរោ** ។

**កលិង្គល** បុំ. សំដីស្រូវ (ដូច **ថុស**) ។

**កលិង្គ** បុំ. សត្វរន្ទេប (ដូច **ធូម្យាដ**) ។

**កលិទ** ធា. **បរិទេវនេ កលិន្ទតិ**"ខ្សឹកខ្សួល, ទួញ" រុ. ។

**កលិល** បុំ. ស្បាត, សាំញ៉ាំ (ដូច **គហណ**) ។

**កលីរ**, **កឡីរ** បុំ. នបុំ. [កល + ឦរ] ពន្លក, ពន្លកឈើ, ទំពាំង, លំពង់ (ដូច **មត្ថក**)។

**កលុស** គុ. ល្អក់ (ដូច **អាវិល**), បាប (ដូច **អកុសល**) ។

**កល** បុំ. សំឡេងមិនជាក់ មិនច្បាស់ តែពីរោះជាទីគាប់ចិត្ត ។

**កល្យាណ** គុ. ល្អ, ស្អាត, ជាទីគាប់ចិត្ត (ដូច **វាម**, **សុន្ទរ**), ចម្រើន (ដូច **មង្គល**) ។

**កល្ល** នបុំ. [កល + ល] ធម្មជាតជាគ្រឿងរាប់ (គួរ, ចំណិត), វិ. **កល្យន្តេ សំខ្យាយន្តេ អនេនាតិ** >**កល្លំ** ។ - **ភាគ** បុំ. ចំណែកនៃចំណិត ។ ពេលព្រឹកព្រលឹម (ដូច **បភាត**,**បច្ចូស**) ។ គុ. អ្នកដែលមានសេចក្ដីសប្បាយខ្លួន, ជាខ្លួន, ឥតរោគ (ដូច **និរោគ**,**និរាមយ**), ការប្រដាប់, ការរៀបចំ (ដូច**សជ្ជ**), អ្នកឆ្លៀវឆ្លាស (ដូច**ទក្ខ**)។

**កល្លកមហាវិ-ហារ** បុំ. [កល្លក + មហាវិហារ] មហាវិហារ (វិហារធំ) ឈ្មោះកល្លកៈ ។

**កល្លវាឡគ្គាមក** បុំ. [កល្លវាឡ + គាមក] ស្រុកតូចឈ្មោះកល្លវាឡៈ ។

**កល្លហារ** នបុំ. ចង្កុលណី, ស្គន្ធ (ដូច **សោគន្ធិក**) ។

**កល្លោល** បុំ. រលកធំ (ដូច **ឧល្លោល**) ។

**កល្លិ** ធា. **អសទ្ទេ កល្លតិ** "ឥតសំឡេង, ស្ងៀម, ស្ងាត់" ភូ. ។

**កលំក** បុំ. គ្រឿងសម្គាល់, ស្នាម (ដូច **លញ្ឆន**) ។

**កលិ** ធា. ១-**សង្ខានេ កលតិ**"រាប់" ភូ. ។ ន. **កលា** ឥ. "ចំណែក" = **អវយ-វោ**= **សោឡសាទិភាគោ** ។ **កាល** បុំ. កាល, ពេល, វេលា រាប់ វិ. **កលិតព្វោ សង្ខាតព្វោតិ កាលោ**-ស. ។

២-**ខេបេ (អប្បករណេ)កាលេតិ កាលយតិ**"ឲ្យអស់ទៅ, ឲ្យតិចចុះ, ឲ្យអស់រលីង" ចុ. ។ ន. **កាល** បុំ. ប្រែបានពីរយ៉ាង ៖ ១/ កាល, ពេល, វេលា "ឲ្យអាយុអស់ទៅ" ឧ. **កាលោ ឃសតិ ភូតា-និ** "ពេលវេលា ស៊ី សត្វ ទ.″ ។ ២/ សេចក្ដីស្លាប់, មច្ចុ "ឲ្យជីវិតអស់ទៅ" ឧ. **កាលកតោ** "គឺសេចក្ដីស្លាប់ធ្វើហើយ ឬស្លាប់ហើយ" (**កាលេន មច្ចុនា កតោ នាសិតោ កាលកតោ**) ស. ។

៣- **គតិសង្ខានេសុ កាលេតិ កាលយតិ កលា កាលោ** "ទៅ, ដល់, ប្រព្រឹត្តទៅ, រាប់" ចុ. ។

**កវច** បុំ. ក្រោះ (ដូច **កំកដ**) ។

**កវរគាវី** ឥ. [កវរ + គាវី] មេគោពពាល ។

**កវលិង្ការាហារ** បុំ. [កវលិង្ការ + អាហារ] អាហារដែលបុគ្គលធ្វើឲ្យទៅជាពំនូត ។

**កវាដ** បុំ. សន្ទះ, សន្ទះទ្វារ, (គន្លឹះ, គន្លឹះទ្វារ) ។

**កវិ** បុំ. ស្វា (ដូច **វានរ**), អ្នកប្រាជ្ញ (ដូច **ពុធ**) ។

**កវិដ្ឋ** បុំ. ដើមក្វិដ្ឋ (ខ្វិដ្ឋ) (ដូច **កបិដ្ឋ**) ។

**កវី** បុំ. អ្នកប្រាជ្ញ (ដូច **សុធី**) ។

**កវិ** ធា. **វណ្ណេ កវតិ** "ធ្វើឲ្យមានពណ៌, ជ្រលក់ពណ៌" ភូ ។

**កសក** បុំ. [កស+ណ្វុ] ជនអ្នកភ្ជួរ (អ្នកស្រែ ឬអ្នកចម្ការ), វិ. **កសតីតិ>កសកោ** ។ -**ឧបាសក** បុំ. បុគ្គលអ្នកភ្ជួរជាឧបាសក, ឧបាសកអ្នកភ្ជួរ (ឧបាសកអ្នកស្រែ) ។ ផាល (នង្គ័ល) (ដូច **ផាល**)។

**កសន** នបុំ. [កស + យុ] ជាទីភ្ជួរ, កិ.ភ្ជួរ, វិ. **កសន្តិ ឯត្ថាតិ >កសនំ** , **កសិយតេ-តិ >កសនំ** ។ -**ដ្ឋាន** នបុំ. ទីជាទីភ្ជួរ ។ -**អត្ថ** បុំ. ប្រយោជន៍ដល់កិ. ភ្ជួរ, ត្រូវការដល់ដល់កិ.ភ្ជួរ។

**កសម្ពុ** បុំ. សម្រាម (ដូច **សង្ការ**) ។

**កសា** ឥ. [កស + អ + អា-ឥ.] រំពាត់, ខ្សែតី (សម្រាប់វាយសេះជាដើម) ។

**កសាបេតព្វ** គុ. [កស + ណាបេ + តព្វ] គឺ.....គប្បីឲ្យភ្ជួរ ។

**កសាមសេ** កិ. [កស + អ + ម-វ.+ សេ-និ.] ភ្ជួរ, រមែងភ្ជួរ ។

**កសាយ** នបុំ. ទឹករាវ (ដូច **ទ្រវ**), សម្បុរ (ដូច **វណ្ណ**), រសចត់, ក្លិនក្រអូប (ដូច **សុរភិ**) ។

**កសាវ** បុំ. [ក + សី + អវ] សភាវៈសេពនូវទឹក (ទឹកចត់, ទឹកម្ចត់, រសចត់), វិ. **កំ បានីយំ សេវតេតិ > កសាវោ** ។ គុ.(វត្ថុ)មានរសចត់, រសចត់ ។

**កសិកម្ម** នបុំ. [កសិ + កម្ម] កម្មគឺកិ.ភ្ជួរ ការភ្ជួររាស់ (ដូច **កសី**), វិ. **កសនំ >កសិ, សា ឯវ កម្មំ >កសិកម្មំ** ។ - **អាទិក** គុ. មានកសិកម្មជាដើម ។

**កសិគោរក្ខាទិ** គុ. [កសិ + គោរក្ខ + អាទិ] (ជីវិតោបាយ) មានកិ.ភ្ជួរ និងកិ.រក្សានូវគោជាដើម, (កម្ម) មានកសិកម្មនិងគោរក្ខកម្មជាដើម ។

**កសិណ** គុ.,ន. ទាំងអស់ (ដូច **សព្វ**),កសិណ ។-**បរិកម្ម** នបុំ.បរិកម្មមានកសិណជាអារម្មណ៍, បរិកម្មក្នុងកសិណ ។-**មណ្ឌល** នបុំ. មណ្ឌលនៃកសិណ ។

**កសិត** គុ. [កស + ឥ-អា. + ត] ដែល....ភ្ជួរហើយ ។ -**ដ្ឋាន** នបុំ. ទីនៃ....គឺ.... ភ្ជួរហើយ ។

**កសិតុំ** អ. [កស + ឥ-អា. + តុំ] ដើម្បីភ្ជួរ, -រាស់ ។

**កសិត្វា** អ. [កស + ឥ-អា. + ត្វា] ភ្ជួរហើយ, រាស់ហើយ ។

**កសិភណ្ឌ** នបុំ. [កសិ + ភណ្ឌ] ភណ្ឌៈសម្រាប់ភ្ជួរ, គ្រឿងភ្ជួរ ។

**កសិរ** គុ. [កស + ឥរ] ធម្មជាតដល់នូវភាពមិនមែនជាបុណ្យ (លំបាក, គ្រដាប គ្រដួស, ដូច **ទុក្ខ**) វិ.**កសតិ អបុញ្ញន្តិ>កសិរំ**) ។

| | | |
|---|---|---|
| **កសិវណិជ្ជាទិ** | គុ. | [កសិ + វណិជ្ជ + អាទិ] (កម្ម) មានកិ.ភ្ជួរនិងកិ.ជួញជាដើម, មានកសិកម្ម និងវណិជ្ជកម្មជាដើម ។ |
| **កសី** | ឥ. | ការភ្ជួររាស់ (ដូច **កសិកម្ម**) ។ |
| **កសេរុ** | នបុំ. | ផ្លែក្រចាប់, សព្ទនេះជាអត្ថនៃ**សីឃាដក**សព្ទ ។ |
| **កស្មា** | វិ.ស.អ | [កឹ + ស្មា] ព្រោះហេតុអ្វី, ព្រោះហេតុដូចម្តេច ។ |
| **កស្មិរជំ** | នបុំ. | របស់ដែលកើត ក្នុងដែនកស្មីរគឺ **អគ្គិសិខំ**, **ខរខាលិកំ**, **បីតនំ**, **រត្តំ**, **សំភោចំ**, **បិសុនំ**, **ខរំ លោហិតចន្ទនំ** (ដូច **កុំកុម**) ។ |
| **កស្មិរ** | បុំ. | ឈ្មោះដែន ឬ ជនបទមួយ ក្នុងប្រទេសឥណ្ឌៀ ។ |
| **កស្សក** | បុំ. | អ្នកស្រែ (ដូច **ខេត្តាជីវ**) ។ |
| **កស្សចិ** | វិ.ស.អ. | [កឹ + ស-វិ.+ចិ] ដល់អ្នកណា, ដើម្បីអ្នកណា,....។ |
| **កស្សប** | អ.ន. | ភិក្ខុឈ្មោះកស្សបៈ, កុមារឈ្មោះកស្សបៈ, ព្រះពុទ្ធព្រះនាមកស្សបៈ ។ -**ទសពល** បុំ. ព្រះទសពលព្រះនាមកស្សបៈ ។ -**ពុទ្ធកាល** បុំ. កាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ។ -**ពុទ្ធសាសន** នបុំ. សាសនានៃព្រះពុទ្ធព្រះនាមកស្សបៈ។ -**សម្មាសម្ពុទ្ធកាល** បុំ. កាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ ។ ឈ្មោះឥសីអ្នកតែងមន្តមួយ ។ |
| **កស្ស៑** | ធា. | **គតិយំ កស្សតិ បរិកស្សតិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។ **បដិកស្សតិ** "ទាញមក, ត្រឡប់ទៅ" (បដិ+កស្ស)អា. **មូលាយ បដិកស្សេយ្យ** "គប្បីត្រឡប់ទៅ ដើម្បីអាបត្តិដើមវិញ" ។ **បដិកស្សេយ្យ=អាកឌ្ឍេយ្យ** -ស. ន. **បដិកស្សនំ** ។ |
| **កសិ** | ធា. | ១-**វិលេខនេ កសតិ កស្សតិ**"ធ្វើឲ្យមានស្នាម, គូស, ភ្ជួរ, រាស់" ភូ . ទិ. ។ **កស្សកោ** បុំ. **កស្សិកា** ឥ. "អ្នកស្រែ, អ្នកចម្ការ" (កស+ណ្វុ) ។ **អាកាសោ** បុំ. =**នភំ** "អាកាស, មេឃ ភ្ជួរមិនបាន ឬ មិនអាចភ្ជួរ, គូសបាន" វិ. **តំ ហិ ន កស្សតីតិ អាកាសោ** ។ **កសិតុំ វិលេខិតុំ ន សក្កោតីតិ អត្ថោ** ស. ។ស័ព្ទជាវេវចនៈនៃ **អាកាសោ** គឺ **អម្ពរំ អព្ភំ អន្តលិក្ខំ អឃំ នភំ វេហាសោ គគនំ ទេវោ ខំ អាទិច្ចបថោ តារាបថោ នក្ខត្តបថោ រវិបថោ វេហាសយំ វាយុបថោ អបថោ អនិលញ្ជសំ** -ស.។<br>២- **ហឹសាយំ កសតិ**"បៀតបៀន" ភូ. ។<br>៣- **គតិសាសនេសុ កសតិ**"ទៅ, ដល់, ប្រព្រឹត្តទៅ, ប្រៀនប្រដៅ, ទូន្មាន" ភូ.។ |
| **កហាបណ** | បុំ., ន បុំ. | កហាបណៈ (សាច់ប្រាក់ទម្ងន់៨បាទ) (ដូច **ករិសាបណ**)។ -**ការណ** នបុំ. ហេតុនៃកហាបណៈ។ -**អគ្ឃនក** គុ. ដល់នូវថ្លៃមានកហាបណៈជាប្រមាណ, ដល់នូវថ្លៃមួយកហាបណៈ, ថ្លៃមួយកហាបណៈ, តម្លៃមួយកហាបណៈ, ។ |

-**គព្ភទ្វារ** នបុំ. ទ្វារនៃបន្ទប់ដ៏ពេញដោយកហាបណៈ, វិ. **កហាបណេហិ បូរោ គព្ភោ** >**កហាបណគព្ភោ** ។ បន្ទប់សម្រាប់ដាក់នូវកហាបណៈ, វិ. **កហាបណានំ ឋបនោ គព្ភោ**>**កហាបណគព្ភោ** ។ - **បសិព្វក** នបុំ. ការុងដ៏ពេញដោយកហាបណៈ, ការុងសម្រាប់ដាក់នូវកហាបណៈ ។ -**បូរ** គុ. ដ៏ពេញដោយកហាបណៈ ។ -**ភណ្ឌិក** នបុំ. បង្វិចនៃកហាបណៈ, បង្វិចដ៏ពេញដោយកហាបណៈ ។ -**រាសិ** បុំ. គំនរនៃកហាបណៈ ។ -**វស្ស** នបុំ. ភ្លៀងគឺកហាបណៈ ។ -**សត** នបុំ. រយនៃកហាបណៈ ។

**កហំ** អ.ស. [កឹ + ហំ] ក្នុងទីណា, ក្នុងទីដូចម្តេច ។ **ក្វត្ថវាចក** និបាតប្រាប់អត្ថគឺក្នុង..ណា, ក្នុង...ដូចម្តេច ប្រែថា ក្នុងទីណា, ក្នុងទីដូចម្តេច ជាដើម, **កុហិញ្ចនំ**, **កុហឹ**, **កុត្រ**, **កុត្ថ**, **កត្ថ**, **ក្វ** ក៏ជាក្វត្ថវាចក ដែរ ។

**កឡត្ត** នបុំ. ប្រពន្ធ (ដូច **ជាយា**) ។

**កឡាយ** បុំ. សណ្តែកកង់, សណ្តែកខ្មៅ (ដូច **ចណក**) ។

**កឡារ** បុំ. សម្បុរដំដែង, សម្បុរខៀវលឿង (ដូច **កបិល**) ។

**កឡុស** គុ. ល្អក់ (ដូច **អនច្ឆ**)។

**កឡេវរ** បុំ. កាយ, រាងកាយ (ដូច **តនុ**) ។

**កឡ** ធា. ១-**មទកក្ខសេសុ កឡតិ**"ស្រវឹង, មួម៉ៅ, អន់, អាក្រក់, ទារុណ" ភូ. ។ ២- **សេចនេ កឡតិ កឡនំ**"ស្រោច, បាចសាច,ប្រោះព្រំ" ភូ. ។

**កា** វិ.ស.អ. [កឹ + សិ-វិ.] ណា, នាងណា, ដូចម្តេច ។

**កាក** បុំ. [កា+ក] សត្វធ្វើនូវសំឡេងថា «កា» (ក្អែក), វិ. **កាតិ សទ្ទំ ករោតីតិ** > **កាកោ** ។ - **បេ្រត** បុំ. កាកប្រេត, ប្រេតមានសីសៈដូចជាសីសៈនៃក្អែក, ប្រេតដូចជាក្អែក។ -**យោនិ** ឥ. កំណើតនៃក្អែក ។ -**វល្លិយ** អ.ន. សេដ្ឋីឈ្មោះកាកវល្លិយៈ។ - **សទិស** គុ. អ្នកដូចជាក្អែក, អ្នកប្រហែលដោយក្អែក, អ្នកប្រាកដស្មើដោយក្អែក ។ - **សុនខសន្និបាត** បុំ. កិ.ប្រជុំនៃក្អែកនិងឆ្កែ, កិ. ជួបជុំនៃ....។ -**សូរ** គុ. អ្នកក្លៀវក្លាដូចជាក្អែក ។

**កាកណិក** នបុំ. (ឈ្មោះប្រាក់បុរាណ ដែលគេប្រើក្នុងមជ្ឈិមប្បទេស) កាកណិក, ទ្រព្យមានកាកណិកជាប្រមាណ ។ - **មត្ត** គុ. មានកាកណិកជាប្រមាណ, ត្រឹមតែមួយកាកណិក, ទ្រព្យត្រឹមតែមួយកាកណិក ។

**កាកតាលីយ** គុ. (កម្ម)ប្រហែលគ្នានឹងក្អែកហើរ និងផ្លែត្នោតជ្រុះ, (កម្ម)ដែលមិនបានគិតមុន។

**កាកតិន្ទុក** បុំ. ដើមដង្កោ (ដូច **កុលក**) ។

**កាកបក្ខ** បុំ. សក់ដែលគេសិតញែក មានសណ្ឋានដូចជាស្លាបក្អែក (ដូច **សិខណ្ឌក**) ។

**កាកលី** ឥ. សំឡេងតិច, សំឡេងស្រាល, សំឡេងល្អិត ។

**កាកីសទិស** គុ. [កាកី + សទិស] ដូចជាមេក្អែក, ប្រហែលដោយមេក្អែក, ប្រាកដស្មើដោយក្អែក។

**កាក** បុំ. ក្អែក (ដូច **អរិដ្ឋ**) ។

**កាកោទុម្ពរិកា** ឥ. ដើមល្វាដី (ដូច **ផេគ្គុ**) ។

**កាកោបមា** ឥ. [កាក + ឧបមា] វាចាជាគ្រឿងប្រៀបដោយក្អែក, សេចក្ដីប្រៀបដោយក្អែក ។

**កាកោឡូក** បុំ. [កាក + ឧឡូក] ក្អែកនិងមៀម ។

**កាកោឡ** បុំ. ក្អែកព្រៃ (ដូច **វនកាក**) ។

**កាច** បុំ. ដីដែលគេលាយមានសម្បុរខៀវជាដើម, សង្រែក (ដូច **សិក្កា**), រោគភ្នែក (ដូច **នយនាមយ**) ។

**កាជ** បុំ. ដងរែក (ដូច **ព្យាភង្គី**) ។

**កាញ្ចនគុហា** ឥ. [កាញ្ចន + គុហា] គុហាជាវិការៈនៃមាស, គុហាដែលគេធ្វើដោយមាស ។

**កាញ្ចនថូប** បុំ. [កាញ្ចន+ថូប] ស្តូបជាវិការៈនៃមាស, (ចេតិយជាវិការៈនៃមាស), វិ. **កាញ្ចនស្ស វិការោ ថូបោ** >**កាញ្ចនថូបោ** ។ ស្តូបដែលគេធ្វើដោយមាស, វិ. **កាញ្ចនេន កតោ ថូបោ** >**កាញ្ចនថូបោ** ។

**កាញ្ចនរូបក** នបុំ. [កាញ្ចន+រូបក] រូបតូចជាវិការៈនៃមាស (រូបប្រៀបជាវិការៈនៃមាស) ។

**កាណ** គុ. [កណ + ណ] ខ្វាក់, មានភ្នែកខ្វាក់ ។ **អភិ**.សុ. ភ្នែកខ្វាក់តែម្ខាងក្ដី ខ្វាក់ទាំងពីរខាងក្ដី ហៅថា «**កាណ**» ។ អ.ក. ភ្នែកខ្វាក់តែម្ខាងហៅថា«**កាណ**» , ខ្វាក់ទាំងពីរខាងហៅថា «**អន្ធ**», ពាក្យនេះសមតាមកាណកច្ឆបោបមសូត្រ ដែលនិយាយអំពីអណ្ដើកខ្វាក់ភ្នែកតែម្ខាង ។ - **អាទិភាវ** បុំ. ភាវៈនៃ.....ជាសត្វមានភ្នែកខ្វាក់ជាដើម ។ -**មាតា** ឥ. មាតានៃស្ត្រីឈ្មោះកាណា ។ -**មាតាវត្ថុ** នបុំ. រឿងនៃមាតានៃស្ត្រីឈ្មោះកាណា ។

**កាណាជិក** នបុំ. [កណ + ជន + ឥក] បាយកើតអំពីចុងអង្ករ (បាយចុងអង្ករ, បាយលាយដោយកន្ទក់), វិ. **កណតោ ជាយតីតិ** >**កាណាជិកំ** ។ ប្រើជា «**កណាជក**»ក៏មាន ។

**កាតព្វ** គុ. [ករ + តព្វ] គឺ...គប្បីធ្វើ, -ត្រូវធ្វើ, -គួរធ្វើ ។

**កាតរ** បុំ. អ្នករួញរា, អ្នកមិនក្លាហាន (ដូច **អវីរ** ឬ **អធីរ**) ។

**កាតុកាម** គុ. [កាតុំ + កម + ណ] អ្នកប្រាថ្នាដើម្បីធ្វើ, អ្នកចង់ដើម្បីធ្វើ, វិ. **កាតុំ កាមេតីតិ** >**កាតុកាមោ** ។

**កាតុំ** អ. [ករ + តុំ] ដើម្បីធ្វើ, វីកិ.ធ្វើ ។

**កាថ** ធា. **ហឹសាយំ កាថេតិ កាថយតិ** "បៀតបៀន" ចុ. ។

**កាទម្ព** បុំ. ក្អែកទឹក (ដូច **កាឡហំស**) ។

| | | |
|---|---|---|
| **កានន** | នបុំ. | ព្រៃ (ដូច **អរញ្ញ**) ។ |
| **កាបុរិស** | បុំ. | [កុ > កា + បុរិស] បុរសដែលបណ្ឌិតគួរខ្ពើម (បុរសលាមក, បុរសអាក្រក់), វិ. **កុច្ឆិតោ បុរិសោ** >**កាបុរិសោ** ។ |
| **កាបោតក** | គុ. | [កបោត + ណក] មានពណ៌ដូចជាពណ៌នៃព្រាប, មានសម្បុរដូចជាសម្បុរនៃព្រាប ។ |
| **កាម** | បុំ. | [កម+ណ] សេចក្តីប្រាថ្នា, សេចក្តីចង់បាន, ចំណង់, វិ. **កមនំ បដ្ឋនំ** >**កាមោ**។ -**កណ្ដក** បុំ. បន្លាគឺកាម, កាមដូចជាបន្លា ។ -**កាម** គុ. អ្នកប្រាថ្នានូវកាម ។ -**ការណា** នបុំ. ហេតុនៃកាម ។ - **គវេសក** គុ. អ្នកស្វែងរកនូវកាម, វិ. **កាមំ គវេសតីតិ** >**កាមគវេសកោ** ។ - **គវេសី** បុំ. អ្នកស្វែងរកនូវកាម, អ្នកស្វែងរកនូវកាមដោយប្រក្រតី, អ្នកមានកិ.ស្វែងរកនូវកាមជាប្រក្រតី, វិ. **កាមេ គវេសតីតិ** > **កាមគវេសី**, **កាមេ គវេសតិ សីលេនាតិ** > **កាមគវេសី**, **កាមេ គវេសិតុំ សីលមស្សាតិ** >**កាមគវេសី** ។ -**ច្ឆន្ទាទិ** គុ. (កិលេស) មានកាមច្ឆន្ទៈជាដើម, មានសេចក្តីពេញចិត្តប្រព្រឹត្តទៅក្នុងកាមជាដើម ។ -**បង្ក** បុំ. ភក់គឺកាម, កាមដូចជាភក់ ។ -**បរិឡាហ** បុំ. សេចក្តីពេលរាលព្រោះកាម, សេចក្តីក្តៅក្រហាយព្រោះកាម ។ -**ព្យាបាទវិហឹសាវិតក្កវសិកតោ** ឥ. ភាវៈនៃ....នោះជាអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃកាមវិតក្កៈ និងព្យាបាទវិតក្កៈ និងវិហឹសាវិតក្កៈ ។ -**ភវបរិក្ខីណ** គុ. មានកាមភពអស់ជុំវិញហើយ, មានកាមភពអស់រលីងហើយ ។ -**ភវាទិ** គុ. (ភព) មានកាមភពជាដើម ។ -**ភោគី** បុំ. អ្នកបរិភោគនូវកាម, អ្នកបរិភោគនូវកាមដោយប្រក្រតី, អ្នកមានកិ.បរិភោគនូវកាមជាប្រក្រតី ។ -**យន្ត** គុ.[ <កម + ណយ + អន្ត ] កាលប្រាថ្នា, កាលចង់បាន ។ -**យោគាទិ** គុ. (យោគៈ) មានកាមយោគៈជាដើម ។ -**រជ** បុំ. ធូលីគឺកាម។ -**រតិនិស្សិត** គុ. អ្នកអាស្រ័យហើយនូវសេចក្តីត្រេកអរក្នុងកាម, អ្នកគឺសេចក្តីត្រេកអរក្នុងកាមអាស្រ័យហើយ ។ -**រតិសន្ថវ** បុំ. សេចក្តីរីករាយព្រមដោយអំណាចនៃសេចក្តីត្រេកអរក្នុងកាម ។ -**រាគសំយោជនាទិក** គុ. មានសំយោជនៈគឺកាមរាគជាដើម, មានកាមរាគសំយោជនៈជាដើម ។ -**រាគាទិ** គុ. មានសេចក្តីរីករាយក្នុងកាមជាដើម, មានកាមរាគៈជាដើម ។ -**វិតក្កាទិ** គុ. មានសេចក្តីត្រិះរិះក្នុងកាមជាដើម, មានកាមវិតក្កៈជាដើម ។ -**សញ្ញោជនីយ**-**ជន** នបុំ. ការតនូវកិ.ប្រកបព្រមដោយកាម, កិ.តដើម្បីកិ.ប្រកបព្រមគឺកាមជាដើម។ -**សំយោគាទិ** គុ. មានធម៌ជាគ្រឿងប្រកបព្រមគឺកាមជាដើម, មានធម៌ជាគ្រឿងប្រកបព្រមដើម្បីកាមជាដើម ។ -**សុខសទិស** គុ. ប្រាកដស្មើដោយសុខក្នុងកាម ។ -**ហេតុ** បុំ. ហេតុនៃកាម ។ វត្ថុ |

កាមកិលេសកាម, សេចក្តីប្រាថ្នា (ដូច **ឥច្ឆា**), ទេវបុត្តមារ (ដូច **មទន**), មារ (ដូច **អចិត្តភូ**),ជនអ្នកត្រេកអរ (ដូច **រត**), ចំណង់ (ដូច **និកាម**), តណ្ហា (ដូច **អភិលាស**) , អនុញ្ញា ។

**កាមគុណ** បុំ. [កាម + គុណ] កាមគុណ, សភាវៈជាគ្រឿងចងគឺកាម, កាមជាគ្រឿងចង ។ -**បរិយេសន** នបុំ. កិ.ស្វែងរកនូវកាមគុណ ។ -**សម្បត្តិ** ឥ. ឬ គុ. កិ. ដល់ព្រមដោយកាមគុណ, ធម្មជាតិជាហេតុដល់ព្រមដោយកាមគុណ ។

**កាមន** បុំ. អ្នកប្រាថ្នា, អ្នកស្រឡាញ់, អ្នកចង់ (ដូច **កាមី**) ។

**កាមយិតា** បុំ. អ្នកប្រាថ្នា, អ្នកស្រឡាញ់, អ្នកចង់ (ដូច **កាមន**) ។

**កាមាទិ** គុ. (យោគ ៤ )មានកាមយោគជាដើម, សព្ទនេះជាអត្ថនៃ**យោគ**សព្ទ ។

**កាមាវចរ** គុ. [កាម + អវ + ចរ + អ] ដែលត្រាច់ចុះក្នុងកាមភព ឬដែលប្រព្រឹត្តទៅក្នុងកាមភព , វិ. **កាមភវេ អវចរតិ បវត្តតីតិ** >**កាមាវចរំ** ។ -**កុសលចិត្ត** នបុំ. ចិត្តជាកុសលជាកាមាវចរ, កុសលចិត្តជាកាមាវចរ ។ -**កុសលាទិភេទ** គុ. ផ្សេងដោយចិត្តមានចិត្តជាកុសលជាកាមាវចរជាដើម, មានចិត្តជាកុសលជាកាមាវចរជាដើមជាប្រភេទ ។

**កាមាសវាទិ** គុ. (អាសវៈ ៤ )មានកាមាសវៈជាដើម, សព្ទនេះជាអត្ថនៃ **អាសវ**សព្ទ ។

**កាមី** បុំ. អ្នកប្រាថ្នា, អ្នកស្រឡាញ់, អ្នកចង់ (ដូច **កាមយិតា**) ។

**កាមិនី** ឥ. ស្រី (ដូច **លលនា**) ។

**កាមុក** បុំ. អ្នកប្រាថ្នា, អ្នកស្រឡាញ់, អ្នកចង់ (ដូច **កមិតា**) ។

**កាមោឃាទិ** គុ. [កាមោឃ + អាទិ] (ឱឃៈ) មានកាមោឃៈជាដើម, (អន្លង់) មានអន្លង់គឺកាមជាដើម ។

**កាមោឃាទិ** គុ. (ឱឃៈ ៤ )មានកាមោឃៈជាដើម, សព្ទនេះអត្ថនៃ**ឱឃ**សព្ទ ។

**កាមំ** និ. ពិត, ដោយពិត ។ ឯកំសត្ថវាចក និបាតប្រាប់អត្ថគឺចំណែក ១, តែម្យ៉ាង ប្រែថា ដោយពិត, **អញ្ញទត្ថុ**, **តគ្ឃ**, **សសក្កំ**, **អទ្ធា**, **ជាតុ**, **វេ**, **ហវេ** ក៏ជាឯកំសត្ថវាចកដែរ, មួយទៀតប្រព្រឹត្តទៅក្នុងអត្ថគឺ **យទិ** សព្ទនិង **អបិ**សព្ទ ប្រែដូច **យទិ** និង **អបិ** ។

**កាយ** បុំ. [កុ+អាយ] សភាវៈជាទីនៅនៃធម៌ប្រព្រឹត្តទៅមួយអន្លើដោយអាសវៈដែលបណ្ឌិតគួរខ្ពើម, (កាយដូច **ទេហ**, សរីរៈ, ហ្វូង, ប្រជុំ, ពួក, គំនរ ដូច **រាសិ**), វិ. **កុច្ឆិតានំ សាសវធម្មានំ អាយោតិ** >**កាយោ** **កុច្ឆិតានំ កេសាទីនំ អាយោ ឧប្បត្តិទេសោតិ** >**កាយោ** ។ -**កម្ម** នបុំ. កាយកម្ម, កម្មគឺបុគ្គលគប្បីធ្វើដោយកាយ, វិ. **កាយេន កាតព្វំ កម្មំ** >**កាយកម្មំ**។ -**កម្មាទិក** គុ. មានកាយកម្មជាដើម ។ -**គត** គុ. ទៅហើយក្នុងកាយ, តាំងនៅក្នុងកាយ ។ -**ចលនសីសុក្ខិបនភមុកវិការាទិ** គុ. (អាការ) មាន កិ.កម្រើកនៃកាយ និងកិ.ងើបនៃក្បាល និងកិ.ញាក់នូវចិញ្ចើមជាដើម ។ -**ទណ្ឌាទិវិរហិត**

គុ. ដែលប្រាសចាកអាជ្ញា មានអាជ្ញាគឺកាយជាដើម, ដែលវៀរចាកអាជ្ញា មានអាជ្ញាគឺកាយជាដើម ។ -**ទណ្ឌាទិ** គុ. (អាជ្ញា) មានអាជ្ញាគឺកាយជាដើម, មានអាជ្ញាដោយកាយជា ដើម ។ -**ទុច្ចរិតាទិ-អកុសលកម្មាភិរត** គុ. អ្នកត្រេកអរស៊ប់ហើយក្នុងអកុសលកម្មមានកាយទុច្ចរិតជាដើម ។ -**ទុច្ចរិតាទិ** គុ. (ទុច្ចរិត) មានកាយទុច្ចរិតជាដើម ។ -**ទុច្ចរិតតាទិប្បវេសននិវារណត្ថាចារ** គុ. មានអាចារៈគឺកិ.ឃាត់នូវកិ.ចូលទៅ នៃទុច្ចរិតមានកាយទុច្ចរិតជាដើមជាប្រយោជន៍ ។ -**ទុច្ចរិតាទិភេទ** គុ. ផ្សេងដោយទុច្ចរិតមានកាយទុច្ចរិតជាដើម ។ -**ទុច្ចរិតាទិវិរហិត** គុ. ដែលប្រាសចាកទុច្ចរិតមានកាយទុច្ចរិតជាដើម, ដែលវៀរចាកទុច្ចរិតមានកាយទុច្ចរិតជាដើម ។ -**ទ្វារ** នបុំ. កាយទ្វារ, ទ្វារគឺកាយ ។ -**និស្សិត** គុ. អាស្រ័យហើយនូវកាយ, អាស្រ័យហើយក្នុងកាយ។ -**ប្បគព្ភិយាទិ** គុ. (សេចក្ដីឃ្នើសឃ្នង) មានសេចក្ដីឃ្នើសឃ្នងដោយកាយជាដើម, (អាការ) មានកិ.ច្រឡើសបើសដោយកាយជាដើម ។ -**ប្បកោប** បុំ. កិ.កម្រើកដោយកាយ, កិ.កម្រើកនៃកាយ ។ -**ពន្ធនមណ្ឌន** នបុំ. កិ.ប្រដាប់នូវចីវរ (នូវសំពត់) សម្រាប់ចងនូវកាយ, កិ.ប្រដាប់នូវវត្ថពន្ធន៍, កិ.ប្រដាប់នូវវត្ថពន្ធន៍ចង្កេះ ។ -**ពន្ធន** នបុំ. សំពត់សម្រាប់ចងនូវកាយ, វត្ថពន្ធន៍ចង្កេះ ។ -**វចីមនោកម្ម** នបុំ. កាយកម្ម និងវចីកម្ម និងមនោកម្ម ។ -**វង្កាទិ** គុ. (កិ.វៀច) មាន កិ.វៀចដោយកាយជាដើម ។ -**វត្ថុក** គុ. មានកាយជាវត្ថុ, មានកាយជាលំនៅ, មានកាយជាទីតាំង ។ -**វាចាទិ** គុ. (ទ្វារ) មានកាយ និងវាចាជាដើម ។ -**វិជម្ភនរហិត** គុ. ដែលប្រាសចាកកិ.មិតពត់នូវកាយ, ដែលវៀរចាកកិ.កែក្រាយដោយកាយ ។ -**វិជម្ភិតា** ឥ. ភាវៈនៃ....ជាអ្នកមានកិ.មិតពត់នូវកាយ, ភាវៈនៃ.......ជាអ្នកមានកិ.កែក្រាយដោយកាយ ។ -**វិវេកាទិក** គុ. មានសេចក្ដីស្ងប់ស្ងាត់នៃកាយជាដើម, មានកាយវិវេកជាដើម ។ -**វិវេក** បុំ. សេចក្ដីស្ងប់ស្ងាត់នៃកាយ (វិវេក <វិ + វិច + ណ) ។ -**វេយ្យាវដ្ដិក** គុ. កិ.ខ្វល់ខ្វាយដោយកាយ, កិច្ចប្រកបដោយកិ.ខ្វល់ខ្វាយដោយកាយ, អ្នកប្រកបក្នុងកិ.ខ្វល់ខ្វាយដោយកាយ ។ -**សញ្ញាមាទនវិរហិត** គុ. ដែលប្រាសហើយចាកកិ.សង្រួមមានកិ.សង្រួមដោយកាយជាដើម, វៀរហើយចាកកិ.សង្រួមមានកិ.សង្រួមដោយកាយជាដើម ។ -**សញ្ញមាទិ** គុ. (កិ.សង្រួម) មានកិ.សង្រួមដោយកាយជាដើម ។ - **សមាចារ** បុំ. សមាចារៈនៃកាយ, មារយាទជាគ្រឿងប្រព្រឹត្តស្មើដោយកាយ ។ -**សុចរិត** នបុំ. កាយសុចរិត, កម្មដែលបុគ្គលប្រព្រឹត្តល្អហើយដោយកាយ ។ -**សុចរិតាទិ** គុ. មានកាយសុចរិត

ជាដើម ។ -**សុចរិតាទិភេទ** គុ. ផ្សេងដោយសុចរិតមានកាយសុចរិតជាដើម, មានកម្មដែលបុគ្គលប្រព្រឹត្តល្អហើយដោយកាយសុចរិតជាដើមជាប្រភេទ ។ -**អាទិសញ្ញមវិរហិត** គុ. អ្នកប្រាសហើយចាកកិ.សង្រួមនូវទ្វារមានកាយទ្វារជាដើម, អ្នកវៀរហើយចាក កិ.សង្រួមនូវទ្វារមានកាយទ្វារជាដើម ។ -**អានុបស្សនា-ភាវនា** កិ.ញ៉ាំងបញ្ញាជាគ្រឿងឃើញរឿយៗក្នុងកាយឲ្យចម្រើន, គុណជាតិជាគ្រឿងញ៉ាំងបញ្ញាជាហេតុឃើញតាមបញ្ញាជាគ្រឿងឃើញរឿយៗក្នុងកាយ ។ -**អារុឡ្ហ** គុ. ឡើងកាន់កាយ ។ -**អាល-សិយ** នបុំ. ភាវៈនៃបុគ្គលខ្ជិលដោយកាយ, វិ. **អលសស្ស ភាវោ** >**អាលសិយំ**, **កាយេន អាលសិយំ** > **កាយាលសិយំ** ។

**កាយពន្ធន** នបុំ. វត្ថុពន្ធន៍ចង្កេះ។

**កាយិក** គុ. [កាយ + ណិក] ប្រព្រឹត្តទៅក្នុងកាយ, វិ. **កាយេ វត្តតីតិ** >**កាយិកំ** ។ ប្រកបក្នុងកាយ, វិ. **កាយេ និយុត្តំ** >**កាយិកំ** ។ -**ចេតសិកវីរិយ** នបុំ. ព្យាយាមប្រព្រឹត្តទៅក្នុងកាយ និងប្រព្រឹត្តទៅក្នុងចិត្ត ។ -**បរិ-ឡាហ** បុំ. សេចក្ដីរោលរាលប្រព្រឹត្តទៅក្នុងកាយ, សេចក្ដីក្ដៅក្រហាយប្រព្រឹត្តទៅក្នុងកាយ ។ បុំ. អ្នកទិញ (ដូច **កយិក**) ។

**ការ** បុំ. [ករ + ណ] កុសលគឺបុគ្គលគប្បីធ្វើ, សក្ការៈគឺបុគ្គលគប្បីធ្វើ, វិ. **កាតព្វោតិ** >**ការោ** ។ បុំ. ដើមដង្កៀបក្ដាម, សក្ការ, គុក (ដូច **ពន្ធនាលយ**) ។

**ការក** បុំ., ន [ករ + ណ្វុ] អ្នកធ្វើ, វិ. **ករោតីតិ** >**ការកោ** ។ -**បុគ្គល** បុំ. បុគ្គល បុំ. អ្នកធ្វើ ។ -**សត្ត** បុំ. សត្វអ្នកធ្វើ ។ ការក ៧ មានកត្តុការកជាដើម, សព្ទនេះជាអត្ថនៃសាធនសព្ទ ។

**ការកា** ឥ. ការធ្វើ (ដូច **ក្រិយា**), ឆន្ទមានអនុដ្ឋុភជាដើម (ដូច **ឆន្ទ**) ។

**ការណ** នបុំ. [ករ + យុ] ធម្មជាតធ្វើនូវផលពោលគឺកិ.ដឹងច្បាស់ក្នុងកាលជាខាងក្រោយ (ហេតុ, ការណ៍), វិ. **ករោតិ បច្ឆា សញ្ញានសង្ខាតំ ផលន្តិ** > **ការណំ** ។ -**ភូត** គុ. ជាហេតុកើតហើយ, កើតហើយជាហេតុ ។ -**វចន** នបុំ. ជាគ្រឿងពោលនូវហេតុ, កិ.ពោលនូវហេតុ ។ -**វសិ-កតា** ឥ. ភាវៈនៃ....ជាអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ, វិ. **កា-រណស្ស វសោ** >**ការណវសោ**, **ការណវសេ វត្តតីតិ** >**កា-រណវសិកោ**, **តស្ស ភាវោ** >**ការណវសិកតា** ។ -**វសិក** គុ. អ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ។ -**ឧត្តរយុគ្គាហកថា** ឥ. វាចាជាគ្រឿងពោលគឺកិ.កាន់យកជាគូឲ្យក្រៃលែងជាងហេតុ, វាចាជាហេតុពោលគឺកិ.កាន់យកនូវគូឲ្យក្រៃលែងជាងហេតុ ។

**ការណ** នបុំ. ការសម្លាប់ (ដូច **ឃាត**), ហេតុ, ដើមកំណើតផល (ដូច **និមិត្ត**) ។

**ការណា** ឥ. វេទនាដ៏ក្លា, ការបៀតបៀន, ការធ្វើទុក្ខធ្វើបាប, ការផ្ដន្ទា (ដូច

**យាតនា**) ។

**ការណាការណ** នបុំ. [ការណ + អការណ] ហេតុនិងមិនមែនហេតុ, ហេតុគួរ និងហេតុមិនគួរ ។ -**ឋាននលក្ខណ** គុ. មានកិ.ដឹងនូវហេតុនិងមិនមែនហេតុជាលក្ខណៈ, មានកិ.ដឹងនូវហេតុគួរ និងហេតុមិនគួរជាលក្ខណៈ ។

**ការណិក** គុ. អ្នកដឹងនូវហេតុដ៏របស (ដូច **បរិក្ខក**) , នាយនិរយបាល, អ្នកធ្វើនូវការផ្តន្ទា (ដូច **និរយប**) ។

**ការណ្ឌវ** បុំ. សត្វចង្កៀលខ្យង ។

**ការយឹសុ** កិ. [ករ + ណយ + ឪ-អជ្ជ.] ញុំាង...ឲ្យធ្វើហើយ, ឲ្យធ្វើហើយ ។

**ការា** ឥ. គុកសម្រាប់ដាក់មនុស្សទោស (ដូច **ពន្ធនាគារ**) ។

**ការាបនីយ** គុ. [ករ + ណាបេ + អនីយ] គឺ...គប្បីញុំាង...ឲ្យធ្វើ, -គប្បីឲ្យធ្វើ, វិ. **ការាបេតព្វោតិ** >**ការាបនីយោ** ។

**ការាបេត្វា** អ. [ករ + ណាបេ + ត្វា] ញុំាងឲ្យធ្វើហើយ, ឲ្យធ្វើហើយ ។

**ការាបេស្សាមិ** កិ. [ករ + ណាបេ + ស្សាមិ-ភ.] នឹងញុំាង....ឲ្យធ្វើ, នឹងឲ្យធ្វើ ។

**ការិត** គុ. [ករ + ណេ + ត] គឺ...ញុំាង...ឲ្យធ្វើហើយ ។ -**ត្ត** នបុំ. ភាវៈនៃ...នោះជា...គឺ..ញុំាង...ឲ្យធ្វើហើយ។ -**បណ្ណសាលា** ឥ. បណ្ណសាលាគឺ...ញុំាង...ឲ្យធ្វើហើយ។

**ការី** បុំ. [ករ+ណី] អ្នកធ្វើ, អ្នកធ្វើដោយប្រក្រតី, អ្នកមានកិ.ធ្វើជាប្រក្រតី, វិ. **ករោតីតិ** >**ការី**, **ករោតិ សីលេនាតិ** >**ការី**, **កាតុំ សីលមស្សាតិ** >**ការី** ។

**ការុ** បុំ. អ្នកមានសិល្ប (ដូច **សិប្បិក**) ។

**ការុញ្ញតរ** គុ. [ការុញ្ញ+តរ] ភាវៈនៃករុណាជាង, មានភាវៈនៃសេចក្តីអាណិតជាង ។

**ការុញ្ញតា** ឥ. [ករុណា+ណ្យ+តា-ស.] ភាវៈនៃសេចក្តីករុណា, ភាវៈនៃសេចក្តីអាណិត, វិ. **ករុណាយ ភាវោ** >**ការុញ្ញំ**, **ការុញ្ញំ ឯវ** >**ការុញ្ញតា** ។

**ការុញ្ញវស** បុំ. [ការុញ្ញ + វស] អំណាចនៃភាវៈនៃសេចក្តីករុណា ។

**ការុញ្ញ** នបុំ. សេចក្តីករុណា, សេចក្តីអាណិត (ដូច **ទយា**) ។

**ការុណិក** បុំ. អ្នកមានសេចក្តីករុណា (ដូច **ទយាលុ**) ។

**ការេតុកាម** គុ. [ការេតុំ + កម + ណ] អ្នកចង់ដើម្បីញុំាង....ឲ្យធ្វើ ។

**ការេតុំ** អ. [ករ + ណេ + តុំ] ដើម្បីញុំាង...ឲ្យធ្វើ ។

**ការេន្ត** គុ. [ករ + ណេ + អន្ត] កាលញុំាង....ឲ្យធ្វើ ។

**ការេន្តិ** កិ. [ករ + ណេ + អន្តិ-វ] ញុំាង...ឲ្យធ្វើ ។

**ការេយ្យុំ** កិ. [ករ + ណេ + ឯយ្យុំ-ស.] គប្បីញុំាង....ឲ្យធ្វើ ។

**ការេសិ** កិ. [ករ + ណេ + ឦ-អជ្ជ., ចុះស-អា.] ញុំាង...ឲ្យធ្វើហើយ ។

**ការេស្សថ** កិ. [ករ + ណេ + ស្សថ-ភ.] នឹងញុំាង....ឲ្យធ្វើ ។

**ការេស្សំ** កិ. [ករ + ណេ + ស្សំ-ភ.] នឹងញុាំង....ឲ្យធ្វើ ។

**កាល** បុំ. [កល + ណ] (បរិច្ឆេទ) ដែលជនគប្បីរាប់ ដោយន័យថា កាលមានប្រមាណប៉ុណ្ណោះកន្លងទៅហើយដូច្នេះជាដើម ឬ (បរិច្ឆេទ) ដែលញុាំងអាយុនៃសត្វឲ្យអស់ទៅ (កាល, ពេល, សម័យ ដូច **សមយ**, សេចក្តីស្លាប់ ដូច **មច្ចុ**, **បលយ**), វិ. **ឯត្តកោ អតិក្កន្តោតិអាទិនា កលិតព្វោ សង្ខាតព្វោតិ** >**កាលោ**, **សត្តានំ អាយុំ កលយតិ ខេបេតីតិ វា** >**កាលោ** ។ -**កត** គុ. អ្នកមានកាលៈធ្វើហើយ, អ្នកមានមរណកាលធ្វើហើយ, វិ. **កាលោ កតោ យេន សោ** >**កាល-កតោ** អ្នកគឺកាលៈ (សេចក្តីស្លាប់) ធ្វើហើយ, អ្នកគឺមច្ចុឲ្យវិនាសហើយ, វិ. **កាលេន មច្ចុនា កតោ នាសិតោតិ** >**កាល-កតោ** ។ -**កតភាវ** បុំ. ភាវៈនៃ....នោះជាអ្នកមានកាលៈធ្វើហើយ, ភាវៈនៃ...នោះជាអ្នកគឺកាលៈធ្វើហើយ ។ -**កិរិយា** ឥ. កិ.ធ្វើនូវកាលៈ, កិ.ធ្វើនូវមរណកាល ។ -**អច្ចយ** បុំ. សម័យជាទីប្រព្រឹត្តកន្លងទៅនៃកាល, វិ. **អច្ចេន្តិ ឯត្ថាតិ** >**អច្ចយោ**, **កាលស្ស អច្ចយោ** >**កាលច្ចយោ** ។ -**ប្បវេទន** នបុំ. កិ.ញុាំង....ឲ្យដឹងច្បាស់នូវកាល, កិ.សម្តែងនូវកាល ។ -**ភេទ** បុំ. សេចក្តីផ្សេងនៃកាល ។

**កាលកិរិយា** ឥ. សេចក្តីស្លាប់ (ដូច **មរណ**) ។

**កាលក្ខន្ធ** បុំ. ដើមទន្លាប់ (ដូច **តិន្ទុក**) ។

**កាលវិសេស** បុំ. កាលដ៏វិសេសគឺ ១ ខណៈ ចំនួនផ្ទាត់ម្រាមដៃ ១០ ដង, សព្ទនេះជាអត្ថនៃ **ខណ** សព្ទ ។

**កាលវេល្ល** បុំ. ម្រះ (ដូច **សុសវី**) ។

**កាលស្សេវ** និ. អំពីកាលមែនពិត, អំពីព្រឹក, អំពីព្រលឹម ។

**កាលា** ឥ. វល្លិប្រេងខ្មៅ (ដូច **សាមា**) ។

**កាលានុកាល** បុំ. [កាល + អនុកាល] កាលប្រព្រឹត្តតាមនូវកាល, កាលដ៏សមគួរដល់កាល, មួយដងមួយកាល ។

**កាលិ** អា.ឥ. ម្នាលទាសីឈ្មោះកាលី ។ ប្រើជា **កាឡិ** ក៏មាន ។

**កាលិង្គរដ្ឋ** នបុំ. [កាលិង្គ + រដ្ឋ] ដែនឈ្មោះកាលិង្គៈ ។

**កាលិង្គ** បុំ. ឈ្មោះដែន ឬ ជនបទមួយ ។

**កាលីទាសី** ឥ. [កាលី + ទាសី] ទាសីឈ្មោះកាលី, ខ្ញុំស្រីឈ្មោះកាលី ។

**កាលីយក្ខិនី** ឥ. [កាលី + យក្ខិនី] យក្ខិនីឈ្មោះកាលី, មេយក្សឈ្មោះកាលី ។

**កាវេរី** ឥ. ឈ្មោះស្ទឹងមួយ ។

**កាស** បុំ. [កាស + អ] កិ.ក្អក, រោគក្អក, ស្មៅត្រែង (ដូច **បោដគល**, **បោ-ដកិល**) ។

**កាសមទ្ទ** បុំ. ម្រះព្រៅ ។

**កាសាយ** នបុំ. [កសាយ + ណ] សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់ (សំពត់កាសាយៈ ដូច **អរហទ្ធជ**), វិ. **កសាយេន រត្តំ** >**កាសាយំ** ។ -**និវត្ថ** គុ. (<និ + វស + ត) អ្នកស្លៀកនូវសំពត់កាសាយៈ, អ្នកស្លៀកនូវសំពត់ដែលជនជ្រលក់ហើយដោយទឹកចត់, វិ. **កាសាយំ និវាសេតីតិ** >**កាសាយនិវត្ថោ** ។ អ្នកមានសំពត់កាសាយៈស្លៀកហើយ, វិ. **កាសាយំ និវត្ថំ យេន សោ** >**កាសាយនិវត្ថោ** ។ -**ប្បដិច្ឆន្ន** គុ. គឺសំពត់កាសាយៈបិទបាំងហើយ មានសំពត់កា-សាយៈបិទបាំងហើយ, ដ៏បិទបាំងហើយដោយសំពត់កាសាយៈ ។ -**វត្ថនិវត្ថ** គុ. ស្លៀកនូវសំពត់កាសាយៈ, ស្លៀកនូវសំពត់ដែលជ្រលក់ហើយដោយទឹកចត់។ -**វត្ថ** នបុំ. សំពត់កាសាយៈ, សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់។

**កាសាវ** នបុំ. [កសាវ + ណ] សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់, (ចីវរ (ដូច **កាសាយ**) សំពត់កាសាវៈ), វិ. **កសាវេន រត្តំ** >**កាសាវំ** ។ -**កណ្ឋ** គុ. មានសំពត់កាសាវៈព្ធដ៏ក, មានកព័ន្ធព័ទ្ធហើយដោយសំពត់កាសាវៈ ។ -**កោដិ** ឥ. ទីបំផុតនៃសំពត់កាសាវៈ, ចុងនៃសំពត់កាសាវៈ ។ -**ធរ** គុ. អ្នកទ្រទ្រង់នូវសំពត់កាសាវៈ, វិ. **កាសាវំ ធារេតីតិ** >**កាសាវធរោ** ។

**កាសិ** បុំ. ឈ្មោះដែន ឬ ជនបទមួយ ។

**កាសិក** គុ. [កាសី + ណិក] អ្នកនៅក្នុងដែនកាសី, កើតក្នុងដែនកាសី ។ -**កោសលរដ្ឋ** នបុំ. ដែនឈ្មោះកាសីនិងដែនឈ្មោះកោសល ។ -**គ្គាមក** បុំ. ស្រុកតូចឈ្មោះកាសិកៈ ឬស្រុកតូចតាំងនៅក្នុងដែនកាសី ។ -**គ្គាមក** បុំ. ស្រុកឈ្មោះកាសិកៈ ឬ ស្រុកតាំងនៅក្នុងដែនកាសី ។ -**វត្ថ** នបុំ. សំពត់ដែលកើតក្នុងដែនកាសី, សំពត់ដែលជននាំមកអំពីដែនកាសី ។ -**រាជ** បុំ. ស្ដេចក្នុងដែនកាសី ។ -**បុរ** នបុំ. បុរីនៃស្ដេចនៅក្នុងដែនកាសី, ក្រុងឈ្មោះកាសី ។

**កាសិត្វា** អ. [កាស + ឥ-អា. + ត្វា] ក្អកហើយ ។

**កាសុ** ឥ. រណ្ដៅ (ដូច **អាវាដ**), ហ្វូង, ប្រជុំ, ពួក, គំនរ (ដូច **ចយ**) ។

**កាស្មីរី** ឥ. ដើមចម្បក់ (ដូច **សេបណ្ណិ**) ។

**កាសិ** ធា. ១-**សទ្ទកុច្ឆាយំ កាសតិ ឧក្កាសតិ**"ក្អក, គ្រហែម" ភូ. ។ **កាស** បុំ. "រោគក្អក" អា. **កាសំ សាសំ ទរំ ពល្យំ ខីណមេធោ និគច្ឆតិ** -ស.។ **កាសមទ្ទ** បុំ. ញាំញី រោគក្អក, ឈ្មោះឈើម្យ៉ាង បុរាណថាដើមម្រះព្រៅ ។

២- **ទិត្តិយំ (បាកដវិជានតាយំ វា) កាសតិ បកាសតិ បកាសកោ បកាសិតុំ បកាសេតុំ កាសនា សង្កាសនា បកាសនា** "ភ្លឺស្វាង,

ប្រាកដ, ប្រកាស, ជាក់ស្តែង, ឲ្យដឹងច្បាស់" ភូ. ។ ការិត. **បកាសេតិ** ។ អា. **ទូរេ សន្តោ បកាសេន្តិ**"មនុស្សល្អ ទ. រមែងប្រាកដក្នុងទីឆ្ងាយ" ស. ។ **កាសុ** ឥ. "រណ្តៅ, អណ្តូង" =**អាវាដោ**, កង, ពួក, គំនរ =**រាសិ**, អា. **កាសុំ ខនសិ សារថិ**"នៃនាយសារថី អ្នកជីករណ្តៅធ្វើអ្វី?" ។ **អង្គារកាសុំ អបរេ ផុនន្តិ**"ពួកជនដទៃ រមែងព្រាចបាចគំនររងើកភ្លើង" ។ **បកាស** បុំ. "ការប្រកាស, បំភ្លឺទូទៅ, ការឲ្យដឹងទូទៅ" (ប+កាស+អ) ។

**កាហសិ** កិ. [ករ + អ + ស្សសិ-ភ., ផ្លាស់ក>កាហ, លុបស្សទុកតែសិ ] នឹងធ្វើ ។

**កាហាមិ** កិ. [ករ + អ + ស្សាមិ-ភ.] នឹងធ្វើ (រូបសិទ្ធិដូច **កាហសិ**) ។

**កាឡ** គុ. [កិរ + ណ] សភាវៈបោះបង់នូវពណ៌ស ( ខ្មៅ, កាឡបក្ខ, រនោច, ពណ៌ខ្មៅ ដូច **កណ្ហ**), វិ. **កិរតិ សុក្កន្តិ** >**កាលោ**, **កាលោ ឯវ** > **កាឡោ** ។ - **កណ្ណិ** អា.ឥ. ម្នាលមេកាឡកណ្ណី(ម្នាលស្រីអ្នកធ្វើនូវទីនៅនៃខ្លួនឲ្យទៅជាទីមានសម្បុរខ្មៅ, ម្នាលមេចង្រៃ) ។ -**កណ្ណិក** គុ. ជាកាឡកណ្ណី ។ -**ចម្ម** នបុំ. ស្បែកខ្មៅ, ស្បែកមានពណ៌ខ្មៅ ។ -**ត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះកាឡៈ ។ -**វណ្ណ** គុ. មានពណ៌ខ្មៅ ។ -**សិលាបទេស** បុំ. ប្រទេសឈ្មោះកាឡសិលា ។ -**សិលា** អ.ន. ប្រទេសឈ្មោះកាឡសិលា, ភូមិឈ្មោះកាឡសិលា ។

**កាឡក** គុ [កាឡ + ណក ឬក-ស.] (វត្ថុ)មានពណ៌ខ្មៅ, (ធម៌)មានពណ៌ខ្មៅ ។

**កាឡកណ្ឌក** បុំ. ក្អែកទឹក, កុកដំបងគ្រញូង (ដូច **ទាត្យូហ**) ។

**កាឡកណ្ណី** .បុំ. មនុស្សកាឡកណ្ណី, មនុស្សធ្វើនិស្ស័យនៃខ្លួនឲ្យដូចជាវត្ថុមានពណ៌ខ្មៅ (ដូច **អលក្ខី**) ។

**កាឡកា** ឥ. សត្វកង្កែន, កំប្រុក (ដូច **កលន្ទក**) ។

**កាឡកូដ** បុំ. ភ្នំកាឡកូដ, ពិសពស់ ដែលមានសម្បុរខ្មៅមានកម្លាំងខ្លាំងដូចញញួរដែក ។

**កាឡតិបុ** នបុំ. សំណខ្មៅ, សំណភក់ (ដូច **សីស**) ។

**កាឡលោណ** នបុំ. អម្បិលខ្មៅ ។

**កាឡសីហ** បុំ. ខ្លាឃ្មុំ (ដូច **អច្ឆ**) ។

**កាឡសុត្ត** បុំ. ឈ្មោះមហានរកមួយ ។

**កាឡហំស** បុំ. ក្អែកទឹក (ដូច **កាទម្ព**)។

**កាឡាគរុ** បុំ. ក្រស្នាខ្មៅ ។

**កាឡានុសារី** បុំ. ភ្លាំពាក់ (ដូច **កាឡីយ**) ។

**កាឡាយមត្ត** គុ. [កាឡាយ+មត្ត] មានសណ្តែកខ្មៅជាប្រមាណ, ប៉ុនសណ្តែកខ្មៅ ។

**កាឡាយស** នបុំ. ដែក (ដូច **អយ**) ។

**កាឡាវក** បុំ. ឈ្មោះត្រកូលដំរីមួយ ។

**កាឡី** ឥ. [កាឡ + ឦ] មានពណ៌ខ្មៅ, ស្រីមានសម្បុរខ្មៅ ។

**កាឡីយ** នបុំ. ក្លាំពាក់ (ដូច **កាឡានុសារី**) ។

**កាឡុទាយិត្ថេរ** បុំ. [កាឡុទាយិ + ថេរ] ព្រះថេរៈឈ្មោះកាឡុទាយិ ។

**កិកិ** អ.ន. ឈ្មោះកិកិ ។

**កិច្ច** នបុំ. [ករ + រិច្ច] កម្មគឺបុគ្គលគប្បីធ្វើ (កិច្ចដូច **ករណីយំ**), វិ. **កាតព្វន្តិ** > **កិច្ចំ** ។ -**បរិយោសាន** នបុំ. កាលជាទីបំផុតចុះជុំវិញនៃកិច្ច, កាលជាទីចប់នៃកិច្ច, កាលជាទីស្រេចហើយនៃកិច្ច ។

**កិច្ចាកិច្ច** នបុំ. [កិច្ច + អកិច្ច] កិច្ច និងមិនមែនកិច្ច (<អ = ប្រែថា «មិនមែន»), កិច្ច និងកិច្ចដ៏ចម្រើន (អ=ប្រែថា «ចម្រើន»), កិច្ចតូច និងកិច្ចធំ (អ=ប្រែថា «ធំ») ។

**កិច្ឆ** គុ. [កិរ+ឆ] ធម្មជាតបោះបង់នូវសេចក្តីសុខ (ក្រ, លំបាក, ត្រដាបត្រដួស ដូច **កសិរ** ), វិ. **កិរតិ សុខន្តិ** >**កិច្ឆំ** ។ (កិច្ឆ <កិត + ឆ ) ធម្មជាតជាគ្រឿងលំបាក, វិ. **កិច្ឆតិ តាយ កិលមតីតិ** >**កិច្ឆា** ។ -**ជីវក** គុ. អ្នកមានកិ.រស់នៅដោយលំបាក, វិ. **ជីវនំ** >**ជីវោ**, **កិច្ឆេន ជីវោ** >**កិច្ឆជីវោ**, **កិច្ឆជីវោ យស្ស អត្ថីតិ** >**កិច្ឆជីវី**, **កិច្ឆជីវី ឯវ** >**កិច្ឆជីវិកោ** ។

**កិច្ឆាធិគត** គុ. [កិច្ឆ + អធិគត] គឺ....បានហើយដោយលំបាក, -ដោយកម្រ ។

**កិញ្ចន** នបុំ. [កិច + យុ, ចុះនិ-អា.] កិលេសជាតជាគ្រឿងកង្វល់, កិលេសជាតជាគ្រឿងញាំញី, វិ. **កិញ្ចតិ ឯតេនាតិ** >**កិញ្ចនំ** ។ សេចក្តីខ្វល់, កង្វល់, វិ. **កិញ្ចិយតេតិ** >**កិញ្ចនំ** ។

**កិញ្ចាបិ** និ. [កឹ + ច + អបិ] ប្រាកដមែនហើយ, ក៏មែនហើយ, ក៏ពិតមែនហើយ, សូម្បីតិចតួច ។

**កិញ្ចិ** វិ.ស. [កឹ + ចិ] តិចតួច, អ្វីៗ, នីមួយៗ.... ។ អប្បត្ថវាចក និបាតប្រាប់អត្ថ
អ. គឺតិច ប្រែថា តិចតួច, **ឦសំ**, **មនំ** ក៏ជាអប្បត្ថវាចក ដែរ ។

**កិញ្ចិ** ធា. **មទ្ទនេ កិញ្ចេតិ កិញ្ចយតិ** "ញាំញី, កម្ចាត់បង់" ចុ. **កិញ្ចនំ** នបុំ. "សេចក្តីខ្វល់, អំពល់, រវល់ "ញាំញីសត្វ =**បលិពោធោ** វិ. **កិញ្ចេតិ សត្តេ មទ្ទតីតិ កិញ្ចនំ** -**ស**.។ **អកិញ្ចន** គុ. "អ្នកឥតកង្វល់, ឥតរវល់, អ្នកក្រ" ។

**កិញ្ជក្ខ** បុំ. កេសរផ្កា (ដូច **កេសរ**) ។

**កិជាគិរិ** បុំ. ភ្នំឈ្មោះកិជា ។

**កិដ្ឋ** នបុំ. [កស + ឋ] ធម្មជាតដែលកើតអំពីកិ.ភ្ជួរ (សំទូង, សំណាប ដូច **សស្ស**), វិ. **កសិតោ សម្ភូតំ** >**កិដ្ឋំ** ។ - **ខាទកគោណោ** បុំ. គោទំពាស៊ីនូវសំទូង ។ -**សម្ពាធ** គុ. ដ៏ចង្អៀតដោយសំទូង, ដែលតាន់តាប់ដោយសំទូង, -ដោយសំណាប ។

**កិជ** ធា. ១-**គតិយំ កិជតិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។
២- **ពន្ធេ កិជេតិ កិជយតិ**"ចង, រឹតរួត" ចុ. ។ **កីជ** បុំ. "កណ្តាប, កំពោង, កន្លាត"។

**កិណ្ណ** នបុំ. ពូជនៃសុរា (ដូច **មទិរាពីជ**) ។

**កិតវ** បុំ. [កិត + អវ] មេកឈើ, គ្រឿងបិទបាំង ។ អ្នកលេង, អ្នកលេងបាសកា (ដូច **ជូតការ**) ។

**កិត្តក** គុ. [កិត្ត + ក] មានប្រមាណប៉ុន្មាន, ប៉ុន្មាន, វិ. **កិត្តានិ បរិមាណានិ ឯតស្សាតិ** >**កិត្តកំ** ។

**កិត្តាវតា** និ. ដោយហេតុមានប្រមាណប៉ុន្មាន, ដោយហេតុមានប៉ុន្មាន ។ បរិច្ឆេទត្ថវាចក និបាតប្រាប់អត្ថគឺកំណត់ ប្រែថា មានកំណត់ប៉ុន្មាន, **យាវតា**, **តាវតា**, **យាវ**, **តាវ**, **ឯត្តាវតា**, **កីវ** ក៏ជាបរិច្ឆេទត្ថវាចក ដែរ ។

**កិត្តិ** ឥ. [កិត + តិ] វាចាជាគ្រឿងសម្តែង (សេចក្តីសរសើរ, កិត្តិគុណ,កេរ្តិ៍ឈ្មោះ ដូច **សិលោកោ**) , វិ. **កិតេតិ ឯតាយាតិ** >**កិត្តិ** ។ -**វណ្ណ-គុណានសទ្ធាតំ** គុ. ពោលគឺកិរិយាពោលនូវគុណគឺបុគ្គលគប្បីពណ៌នាគឺសរសើរ, ពោលគឺកិរិយាពោលនូវកេរ្តិ៍ឈ្មោះនិងសេចក្តីសរសើរ ។

**កិត្តិម** គុ. របស់ប្លម, របស់កាឡៃ, របស់ក្លែងធ្វើ ។

**កិត្តេន្ត** គុ. [កិត + ណេ + អន្ត] កាលសម្តែង ។

**កិត្ត** ធា. **សំសទ្ទនេ កិត្តេតិ កិត្តយតិ កិត្តនា បរិកិត្តនា**"សន្ទនា, ប្រៀបធៀប, សម្តែង, ថ្លែង, សរសើរ" ចុ. ។ កម្ម. **កិត្តយតិ** ។ **កិត្តិ** ឥ. "កេរ្តិ៍, ពាក្យសរសើរ, ពាក្យកោត" ។ **កិត្តិសទ្ទ** បុំ. កិត្តិសព្ទ, សំឡេងសរសើរ, សំឡេងសរសើរគុណ (កិត្ត+ឥ) ។

**កិត** ធា. ១-**និវាសេ កេតតិ**"នៅ, អាស្រ័យ, ស្នាក់" ភូ. ។ **និកេត** បុំ. "ទីនៅ, ទីអាស្រ័យ, ស្រុក" អា. **និកេតំ បាវិសិ**"គេបានចូលទៅហើយកាន់លំនៅ" ។ **អាមោទមានោ គច្ឆតិ សន្និកេតំ**"គេកំពុងតែសប្បាយចិត្ត ដើរទៅកាន់ស្រុករបស់ខ្លួន" -ស. ។ **សាកេត** នបុំ. ឈ្មោះក្រុងសាកេត (ក្នុងពុទ្ធកាល) ។
២-**រោគាបនយនេ តិកិច្ឆតិ ចិកិច្ឆតិ ចិកិច្ឆា តិកិច្ឆា** "បំបាត់រោគ, រក្សា, ព្យាបាល" ភូ. (កិ-កិត+ឆ) ។ **ចិកិច្ឆកោ តិកិច្ឆកោ** បុំ. "ពេទ្យ" អ្នកព្យាបាល ។ **វិចិកិច្ឆតិ វិចិកិច្ឆា** សង្ស័យ, ឆ្ងល់, ភូ. (វិ+កិ.កិត+ឆ) ។
៣- **ញាណេ កេតតិ កេតកោ កេតនំ សង្កេតោ**"ដឹង, ស្គាល់, កំណត់, ចំណាំ, សង្កេត" ភូ. ។

**កិន្តិ** និ. [កឹ + ឥតិ] ថាអ្វី, ថាដូចម្តេច ។

**កិន្នរ** បុំ. កិន្នរ (ដូច **កឹបុរិស**) ។

**កិបិល្លិក** បុំ. ស្រមោចក្រហម(ស្រមោចភ្លើង, អង្ក្រង) ។

**កិប** ធា. **ទុព្វល្យេ កិបេតិ កិបយតិ** "ទុព៌ល, អន់, ទ្រម" ចុ.។

**កិព្វិស** គុ បាប, ទោសកំហុស (ដូច **អាគុ**, **អបុញ្ញ**) ។

**កិមង្គំ** និ. [កឹ + អង្គំ] នឹងបាច់ពោលទៅថ្វី,ចាំបាច់និយាយទៅថ្វី(ពាក្យមានអ្វីជាហេតុ) ។

**កិមត្ថ** បុំ. [កឹ + អត្ថ] ប្រយោជន៍អ្វី, គុ. មានអ្វីជាប្រយោជន៍ ។

**កិមត្ថំ** និ. ដើម្បីអ្វី ។

**កិមិ** បុំ. សត្វដង្កូវ (ដូច **បុលវ**) ។

**កិមិជ** នបុំ. សំពត់សូត្រ (ដូច **កោសេយ្យ**) ។

**កិមិល** អ.ន. សក្យៈឈ្មោះកិមិលៈ ។

**កិមុ** និ. **វិកប្បត្ថវាចក** និបាតប្រាប់អត្ថគឺត្រិះរិះ ប្រែថា ដូចម្តេចអេះ, ដូចម្តេចហ្ន៎, ឬ, ចូរមើលអហោសព្ទខាងដើម ។

**កិមុត** និ. **អតិសយត្ថវាចក** និបាតប្រាប់អត្ថគឺក្រៃលែង, ក្រៃពេក, **ពលវំ**, **សុដ្ឋុ**, **អតីវ**, **សុ**, **អតិ** ក៏ជា**អតិសយត្ថវាចក** ដែរ។

**កិមុតោ** និ. **វិកប្បត្ថវាចក** និបាតប្រាប់អត្ថគឺត្រិះរិះ ប្រែថា ឬហ្ន៎, **អហោ**, **កឹ**, **កិមុ**, **ឧទាហុ**, **ឧទ** ក៏ជាវិកប្បត្ថវាចក ដែរ ។

**កិរ** និ. និបាតប្រព្រឹត្តទៅក្នុងអត្ថគឺ **អនុស្សវ** ការឮតាមគ្នា ប្រែថា បានឮថា ឧ. **អស្សោសិ ខោ ចិត្តោ គហបតិ "និគណ្ឋោ កិរ នាដបុត្តោ មច្ឆិកាសណ្ឌំ អនុប្បត្តោតិ"គហបតិ** រីគហបតី **ចិត្តោ** ឈ្មោះចិត្ត **អស្សោសិ ខោ** បានឮហើយមែនពិត **ឥតិ** ដូច្នេះ **កិរ** បានឮថា **និគណ្ឋោ** រីនិគ្រន្ថ **នាដបុត្តោ** ឈ្មោះនាដបុត្រ **អនុប្បត្តោ** មកដល់ហើយ **មច្ឆិកាសណ្ឌំ** នូវប្រទេសឈ្មោះមច្ឆិកាសណ្ឌ, **អរុចិ** សេចក្តីមិនគាប់ចិត្ត ឧ.

**ខណាវត្ថុបរិត្តត្តា អាបាថំ ន វជន្តិ យេ**
**តេ ធម្មារម្មណា នាម យេសំ រូបាទយោកិរ**

**យេ ធម្មា** រីធម៌ទាំងឡាយឯណា **រូបាទយោកិរ** សូម្បីមានរូបជាដើម **ន វជន្តិ** មិនទៅ **អាបាថំ** កាន់គន្លង **យេសំ ជនានំ** នៃជនទាំងឡាយឯណា **តេ ធម្មា** រីធម៌ទាំងឡាយនោះ **ធម្មារម្មណា នាម** ឈ្មោះថាធម្មារម្មណ៍ **តេសំ ជនានំ** នៃជនទាំងឡាយនោះ **ខណាវត្ថុបរិត្តត្តា** ព្រោះភាវៈនៃធម៌ទាំងឡាយនោះ មានខណ និងវត្ថុដ៏តិច (ប្រែគាថានេះមិនទាន់ប្រាកដ ព្រោះមិនទាន់ឃើញអដ្ឋកថា) ។

**កិរណោ** ប៉ុ. រស្មី (ដូច **មយូខ**) ។

**កិរាតោ** ប៉ុ. មនុស្សព្រៃ (ដូច **មិលក្ខជាតិយ**) ។

**កិរិយា** ឥ. [ករ + រីយ] ធម្មជាតិដែលជនគប្បីធ្វើ, វិ. **កាតព្វាតិ** >**កិរិយា** ។ នប៉ុ. កិ.ធ្វើ, ដំណើរធ្វើ, វិ. **ករិយតេតិ** >**កិរិយំ** ។

**កិរិយវាទ** ប៉ុ. [កិរិយ+វាទ] អ្នកពោលថារីកម្មគឺបុគ្គលធ្វើហើយឈ្មោះថាគឺបុគ្គលធ្វើ, អ្នកមានលទ្ធិជាគ្រឿងពោលថា កម្មឈ្មោះថាគឺបុគ្គលធ្វើ ។

**កិរិយ** នប៉ុ. ការងារ, ការធ្វើ, អំពើ (ដូច **កម្ម**) ។

**កិរីដ** ប៉ុ. មង្កុដ (ដូច **មកុដ**) ។

**កិលញ្ជ** ប៉ុ. [កិល + ជន + ក្វិ] កន្ទេល, កន្ទេលផែង (ដូច **កដ**) ។

**កិលន្ត** គុ. [កិលម + ត] លំបាកហើយ, នឿយហត់ហើយ ។ -**កាយ** គុ. មានកាយលំបាកហើយ, មានកាយនឿយហត់ហើយ, វិ. **កិលន្តោ កាយោ យស្ស សោ** >**កិលន្តកាយោ** ។ -**ភាវ** ប៉ុ. ភាវៈនៃ...ជាអ្នកលំបាកហើយ ។ -**សរីរ** គុ. អ្នកមានសរីរៈហត់នឿយហើយ ។ -**រូប** គុ. មានរូបលំបាកហើយ ។ -**ឥន្ទ្រិយ** គុ. មានឥន្ទ្រិយលំបាកហើយ ។

**កិលមថ** កិ. [កិលម + អ + ថ] លំបាក, នឿយ។ ប៉ុ.សេចក្ដីលំបាក, សេចក្ដីនឿយ(ដូច**កិលមន**), វិ. **កិលមនំ** >**កិលមថោ** ។

**កិលមន** នប៉ុ. [កិលម + យុ] សេចក្ដីលំបាក (ដូច **កិលមថ**), វិ. **កិលមិយតេតិ** > **កិលមនំ** ។ -**កិច្ច** នប៉ុ. កិច្ចគឺសេចក្ដីលំបាក, កិច្ចដោយសេចក្ដីលំបាក ។ -**ភាវ** ប៉ុ. ភាវៈនៃសេចក្ដីលំបាក, ភាវៈគឺសេចក្ដីលំបាក ។

**កិលមន្ត** គុ. [កិលម + អ + អន្ត] កាលលំបាក, កាលនឿយហត់ ។

**កិលមន្តិ** កិ. [កិលម + អ + អន្តិ-វ.] លំបាក, នឿយហត់ ។

**កិលមិស្សថ** កិ. [កិលម + អ + ឥ-អា. + ស្សថ-ភ.] នឹងលំបាក, នឹងនឿយហត់ ។

**កិលមេន្តិ** កិ. [កិលម + ណេ + អន្តិ-វ.] ញុំាង....ឲ្យលំបាក,..... ។

**កិលិដ្ឋ** គុ. [កិលិស + ត] សៅហ្មងហើយ, កខ្វក់ហើយ ។ -**កម្ម** នប៉ុ. កម្មដ៏សៅហ្មង, អំពើដ៏សៅហ្មង ។ -**គត្ត** គុ. មានខ្លួនសៅហ្មងហើយ ។ -**ករ** គុ. ជាអ្នកសៅហ្មង, ជាអ្នកគឺ....ឲ្យសៅហ្មងជាង ។ -**និវាសនបារុបន** គុ. មានសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្ដប់សៅហ្មងហើយ, មានសំពត់សម្រាប់ស្លៀកនិងសំពត់សម្រាប់ដណ្ដប់គឺធូលីឲ្យសៅហ្មងហើយ ។ -**វត្ថ** នប៉ុ. សំពត់សៅហ្មងហើយ, សំពត់គឺធូលីឲ្យសៅហ្មងហើយ ។

**កិលិដ្ឋ** គុ. ពាក្យខុសដើមខុសចុង (ដូច **សំកុល**) ។

**កិលិន្នបាយាស** ប៉ុ. [កិលិន្ន + បាយាស] បាយបាយាសដ៏ជ្រាយ, បាយាសដ៏ជ្រាយ (**កិលិន្ន** <កិលិទ + ត, ត>ឥន្ន ) ។

**កិលិន្ន** គុ. ទទឹក, សើម, ជ្រាយ (ដូច **អល្ល**) ។

**កិលិស្សតិ** កិ. [កិលិស + យ + តិ-វ.] សៅហ្មង ។

**កិលិស្សេយ្យ** កិ. [កិលិស + យ + ឯយ្យ-ស.] គប្បីសៅហ្មង, គប្បីឲ្យសៅហ្មង ។

**កិលិសិ** ធា. ១- **ឧបតាបេ កិលិស្សតិ សំកិលិស្សតិ ក្លិស្សតិ សង្កិលេសោ, កិលិដ្ឋោ កិលិដ្ឋិ**"ដុត, កម្តៅ, ធ្វើឲ្យក្តៅ, បៀតបៀន" ទិ. ។ **កិលេសោ** បុំ. "កិលេស" បៀតបៀនមានន័យ ៣ យ៉ាង៖
១/ កិលេស មានរាគៈជាដើម ដូចបាលីថា **រាគាទយោ កិលេសា** ។
២/ សេចក្តីទុក្ខ, លំបាកដូចបាលីថា **ឥទញ្ច បច្ចយំ លទ្ធា បុព្វេ កិលេសមត្តនោ**
៣/ សេចក្តីសៅហ្មង, ក្អែល, មន្ទិល = **មលិនតា** ដូចបាលីថា **កិលិដ្ឋវត្ថំ បរិទហតិ ។ ចិត្តេន សង្កិលិដ្ឋេន សង្កិលិស្សន្តិ មានវា**. ស.។
២- **ពាធនេ កិលិសតិ កិលេសោ**"បៀតបៀន" ភូ. ។

**កិលេស** បុំ. [កិលិស + ណ] ធម៌ជាគ្រឿងសៅហ្មង (កិលេស), វិ. **កិលិស្សន្តិ តេហីតិ> កិលេសា** ។ -**កាម** បុំ. កិលេសកាម, សេចក្តីប្រាថ្នាដោយអំណាចនៃកិលេស។ -**ចោរ** បុំ. ចោរគឺកិលេស ។ -**ជយ** បុំ. កិ.ឈ្នះនូវកិលេស ។ -**ទរ** បុំ. សេចក្តីក្រវល់ក្រវាយគឺកិលេស, សេចក្តីក្រវល់ក្រវាយដោយអំណាចនៃកិលេស ។ -**ទុគ្គ** គុ. ទីដែលបុគ្គលទៅបានដោយលំបាកគឺកិលេស (ទុគ្គ <ទុ + គម + វ, វិ. **ទុក្ខេន គមិយតេតិ >ទុគ្គំ**) ។ - **និព្វាន** នបុំ. កិលេសនិព្វាន, កិ. រលត់នៃកិលេស ។ -**បរិនិព្វាន** នបុំ. កិលេសបរិនិព្វាន, កិ.រលត់ជុំវិញនៃកិលេស, កិ.រលត់ស្និទ្ធនៃកិលេស ។ -**ពន្ធ** នបុំ. វត្ថុជាគ្រឿងចងគឺកិលេស, ចំណងគឺកិលេស ។ -**ពន្ធនាភាវ** បុំ. កិ.មិនមាននៃវត្ថុជាគ្រឿងចងគឺកិលេស, កិ.មិនមាននៃចំណងគឺកិលេស (ពន្ធន + អភាវ) ។ -**ភយ** នបុំ. ភ័យគឺកិលេស, ភ័យកើតអំពីកិលេស ។ -**មយ** គុ. ដែលកើតអំពីកិលេស ។ -**មល** នបុំ. មន្ទិលគឺកិលេស ។ -**មារសង្ខាត** គុ. គឺបណ្ឌិតពោលថាមារគឺកិលេស, ពោលគឺមារគឺកិលេស, ពោលថាមារគឺកិលេស ។ -**មារ** បុំ. មារគឺកិលេស ។ -**រតិ** ឥ. សេចក្តីត្រេកអរក្នុងកិលេស, សេចក្តីត្រេកអរដោយអំណាចនៃកិលេស ។ -**វដ្ដ** នបុំ. វដ្តៈគឺកិលេស ។ -**វន** នបុំ. ព្រៃគឺកិលេស, កិលេសដូចជាព្រៃ ។ -**វនថ** គុ. ដើមឈើតាំងនៅក្នុងព្រៃគឺកិលេស ។ -**វូបសមននិព្វានរតិ** ឥ. សេចក្តីត្រេកអរក្នុងព្រះនិព្វានជាទីញ៉ាំងកិលេសឲ្យចូលទៅរម្ងាប់, សេចក្តីត្រេកអរក្នុងនិព្វានជាទីចូលទៅរម្ងាប់នូវកិលេស ។ -**សង្ខណិក** គុ. ដែលច្រឡូកច្រឡំដោយកិលេស ។ -**អាតុរ** គុ. អ្នកក្តៅក្រហាយព្រោះ

កិលេស, អ្នកក្រហល់ក្រហាយព្រោះកិលេស, អ្នករសាប់រសល់ព្រោះកិលេស ។ -**អាទិមលវិរហិត** គុ. ដែលប្រាសហើយចាកមន្ទិលមានកិលេសជាដើម, ដែលវៀរហើយចាកមន្ទិលមានកិលេសជាដើម ។ -**ឧបសម** បុំ. ជាទីចូលទៅរម្ងាប់នូវកិលេស, ជាទីស្ងប់នៃកិលេស ។

**កិលេសេតិ** កិ. [កិលិស + ណេ + តិ-វ.] ញុំាង.....ឲ្យសៅហ្មង ។

**កិលេសោឃ** បុំ. [កិលេស + ឱឃ] អន្លង់គឺកិលេស, ធមិដូចជាអន្លង់គឺកិលេស, កិលេសដូចជាអន្លង់ ។

**កិលោត** ធា. **អទ្ទភាវេ** (**តិន្តភាវេ**) **កិលោតតិ បកិលោតតិ** "ទទឹក" ភូ. ការិត. **កិលោតេតិ បកិលោតយតិ** អា. **ឧណ្ហោទកស្មឹ បកិលោតយិត្វា** "ឲ្យទទឹកក្នុងទឹកក្ដៅ (ជ្រលក់ឬជ្រមុជក្នុងទឹកក្ដៅ)" -ស. ។

**កិវិ** ធា. **ហឹសាយំ កិវុណាតិ** "បៀតបៀន" សុ. ។

**កិស** គុ. [កិស + អ] ស្គម, តូច, តិច, ល្អិត, ស្ដើង, (ដូច **តនុ**) ។ -**សរីរតា** ឥ. ភាវៈនៃ.....នោះជាអ្នកមានសរីរៈស្គម, វិ. **កិសំ សរីរំ យស្ស សោ** > **កិសសរីរោ**, **តស្ស ភាវោ** >**កិសសរីរតា** ។

**កិសលយ** នបុំ. ត្រួយឈើ, ថ្នាំង (ដូច **បល្លវ**) ។

**កិសាគោតមី** អ.ន. កុមារិកាឈ្មោះកិសាគោតមី ។ -**វត្ថុ** នបុំ. រឿងនៃកុមារិកាឈ្មោះកិសាគោតមី

**កិសោរ** នបុំ. កូនសេះ (ដូច **ហយបោតក**) ។

**កិស្មិញ្ចិបិ** វិ.ស.អ. [កឹ + ស្មឹ + ចិ + បិ] សូម្បីអ្វីៗ, សូម្បីតិចតួច,.... ។

**កី** ធា. ១-**ទព្វវិនិមយេ កីណាតិ វិក្កីណាតិ ឧបក្កីណាតិ កេតុំ កីណិតុំ វិក្កេតុំ វិក្កីណិតុំ កីណិត្វា កយោ វិក្កយោ ឧបក្កីតកោ**"ប្ដូរដោយទ្រព្យ, ទិញ, លក់, ជួល" កី. ។ ធាតុនេះ ប្រែថា "ទិញ" បើមានវិបុព្វបទ ប្រែថា "លក់" បើមាន**ឧប**បុព្វបទប្រែថា "ជួល" ។ កម្ម. **កីយតិ វិក្កីយតិ ឧបក្កីយតិ** ។
២- **ហឹសាយំ កីណោតិ កីណាតិ** "បៀតបៀន" សុ. ។

**កិកី** ឥ. សត្វត្រដេវវិច (ដូច **ទិន្ទិភ**) ។

**កីចក** បុំ. ដើមឫស្សីដែលខ្យល់ពាល់ត្រូវ ឬ គ្របសង្កត់ ។

**កីជ** បុំ. [កិជ + ណ] កណ្ដាប, កន្លាត, កំពោង (**ជន្ទូវ**) ។

**កីទិស** គុ. [កឹ + ទិស + អ] ដូចជាអ្វី, ប្រាកដដូចម្ដេច, ប្រាកដយ៉ាងណាទៅ ។

**កីរ** បុំ. សត្វសេក (ដូច **សុវ**) ។

**កីលិត** គុ. ចង (ដូច **ពទ្ធ**) ។

**កីលិ** ធា. ១-**ពន្ធនេ កីលតិ កីលំ កីលេយ្យ កីល្យេ**"ចង, ទាក់" ភូ. ។ **កីលំ** នបុំ. "ចំណង" ។ **កីលេយ្យ កីល្យេ**"គប្បីចង់, ទាក់" ឧ. **សុតេន**

**វា សុតំ កីឡេ្យ**"គប្បីទាក់នូវហង្សមានឈ្មោះល្បី ដោយស្រះមានឈ្មោះល្បីដែរ" ។ **កីឡេ្យ** =**កីលេយ្យ** = **ហឹសេយ្យ** (មហាហំសជាតក) ។

២-**បីតិកីឡនេសុ កីឡតិ** "រីករាយចិត្ត, ឆ្អែតចិត្ត, លេងកីឡា" ភូ. ។

**កីវ** និ. បរិច្ឆេទត្ថវាចក និបាតប្រាប់អត្ថគឺការកំណត់ប្រែថាប៉ុន្មាន, ប៉ុនណា, ចូរមើល **ឯត្តាវតា** ខាងដើម ។

**កីវទូរ** គុ. [កីវ + ទូរ] ឆ្ងាយប៉ុន្មាន, ចម្ងាយប៉ុន្មាន, ចម្ងាយប៉ុន្មានទៅ ។

**កីឡតិ** កិ. [កីឡ + អ + តិ-វ.] លេង, ប្រឡែង,លេង ។

**កីឡន** នបុំ. [កីឡ + យុ] ជាទីលេង, កិ.លេង, វិ. **កីឡតិ ឯត្ថាតិ**>**កីឡនំ**, **កីឡិយតេតិ**> **កីឡនំ** ។ -**កាល** បុំ. កាលជាទីលេង ។ -**អត្ថ** បុំ. ប្រយោជន៍ដល់កិ.លេង, ត្រូវការដល់កិ.លេង ។

**កីឡមាន** គុ. [កីឡ + មាន] កាលលេង, កំពុងលេង ។

**កីឡា** ឥ. ល្បែង, ការលេង (ដូច **ខិឌ្ឌា**) ។

**កីឡាបយមាន** គុ. [កីឡ + ណាបយ + មាន] កាលញុំាង....ឲ្យលេង ។

**កីឡាបេតិ** កិ. [កីឡ + ណាបយ + តិ-វ.] ញុំាង....ឲ្យលេង ។

**កីឡាមណ្ឌល** នបុំ. [កីឡា + មណ្ឌល] មណ្ឌលជាទីលេង, មណ្ឌលនៃកីឡា ។

**កីឡិត** គុ. [កីឡ + ឥ-អា. + ត] គឺ....លេងហើយ ។នបុំ. ល្បែង, ការលេង (ដូច **ទវ**) ។

**កីឡិតព្វ** គុ. [កីឡ + ឥ-អា. + តព្វ] គឺ....គប្បីលេង ។

**កីឡិតុកាម** គុ. [កីឡិតុំ + កម + ណ] អ្នកចង់ដើម្បីលេង, អ្នកចង់លេង ។

**កីឡិស្សតិ** កិ. [កីឡ + អ + ស្សតិ-ភ. ចុះឥ-អា.] នឹងលេង ។

**កីឡ** ធា. **វិហារេ កីឡតិ កីឡា កីឡិតំ**"ចិត្តនៅ, ចិត្តសម្រាន្ត, លេង" ភូ. ។

**កឹ** និ. ឬ, អី., ដូចម្ដេច, ប្រយោជន៍អ្វី ។ **វិកប្បត្ថវាចក** និបាតប្រាប់អត្ថគឺត្រិះរិះ ប្រែថា ដូចម្ដេចអេះ, **អហោ**, **កិមុ**, **ឧទាហុ**, **កិមុតោ**, **ឧទ** ក៏ជាវិកប្បត្ថវាចក ដែរ, ជា**បញ្ហត្ថវាចក** និបាតប្រាប់អត្ថគឺសាកសួរ ប្រែថា ឬ, ដូចម្ដេច, **កថំ**, **កឹសុ**, **ននុ**, **កច្ចិនុ** ក៏ជាបញ្ហត្ថវាចក ដែរ ។

**កឹ** និ. ពាក្យសួរ (**បុច្ឆា**) សេចក្ដីតិះដៀល (**គរហា**), ពាក្យមិនកំណត់, ដូចម្ដេច (**អនិយម**) ។

**កឹកណិកជាលា** ឥ. [កឹកណិក + ជាល] បណ្ដាញនៃកណ្ដឹង ។

**កឹការណ** នបុំ. [កឹ + ការណ] ហេតុដូចម្ដេច, ហេតុអ្វី ។

**កឹការ** បុំ. ជនជាខ្ញុំកំដរ, បាវ (ដូច **ទាស**) ។

**កឹកិរាត** បុំ. ស្មោកន្ទុយដំរី (ដូច **កុរណ្ឌក**) ។

**កឹកិណី** ឥ. កណ្ដឹង, ចង្រ្កង់ (ដូច **ខុទ្ទឃណ្ឋិកា**) ។

**កឹនានាករណា** គុ. [កឹ+នានាករណ] មានអ្វីជាគ្រឿងធ្វើផ្សេងៗគ្នា, មានអំពើផ្សេងៗគ្នាដូចម្ដេច។

**កឹនាម** និ. ឈ្មោះអ្វី, ឈ្មោះដូចម្ដេច ។

**កឹនុខោ** និ. អ្វីហ្ន៎, ដូចម្ដេចហ្ន៎, ព្រោះហេតុអ្វីអេះ ,... ។

**កឹបុរិស** បុំ. កិន្នរ (ដូច **កិន្នរ**) ។

**កឹសមាចារ** គុ. [កឹ+សមាចារ] អ្នកមានសមាចារៈដូចម្ដេច, អ្នកមានអ្វីជាសមាចារៈ, អ្នកមានមារយាទជាគ្រឿងប្រព្រឹត្តល្អដូចម្ដេច ។

**កឹសុ** និ. បញ្ហត្ថវាចក និបាតប្រាប់អត្ថគឺសាកសួរ ប្រែថា អ្វីអេះ, ដូចម្ដេចអេះ, ចូរមើល **កចំ** ខាងដើម ។

**កឹសុក** បុំ. ដើមរលួសបាយ (ដូច **បាលិភទ្ទ**), ដើមចារ (ដូច **បលាស**) ។

**កឹអគ្ឃនក** គុ. [កឹ + អគ្ឃន + ក] មានតម្លៃប៉ុន្មាន, វិ. **កឹ អគ្ឃនំ យស្ស សោ**>**កឹអគ្ឃនកោ** ។

**កឹសីល** គុ. [កឹ + សីល] អ្នកមានសីលដូចម្ដេច, អ្នកមានអ្វីជាសីល, វិ. **កឹ សីលំ យេសំ តេ** >**កឹសីលា** ។

**កុ** ឥ. ផែនដី (ដូច **វសុធា**) ។

**កុ** និ. **កុច្ឆាត្ថវាចក** និបាតប្រាប់អត្ថគឺតិះដៀល ប្រែថា អាក្រក់, គួរខ្ពើម, កាច, **ទុដ្ឋុ** ក៏ជា **កុច្ឆាត្ថវាចក** ដែរ, មួយទៀត **កុ** ប្រព្រឹត្តទៅក្នុងអត្ថគឺ បាប អាក្រក់ ឧ. **កុរូ** អំពើអាក្រក់, **កាបុរិសោ** បុរសកាច, **កុសលំ** ធម្មជាតិកាត់បង់នូវអំពើអាក្រក់, **ឦសស** តិច ឧ. **កាលវណំ** អម្បិលតិច, **កុច្ឆនំ** គួរខ្ពើម, គួរតិះដៀល។

**កុ** ធា. ១-**សទ្ទេ កោតិ កវតិ**"ចេញសំឡេង, ស្រែក, យំ (សត្វ) ពោល" ភូ. ។ កម្ម. **កុយ្យតិ** ។ **កាននំ** នបុំ. "ព្រៃ" សូររំពងក្នុងពេលថ្ងៃត្រង់ ឬជាទីជ្រកនៅនៃសត្វ -ស. ។ **កព្វំ កាវិយំ កាវេយ្យំ** នបុំ. "កាព្យ, ឃ្លោង, ស្លោក, ឆន្ទ" ពាក្យរបស់កវី ។ **កវិ** បុំ. "អ្នកប្រាជ្ញ" វិ. **កវតិ វទតិ បេមនីយវចនំ សីលេនាតិ កវិ** ( សូចិ) ។ ស្វា = **វានរោ** ស្រែក ។

២- **កិច្ឆាយំ** (**គរហាយំ**) **កណ្ហោ** គុ. "គួរខ្ពើម" ខ្មៅ, ងងឹត, បុំ. ព្រះនារាយណ៍, មារ (កុ+ណ្ហ ឬ ក+ហានិ) វិ. **កំ** =**សុខំ ហនតីតិ កណ្ហោ** សូចិ ។

**កុក្កុ** បុំ. ហត្ថ (ដូច **រតន**) ។

**កុក្កុច្ច** នបុំ. [កុកត + ណ្យ] ភាវៈនៃកម្មដែលបុគ្គលធ្វើហើយគួរខ្ពើម (សេចក្ដីក្ដៅក្រហាយ, សេចក្ដីសង្ស័យ, សេចក្ដីរង្កៀស), វិ. **កុកតស្ស ភាវោ** >**កុក្កុច្ចំ** ។ **-មត្ត** គុ. កម្មត្រឹមតែសេចក្ដីសង្ស័យ, ហេតុ

គ្រាន់តែសេចក្តីរង្កៀស ។

**កុក្កុច្ចាយន្ត** គុ. [កុក្កុច្ច + អាយ + អន្ត] កាលប្រព្រឹត្តនូវសេចក្តីសង្ស័យ, កាលប្រព្រឹត្តនូវសេចក្តីរង្កៀស (កាលសង្ស័យ, កាលរង្កៀស) ។

**កុក្កុច្ចាយិត្វា** អ. [កុក្កុច្ច + អាយ + ឥ-អា. + ត្វា] ប្រព្រឹត្តនូវសេចក្តីសង្ស័យហើយ, ប្រព្រឹត្តនូវសេចក្តីរង្កៀសហើយ (សង្ស័យហើយ, រង្កៀសហើយ) ។

**កុក្កុច្ច** នបុំ. សេចក្តីក្តៅក្រហាយ (ដូច **តាប**) ។

**កុក្កុដ** បុំ. [កុ + កុដ + អ] សត្វកាយនូវផែនដី ឬ ក្តាប់នូវដី (មាន់ ដូច **តម្ពចូឡ**), វិ. **កុំ បថវឹ កុដតីតិ** >**កុក្កុដោ** ។ ម្យ៉ាងទៀត ( <កុក + អដ) សត្វតែងកាន់យកនូវចំណី, វិ. **កុកតិ គោចរមាទទាតីតិ វា** >**កុក្កុដោ** ។ -**អណ្ឌខាទិកា** ឥ. អ្នកទំពាស៊ីនូវពងនៃមាន់, វិ. **កុក្កុដណ្ឌានិ ខាទតីតិ**>**កុក្កុដណ្ឌខាទិកា** ។ -**អណ្ឌខាទិកវត្ថុ** នបុំ. រឿងនៃកុមារិកាអ្នកទំពាស៊ីនូវពងនៃមាន់ ។ -**មិត្តវត្ថុ** នបុំ. រឿងនៃនេសាទឈ្មោះកុក្កុដមិត្ត ។ -**វតីនគរ** នបុំ. នគរឈ្មោះកុក្កុដវតី ។ -**សត** នបុំ. រយនៃមាន់ ។ -**សេដ្ឋី** បុំ. សេដ្ឋីឈ្មោះកុក្កុដៈ ។ - **អារាម** បុំ. អារាមឈ្មោះកុក្កុដៈ ។

**កុក្កុដី** ឥ. [កុក្កុដ + ឦ] មេមាន់ ។

**កុក្កុត្ថក** បុំ. មាន់ព្រៃ ។

**កុក្កុរ** បុំ. [កុក + ឧរ] (សត្វ) ចាប់នូវម្រឹគមានទន្សាយជាដើម (ឆ្កែ), វិ. **កុកតិ សសាទយោ អាទទាតីតិ** >**កុក្កុរោ** ។

**កុក្កុរ** បុំ. ឆ្កែ (ដូច **សុនខ**) ។

**កុក្កុល** បុំ. [កុក្កុ + លុ + អ] (សភាវៈ) កាត់នូវដៃ (ផេះក្តៅ ដូច **ឧណ្ហភស្ម**), វិ. **កុក្កុំ ហត្ថំ លុនាតិ ឆិន្ទតីតិ** >**កុក្កុលោ** ។ -**សទិស** គុ. ប្រាកដស្មើដោយផេះក្តៅ ។

**កុក្កុហ** បុំ. សត្វលលក (ដូច **ឧក្កុស**) ។

**កុកិ** ធា. **អាទានេ កុកតិ**"ចាប់, កាន់, ទទួល" ភូ. ។ **កោកោ** បុំ. "ឆ្កែព្រៃ" (ម្រឹគនេះសម្បុរឆ្នាត់ មាឌប៉ុនឆ្កែ ខ្លះថាខ្លាដំបងតូច ខ្លះថាខ្លាធំ) -ស. ។ **កកុធោ** បុំ. "គ្រឿងទ្រង់សម្គាល់រាជ ឈ្មោះថា រាជកកុធភណ្ឌ, បូកគោ, ដើមថ្ងាន់" ។

**កុង្កុម** នបុំ. ចន្ទន៍ក្រហម, សព្ទនេះជាគូរគ្នានឹង **កស្មិរជ** សព្ទចូរមើល **កស្មីរ** ជាខាងដើម ។

**កុច** បុំ. ដោះ (ដូច **ថន**) ។

**កុច្ឆា** ឥ. ការតិះដៀល (ដូច **និន្ទា**) ។

**កុច្ឆិ** ឥ. [កុស + ឆិ, ស >ច] ផ្ទៃ, ពោះ (ដូច **គព្ភ**), (វិ. **កុសិយតិ អក្កោសិយតីតិ** >**កុច្ឆិ**)។ **-គត** គុ. ទៅហើយក្នុងផ្ទៃ (តាំងនៅក្នុងផ្ទៃ)។ **-ទាហ** បុំ. សេចក្ដីក្ដៅក្រហាយក្នុងផ្ទៃ, កិ.រោលរាលក្នុងផ្ទៃ។ **-បូរមត្ត** គុ. អាហារត្រឹមតែពេញក្នុងផ្ទៃ, អាហារត្រឹមតែកិ.ញុំាងផ្ទៃឲ្យពេញ ។ **-បូរ** គុ. ដែលញុំាងផ្ទៃឲ្យពេញ, កិ.ពេញក្នុងផ្ទៃ ។ **-ប្បមាណ** គុ. ប្រមាណនៃផ្ទៃ ។ **-រោគ** បុំ. រោគក្នុងផ្ទៃ, រោគកើតក្នុងផ្ទៃ ។

**កុច្ឆិដ្ឋសត្ត** បុំ. សត្វដែលឋិតនៅក្នុងផ្ទៃ, សព្ទនេះជាអត្ថនៃ **គព្ភ** សព្ទ ។

**កុច្ឆិដ្ឋ** គុ. (ខ្យល់)ឋិតនៅក្នុងផ្ទៃ ។

**កុច្ឆិត** គុ. អាក្រក់, គួរខ្ពើម, ថោកទាប (ដូច **និហីន**) ។

**កុច្ឆ** ធា. **អវក្ខេបេ** (**អធោខេបេ**) **កុច្ឆេតិ កុច្ឆយតិ**"គ្រវែងចោល, បោះចោល, បោះទៅក្រោម" ចុ. ។

**កុច** ធា. ១ **តារេ** (**អច្ចុច្ចសទ្ទេ**) **កោចតិ**"ស្រែករំពង, ស្រែកគឹកកង" ភូ. ។ **កោញ្ចោ** បុំ. "ក្រៀលឈ្មោល, **កោញ្ចា** ឥ. ។ **កោញ្ចនាទោ** បុំ. "កោញ្ចនាទ, សំឡេងក្រៀល, សម្រែកក្រៀល, សំឡេងដំរីស្រែក" ។

២ **សំបច្ចនកោដិល្លបដិក្កមវិលេខនេសុ កុចតិ សង្កុចតិ** "ចម្អិន, ទុំ, ចងចិញ្ចើម, វៀច, កោង, ង, ជ្រួញ, ត្រឡប់, ថយក្រោយ, សរសេរ, គូស, ធ្វើឲ្យមានស្នាម" ភូ. ។

**កុជ** បុំ. ឈើ (ដូច **ទុម**) ។

**កុជ្ជ** ធា. **អធោមុខីករណេ កុជ្ជតិ និក្កុជ្ជតិ បដិកុជ្ជតិ**"ធ្វើឲ្យមានមុខចុះក្រោម, ផ្កាប់, គ្រប" ភូ. ។ **ឧក្កុជ្ជតិ** កិ. "ផ្ងារ (ចំហ)" អា. **និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ**"គប្បីផ្ងាររបស់ដែលផ្កាប់" **អញ្ញិស្សា បាតិយា បដិកុជ្ជតិ** "គេគ្របដោយភាជនៈដទៃ" ។ **អវកុជ្ជោ និបជ្ជាហំ** "ខ្ញុំដេកផ្កាប់មុខ" ។ (**ឧ**+**កុជ្ជ**) =**ឧបរិមុខំ ករោតិ** -ស. ។ (**បដិ**+**កុជ្ជ**) =**មុខេ មុខំ ឋបេតិ** ស. ។

**កុជ្ឈតិ** កិ. [កុធ + យ + តិ-វ.] ក្រោធ, ខឹង ។

**កុជ្ឈាបន** នបុំ. [កុធ + យ + ណាបេ + យុ] កិ.ញុំាង.....ឲ្យក្រោធ, ខឹង។ **-វស** បុំ. អំណាចនៃកិ.ញុំាង...ឲ្យក្រោធ ។

**កុជ្ឈាបេន្ត** គុ. [កុធ + យ + ណាបេ +អន្ត] កាលញុំាង....ឲ្យក្រោធ ។

**កុជ្ឈាយថ** កិ. [កុធ + យ + ថ-វ.] ក្រោធ, ឲ្យក្រោធ ។

**កុជ្ឈិតព្វ** គុ. [កុធ + យ + ឥ-អា. + តព្វ] គឺ....គប្បីក្រោធ ។

**កុជ្ឈិស្សតិ** កិ. [កុធ + យ + ឥ-អា. + ស្សតិ-ភ.] នឹងក្រោធ ។

**កុជ្ឈេយ្យ** កិ. [កុធ + យ + ឯយ្យ-ស.] គប្បីក្រោធ ។

**កុជ** ធា. **ថេយ្យករណេ កោជតិ** "លួច" ភូ. ។

**កុជិ** ឬ **កូជិ** ធា. **សទ្ទេ អព្យត្តសទ្ទេ ច កុញ្ជាតិ កូជតិ** "ចេញសំឡេង, សំឡេងមិនច្បាស់, រងាវ, បូល, យំ (នៃសត្វ) រុ. ភូ. ។

**កុញ្ចិកច្ឆិទ្ទ** នបុំ. [កុញ្ចិក + ឆិទ្ទ] ប្រហោងនៃសោ ។

**កុញ្ចិកហត្ថ** គុ. [កុញ្ចិក + ហត្ថ] អ្នកមានសោក្នុងដៃ, វិ. **កុញ្ចិកំ ហត្ថេ យស្ស សោ** >**កុញ្ចិកហត្ថោ** ។

**កុញ្ចិកា** ឥ. កូនសោ (ដូច **តាឡ**) ។

**កុញ្ចិកាវិវរ** នបុំ. ប្រហោងកូនសោ (ដូច **តាឡច្ឆិគ្គឡ**) ។

**កុញ្ចិត** បុំ.គុ. រំពត់, វៀច, កោង (ដូច **វង្ក**) ។

**កុញ្ច** ធា. **កោដិល្លប្បិតាវេ កុញ្ចតិ កុញ្ចិត្វា**"វៀច, កោង, ង, ជិតស្និទ្ធ, ចាក់សោ" ភូ. ។ **កុញ្ចិកា** ឥ. "កូនសោ" ។ **កិញ្ចិតកោសោ** "ឃ្លាំង ឬ បន្ទប់ដែលចាក់សោហើយ (បិទហើយ)" ។

**កុញ្ជរ** បុំ. [កុំ + ជរ + អ] (សត្វ) ញាំងផែនដីឲ្យគ្រាំគ្រា (ដំរី ដូច**ហត្ថី**), វិ. **កុំ បថវឹ ជរាបេតីតិ** >**កុញ្ជរោ** ។ -**សទ្ធាត** គុ. ពោលគឺដំរី, គឺបណ្ឌិតពោលថាកុញ្ជរ ។ - **សាលា** ឥ. កុញ្ជរសាលា, រោងនៃដំរី (សាលាមានសណ្ឋានដូចជាសណ្ឋាននៃដំរី ) ។ គុ. ប្រសើរ, ខ្ពង់ខ្ពស់, ថ្លៃថ្លា (ដូច **វិសិដ្ឋ**) ។

**កុញ្ជ** បុំ. ផ្ទៃនៃភ្នំជាដើម ដែលដេរដាសដោយវល្លិឈើស្មៅជាដើម (ដូច **និកុញ្ជោ**) ។

**កុដ** បុំ., នបុំ. ក្អម, ឆ្នាំង, បាវ (បាវគឺប្រដាប់ដែលគេរំលាយមាស ) ។

**កុដចរិយា** ឥ. ការប្រព្រឹត្តកោង, ការប្រព្រឹត្តកុហក, សព្ទនេះជាអត្ថនៃ **កុហនា** សព្ទ ។

**កុដជ** បុំ. [កុដ + ជ] (ឈើ) កាត់បង់នូវរោគ (ដើមក្លែងគង់), វិ. **រោគំ កុដតិ ឆិន្ទតីតិ** >**កុដជោ** ។

**កុដជ** បុំ. ដើមខ្លែងគង់ (ដូច **គិរិមល្លិកា**) ។

**កុដដ្ឋ** គុ. ស្មើគ្នា, ទៀងទាត់ ។

**កុដទារិកា** ឥ. ទាសី (ខ្ញុំស្រី) (ដូច **ចេដី**) ។

**កុដន្នជ** នបុំ. ស្មៅក្រវាញជ្រូក (ដូច **វានេយ្យ**) ។

**កុដមុខវដ្ដី** ឥ. [កុដ + មុខ + វដ្ដី] កណ្ដាប់ដៃមាត់នៃក្អម ។

**កុដិ** ឥ. [កុដ + ឥ] កុដិ (ផ្ទះដូច **គេហ**) ។ -**ទូសកភិក្ខុ** បុំ. ភិក្ខុអ្នកប្រទូស្តនូវកុដិ ។

**កុដិកណ្ណ** គុ. [កុដិ + កណ្ណ] មានត្រចៀកពាក់នូវគ្រឿងប្រដាប់មានតម្លៃមួយកោដិ (តាម ទម្លាប់ថា «មានត្រចៀកយារ») ។ -**សោណត្ថេរ** បុំ. ព្រះថេរឈ្មោះសោណៈមានត្រចៀក..... ។

**កុដិល** បុំ. គុ. រំពត់, កោង, វៀច (ដូច **ជិម្ហ**)។

**កុដុម្ព** នបុំ. ទ្រព្យ, សម្បត្តិ ។

**កុដុម្ពិក** បុំ. [កុដុម្ព + ឥក] (ជន) អ្នកមានទ្រព្យ, អ្នកមានសម្បត្តិ, វិ. **កុដុម្ពំ យស្ស អត្ថីតិ** >**កុដុម្ពិកោ** ។ -**បុត្ត** បុំ. កូននៃជនអ្នកមានទ្រព្យ, កូននៃជនអ្នកមានសម្បត្តិ, កូននៃកុដុម្ពិកៈ ។

**កុដ** បុំ. ក្អម (ដូច **ឃដ**) ។

**កុដ្ឋ** នបុំ. រោគឃ្លង់(ដូច **ព្យាធ**), ដើមរោគ ,ដើមកោដ្ឋ (ដូច **អជបាលក**) ។

**កុដ្ឋិ** បុំ. [កុដ្ឋ+ល្យ, ល្យ >ឥ] អ្នកមានរោគឃ្លង់, វិ. **កុដ្ឋំ យស្ស អត្ថីតិ** >**កុដ្ឋិ** ។ -**តាបត្តិ** ឥ. កិ.ដល់នូវភាវៈនៃ...ជាអ្នកមានរោគឃ្លង់ ។ -**តាប** បុំ. ភាវៈនៃ.....ជាអ្នកមានរោគឃ្លង់ ។

**កុដី** ធា. **កោដិល្លេ កុដតិ បដិកុដតិ**"វៀច, កោង, ង, ជ្រួញ, ខ្វះ" ភូ. ។ **កុដ** បុំ. នបុំ. "ក្អម, ថូទឹក" ។

**កុដី** ឬ **កុដ្ដី** ធា. **ឆេទនេ កុដតិ កុដ្ដេតិ កុដ្ដយតិ**"កាត់, ផ្តាច់" ភូ. ចុ. ។ **កុដ្ឌ** នបុំ. "ជញ្ជាំង" ។ **កោដេតិ កោដយតិ អាកោដេតិ អាកោដយតិ អាកោដយន្តោ** "វាយគោះ, បោក, គក់, ..." ចុ. ។

**កុឋី** ធា. **អាលសិយគតិប្បដិឃាតសោកេសុ កុណ្ឋតិ** "ខ្ជិល, ចំអៀក, ទំរន់, សោក, ស្ងួត, ស្វិត" រុ. ។

**កុឋារី** ឥ. ដឹង, ពូថៅ (ដូច **ផរសុ**) ។

**កុឌុមល** បុំ. ផ្កាក្រពុំ, ផ្កាក្តោប (ដូច **មកុល**) ។

**កុឌុប** បុំ. ទូកដៃ (ដូច **បសត**) ។

**កុឌ្ឌ** នបុំ. ជញ្ជាំង (ដូច **តិត្តិ**) ។

**កុឌិ** ធា. **ទាហេ កុណ្ឌតិ**"ដុត, ឆេះ, ក្តៅ" រុ. ។ **កុណ្ឌ** បុំ. "ជើងក្រានភ្លើង, សត្វទន្សង" នបុំ. "ឆ្នាំង" ។ **កុណ្ឌល** នបុំ. "ទំហូ" ។ **កុណ្ឌក** បុំ. "កន្ទក់" ។

**កុណប** បុំ. សព, សាកសព, សាកអសុភ (ដូច **ឆវ**)។ -**គន្ធប្បដិកុលតា** ឥ. ភាវៈនៃ.....ជា....បដិកូលដោយក្លិននៃសាកសព, ភាវៈនៃ...ជា... មានក្លិននៃសាកសពជាបដិកូល ។

**កុណាល** បុំ. សត្វតាវ៉ៅ (ដូច **ឋិក**),ឈ្មោះមហាស្រះមួយក្នុងព្រៃហិមពាន្ត ។

**កុណី** គុ. [កុណ + ល្យ] អ្នកមានអវយវៈជាគ្រឿងខ្វះ ឬរួយ (ក្ញែង), វិ. **កុណោ យស្ស អត្ថីតិ** >**កុណី** ។ បុំ. មនុស្សដៃក្ញែង ។

**កុណ្ឋ** គុ. [កុណ្ឋ + អ] ខ្វក, ហិល, រឹល, វេច ។ -**កុទ្ទាល** បុំ. ចបរឹល, ចបគំរឹល ។ -**ធារ** គុ. មានមុខរឹល, មានមុខហិល ។ -**បាទច្ឆិន្នជប** គុ. មានជើងខ្វក និង មានសន្ទុះដាច់ហើយ, មានសន្ទុះដាច់ហើយដោយអំណាចនៃជើងខ្វក, មានសន្ទុះដាច់ហើយ ព្រោះមានជើងខ្វក ។ បុំ.អ្នកខ្ជិលច្រអូស ។

**កុណ្ឌក** បុំ. [កុណ្ឌ + អ + ក-ស.] (ផង់នៃអង្ករ, កំទេចនៃអង្ករ) កន្ទក់(ដូច **កណ**) ។ -**អង្គារបូវ** បុំ. នំគឺបុគ្គលចម្អិនលើរងើកភ្លើង ដែលទាសីឈ្មោះបុណ្ណាធ្វើហើយដោយកន្ទក់, នំអំបែង គឺទាសីឈ្មោះបុណ្ណាធ្វើហើយដោយកន្ទក់ ។ -**មុដ្ឋិ** ឥ. ក្តាប់នៃកន្ទក់, កន្ទក់មានក្តាប់ជាប្រមាណ ។ -**សិន្ធវបោតកជាតក** នបុំ. ជាតកគឺបណ្ឌិតកំណត់ហើយដោយកូននៃសេះសិន្ធវៈស៊ីនូវកន្ទក់ ។ -**អាទិ**គុ. (វត្ថុ) មានកន្ទក់ជាដើម ។

**កុណ្ឌល** នបុំ. [កុណ្ឌ + អល] កុណ្ឌល (ទំហូ,ការ, គ្រឿងប្រដាប់ត្រចៀក (ដូច **កណ្ណវេឋន**)។

**កុណ្ឌលកេសី** អ.ន. ព្រះថេរីឈ្មោះកុណ្ឌលកេសី ។ -**ថេរីវត្ថុ** នបុំ. រឿងនៃព្រះថេរីឈ្មោះកុណ្ឌលកេសី ។

**កុណ្ឌិកា** ឥ. [កុឌិ + ក-ស.+ អា-ឥ.] កុណ្ឌីទឹក (កុន្ទីទឹក) ភាជនៈសម្រាប់ដាក់ទឹកជ្រូច, លក្ខចាន់ (ដូច **កមណ្ឌលុ**)។

**កុណ្ឌិធានវន** អ.ន. វិហារឈ្មោះកុណ្ឌិធានវន ។

**កុណ្ឌ** បុំ. ទន្សង (ដូច **គោធា**) ។ នបុំ. ឆ្នាំង (ដូច **ឧក្ខលិ**)។

**កុណ្ឌិ** ធា. **វេទនេ កុណ្ឌេតិ កុណ្ឌយតិ**"ដឹងច្បាស់" ចុ. ។ **កុណ្ឌល** នបុំ. "ទំហូ, ការ" ។

**កុណិ** ធា. ១-**សទ្ទោបករណេ កោណតិ** "ឧបករណ៍នៃសំឡេង, សមគួរដល់សំឡេង"ភូ.
២-**សង្កោចនេ កុណេតិ កុណយតិ**"រួញ, ជ្រួញ, រួញខ្លី" ចុ. ។ **កុណហត្ថ** គុ. "មានដៃក្ងែង" ។ **កុណី** បុំ. "មនុស្សក្ងែង" ។ **កោណ** បុំ. "មុម, ជ្រុង, ទីបំផុត, គ្រឿងពិណ" ។
៣-**អាមន្តនេ កុណេតិ កុណយតិ**"ហៅ, ហៅរក" ចុ. ។

**កុតូហល,-ឡ** នបុំ. [ កុ + តុល + អ, ចុះ ហ-អា. ],សេចក្តីភ្ញាក់ផ្អើល, សេចក្តីជ្រួលជ្រើម (ដូច **កោតូហឡ**), វិ. **កុំ បាបំ តុលយតីតិ** >**កុតូហលំ**។ -**ជាត** គុ. ជាអ្នកមានសេចក្តីជ្រួលជ្រើមកើតហើយ, ជាអ្នកមានការរឹករររកើតហើយ ។

**កុត្តក** នបុំ. កម្រាលចំណុះស្រីរបាំ ១៦ នាក់ ។

**កុត្ថ** និ. **កុត្ថវាចក** និបាតប្រាប់អត្ថគឺ ក្នុង... ណា, ក្នុង...ដូចម្តេច ប្រែថា ក្នុងទីណា, ក្នុងទីដូចម្តេចជាដើម, ចូរមើល **កត្ថ** ខាងដើម ។

**កុថ** បុំ. កម្រាលខ្នងដំរី (**ហត្ថិបិដ្ឋត្ថរណំ**) **កុថ**សព្ទនេះជាអត្ថនៃ **បវេណិ** សព្ទ ។

**កុថិ** ធា. ១-**ហឹសាយំ កោថតិ**"បៀតបៀន" ភូ. ។
២-**ហឹសាសង្កិលេសេសុ កុន្ថតិ** "បៀតបៀន, សៅហ្មង, ប្រឡាក់"រុ. ។ **កុន្ថ** បុំ. ស្រមោចម្យ៉ាង ។ **កុន្ថកិបិល្លិក** នបុំ. "អង្រ្គង, ស្រមោចខ្មៅ

និងស្រមោចក្រហម" ។ **កុន្ថិត** កិ. គុ. "ប្រឡាក់" អា. **ទិស្វាន បតិតំ សាមំ បុត្តកំ បំសុកុន្ថិតំ**"ឃើញកូនតូចដួលដោយខ្លួនឯងប្រឡាក់ប្រឡូសដោយធូលី"-ស. ។

**កុទាចនំ** កា.ស. [កឹ + ទាចនំ, កឹ>កុ] ក្នុងកាលណាៗ, ក្នុងកាលណាខ្លះ, ជូនកាល, ជូនណា,....។ និ.កទាត្ថវាចក និបាតប្រាប់អត្ថគឺ ក្នុងកាលណា (ដូច **កទា**) ។

**កុទ្ទាល** បុំ. [កុំ + ទល + ណ] គ្រឿងទម្លាយនូវផែនដី (ចប), វិ. **កុំ បឋវឹ ទលតីតិ** > **កុទ្ទាលោ** ។ -**អត្ថ** បុំ. ប្រយោជន៍ដល់ចប, សេចក្តីត្រូវការដល់ចប ។ -**បណ្ឌិត** អ.ន. ឈ្មោះកុទ្ទាលបណ្ឌិត ។ -**ផល** នបុំ. ផ្លែនៃចប ។ -**អាទិហត្ថ** គុ. មានវត្ថុមានចបជាដើមក្នុងដៃ ។

**កុទ្ធ** គុ. [កុធ + ត] ក្រោធហើយ, ខឹងហើយ ។ -**បុព្វ** គុ. ធ្លាប់ក្រោធហើយ (ខឹងហើយក្នុងកាលមុន) ។ -**មនុស្ស** បុំ. មនុស្សក្រោធហើយ ។ -**មានស** គុ. មានចិត្តក្រោធហើយ, មានឆន្ទៈមានក្នុងចិត្តក្រោធហើយ ។

**កុទ្រូស** បុំ. ស្រូវគៃលលក ។

**កុទិ** ធា. **កីឡាយំ កោទិតិ** "លេង" ភូ. ។

**កុធារី** ឥ. [កុ + ធរ + ណី] ដឹង, ប៉ូវថៅ (ប្រើជា **កុឋារី** ក៏មាន) ។

**កុធិ** ធា. **កោបេ កុជ្ឈតិ កុជ្ឈិត្វា កុទ្ធោ កោធោ**"ខឹង" រុ. ។

**កុន្តនី** ឥ. សត្វក្រៀល (ដូច **កោញ្ចា**) ។

**កុន្តល** បុំ. សក់ (ដូច **កេស**) ។

**កុន្ត** បុំ. ទួន ជាគ្រឿងអាវុធម្យ៉ាងស្រដៀងលំពែង, ឈើសម្រួចកន្ទុយអន្ទង់ ។

**កុន្ទ** នបុំ. ដើមរុន, ភ្ញែកខ្លា (ដូច **មាឃ្យ**) ។

**កុន្ថិ** ធា. **អន្តភាសនេ កុន្ថេតិ កុន្ថយតិ**"ពោលទីបំផុត" ចុ. ។

**កុបិត** គុ. [កុប + ត-អា. + ត] កម្រើកហើយ, គឺ....ឲ្យកម្រើកហើយ (ក្រោធ, ខឹង) ។ -**ភាវ** បុំ. ភាវៈនៃ...ជា...កម្រើកហើយ ។ -**មានស** គុ. អ្នកមានចិត្តកម្រើកហើយ, អ្នកមានឆន្ទៈមានក្នុងចិត្តកម្រើកហើយ ។

**កុប្បន្តិ** កិ. [កុប + យ + អន្តិ-វ.] កម្រើក, កក្រើក ។

**កុប្យ** នបុំ. លោហធាតុមានទង់ដែងជាដើមក្រៅអំពីមាសប្រាក់ ។

**កុបិ** ធា. **កោបេ កុប្បតិ កោបោ បកោបោ**"ខឹង, កម្រើក, ក្រោធ" ទិ. ។ អា. **កុប្បតិ វាតស្ស ឯរិតស្ស** "រញ្ជួយព្រោះខ្យល់បក់" ។ **វចីបកោបំ រក្ខេយ្យ** "គួររក្សានូវការកម្រើកនៃវាចា" -ស. ។

**កុព្វតោ** គុ. [ករ + ឱ + អន្ត + ស-វិ.] កាលធ្វើ(នៃ....កាលធ្វើ) ។

**កុព្វន្តិ** កិ. [ករ + ឱ + អន្តិ-វ.] ធ្វើ, រមែងធ្វើ ។

**កុព្វរ** បុំ. ក្បាលក្រពើរទេះ (ដូច **យុគន្ធរ**)។

**កុច្ច** ធា. **ឧគ្គមេ កុច្ចតិ**"ឡើងទៅខ្ពស់, ទៅខាងលើ" ភូ. ។

**កុច** ធា. **អច្ឆាទនេ កុច្ចតិ**"ស្លៀកពាក់" ទិ. ។

**កុមារ** បុំ. [កុ + មរ + ណ, កុម + អារ, កុមារ + អ] អ្នកគួសវាសនូវផែនដី, (ទារក) ដែលគេប្រាថ្នា, អ្នកតែងលេង (កុមារ,ក្មេង), **កុំ ត្វមី មរតិ ភិន្ទតិ វិលេខតីតិ** >**កុមារោ**, **កាមិយតីតិ** >**កុមារោ**, **កុមារតិ កីឡតីតិ** >**កុមារោ** ។ -**កស្សបត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះកុមារកស្សប ។ -**បរិវារ** បុំ. បរិវារនៃកុមារ, កុមារជាបរិវារ ។ - **បរិហារ** នបុំ. វត្ថុជាគ្រឿងនាំទៅជុំវិញនៃកុមារ, វត្ថុជាគ្រឿងរក្សានូវកុមារ ។ -**វណ្ណ** គុ. មានភេទដូចជាភេទនៃកុមារ ។ព្រះរាជកុមារ (ដូច **យុវរាជ**), ខន្ទកុមារ(ដូច **សត្តិធរ**), កូនក្មេង (ដូច **សុសុ**) ។

**កុមារក** បុំ. ដូចជា «កុមារ» ដែរ ប្លែកតែចុះ «**កសកត្ថ**» ខាងចុង ប្រែថា «កុមារ, ក្មេង ឬកុមារតូច, ក្មេងតូច» ។ -**វណ្ណ** បុំ. ភេទដូចជាភេទនៃកុមារ ។

**កុមារិកា** ឥ. កុមារិកា, ក្មេងស្រី ឬ កុមារីតូច, ក្មេងស្រីតូច ។ -**កាល** បុំ. កាលនៃ.....ជាកុមារិកា ។ -**វណ្ណាធិវស** បុំ. អំណាចនៃភេទមានភេទនៃកុមារិកាជាដើម ។

**កុមារីសត** នបុំ. [កុមារី + សត] រយនៃកុមារី ។

**កុមារិ** ធា. **កីឡាយំ កុមារេតិ កុមារយតិ**"លេង" ចុ. ។ សូចិថា "**កាមីយតីតិ កុមារោ** (កមិ+អារ), **កុំ ត្វមី មរតិ ភិន្ទតិ វិលេខតីតិ កុមារោ**, (កុ+មរិ+អ), **អថវា កុយំ ត្វមិយំ រមតីតិ កុមារោ** (កុ+រមិ+ណ)″ ។ **កុមារ** បុំ. "កុមារ, ក្មេងប្រុស" ឥ. **កុមារី**, ។ **កុមារកោ** បុំ. "ក្មេងតូច" ឥ. កុមារិកា ។ វិ. **កុមារោ ឯវ កុមារកោ** ។

**កុមិន** នបុំ. លប (សម្រាប់ដាក់ត្រី) (ដូច **កុវេណី**) ។

**កុមុទ** នបុំ. [កុ + មុទ + ណ] (ជលជាត) ត្រកអរក្នុងទឹក ឬត្រេកអរក្នុងផែនដី (កុមុទ, ផ្កាកុមុទ), វិ. **កុយំ បថវិយំ មោទតីតិ** > **កុមុទំ** ។ -**ឧប្បល** នបុំ. ផ្កាកុមុទនិងផ្កាឧប្បល ។ ឈ្មោះសំខ្យាម្យ៉ាងដាក់លេខមួយមានពិន្ទុ មួយរយប្រាំ (១០៥) គឺមួយរយសែនឧប្បល, ឧប្បលស (ព្រលិតស) ។ បុំ.ឈ្មោះដំរីប្រចាំទិសមួយ ។

**កុមុទិកា** ឥ. ដើមអង្គ្រង (ដូច **កុម្ភី**) ។

**កុម្ភ** បុំ. ពោងដំរី (ដូច **មាតង្គមុទ្ធបិណ្ឌ**), ក្អម, ឆ្នាំង (ដូច **វារក**,**ឃដ** ), ចំនួន ១០ អម្មណ ។

**កុម្ភការ** បុំ. [កុម្ភ + ករ + ណ] (ជន) អ្នកធ្វើនូវឆ្នាំង ឬ ក្អម (ស្មូនឆ្នាំងដូច **កុលាល** ),វិ. **កុម្ភំ ករោតីតិ** >**កុម្ភការោ** ។ - **សាលា** ឥ. សាលា (រោង) នៃជនអ្នកធ្វើនូវឆ្នាំង, រោងនៃស្មូនឆ្នាំង ។

**កុម្ភក** នបុំ. ដងក្ដោងទូក ឬ សំពៅ (ដូច **កូបក** ) ។

**កុម្ភឃោសក** អ.ន. សេដ្ឋីឈ្មោះកុម្ភឃោសកៈ ។ -**វត្ថុ** នបុំ. រឿងនៃ...... ។

**កុម្ភណ្ឌ** បុំ. កំណើតទេវតាម្យ៉ាង, វល្លិរពៅ ។

**កុម្ភណ្ឌសាមិ** បុំ. មហារាជជានាយកឬជាម្ចាស់នៃកុម្ភណ្ឌ, កុម្ភណ្ឌ ជាប្រភេទនៃទេវតាមួយពួក (ដូច **វិរុឡ្ហក**),បន្លែរពៅ (ដូច **វល្លិភ**) ។

**កុម្ភទាសី** ឥ. [កុម្ភ + ទាសី] ទាសីអ្នកនាំទៅនូវទឹកដោយក្អម(**កុម្ភទាសី**)។

**កុម្ភភារ** បុំ. [កុម្ភ+ភារ] ភារៈមានកុម្ភៈជាប្រមាណ, ទ្រព្យមានទម្ងន់មួយកុម្ភៈ ។

**កុម្ភិមុខ** នបុំ. [កុម្ភិ + មុខ] មាត់នៃឆ្នាំង, មាត់នៃក្អម ។

**កុម្ភី** ឥ. ឆ្នាំង, ខ្ទះ (ដូច **ថីថរ**),ដើមអង្រ្កង (ដូច **កុម្ភុទិកា**)។

**កុម្ភីល** បុំ. [ក + ឧភ + ល្បល, ឧល + អ] ក្រពើ(ដូច **សុំសុមារ**),វិ. **កេន ជលេន ឧភតិ បូរេតីតិ** >**កុម្ភោ** (**ជលាសយោ**) , **តត្រ ឧលតិ គច្ឆតីតិ** > **កុម្ភីលោ**)។

**កុម្ភូបម** គុ. [កុម្ភ+ឧបមា] មានឧបមាដោយក្អម, មានក្អមជាគ្រឿងប្រៀបធៀប ។

**កុម្ម** បុំ. អណ្ដើក (ដូច **កច្ឆប**) ។

**កុរ** នបុំ. [ករ + អ] (វត្ថុ) ធ្វើនូវកម្លាំង (បាយដូច **ឱទន**), វិ. **ករោតិ ពលន្តិ** > **កុរំ** ។

**កុរង្គ** បុំ. ម្រឹគប្រើស (ដូច **កុរុង្គ**) ។

**កុរណ្ឌក** បុំ. ស្មៅកន្ទុយដំរី (ដូច **ភីភិរាត**) ។

**កុររឃរ** អ.ន. ក្រុងឈ្មោះកុររឃរៈ ។ - **នគរ** នបុំ. នគរឈ្មោះកុររឃរៈ ។

**កុររ** បុំ. សត្វលលក (ដូច **ឧក្កុស**) ។

**កុរុង្គ** បុំ. [កុ + រគ + អ, ចុះនិ-អា.] (សត្វ) ដើរទៅលើដី (ប្រើស ឬម្រឹគឈ្មោះកុរុង្គៈ) វិ. **កុយំ រង្គតីតិ** >**កុរុង្គោ** ។ -**ជាតកាទិ** គុ. (ជាតក) មានកុរុង្គជាតកជាដើម ។ ប្រើជា ករុង្គ ក៏មាន ។

**កុរុតេ** កិ. [ករ + ឱ + តេ-វ.] ធ្វើ ។

**កុរុធម្ម** បុំ. [កុរុ + ធម្ម] កុរុធម៌, ធម៌នៃអ្នកដែនកុរុ ។

**កុរុមាន** គុ. [ករ + ឧ + មាន] កាលធ្វើ ។

**កុររដ្ឋ** នបុំ. [កុរុ + រដ្ឋ] ដែនឈ្មោះកុរុ ។ -**វាសី** បុំ. ជនអ្នកនៅក្នុងដែនកុរុ, អ្នកមានកិ.នៅក្នុងដែនកុរុជាប្រក្រតី ។

**កុរុរាជ** បុំ. [កុរុ + រាជ] ស្ដេចក្នុងដែនកុរុ, ស្ដេចជាធំក្នុងដែនកុរុ ។

**កុរូ** អ.ស. ឈ្មោះដែន ឬ ជនបទ ១ ។

**កុរូរ** គុ. ធ្វើនូវសេចក្ដីភ័យ (ដូច **ភយំករ**),រឹង, រឹងត្អឹង, រឹងរូស (ដូច **កឋិន**, **កក្ខល**), អ្នកកាច, អ្នកឥតករុណា (ដូច **និទ្ទយ**)។

**កុរិ** ធា. **សទ្ទេ អក្កោសនេ ច កុរតិ**"ចេញសំឡេង, ជេរ" ភូ. ។ **កុររ** បុំ. **កុររី** ឥ. "សត្វអក, អកសមុទ្រ" (ឥន្រ្ទី) ។ **កុម្ម** បុំ. **កុម្មិ** ឥ. "អណ្ដើក" (កុរិ+រម្ម) ។

**កុល** នបុំ. [កុល + អ] (វង្ស) ជាហេតុតភ្ជាប់នូវគ្នានិងគ្នា (ត្រកូល, វង្ស ដូច **វំស**,

ពួកជនដែលមានជាតិជាមួយគ្នា), វិ. **កុលតិ អញ្ញមញ្ញមេតេនាតិ** > **កុលំ** ។ -**កុមារិកា** ឥ. កុមារិកានៃត្រកូល, ក្មេងស្រីនៃត្រកូល ។ -**គ្គាម** បុំ. ស្រុកនៃត្រកូល ។ -**គេហ** នបុំ. ផ្ទះនៃត្រកូល ។ -**ឃរគមន** នបុំ. កិ.ទៅកាន់ផ្ទះនៃត្រកូល ។ -**ឃរគមនភាវ** បុំ. ភាវៈគឺកិ.ទៅកាន់ផ្ទះនៃត្រកូល, ភាវៈនៃកិ.ទៅកាន់ផ្ទះនៃត្រកូល ។ -**ទត្តិយ** គុ. ដែលត្រកូលឲ្យហើយ ឬ ជារបស់ដែលត្រកូលគប្បីឲ្យ ។ -**ទមក** គុ. អ្នកទូន្មាននូវត្រកូល ។ -**ទូសកកម្ម** នបុំ. កម្មនៃបុគ្គលអ្នកទ្រុស្តនូវត្រកូល ។ -**ធីតា** ឥ. ធីតានៃត្រកូល, កូនស្រីនៃត្រកូល ។ - **ប្បវេណិ** ឥ. លំដាប់នៃត្រកូល ។ -**បរិវដ្ដ** បុំ. កិ.វិលទៅជុំវិញនៃត្រកូល ។ -**វំស** បុំ. វង្សនៃត្រកូល ។ -**វំសានុគត** គុ. ទៅតាមហើយនូវវង្សនៃត្រកូល, ប្រព្រឹត្តទៅតាមហើយនូវវង្សនៃត្រកូល ។ -**ភាតា** បុំ. បងប្អូនប្រុសនៃត្រកូល ។ -**សតិក** គុ. មានរយនៃត្រកូល, ប្រកបដោយរយនៃត្រកូល, វិ. **កុលានំ សតំ** >**កុលសតំ**, **កុលសតំ យេសមត្ថីតិ** >**កុលសតិកា**, **កុលសតេន និយុត្តា** >**កុលសតិកា** ។ - **សន្តក** គុ. ជារបស់នៃត្រកូល ។ -**សម្ពន្ធវស** បុំ. អំណាចនៃកិ.ជាប់ព្រមដោយត្រកូល, អំណាចនៃកិ.ទាក់ទងដោយត្រកូល ។ គោត្រ, គំនរ (ដូច **រាសិ**)។

**កុលក** បុំ. ដើមដង្កោ (ដូច **ភាកតិន្ទុក**) ។

**កុលជា** ឥ. ស្ត្រីកោងកាច, ស្ត្រីខូចកាច, ស្ត្រីញុាំងត្រកូលឲ្យវិនាស (ដូច **ពន្ធកី**) ។

**កុលបាលិកា** ឥ. ស្ត្រីសមគួរដល់ត្រកូល, ស្ត្រីរក្សាត្រកូល (ដូច **កុលិត្ថី**) ។

**កុលល** បុំ. សត្វខ្លែង (ដូច **សេន**),ស្ទួនឆ្មាំង (ដូច **កុម្ភការ**) ។

**កុលាល** បុំ. [កុ+លល+ណ] អ្នកប្រាថ្នានូវដី ឬ អ្នកក្រាលនូវសិល្បៈរបស់ខ្លួន, អ្នកកាន់យកនូវដីធ្វើ (ស្ទួនឆ្មាំង),វិ. **កុំ លលយតិ ឥច្ឆតីតិ** >**កុលាលោ**, **កុលតិ អត្តនោ សិប្បំ បត្ថរតីតិ** >**កុលាលោ** ។ -**ចក្ក** នបុំ. ចក្រនៃស្ទួនឆ្មាំង ។ -**ភាជនសទិស** គុ. ប្រាកដស្មើដោយភាជន៍នៃស្ទួនឆ្មាំង, ប្រហែលដោយភាជន៍នៃបុគ្គលអ្នកកាន់នូវដីធ្វើ ។

**កុលាវក** នបុំ. [កុ + លុ + ណ្វុ] សម្បុក, សំបុកសត្វស្លាប (ដូច **នីឡ**) (វិ. **កុច្ឆិត-មណ្ឌវិនាសនាទិកំ លុនាតីតិ**>**កុលាវកំ**)។

**កុលិត្ថី** ឥ. ស្ត្រីសមគួរដល់ត្រកូល, ស្ត្រីរក្សាត្រកូល (ដូច **កុលបាលិកា**) ។

**កុលិស** នបុំ. អាវុធព្រះឥន្ទ (ដូច **វជិរ**)។

**កុលីនក** នបុំ. សេះអាជានេយ្យ, សេះដឹងហេតុនិងមិនមែនហេតុ (ដូច**អាជានីយ**) ។

**កុលីន** បុំ. ជនមានត្រកូល (ដូច **សជ្ជន**) ។

**កុលីរ** បុំ. សត្វក្ដាម (ដូច **កក្កដក**) ។

**កុលុបគ** គុ. [កុល+ឧប+គម+ក្វិ] អ្នកចូលទៅកាន់ត្រកូល, វិ. **កុលំ ឧបគច្ឆតីតិ**> **កុលុបគោ** ។ -**ត្ថេរ** បុំ. ព្រះថេរៈអ្នកចូលទៅកាន់ត្រកូល, ព្រះថេរៈជាជីតុន ។

**កុលុបច្ឆេទ** ប៉ុ. [កុល + ឧប + ឆិទ + ណ] កិ.ចូលទៅកាត់បង់នូវត្រកូល, ការចូលទៅផ្តាច់បង់នូវត្រកូល, វិ. **កុលំ ឧបច្ឆិន្ទិយតេតិ** >**កុលុបច្ឆេទនំ**, **កុលុបច្ឆេទនំ** >**កុលុបច្ឆេទោ** ។

**កុលុស** នប៉ុ. បាប (ដូច **អកុសល**) ។

**កុល្ល** ប៉ុ. ចង្អេរ (ដូច **សុប្ប**),ផែ, ក្បូន (ដូច **ឧឡុម្ប**) ។

**កុលិ** ធា. **សង្ខានេ ពន្ធុម្ហិ ច កោលតិ**"រាប់, ជាប់,សាច់ឈាមជាប់ខ្សែស្រឡាយ" ភូ. ។ **កុល** នប៉ុ. "វង្ស, ត្រកូល, គ្រួសារ, សង្គម, ផ្ទះ, លំនៅ, ហ្វូង, ពួក, ក្រុម" ។ **កោល** គុ. "អ្នកកើតក្នុងត្រកូល, ន. ឈ្មោះរុក្ខជាតិម្យ៉ាង" ។

**កុវលយ** នប៉ុ. ឧប្បលសាមញ្ញមានផ្កាឈូកជាដើម (ដូច **ឧប្បល**)។

**កុវេណី** ឥ. លប (សម្រាប់ដាក់ត្រី) (ដូច **កុមិន**) ។

**កុវេរានុចរ** ប៉ុ. អមនុស្សជាបរិវាររបស់ព្រះបាទកុវេរមហារាជ ។

**កុវេរ** ប៉ុ. ព្រះបាទកុវេរមហារាជ ជាធំលើយក្ស នៅខាងជើងភ្នំមេរុ (ដូច **វេស្សវណ**) ។

**កុស** ប៉ុ. ស្បូវភ្លាំង, ស្លា (ដូច **ឧព្ព**), ស្លាក (ដូច **សលាកា**) ។

**កុសគ្គ** នប៉ុ. [កុស + អគ្គ] ចុងនៃស្លា (ដែលធ្លាប់ប្រែថា ចុងនៃស្បូវ) ។

**កុសរាជសន្តក** គុ. [កុសរាជ + សន្តក] ជារបស់នៃស្តេចឈ្មោះកុសៈ ។

**កុសល** នប៉ុ. [កុស+អល] (គុណជាត) គួរក្នុងកិ.ផ្តាច់បង់នូវបាប (កុសល,បុណ្យ (ដូច **សុភជ**)គុ. ឈ្លាស, ប៉ិន, ប្រសប់, វាងវៃ ), វិ. **កុសេ បាបច្ឆេទនេ អលន្តិ** >**កុសលំ** ។ (គុណជាត) ផ្តាច់នូវធម៌ដ៏អាក្រក់គឺធម៌ជាអកុសល, វិ. **កុសតិ បាបកេ អកុសលេ ធម្មេ ឆិន្ទតីតិ** >**កុសលំ** ។ ម្យ៉ាងទៀត (កុស + លុ + អ) គុណជាតកាត់នូវកិលេសមានរាគៈជាដើមដេកនៅក្នុងសន្តានដោយអាការៈដែលបណ្ឌិតគួរខ្ពើម, វិ. **កុច្ឆិតេនាការេន សន្តានេ សេន្តីតិ** >**កុសា** , **រាគាទយោ តេ លុនាតិ ឆិន្ទតីតិ** >**កុសលំ** ។ - **កម្មករណ** នប៉ុ. កិ.ធ្វើនូវកម្មជាកុលស ។ -**កម្មករណកាល** ប៉ុ. កាលនៃកិ.ធ្វើនូវកម្មជាកុសល, កាលជាទីធ្វើនូវកម្មជាកុសល ។ -**កម្មប្បតិដ្ឋាករណ** នប៉ុ. កាលជាទីធ្វើនូវទីជាទីពឹងគឺកម្មកុសល, កាលជាទីធ្វើនូវគុណជាតិជាទីពឹងគឺកម្មជាកុសល ។ -**កម្មបថ** ប៉ុ. គន្លងគឺកម្មជាកុសល ។ -**កោដ្ឋាស** ប៉ុ. ចំណែកនៃធម៌ជាកុសល, ចំណែកនៃកម្មជាកុសល ។ -**តា** ឥ. ភាវៈនៃ.....នោះជាអ្នកឆ្លាត, -ឈ្លាស, -ប្រសប់ ។ -**ត្ត** នប៉ុ. ភាវៈនៃ.....នោះជាអ្នកឈ្លាស ។ -**បាថេយ្យ** នប៉ុ. វត្ថុជាប្រយោជន៍ក្នុងផ្លូវជាកុសល ឬ វត្ថុជាប្រយោជន៍ដល់ផ្លូវគឺកុសល, ស្បៀងគឺកុសល, វិ. **បថេ បថស្ស វា ហិតំ** > **បាថេយ្យំ** <**បថ** + **ណេយ្យ** ។ -**វិថិ** ឥ. វិថីនៃចិត្តជាកុសល ។

គុ.ជាខ្លួន, សប្បាយខ្លួន, ឥតរោគ (ដូច **អារោគ្យ**), អ្នកប្រាជ្ញ, អ្នកមានថ្វីដៃ, អ្នកឆ្លៀវឆ្លាស, អ្នកជំនាញ (ដូច**ឆេក**,**កតហត្ថ**),ឥតទោស (ដូច **អនវជ្ជ** ) ។

**កុសលាកុសល** នបុំ. [កុសល + អកុសល] កុសលនិងអកុសល ។ -**កម្មករណ** នបុំ. ជាទីធ្វើនូវកម្មជាកុសលនិងកម្មជាអកុសល ។ -**កម្មពីជ** នបុំ. ពូជគឺកម្មជាកុសលនិងអកុសល។

**កុសលាភិនិព្វត្ត** គុ. [កុសល + អភិនិព្វត្ត] ដែលកើតចំពោះហើយអំពីកម្មជាកុសល, គឺកម្មជាកុសលឲ្យកើតចំពោះហើយ ។

**កុសលូបទេស** បុំ. [កុសល + ឧបទេស] ឧបទេសនៃបុគ្គលអ្នកឈ្លាស, ឧបាយជាគ្រឿងណែនាំនៃបុគ្គលអ្នកឈ្លាស, ឧបាយជាគ្រឿងចូលទៅសម្តែងនៃបុគ្គលអ្នកប្រសប់ ។ <ឧប + ទិស + ណ ។

**កុសា** ឥ. ខ្សែឃ្លុំសេះ, ខ្សែច្រមុះសេះ (ដូច **នាសារជ្ជុ**)។

**កុសិ** ឥ. អវយវៈនៃចីវរ ជាសំពត់វែងៗ គឺអនុវាតទទឹង និងអនុវាតបណ្តោយ និងខ្ទង់វែងក្នុងចន្លោះមួយខណ្ឌ ។

**កុសិនារា** អ.ន. ក្រុងឈ្មោះកុសិនារា, ឈ្មោះទីក្រុងមួយ ក្នុងប្រទេសឥណ្ឌៀ ។

**កុសីត** គុ. [កុ + សទ, សទ>សីទ, ទ>ត + អ] អ្នកលិចចុះ ដោយអាការៈគឺបណ្ឌិតគប្បីខ្ពើម, ម្យ៉ាងទៀត អ្នកលិចចុះ ក្នុងកិលេសគឺបណ្ឌិតគប្បីខ្ពើម (អ្នកខ្ជិល), វិ. **កុច្ឆិតេនាការេន សីទតីតិ** >**កុសីតោ**, **កុច្ឆិតេ កិលេសេ សីទតីតិ**>**កុសីតោ** ។ -**បុគ្គល** បុំ. បុគ្គលអ្នកខ្ជិល ។ - **មាណវ** បុំ. មាណពអ្នកខ្ជិល, មាណពអ្នកខ្ជិលច្រអូស ។

**កុសុម** នបុំ. [កុស + ឧម] ផ្កា, ផ្កាឈើ (ដូច **បុប្ផ**), រដូវងារនៃស្រី (ដូច **ថីរជ** )។

**កុសុម្ភរត្ត** គុ. [កុសុម្ភ + រត្ត] ដែលបុគ្គលជ្រលក់ហើយដោយផ្កាដកគាំ ។

**កុសូល** បុំ. ដោកស្រូវ, កន្លែងសម្រាប់ដាក់វត្ថុមានស្រូវជាដើម (ដូច **កោដ្ឋ**) ។

**កុសេសយ** នបុំ. ផ្កាឈូក (ដូច **បទុម** ) ។

**កុស៑** ធា. ១-**អវ្ហានេ កោសតិ បក្កោសតិ បក្កោសិត្វា បក្កោសេត្វា បក្កោសិតុំ បក្កោសនំ**"ហៅ, ហៅរក" ភូ. ។

២-**រោទនេ កោសតិ**"យំ" ភូ. ។ **កុស៑**ធាតុក្នុងសទ្ទនីតិអស់ត្រឹមប៉ុណ្ណោះ ប៉ុន្តែក្នុងកច្ចាយនៈថា **កុស៑** =**អក្កោសនឆេទនបូរណេសុ អក្កោសតិ បច្ចក្កោសតិ អក្កុដ្ឋោ** "ជេរ" ភូ. (អា+កុស៑, បដិ+អា+កុស៑) ។

៣-**ហរណទិត្តីសុ កុស្យតិ**"នាំទៅ, ភ្លឺស្វាង, រុងរឿង" ទិ. ។

**កុហក** បុំ. [កុហ + ណ្វុ] អ្នកកុហក, អ្នកបំភាន់, អ្នកបញ្ឆោត, អ្នកលលួង, អ្នកបោកប្រាស់, អ្នកញុំាងគេឲ្យភាន់ភាំង, វិ. **កុហយតីតិ** >**កុហកោ** ។ -**ចោរ** បុំ. ចោរអ្នកកុហក ។ -**តាបស** បុំ. តាបសអ្នកកុហក,

តាបសអ្នកញ៉ាំងលោកឲ្យភាន់ភាំង ។ -**ព្រាហ្មណវត្ថុ** នបុំ. រឿងនៃព្រាហ្មណ៍អ្នកកុហក ។សព្ទនេះជាអត្ថន័យ**កុហន**សព្ទ ។

**កុហន** នបុំ. ការប្រព្រឹត្តកោង (ដូច **កុដចរិយា**), បុំ. អ្នកប្រព្រឹត្តកោង, អ្នកកុហកដោយកាយ (ដូច **កុហក**) ។

**កុហរ** នបុំ. គុហា (ដូច **គព្ភរ**),ប្រហោង, រន្ធ (ដូច **ពិល**)។

**កុហិញ្ចនំ** កា.ស. ដូចកុត្ត ។

**កុហឹ** អ.ន. [កឹ + ហឹ, កឹ >កុ] ក្នុងទីណា, ត្រង់ទីណា ។

**កុហិ** ធា. **វិម្ហាបនេ កុហេតិ កុហយតិ កុហកោ កុហនំ កោហញ្ញំ** "កុហក, បំភាន់, ឲ្យភិសវង់" ចុ. ។

**កុឡីរបាទ** បុំ. ក្រែមានជើង ដូចជាជើងក្ដាម ។

**កុឡ** ធា. **យសនេ កុឡតិ**"ស៊ី, ទំពា, កកេរ" ភូ. ។

**កុំកុម** នបុំ. ចន្ទន៍ក្រហម, វត្ថុទាំងឡាយមានចន្ទន៍ក្រហមជាទីបំផុត (ដូច **កស្មីរជ**) ។

**កុំសិ** ធា. **ភាសាយំ កុំសេតិ**, **កុំសយតិ**"ពោល, និយាយ" ចុ. ។

**កូដ** គុ. ឬ ន. [កុ + អដ + អ, កុដ + ណ] ធម្មជាតប្រព្រឹត្តទៅដោយអាការៈគឺបណ្ឌិតគួរខ្ពើម (គុ. កោង, កាច, បៀតបៀន, ដំ, ក្ដៅក្រហាយ,នឹងនួន, មិនកគ្រើក ដូច **និច្ចល**, មិនពិត ដូច **អសច្ច**), វិ. **កុច្ឆិតេនាការេន អដតីតិ** >**កូដំ** ។ -**ជដិល** បុំ. ជដិលកោង, ជដិលកោងកាច ។ -**ដ្ឋករណ** នបុំ. កិ.ធ្វើនូវក្ដីកោង ។ -**ដ្ឋបរាជិត** គុ. អ្នកមានក្ដីកោងចាញ់ហើយ, អ្នកចាញ់ហើយដោយក្ដីកោង ។ -**សក្ខិ** បុំ. សាក្សីកោង, បន្ទាល់កោង ។ -**សហស្ស** នបុំ. ពាន់នៃកំពូល, ពាន់នៃញញួរ ។ ន.បុំ.កំពូល,កំពូលភ្នំ (ដូច **សិខរ**, **គិរិសិខ្គ**),ញញួរ (ដូច **អយោឃន**),ក្បាល (ដូច **សិរ**),គំនរ (ដូច **រាសិ**),យន្ត។ នបុំ. មាយា, អំពើកោង, បោកប្រាស់, បំបាត់ (ដូច **និកតិ**, **ទម្ភ**) ។

**កូដាគារ** នបុំ. [កុដ + អគារ] ផ្ទះប្រកបដោយកំពូល, វិ. **កូដេន យុត្តំ អគារំ** >**កូដាគារំ** ។ ផ្ទះ គឺបុគ្គលសង្គ្រោះហើយដោយកំពូល, វិ. **កូដេន សង្គហិតំ អគារំ** >**កូដាគារំ**, (ផ្ទះមានកំពូល, ភ្នំយោង) ។ -**កណ្ណិកា** ឥ. ហោជាងនៃផ្ទះមានកំពូល ។ -**កុច្ឆិប្បមាណ** គុ. មានផ្ទៃនៃផ្ទះមានកំពូលជាប្រមាណ, មានប្រមាណប៉ុនផ្ទៃនៃផ្ទះមានកំពូល ។ -**មត្ត** គុ. មានផ្ទះគឺបុគ្គលសង្គ្រោះហើយដោយកំពូលជាប្រមាណ, ប៉ុនផ្ទះមានកំពូល ។ -**សត** នបុំ. រយនៃផ្ទះគឺបុគ្គលសង្គ្រោះហើយដោយកំពូល, រយនៃផ្ទះមានកំពូល ។ -**សាលា** ឥ. សាលា (រោង) គឺផ្ទះដែលបុគ្គលសង្គ្រោះហើយដោយកំពូល ។

**កូដ** ធា. **អប្បសាទនេ កូដេតិ កូដយតិ កូដោ** "មិនជ្រះថ្លា, កោង, វៀចវេ, កុហក, បំភាន់, ក្លែង" ចុ. ។ អា. **កូដតាបសោ** "តាបសក្លែងក្លាយ" ។ **កូដា គាវី** "គោញីកៀច, ក្រាញ" ។ **កូដំ រជតំ** "ប្រាក់ក្លែង ឬកាឡៃ" -ស. ។

**កូប** បុំ. រណ្ដៅ (ដូច **អាវាដ**), អណ្ដូងទឹក (ដូច **ឧទបាន**), ក្អម (ដូច **កុម្ភ**) ។

**កូបក** បុំ. ដងក្ដោងទូក ឬ សំពៅ (ដូច **កុម្ភក**) ។

**កូល** នបុំ. [កុល + ណ] (វត្ថុ) បិទរាំងនូវទឹកមិនឲ្យហូរចេញទៅខាងក្រៅ (ច្រាំង, ឆ្នេរដូច **តីរ**), វិ. **កូលតិ អាវរតិ ឧទកំ ពហិ និក្ខមិតុំ ន ទេតីតិ** >**កូលំ** ។

**កូលិ** ធា. **អាវរណេ កូលតិ** "ហាមឃាត់, រាំង" ភូ. ។ **កូលំ** នបុំ. "ច្រាំង, ទ្រនប់,ទំនប់" អា. **នទីកូលេ វសាមហំ**" ខ្ញុំនៅក្បែរច្រាំងស្ទឹង" ។

**កេ** ធា. **សទ្ទេ កាយតិ កាយិតុំ កាយិត្វា** កម្ម. **កិយ្យតិ**"ចេញសំឡេង, ពោល, ថ្លែង, និទាន" ភូ. ។ **ជាតកំ** នបុំ. "ជាតក, រឿងរ៉ាវក្នុងអតីតកាល =ពោលនូវរឿងដែលកើតហើយ" ។

**កេករ** បុំ. មនុស្សភ្នែកស្រលៀង (ដូច **វលិរ**)។

**កេកា** ឥ. សំឡេងយំនៃសត្វក្ងោក (ដូច **សិខណ្ឌិនាទ**) ។

**កេកី** ឥ. សត្វក្ងោក (ដូច **សិខី**)។

**កេចិ** វិ.ស.អ. [កឹ + ចិ] ពួកមួយ, ពួកខ្លះ, អ្នកខ្លះ, នីមួយ ។

**កេដុភ** នបុំ. កេដុភសាស្ត្រ, ជាឈ្មោះគម្ពីរមួយ ។

**កេតកី** ឥ. ដើមកាកែស, លំចេក ។

**កេតន** នបុំ. ទង់ (ដូច **កេតុ, កទលី**),ផ្ទះ (ដូច **គេហ**) ។

**កេតវ** នបុំ. អំពើកោង, បោកប្រាស់, បំបាត់ (ដោយជញ្ជីងជាដើម) (ដូច **កូដ**)។

**កេតុ** បុំ. ទង់ (ដូច **ធជ**), គ្រឿងកំណត់, គ្រឿងសម្គាល់, ស្នាម (ដូច **ចិហន**)។

**កេតិ** ធា. **អាមន្តនេ កេតេតិ កេតយតិ កេតកោ**"ហៅ, ហៅរក" ចុ. ។

**កេទារ** នបុំ. [ក្លេទឬក្លឹទ+អ, លុបល] ស្រែ(ដូច **ខេត្ត**) (វិ. **ក្លេទីយតីតិ** >**កេទារំ**)។ -**ន្តរ** នបុំ. ចន្លោះនៃស្រែ ។ -**មរិយាទា** ឥ. ភ្លឺស្រែ, ភ្លឺនៃស្រែ ។

**កេនិបាត** បុំ. ច្រវា, ចែវ, ថ្មោល (ដូច **អរិត្ត**)។

**កេយូរ** នបុំ. គ្រឿងប្រដាប់ដើមដៃ (ដូច **ពាហុមូលវិភូសន**)។

**កេរាដិកបក្ខភ-ជន** នបុំ. [កេរាដិក + បក្ខ + ភជន] កិ.គប់រកនូវពួកនៃជនអ្នកអែបអប, កិ. គប់រកនូវពួកនៃជនដែលចាក់បណ្ដោយ,ការគប់រកនូវពួកនៃជនអ្នកអួតអាង ។

**កេលាស** បុំ.នបុំ. ភ្នំឈ្មោះកេលាស ឬភ្នំឈ្មោះកីលាស, ភ្នំក្រៃលាស ជាភ្នំមួយក្នុងប្រទេសហិមពាន្ត ។ -**កូដប្បដិភាគ** គុ. មានចំណែកប្រៀបដោយ

កំពូលនៃភ្នំឈ្មោះកៃលាស ។

**កេលេ** ធា. **មមាយនេ កេលាយតិ** "រាប់ ឬ កាន់យកថាជារបស់ខ្លួន, ស្រឡាញ់" ភូ. ។ អា. **ត្វំ កំ កេលាយសិ**"ចុះនាងស្រឡាញ់អ្នកណា?"

**កេលិ** ធា. គតិយំ កេលតិ "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។

**កេវដ្ដ** បុំ. [កេ + វដ្ដ + ណ] ជនអ្នកវិលទៅក្នុងទឹកដើម្បីប្រយោជន៍ដល់កិ. ចាប់នូវត្រី ឬ ជនអ្នកញ៉ាំងទឹកឲ្យវិល (ព្រានប្រមង់, ព្រានសន្ទូច, អ្នកចាប់ត្រី, ព្រានសំណាញ់ ដូច **ជាលិក**), វិ. **កេ ឧទកេ មច្ឆគ-ហណត្ថាយ វដ្ដេតីតិ** >**កេវដ្ដោ**, **កំ ឧទកំ វដ្ដេតីតិ** > **កេវដ្ដោ** ។ -**គាមវាសី** បុំ. ជនអ្នកនៅក្នុងស្រុកនៃព្រានប្រម៉ង់, ជនអ្នកមានកិ.នៅក្នុងស្រុកនៃព្រានប្រមង់ជាប្រក្រតី, វិ. **កេវដ្ដគាមេ វសតីតិ** >**កេវដ្ដគាមវាសី**, **កេវដ្ដគាមេ វសិតុំ សីលមស្សាតិ** >**កេវដ្ដគាមវាសី** ។ -**គាម** បុំ. ស្រុកនៃព្រានប្រមង់ ។ -**ជេដ្ឋក-បុត្ត** បុំ.កូននៃព្រានប្រមង់ជាច្បង, កូនច្បងនៃព្រានប្រមង់ ។

**កេវល** គុ. [កេវ + អល] ទាំងអស់, ទាំងស្រុង, តែម្យ៉ាង, មិនមានសេសសល់, សុទ្ធ(ដូច **អនវសេស**),ច្រើន (ដូច **យេភុយ្យតា**),មិនច្រឡូកច្រឡំ (ដូច **អព្យាមិស្ស**), ព្រាត់ប្រាស (ដូច **វិសំយោគ**), មាំ (ដូច **ទឡ្ហ**), មិនច្រើន (ដូច **អនតិរេក**),ព្រះនិព្វាន, វិ. **កេវនំ បវត្តនំ** > **កេវលំ** ។

**កេវលី** គុ. [កេវល + ល្បុ] មានកំពូលដ៏សុទ្ធ ។

**កេវិ** ធា. **សេវនេ កេវតិ** "សេពគប់, ប្រតិបត្តិ" ភូ. ។

**កេស** បុំ. [កេ + សី + អ] សភាវៈដេកគឺប្រព្រឹត្តទៅឰដ៏ក្បាល (សក់), វិ. **កេ-សិរស្មឹ សយន្តិ បវត្តន្តីតិ** >**កេសា** ។ ម្យ៉ាងទៀត សភាវៈស្ថិតនៅឰដ៏ក្បាល,វិ. **កេ មត្ថកេ សេន្តិ តិដ្ឋន្តីតិ** > **កេសា** ។ -**កល្យាណ**នបុំ. លម្អគឺសក់, លម្អនៃសក់។ -**កលាប** បុំ. បាច់នៃសក់, សំណុំនៃសក់ ។ -**អគ្គមត្ត** គុ. មានចុងនៃសក់ជាប្រមាណ, ប៉ុនចុងនៃសក់ ។ -**មស្សុ** នបុំ. សក់និងពុកមាត់ ។ -**លុញ្ចន** នបុំ. កិ.ដកនូវសក់ ។ -**អាទិសមុហសង្ខាត** គុ. ពោលគឺប្រជុំនៃអាការមានសក់ជាដើម, គឺបណ្ឌិតរាប់ព្រមហើយថាប្រជុំនៃកោដ្ឋាសៈមានសក់ជាដើម ។

**កេសរី** បុំ. រាជសីហ៍ (ដូច **សីហ**) ។

**កេសរ** បុំ. ដើមបុសនាគ (ដូច **បុន្នាគ**),ដើមពកុល (ផ្កុល) (ដូច **វកុស**), កេសរ (ដូច **កិញ្ជក្ខ**) ។

**កេសវ** អ.ន. ឈ្មោះកេសវៈ, ព្រះនារាយណ៍ (ដូច **វាសុទេវ**)។ -**តាបស** បុំ.

តាបសឈ្មោះកេសវៈ ។

**កេសិ** អ.ន. តាបសឈ្មោះកេសី, តាបសឈ្មោះកេសវៈ ។

**កេសោរោបន** នបុំ. [កេស + អវ + រុប + យុ] កិ.ដាច់ចុះនូវសក់, កិ.កោរនូវសក់ ។ -**អត្ថ** បុំ. ប្រយោជន៍ដល់កិ.ដាក់ចុះនូវសក់ ។ -**សត្ថ** នបុំ. សស្ត្រាសម្រាប់ដាក់ចុះនូវសក់, កាំបិតសម្រាប់កោរនូវសក់ ។

**កេឡិ** ឥ. [កិឡ + ឥ] កិ.លេង, កិ.ឡកឡឺយ, កិ.ចំអក, កិ.ចំអកចំអន់, ល្បែង, ការលេង, ចំអក (ដូច **បរិហាស**) (ប្រើជា «**កេលិ**» ក៏មាន) ។

**កោ** វិ.ស.អ. [កឹ + សិ-វិ.] អ្នកណា, ណា, អ្វី, ដូចម្ដេច ។

**កោក** អ.ន. ឈ្មោះកោកៈ ។ -**សុនខលុទ្ទកវត្ថុ** នបុំ. រឿងនៃព្រានព្រោះឆ្កែឈ្មោះកោកៈ, រឿងនៃព្រានអ្នកបណ្ដើរនូវឆ្កែឈ្មោះកោកៈ ។

**កោកនទ** នបុំ. [កោក + នទ + អ] ឈ្មោះកោកនទៈ, ជាទីបន្លឺនៃសត្វធ្វើនូវសំឡេងថាកិកិ ។ ម្យ៉ាងទៀតធម្មជាតញ៉ាំងពួកសត្វធ្វើនូវសំឡេងថាកិកិឲ្យបន្លឺឡើង, វិ. **កោកេ នាទយតីតិ** >**កោកនទំ**, (ឈូកក្រហមដូច **កោកាសក**) ។

**កោកាលិក** អ.ន. ឈ្មោះកោកាលិកៈ ។ -**វត្ថុ** នបុំ. រឿងនៃភិក្ខុឈ្មោះកោកាលិកៈ ។

**កោកាសក** បុំ. ឈូកក្រហម (ដូច **កោកនទ**)។

**កោកិល** បុំ. សត្វតាវៅ (**ដូច បរភត**) ។

**កោក** បុំ. ឆ្កែព្រៃ (ដូច **វក**) ។

**កោចិ** វិ.ស.អ. [កឹ + ចិ + សិ-វិ.] អ្នកណា, អ្នកណានីមួយ, ណានីមួយ, តិចតួច ។

**កោច្ឆ** បុំ. កៅអី, តាំងដ៏សមគួរដល់ជនដ៏ខ្ពង់ខ្ពស់ (ដូច **ភទ្ទបីឋ**)។

**កោជវ** បុំ. កម្រាល, ព្រំ (តាមទម្លាប់ថាអង្រឹង), កម្រាលដ៏វិសេស ។

**កោញ្ច** បុំ. [កោញ្ច + អ] ក្រៀល, សត្វក្រៀល ។ -**រវ** សម្រែកនៃក្រៀល, កិ.ស្រែកនៃក្រៀល, កិ.ស្រែកដូចជាក្រៀល (ដូច **កុន្តនី**)។ -**សកុណា** សត្វស្លាបក្រៀល, សត្វក្រៀល។

**កោញ្ចនាទ** បុំ. សម្រែកដូចសត្វក្រៀលនៃដំរី គឺសំឡេងដំរីស្រែកតែសម្រែកនោះស្រដៀង សំឡេងក្រៀល ។

**កោដបព្វត** បុំ. ភ្នំឈ្មោះកោដបពិត ។ -**មហាវិហារវាសី** បុំ.[កោដបព្វតមហាវិហារ+វស +ណី] អ្នកនៅក្នុងវិហារធំឈ្មោះ**កោដបព៌ត** ។

**កោដរ** បុំ. ប្រហោងឈើ, រន្ធឈើ (ដូច **រុក្ខច្ឆិទ្ទ**) ។

**កោដិ** ឥ. [កុដ + ឥ] កោដិ, ទីបំផុត, ចុង, មុម,ជ្រុង (ដូច **កោណ**),ទីបំផុត (ដូច **ឧក្កំស**),ឈ្មោះសំខ្យាម្យ៉ាងដាក់លេខ ១ មានពិន្ទុ ៧ ។ -**ប្បត្ត** គុ. ដល់ហើយនូវទីបំផុត ។ - **សតសហស្ស** ប.ស. សែននៃកោដិ ។

**កោដិកណ្ណ** គុ. [កោដិ + កណ្ណ] មានត្រចៀកទ្រទ្រង់នូវគ្រឿងសម្រាប់ពាក់មានតម្លៃមួយកោដិ, វិ. **កោដិអគ្ឃនកបិលន្ធនធារិនោ កណ្ណា**

**យស្ស សោ**>**កោដិកណ្ណោ**។

**កោដិតខាណុក** បុំ. [កោដិត + ខាណុក] ដង្គត់ដែលបុគ្គលបោះហើយ, បង្គោលដែលបុគ្គលដាំហើយ, -ដែលបុគ្គលដោតហើយ ។ កោដិត <កុដ+ឥ+ត ។

**កោដិបកោដិ** ឥ. ឈ្មោះសំខ្យាម្យ៉ាង ដាក់លេខ ១ មានពិន្ទុ ២១ ។

**កោដិសិម្ពលី** ឥ. ដើមរកាជ្រៃ (ដូច **រោចន**)។

**កោដុម្ពរ** នបុំ. សំពត់ធ្វើដោយរោមសត្វ ធ្វើឲ្យមានសាច់ល្អិតឬម៉ដ្ឋ ។

**កោដ្ដាបេត្វា** អ. [កុដ្ដ + ណាបេ + ត្វា] ញុំាង...ឲ្យបោះហើយ, -ឲ្យដោតហើយ, -ឲ្យចិញ្ច្រាំហើយ, ... ។

**កោដ្ដេតព្វយុត្តក** គុ. [កោដ្ដេតព្វ + យុត្តក] ជារបស់គួរគឺ...គប្បីដំ, - គប្បីផៃ,... ។

**កោដ្ដេតិ** កិ. [កុដ្ដ + ណេ + តិ-វ.] ដំ, វាយ, បុក, ...។

**កោដ្ដេត្វា** អ. [កុដ្ដ + ណេ + ត្វា] ដំហើយ, ផៃហើយ, វាយហើយ, បុកហើយ, ចិញ្ច្រាំហើយ

**កោដ្ឋ** នបុំ. ដោកស្រូវ, ជង្រុកស្រូវ, ឃ្លាំង (ដូច **កុសូល**), ខាងក្នុងផ្ទះ (ដូច **អន្តោឃរ**) ។ បុំ.ក្រពះ, (ដូច **អន្តោកុច្ឆិ**) ។

**កោដ្ឋគ្គ** គុ. [កោដ្ឋ + អគ្គ] ទានដ៏ប្រសើរគឺបុគ្គលគប្បីឲ្យក្នុងកាលជាទីឡើងកាន់ជង្រុក, ទានដ៏ថ្លោងគឺ......, ទានដ៏លើសគឺ.... ។

**កោដ្ឋសត** គុ. [កោដ្ឋ + សត] រយនៃជង្រុក ។

**កោដ្ឋាគារ** បុំ., នបុំ. [កោដ្ឋ + អគារ] ផ្ទះគឺជង្រុក (ឃ្លាំង) ។

**កោដ្ឋាគារិក** គុ. [កោដ្ឋាគារ + ណិក] អ្នកប្រកបក្នុងផ្ទះគឺជង្រុក, អ្នកប្រកបក្នុងឃ្លាំង (នាយ ឃ្លាំង), វិ. **កោដ្ឋាគារេ និយុត្តោ** >**កោដ្ឋាគារិកោ** ។

**កោដ្ឋាទិ** គុ. [កោដ្ឋ + អាទិ] មានជង្រុកជាដើម ។

**កោដ្ឋាស** បុំ. [កោដ្ឋ + សី + អ] ចំណែក (វិ. **កោដ្ឋំ ឧច្ឆតិ សរីរំ តត្ថ សេតីតិ**>**កោដ្ឋាសោ**)។

**កោដ្ឋាសភេទ** បុំ. ប្រភេទនៃកោដ្ឋាស, សព្ទនេះជាអត្ថនៃវគ្គសព្ទ ។

**កោដ្ឋាសយ** បុំ. ខ្យល់ដេកនៅឬតាំងនៅក្នុងពោះវៀន, ខ្យល់នៅខាងក្នុងនៃពោះវៀន ។

**កោដ្ឋាស** បុំ. ចំណែក (ដូច **ភាគ**) ។

**កោដ្ដន** នបុំ. [កុដ្ដ + យុ] កិ.ដំ, កិ.បុក,....។ -អត្ថ បុំ. ប្រយោជន៍ដល់កិ.ដំ,.... ។ -បចនាទិ គុ. (កិច្ច) មានកិ.បុក,និងកិ. ចម្អិនជាដើម ។

**កោណ** បុំ. ទីបំផុត, ចុង, មុម, ជ្រុង (ដូច **កោដិ**), វត្ថុសម្រាប់ដេញពិណជាដើម (ដូច **វាទិត្តវាទន**, **វីណាទិវាទន**) ។

**កោណ្ឌ** គុ. [កុណ្ឌ + ណ] កំបុត, ខ្លៅ, ឆោត, អាក្រក់, លាមក ។

**កោណ្ឌញ្ញ** អ.ន. ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ។

**កោណ្ឌធាន** អ.ន. ព្រះថេរៈឈ្មោះកោណ្ឌធាន ។ -**ត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះកោណ្ឌធាន ។

**កោតុហល** នបុំ. [កុ + តុល + អល] កិ.ភ្ញាក់ផ្អើល, សេចក្តីជ្រួលជ្រើម, ការរំជួល ។ -**ជាត** គុ. អ្នកមានសេចក្តីភ្ញាក់ផ្អើលកើតហើយ, វិ. **កោតុហលំ ជាតំ យេសំ តេ** >**កោតុហលជាតា** ។

**កោតុហលិក** បុំ. [កោតុហល + ណិក] បុរសឈ្មោះកោតុហលិក, បុរសអ្នកមានសេចក្តីភ្ញាក់ផ្អើល, វិ. **កោតុហលំ យស្ស អត្ថីតិ** >**កោតុហលិកោ** ។ -**ភាល** បុំ. កាលនៃឃោសកៈជាបុរសឈ្មោះកោតុហលិកៈ ។

**កោត្ថុ** បុំ. សត្វចចក (ដូច **សិគាល**) ។

**កោតុហឡ** នបុំ. សេចក្តីភ្ញាក់ផ្អើល (ដូច **កុតូហឡ**) ។

**កោទណ្ឌ** នបុំ. ព្រះកៅទណ្ឌ, ធ្នូ (ដូច **ចាប**) ។

**កោធ** បុំ. [កុធ+ណ] សេចក្តីក្រោធ, សេចក្តីខឹង, កំហឹង, វិ. **កុជ្ឈនំ** > **កោធោ** ។ -**វគ្គវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវកោធវគ្គ, វិ. **កោធវគ្គំ វណ្ណេតិ ឯតាយាតិ** > **កោធវគ្គវណ្ណនា** ។ - **វស** បុំ. អំណាចនៃសេចក្តីក្រោធ ។

**កោធន** បុំ. [កុធ+យុ] (បុគ្គល) អ្នកក្រោធ, អ្នកខឹង, វិ. **កុជ្ឈតីតិ** >**កោធនោ** ។ អ្នកមានកិ.ក្រោធជាប្រក្រតី, វិ. **កុជ្ឈិតុំ សីលមស្សាតិ** > **កោធនោ** ។

**កោធនទ្ធិ** ឥ. [កោធ+នទ្ធិ] ខ្សែជាគ្រឿងចងគឺសេចក្តីក្រោធ, ខ្សែជាគ្រឿងត្របែងគឺសេចក្តីក្រោធ ។

**កោធនមត្ត** គុ. [កោធន + មត្ត] ទោសជាតគ្រាន់តែសេចក្តីក្រោធ ។

**កោធន** បុំ. អ្នកក្រោធ, អ្នកខឹង (ដូច **រោសន**) ។

**កោធាភិភូ** គុ. [កោធ + អភិ + ភូ + អ] អ្នកគ្របសង្កត់នូវសេចក្តីក្រោធ, វិ. **កោធំ អភិភវតីតិ** >**កោធាភិភូ** ។

**កោធាភិភូត** គុ. [កោធ+អភិភូត] អ្នកគឺសេចក្តីក្រោធគ្របសង្កត់ហើយ , វិ. **កោធេន អភិភូតោ** >**កោធាភិភូតោ** ។

**កោធុប្បាទ** បុំ. [កោធ + ឧប្បាទ] កិ.ញ៉ាំងសេចក្តីក្រោធឲ្យកើតឡើង, កិ.កើតឡើងនៃសេចក្តីក្រោធ ។

**កោធ** បុំ. សេចក្តីក្រោធ, សេចក្តីខឹង (ដូច **រោស**)។

**កោនាគមន** អ.ន. ព្រះពុទ្ធព្រះនាមកោនាគមនៈ ។

**កោប** បុំ. [កុប + ណ] កិ.កម្រើក, សេចក្តីក្រោធ, សេចក្តីខឹង, កំហឹង, វិ. **កុបនំ** > **កោបោ**។ -**និព្វាបនមត្ត** គុ. (កុសល) ត្រឹមតែកិ.ញ៉ាំងសេចក្តីក្រោធឲ្យរលត់ ។ -**មត្ត** គុ. ទោសជាតត្រឹមតែសេចក្តីក្រោធ, ទោសជាតគ្រាន់តែកិ.កម្រើក។

**កោបិន** នបុំ. អំពើមិនគួរធ្វើ (ដូច **អការិយ**), អង្គជាតិ, អវយវៈដែលគួរលាក់

(ដូច **គុយ្ហត្ថ**),សម្បកឈើ (ដូច **ចីរ**) ។

**កោបី** បុំ. អ្នកក្រោធ, អ្នកខឹង (ដូច **កោធន**) ។

**កោបេតុំ** អ. [កុប + ណេ + តុំ] ដើម្បីញ៉ាំង....ឲ្យកម្រើកបាន ។

**កោមល** គុ. ទន់, ល្អិត (ដូច **មុទុ**) ។

**កោមារភច្ច** បុំ. [កុមារភត + ណ្យ] ពេទ្យដែលអភយរាជកុមារឲ្យចិញ្ចឹមហើយ, ពេទ្យឈ្មោះកុមារភច្ចៈ, វិ. **កុមារេន ភតោ បោសាបិតោតិ**> **កុមារភតោ**, **កុមារភតោ ឯវ** >**កោមារភច្ចោ** ។

**កោមុទី** ឥ. [កោមុទ+ណី] ជាទីរីកនៃផ្កាកុមុទ, ពន្លឺព្រះចន្ទ, ខ្នើត (ដូច **ជុណ្ហា**) (វិ. **កុយំ បថវិយំ មោទន្តីតិ** >**កុមុទា**, **កុមុទានំ សមូហោ** > **កោមុទោ**, **កោមុទោ ឯត្ថ អត្ថីតិ**>**កោមុទី** )។

**កោរក** បុំ. ផ្កានិងផ្លែដែលចម្រើន (ដូច **កលិកា**) ។

**កោលក** នបុំ. ក្រវាញ (ដូច **តក្កោល** ) ។

**កោលក** នបុំ. ម្រេច (ដូច **មរិច** )។

**កោលដ្ឋិមត្ត** គុ. [កោលដ្ឋិ + មត្ត] មានគ្រាប់នៃក្របៅជាប្រមាណ, ប៉ុនគ្រាប់នៃក្របៅ ។ កោលដ្ឋិ <កោល + អដ្ឋិ ។

**កោលម្ព** នបុំ. ថ្លាង, ឆ្នាំង (ដូច កុម្ភី) ។

**កោលរុក្ខ** បុំ. [កោល + រុក្ខ] ដើមនៃក្របៅ ។ -**វាសី** បុំ. អ្នកនៅទៀបដើមនៃក្របៅ, អ្នកមានកិ.នៅទៀបដើមនៃក្របៅជាប្រក្រតី ។

**កោលវល្លី** ឥ. ដីប្លីធំ, ជាភ្លូ (ដូច **ឥតបុប្ផលី** ) ។

**កោលាប** គុ. [កុល + អាប] ពុក, ឈើពុក, (ប្រើជា **កោឡាប** ក៏មាន) ។

**កោលាហល** បុំ. [កុល+អាហល] កោលាហល, ការជ្រួលជ្រើម, សំឡេងគឹកកង, សំឡេងជាគ្រឿងបាននូវកិ.ប្រសព្វរាប់(ដូច **កលហលោ**) (វិ. **កោលនំ** > **កោលោ**, **តមាហលតិ វិន្ទតីតិ** >**កោលាហលោ** )។

**កោលិត** គុ. [កុល + ណិក] អ្នកកើតក្នុងត្រកូល, វិ. **កុលេ ជាយតីតិ** >**កោលិកោ**, **សោ ឯវ** >**កោលិកោ** ។ អ.ន. ឈ្មោះកោលិតៈ, ព្រះនាមព្រះមោគ្គល្លាន ។ -**គាម** បុំ. កោលិតគ្រាម, ស្រុកឈ្មោះកោលិតៈ។ -**បរិព្វាជក** បុំ. បរិព្វាជកឈ្មោះកាលិតៈ ។ -**មាណវ** បុំ. មាណពឈ្មោះកោលិតៈ ។

**កោលិយ** គុ. [កោល+ណិយ] អ្នកកើតទៀបដើមក្របៅ ឬអ្នកនៅទៀបដើមក្របៅ (ក្រុងឈ្មោះកោលិយ), វិ. **កោលរុក្ខេ ជាយន្តីតិ** >**កោលិយា**, **កោលរុក្ខេ វសន្តីតិ វា** >**កោលិយា** ។ -**កម្មករ** បុំ. ជនអ្នកធ្វើនូវការងារនៃព្រះរាជានៅក្នុងក្រុងកោលិយៈ, កម្មករនៃអ្នកក្រុងកោលិយៈ ។ -**ធីតា** ឥ. ធីតានៃជនអ្នកក្រុងកោលិយៈ ។ -**នគរវាសី** បុំ. អ្នកនៅក្នុងក្រុងកោលិយៈ ។

**កោលី** ឥ. ដើមក្របៅ (ដូច **ពទរី** ) ។

**កោល** បុំ. ដើមពុទ្រា (ពុទ្រា) (ដូច **ពទរ**) ។

**កោវិទ** បុំ. [កុ + វិទ + ណ] អ្នកបាននូវវាចា, អ្នកបាននូវសម្តី (អ្នកឆ្លាត, ឈ្លាស, វាងវៃ ដូច **ពុធោ**),វិ. **កុំ វាចំ វិន្ទតីតិ** >**កោវិទោ** ។

**កោវិឡារ** បុំ. ដើមបារិច្ឆត្តកព្រឹក្ស, ដើមរលួសផ្អុង (ដូច **យុគ្គបត្ត**) ។

**កោវិលាររុក្ខ** បុំ. [កោវិលារ + រុក្ខ] ដើមរលួស, ដើមរលួសផ្អុង ។ ប្រើជា **កោវិឡារ** ក៏មាន ។ <កុ + វិទ + អារ = វិ. **កុំ បថវឹ វិទារយតិ មូលេនាតិ** > **កោវិឡារោ** ។

**កោស** បុំ. ផ្កាក្តោប, ផ្កាក្រពុំ (ដូច **មុកុល**),ឃ្លាំង, គំនរទ្រព្យ (ដូច **ធនរាសិ**), ស្រោមនៃដាវជាដើម (ដូច **នេត្តឹសាទិបិធាន**)។

**កោស** បុំ. ចំនួនប្រាំរយជួរធ្នូ (ក្រោស) ។

**កោសជ្ជ** នបុំ. [កុសីត + ណ្យ] ភាវៈនៃបុគ្គលអ្នកលិចចុះក្នុងកិលេស គឺបណ្ឌិតគប្បីខ្ពើម (ភាវៈនៃបុគ្គលខ្ជិល, ភាវៈនៃសេចក្តីខ្ជិល, សេចក្តីខ្ជិល) វិ. **កុច្ឆិតេ កិលេសេ សីទតីតិ**>**កុសីតោ**, **កុសីតស្ស ភាវោ**> **កោសជ្ជំ**, **កុសីតោ ឯវ វា**>**កោសជ្ជំ** ។ -**វស** បុំ. អំណាចនៃសេចក្តីខ្ជិល ។

**កោសផល** នបុំ. ក្រវាញ (ដូច **តក្កោលំ**)។

**កោសម្ពិ** អ.ន. ឈ្មោះទីក្រុងមួយ ក្នុងប្រទេសឥណ្ឌៀ ។

**កោសម្ពិក** គុ. [កោសម្ពី+ណិក] អ្នកនៅក្នុងក្រុងកោសម្ពី,វិ. **កោសម្ពិយំ វសន្តីតិ** > **កោសម្ពិកា** ។ -**វត្ថុ** នបុំ. រឿងនៃភិក្ខុអ្នកនៅក្នុងក្រុងកោសម្ពី ។ -**សេដ្ឋី** បុំ. សេដ្ឋីអ្នកនៅក្នុងក្រុងកោសម្ពី ។ -**វាសិតិស្សត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះតិស្សៈនៅក្នុងក្រុងកោសម្ពី ។

**កោសល** អ.ន. ដែនឈ្មោះកោសល ។ -**ជនបទ** បុំ. ជនបទឈ្មោះកោសល ។
បុំ. -**នរិន្ទ** គុ. ព្រះរាជាជាធំជាងនរៈឈ្មោះកោសល, ព្រះរាជាជាធំរបស់នរៈក្នុងដែនកោសល ។ -**រដ្ឋ** នបុំ. ដែនឈ្មោះកោសល ។ -**រាជ** បុំ. ស្តេចជាធំក្នុងដែនកោសល ។ -**សំយុត្ត** អ.ន. គម្ពីរឈ្មោះកោសលសំយុត្ត ។

**កោសិក** បុំ. ឈ្មោះឈើម្យ៉ាងប្រើធ្វើថ្នាំ (ដូច **គុគ្គុឡុ**)។

**កោសិយ** អ.ន. ឈ្មោះកោសិយៈ, ព្រះឥន្ទ (ដូច **មឃវា**, **ឥន្ទ**), សត្វមៀម (ដូច
បុំ. **ឧលូក**, **វាយសារិ**)។

**កោសី** ឥ. ស្រោម (នៃដាវជាដើម) ។

**កោសុ** និ. [កោ + សុ ] អ្នកណាអេះ, អ្នកណាហ្ន៎ ។

**កោសេយ្យ** នបុំ. កម្រាលធ្វើដោយសូត្រប៉ាក់ដោយរតនៈផង, សំពត់សូត្រ (ដូច **កិមិជ**) ។

**កោស** បុំ. មួយក្រោសត្រូវជា ៥០០ ជួរធ្នូ, ពងល្វា (ដូច **អណ្ឌ**), គំនរទ្រព្យ ឬ ឃ្លាំង, ប្រាក់ (ដូច **ហិរញ្ញ**) ។

| | | |
|---|---|---|
| **កោហញ្ញ** | នបុំ. | [កុហក + ណ្យ] ភាវៈនៃអ្នកកុហក, ភាវៈនៃអ្នកញ៉ាំងលោកឲ្យភាន់ភាំង, វិ. **កុហកស្ស ភាវោ >កោហញ្ញំ** ។ |
| **កោឡាបរុក្ខ** | បុំ. | [កោឡាប + រុក្ខ] ឈើពុក, ដើមឈើពុក ។ |
| **ក្រិយា** | ឥ. | ការងារ, ការធ្វើ, អំពី (ដូច **កម្មំ**),ក្រិយាចិត្ត (២០) ។ |
| **ក្រិយាចិត្ត** | នបុំ. | ក្រិយាចិត្ត, ក្រិយាចិត្តមាន ២០ គឺអហេតុកក្រិយា ៣ មហាក្រិយា ៨ មហគ្គតក្រិយា ៩ ។ |
| **ក្វ** | និ. | ដូច **កុត្ថ** ។ |
| **កំ** | វិ.ស. | [កឹ + អំ-វិ] អ្នកណា, បុគ្គលណា ។នបុំ. ទឹក (ដូច **ឧទកំ**)។ និបាត |
| | អ. | ប្រព្រឹត្តទៅក្នុងអត្ថគឺ **វារិ** ទឹក, **មុទ្ធ** ក្បាល ។ |
| **កំកជ** | បុំ. | គ្រោះ (ដូច **សន្នាហ**)។ |
| **កំកណ** | នបុំ. | គ្រឿងប្រដាប់ដៃ (ដូច **ករភូសា**) ។ |
| **កំខា** | ឥ. | សេចក្ដីសង្ស័យ (ដូច **សំកា**)។ |
| **កំស** | បុំ. | [កន + ស] មាស, សំរិទ្ធិ, រគាំង។ - **តាលសរ** បុំ. សំឡេងនៃរគាំង, សូរនៃរគាំង ។ -**ថាល** នបុំ. ភាជនៈជាវិការៈនៃមាស ឬថាសជាវិការៈនៃសំរិទ្ធិ ។- **ភាជនបូរ** គុ. ដ៏ពេញក្នុងភាជនៈជាវិការៈសំរិទ្ធិ -នៃមាស ។ - **បាតិ** ឥ. ភាជនៈជាវិការៈនៃមាស (ភាជនៈមាស) ។ **ភាជនសាមញ្ញ**(ដូច **បត្ត**), លោហៈទាំងពួង (ដូច **សព្វលោហ**), ចាន, ភាជនសម្រាប់បរិភោគ (ដូច **ភុញ្ជនបត្ត**), ប្រមាណ ៤ កហាបណ (ដូច **ចតុក្កហាបណ**)។ |

# ខ

**ខគ** ប៉ុ. សត្វបក្សី (ដូច **សកុណា**)។

**ខគាធិបតិ** នប៉ុ. ពងនៃសត្វបក្សីជាដើម, សព្ទនេះជាអត្ថនៃ **អណ្ឌ** សព្ទ ។

**ខគាធិពន្ធន** នប៉ុ. ចំណងនៃសត្វមានបក្សីជាដើម, សព្ទនេះជាអត្ថនៃ **បាស** សព្ទ ។

**ខគ្គ** ប៉ុ. ដាវ, ព្រះខ័ន, គ្រប៊ី (ដូច **នេត្តឹស, អសិ**), សត្វរមាស (ដូច **ភណ្ឌក, បលាសាទ**) ។

**ខគ្គកោស** ប៉ុ. ស្រោមដាវ, សព្ទនេះជាអត្ថនៃ **បរិវារ** សព្ទ ។

**ខគ្គខគ្គ** នប៉ុ. អវយវៈនៃដាវ (មុខដាវ), សព្ទនេះជាអត្ថនៃ **ធារា** សព្ទ ។

**ខគ្គវិសាណ** ប៉ុ. សត្វរមាស (ដូច **ខគ្គ**) ។

**ខចិត្វា** អ. [ខច + ត-អា.+ត្វា] វិចិត្រហើយ, ច្នៃហើយ ។

**ខជ្ជ** នប៉ុ. [ខាទ + ត] វត្ថុគឺបុគ្គលគប្បីទំពាស៊ី, របស់ដែលគួរទំពាស៊ី (បង្អែម, ចំណី), វិ. **ខាទិតព្វន្តិ** >**ខជ្ជំ** ។ - **មំស** នប៉ុ. បង្អែមនិងសាច់ ។ -**វិភត្តិ** ឥ. វត្ថុគឺបុគ្គលគប្បីទំពាស៊ីគឺបុគ្គលធ្វើឲ្យវិសេស, -ឲ្យប្លែក, បង្អែមដ៏ប្លែក ។

**ខជ្ជក** នប៉ុ. [ខាទ + ត + ក-ស.] វត្ថុគឺបុគ្គលគប្បីទំពាស៊ី ( បង្អែម,ចំណី ), វិ. **ខាទិតព្វន្តិ** >**ខជ្ជំ, ខជ្ជំ ឯវ** >**ខជ្ជកំ** ។

**ខជ្ជន្តរ** នប៉ុ. បង្អែមម្យ៉ាង, សព្ទនេះជាអត្ថនៃ **សត្តុ** សព្ទ ។

**ខជ្ជុ** នប៉ុ. រោគរមាស់ (ដូច **កណ្ឌុវន**) ។

**ខជ្ជុរី** ឥ. ដើមល្មើ, ផ្កាវ (ដូច **សិន្ទិ**)។

**ខជ្ជោបនក** ប៉ុ. អំពិលអំពែក ។ - **សទិស** គុ. ប្រាកដស្មើដោយអំពិលអំពែក, ដូចជាអំពិលអំពែក, ។

**ខជិ** ធា. **មជ្ជនសុទ្ធិព្យថនេសុ ខជ្ជតិ**"ស្ងៀប, រមាស់, ក្រហាយ, ធ្វើឲ្យស្អាត, ធ្វើឲ្យលំបាក, អេះ" ភូ. ។ **ខជ្ជុរ** ប៉ុ. ឈ្មោះរុក្ខជាតិម្យ៉ាង ។ **ខជ្ជុរី** ឥ."ដើមល្មើ, ផ្កាវ, ឥន្ទលាំ" ។ **ខជ្ជុ** ឥ. "រោគរមាស់" ។

**ខជិ** ធា. ១-**មន្ថេ** (**វិឡោលនេ**) **ខជតិ**"កូរ,វីក,វិត,ច្របល់,ច្ពេច,កូត"ភូ. ។ ២-**គតិវេកល្លេ ខញ្ជតិ ខញ្ជិតំ ខញ្ជិត្វា**"ខ្វះខាតដំណើរ, ដើរបានដោយលំបាក, ខ្វក" រុ. ។ អា. **ភិស្សុ ឥន្ធេ អយ្យោ ខញ្ជតិ**? -ស. ។ **ខញ្ជ** ប៉ុ. មនុស្សខ្វក, អា. **ឧភោ ខញ្ជា** ស.។ ៣-**ទានគលីសុ ខញ្ជតិ ខញ្ជនំ**"ឲ្យ, ផ្តល់, ទៅ, ដល់, ប្រព្រឹត្តទៅ" រុ. ។

**ខញ្ជ** គុ. [ខញ្ជ + អ] ខ្វក, មនុស្សខ្វក(ដូច **ខោណ្ឌ**), វិ. **ខញ្ជតីតិ**> **ខញ្ជោ** ។

-**ប្បហារ** បុំ. កិ.ប្រហារនៃមនុស្សខ្វក, កិ.ប្រហារនូវអាចម៍នៃពពៃនៃមនុស្សខ្វក (កិ.ប្រហារដោយអាចម៍នៃពពៃ) ។

**ខញ្ជន** បុំ. សត្វប្រវឹក ។

**ខញ្ជរីដ** បុំ. សត្វប្រវឹក ។

**ខញ្ជ** ធា. **កិច្ចជីវនរក្ខនេសុ ខញ្ជេតិ ខញ្ជយតិ** "ចិញ្ចឹមជីវិតបានដោយលំបាក, រក្សា, ថែទាំ" ចុ. ។

**ខជក** បុំ. ក្តាប់ដៃ (ដូច **មុដ្ឋិ**)។

**ខជខជសទ្ទ** បុំ. [ខជខជ + សទ្ទ] សំឡេងថាខជខជៈ ។

**ខដ្ឌ** ធា. **សំវរណោ ខដ្ឌេតិ ខដ្ឌយតិ**"សង្រួម, ការពារ" ចុ. ។

**ខឌិ** ធា. **ខណ្ឌោ ខណ្ឌតិ ខណ្ឌិតោ**"ខ័ណ្ឌ, បែងចែក, ធ្វើឲ្យជាផ្នែក" រុ. ។ **ខណ្ឌ** បុំ. "ដុំ, ផ្នែក, ពួក" បុំ. នបុំ. "កន្លះ, ពាក់កណ្ដាល" ។

**ខណ** បុំ. [ខិ+យុ] កាលជាទីអស់ទៅ, ឬ កាលជាទីអស់ទៅនៃអាយុនៃសត្វ (ខណៈ, ស្របក់, មួយរំពេច **និព្យាបារដ្ឋិតិ**), វិ. **ខីយតិ ឯត្ថាតិ** > **ខណោ**, **សត្តានំ អាយុ ខីយតិ ហាយតិ ឯត្ថ ភាលេតិ វា** > **ខណោ** ។ - **មត្ត** គុ. កាលត្រឹមតែមួយខណៈ ។ -**មុហុត្ត** បុំ. មួយខណមុហុត្ត ចំនួន ១០ មុហុត្ត ។-**លយ** មួយខណលយ ចំនួន ១០ លយ ។ មួយខណៈ កំណត់កាលផ្ទាត់ម្រាមដៃ ១០ ដង (**ទសច្ឆរាកាល**) ។

**ខណា** ឥ. មួយខណៈ កំណត់ចំនួន ១០ អច្ឆរកាល គឺកាលដែលផ្ទាត់ម្រាមដៃ ។

**ខណាតីត** គុ. [ខណ+អតីត] មានខណៈកន្លងទៅហើយ, កន្លងហើយនូវខណៈ ។

**ខណិក** គុ. [ខណ + ណិក] ប្រព្រឹត្តទៅក្នុងខណៈ, ប្រព្រឹត្តទៅអស់កាលមួយស្របក់ ឬមួយរំពេច ។ -**ឥត្តរប្បច្ចុបដ្ឋានត្ត** បុំ. សេចក្តីថាកាយប្រព្រឹត្តទៅក្នុងខណៈ និងកិ.ប្រាកដចំពោះថាជារបស់លាមក, អត្ថថាកាយជាទីចូលទៅតាំងនៅចំពោះថាជារបស់លាមក ប្រព្រឹត្តទៅអស់កាលមួយរំពេច ។

**ខណិត្តិ** នបុំ. ចប, ចបជីក (ដូច **អវទារណា**) ។

**ខណ្ឌ** បុំ., គុ. [ខណ្ឌ + អ] កំណាត់, ចំណែក, ដុំ, បាក់, ដាច់, កន្លះ (ដូច **អឌ្ឍ**), ដុំស្ករអំពៅ (ខណ្ឌស្ករ) (វិ. **ខណ្ឌយតិ សមុទាយមីតិ** > **ខណ្ឌោ**) ។ - **ទន្ត** គុ. អ្នកមានធ្មេញបាក់ ។ -**សីលាទិតា** ឥ. ភាវៈនៃទោសជាតមានសីលដាច់ជាដើម, វិ. **ខណ្ឌំ សីលំ** >**ខណ្ឌសីលំ**, **ខណ្ឌសីលំ អាទិ យស្ស តំ** >**ខណ្ឌសីលាទិ**, **ខណ្ឌសីលាទិនោ ភាវោ** >**ខណ្ឌសីលាទិតា** ។

**ខណ្ឌន** នបុំ. ការកាត់ (ដូច **ឆេទន**)សព្ទនេះជាអត្ថនៃ**អវទានសព្ទ** ។

**ខណ្ឌាខណ្ឌិក** គុ. [ខណ្ឌាខណ្ឌ+ណិក] មានបំណែកតូចនិងបំណែកធំ (ឲ្យជារបស់មានបំណែកតូចនិងបំណែកធំ),វិ. **ខណ្ឌាខណ្ឌា យស្ស អត្ថីតិ**> **ខណ្ឌាខណ្ឌិកំ**។

**ខណ្ឌាទិភាវប្បត្ត** គុ. [ខណ្ឌាទិភាវ + បត្ត] ដល់ហើយនូវភាវៈនៃទោសជាតមានសីលដាច់ជាដើម ។

**ខណ្ឌិច្ចាទិ** គុ. [ខណ្ឌិច្ច + អាទិ] (វិការៈ) មានភាវៈនៃបុគ្គលមានធ្មេញបាក់ជាដើម, វិ. **ខណ្ឌិតស្ស ភាវោ** >**ខណ្ឌិច្ចំ** ។

**ខណ្ឌិ** ធា. **ខណ្ឌោ ខណ្ឌេតិ ខណ្ឌយតិ**"កាត់, បែងចែក" ចុ. ។

**ខត្តា** បុំ. នាយសារថី (ដូច **សូត**), អ្នកឆ្លើយ, អ្នកដោះស្រាយ, អ្នកនាំមកនូវពាក្យ (ដូច **បដិហារ**)។

**ខត្តិយ** បុំ. [ខត្ត + ឥយ] ពូជពង្សនៃខត្តៈ, ជាធំក្នុងខេត្តដែន, ជាអធិបតីនៃស្រែ (ក្សត្រិយ៍ ដូច **រាជញ្ញ**)។ -**កញ្ញា** ឥ. កញ្ញានៃក្សត្រិយ៍ ។ -**ធីតា** ឥ. ធីតានៃក្សត្រិយ៍ ។ -**ប្បព្វជិត** គុ. ជាក្សត្រិយ៍បួសហើយ, ជាក្សត្រិយ៍ទ្រង់ផ្នួសហើយ ។ -**បរិវារ** គុ. មានក្សត្រិយ៍ជាបរិវារ ។ -**ព្រាហ្មណកុល** នបុំ. ត្រកូលនៃក្សត្រិយ៍ និងត្រកូលនៃព្រាហ្មណ៍ ។ -**មហាសាលព្រាហ្មណមហាសាលកុល** នបុំ. ត្រកូលនៃខត្តិយមហាសាលនិងព្រាហ្មណមហាសាល។ -**មហាសាល** នបុំ. ក្សត្រិយ៍ជាមហាសាល ។ -**មាន** នបុំ. មានះនៃក្សត្រិយ៍, មានះថាជាក្សត្រិយ៍, វិ. **ខត្តិយោ** (**អហំ**) **ឥតិ មានោ** >**ខត្តិយមានោ** ។ -**រាជធីតា** ឥ. ធីតានៃព្រះរាជាជាក្សត្រិយ៍ ។ -**មាយា** ឥ. មាយានៃក្សត្រិយ៍, ពុតនៃក្សត្រិយ៍ ។ -**វំស** បុំ. វង្សនៃក្សត្រិយ៍ ។ -**សុខុមាល** គុ. ជាក្សត្រិយ៍ចម្រើននៅក្នុងសេចក្ដីសុខ, ជាក្សត្រិយ៍ចម្រើនដោយសេចក្ដីសុខ, ជាក្សត្រិយ៍ល្អិតទន់, ជាក្សត្រិយ៍ទន់ល្អ ។

**ខត្តិយមហាសាល** បុំ. ក្សត្រិយ៍ដែលមានទ្រព្យចំនួនមួយរយកោដិ ទុកដាក់ ចាយវាយ ១ ថ្ងៃចំនួន ២០ អម្ពណហៅថា **ខត្តិយមហាសាល** ។

**ខត្តិយា** ឥ. នាងក្ស័ត្រិយ៍ ។

**ខត្តិយានី** ឥ. នាងក្ស័ត្រិយ៍ ។

**ខត្ត** បុំ. ក្ស័ត្រ (ដូច **ខត្តិយ** )។

**ខទិរ** បុំ. [ខទ + ឥរ, ខាទ + រ] (ឈើ) ជាគ្រឿងជាប់មាំ, ឬឈើដែលបាណកជាតតែងទំពាស៊ី (គគីរ, សង្កែ, ដើមគគីរ, ដើមពពេល ដូច **ទន្តធាវន**), វិ. **ខទន្តិ ទន្តានេនាតិ** >**ខទិរោ**, **ខាទិយតិ បាណកេហីតិ វា** >**ខទិរោ** ។ -**ខាណុ** បុំ., នបុំ. ដង្កត់នៃឈើគគីរ។ -**គហណ**, -ន នបុំ. ស្បាតនៃគគីរ, ជាទីស្បាតដោយដើមគគីរ (ជាទីស្មុគស្មាញដោយដើមសង្កែ) ។ -**អង្គារជាតក** នបុំ. ជាតក

គឺបណ្ឌិតកំណត់ហើយដោយរងើកភ្លើងនៃឈើគគីរ ។ -**អង្គារ-រាសី** បុំ. គំនរនៃរងើកភ្លើងជាវិការៈនៃឈើគគីរ ។ -**ត្ថម្ភ** បុំ. សសរជាវិការៈនៃឈើគគីរ ។ -**ទារុ** នបុំ. ឧសនៃឈើគគីរ, ឧសជាវិការៈនៃឈើគគីរ, ឧសជាវិការៈនៃដើមសង្កែ ។ -**រុក្ខកណ្តក** បុំ. បន្លានៃឈើគគីរ, បន្លានៃឈើសង្កែ ។ -**រុក្ខ** បុំ. ដើមនៃគគីរ. ដើមនៃសង្កែ ។ -**វនិយរេវតត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះរេវតៈនៅក្នុងព្រៃនៃឈើគគីរ, -នៅក្នុងព្រៃដ៏ដេរដាសដោយដើមគគីរ ។

**ខទ្ទិ** ធា. **ឌំសនេ ខទ្ទតិ** "ខាំ, ចោះ, ចុច, (នៃសត្វ)" ភូ. ។

**ខទិ** ធា. **ធិតិហីសាថិរិយេសុ ខទតិ**"ណែន, បៀតបៀន, មាំមួន" ភូ. ។ **ខទិរ** បុំ. រុក្ខជាតិម្យ៉ាងមានសាច់ណែនស្ថិតជាប់បូរាណថា ដើមគគីរ (សង្កែ)។

**ខនតិ** កិ. [ខន + អ + តិ-វ.] ជីក, គាស់ ។

**ខនថ** កិ. [ខន + អ + ថ-ប] ចូរជីក, ចូរគាស់ ។

**ខនាបេត្វា** អ. [ខន + ណាបេ + ត្វា] ញុំាង....ឲ្យជីកហើយ ។

**ខនាបេស្សាមិ** កិ. [ខន + ណាបេ + ស្សាមិ-ភ.] នឹងញុំាង...ឲ្យជីក ។

**ខនិ** កិ. [ខន + អ + ឦ-អជ្ជ.] ជីកហើយ ។

**ខនិត** គុ. [ខន + ឥ-អា. + ត] គឺ....ជីកហើយ ។

**ខនិត្វា** អ. [ខន + ឥ-អា. + ត្វា] ជីកហើយ ។

**ខនិយមាន** គុ. [ខន + ឥ-អា. + យ + មាន] គឺ....កាលជីក ។

**ខន្តា** បុំ. អ្នកអត់ធន់ (ដូច **តិតិក្ខវា**) ។

**ខន្តិ** ឥ. [ខម+តិ] ខន្តិ, សេចក្តីអត់ធន់ (ដូច **តិតិក្ខា**),សេចក្តីគាប់ចិត្ត (ដូច **រុចិ**), វិ. **ខមនំ** >**ខន្តិ** ។ - **ពល** នបុំ. កម្លាំងនៃខន្តី។ -**មេត្តោទក** នបុំ. ទឹកគឺខន្តីនិងមេត្តា, ខន្តីនិងមេត្តាដូចជាទឹក ។ -**វាទិជាតក** នបុំ. ជាតកគឺបណ្ឌិតកំណត់ហើយដោយតាបសឈ្មោះខន្តិវាទី ។ -**វាទិភូត** គុ. ជាតាបសឈ្មោះខន្តិវាទី, ជាតាបសឈ្មោះខន្តិវាទីកើតហើយ ។ -**សោរច្ច** នបុំ. ខន្តីនិងភាវៈនៃបុគ្គលអ្នកត្រេកអរដោយល្អ, ខន្តិនិងភាវៈនៃសេចក្តីត្រេកអរដោយល្អ, សេចក្តីអត់ធន់និងសេចក្តីស្ងប់ស្ងៀម (សោរច្ច <សុរត + ណ្យ = វិ. **សុរ-តស្ស ភាវោ** >**សោរច្ចំ**, **សុរមោ ឯវ** >**សោរច្ចំ**)។

**ខន្តិមា** បុំ. អ្នកមានសេចក្តីអត់ធន់ (ដូច **តិតិក្ខវា**) ។

**ខន្ធិ** ធា. **គតិសោសនេសុ ខន្ធតិ ខន្ធោ** "ទៅ, ដល់, ប្រព្រឹត្តទៅ, ស្ងិត, ស្ងួត (ក្រៀម)" ។

**ខន្ធ** បុំ. [ខន + ធ ឬខម + ត] ខន្ធ, គំនរ, កង, ដើម, កំណាត់ឈើ, ហ្វូង, ពួក, ប្រជុំ, ក ។ -**អដ្ឋិក** នបុំ. ឆ្អឹងនៃក ។ -**ទុក្ខ** នបុំ. ទុក្ខគឺការរក្សានូវខន្ធ, ទុក្ខដែលកើតអំពីខន្ធ, ទុក្ខប្រចាំខន្ធ ។ -**ធាតុអាយតន-ឥន្ទ្រិយពលពោជ្ឈង្គសតិប្បដ្ឋានបរិទីបក** គុ. ជាគ្រឿងសម្តែងនូវខន្ធ និងធាតុ និងអាយតនៈ និងឥន្ទ្រិយ និងពលៈ និងពោជ្ឈង្គ និងសតិប្បដ្ឋាន ។ -**ធាតុអាយតនពោធិបក្ខិយធម្ម** បុំ. ខន្ធនិងធាតុនិងអាយតនៈនិងពោធិបក្ខិយធម៌ ។ -**ធាតុអាយតន-នានិភេទ** គុ. ផ្សេងដោយធម៌មានខន្ធនិងធាតុនិងអាយតនៈជាដើម ។ -**ធាតុអាយតនមត្ត** គុ. ធម៌ត្រឹមតែខន្ធ និងធាតុនិងអាយតនៈ ។ -**បរិហរណទុក្ខ** នបុំ. ទុក្ខគឺកិ.រក្សានូវខន្ធ ។ -**បរិហ-រណសម** គុ. ស្មើដោយកិ.រក្សានូវខន្ធ, ស្មើដោយកិ.នាំទៅជុំវិញនូវខន្ធ ។ -**រសាទិ** គុ. មានរសនៃដើមជាដើម, មានរសដែលកើតអំពីដើមជាដើម ។ -**លោកាទិសទ្ទាត** គុ. ពោលគឺលោកមានខន្ធលោកជាដើម, គឺបណ្ឌិតរាប់ព្រមហើយថាលោកមានខន្ធលោកជាដើម ។ -**វង្ក** បុំ. វង្កៈគឺខន្ធ ។ -**វស** បុំ. អំណាចនៃខន្ធ ។ -**សម** គុ. ស្មើដោយខន្ធ ។ -**អាទិប្បដិសំយុត្ត** គុ. ប្រកបព្រមចំពោះហើយដោយធម៌មានខន្ធជាដើម ។ -**អាទិភេទ** គុ. ផ្សេងដោយធម៌មានខន្ធជាដើម ។ -**អាវារ** បុំ. ប្រទេសជាទីបិទបាំងដោយកំណាត់ឈើ (បន្ទាយ,កងទ័ព), វិ. **ខន្ធេហិ អាវារេន្តិ ឯត្ថាតិ**>**ខន្ធាវា-រោ** ។ **រូបាទិខន្ធ**, ស្មា (ដូច **អំស**), សំណុំដើមនៃឈើ (ដូច **ឧប-ខន្ធ**), គំនរ(ដូច **រាសិ**), គុណ (ដូច **សីលាទិគុណា**), ខន្ធកុមារ (ដូច **សត្តិធរ**), សំណុំដើមនៃឈើ គឺតាំងអំពីខាងលើឫសឡើងទៅទល់នឹងមែក, ហ្វូង, ប្រជុំ, ពួក, កង (ដូច **កាយ**) ។

**ខន្ធាវារ** បុំ. ទ័ពទាយ, បន្ទាយ ។

**ខនិ** ធា. **អវទារណេ ខនតិ ខតោ ខនិត្វា**"បំបែកចុះ, ជីក, គាស់" ភូ. ។ អា. **ខតោ អាវាដោ** "រណ្តៅ ឬ អណ្តូងដែលគេជីកហើយ" -ស. ។ **សុខំ** នបុំ. "សេចក្តីសុខស្រួល" ជីកល្អ, វិ. **សុដ្ឋុ ខនតីតិ សុខំ** -ស. ។ **ទុក្ខំ** នបុំ. "សេចក្តីទុក្ខលំបាក" ជីកអាក្រក់, វិ. **ទុដ្ឋុ ខនតិ កាយិកចេតសិកសុខន្តិ ទុក្ខំ** ។ សុខទុក្ខនេះ នៅមានន័យផ្សេងទៀតថា **សុករំ ខមស្សាតិ សុខំ**, **ទុក្ករំ ខមស្សាតិ ទុក្ខំ** ស្រួលទ្រាំ, លំបាកទ្រាំ -ស. ។

**ខប្ប** បុំ. ទឹកភ្នែក (ដូច **នេត្តជល**)។

**ខព្វ** ធា. ១-**គតិយំ ខព្វតិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។
២- **ទព្វេ (អហង្ការេ) ខព្វតិ**"មានះ, រឹងរូស, ឆ្មើងឆ្មៃ" ភូ. ។

**ខភិ** ធា. **បដិពន្ធេ ខម្ភតិ វិក្ខម្ភតិ វិក្ខម្ភោ វិក្ខម្ភិតោ** "ចងចំពោះ, ចងក្រៀក, បដិសេធចោល, ទម្លាក់ចោល, កាត់ចេញ" ចុ. ។ អា. **វិក្ខម្ភិតក្កិលេសា**"មានកិលេសកាត់ចោលហើយ" -សុ. ។

**ខម** គុ. [ខម + អ] អត់, អត់ធន់, គួរ, សមគួរ, គាប់ចិត្ត (ដូច **យោគ្គ**), ប្រកប (ដូច **យុត្ត**)។នបុំ. ប្រយោជន៍ (ដូច **ហិត**) ។

**ខមថ** កិ. [ខម + អ + ថ-ប.] ចូរអត់, ចូរអត់ទោស, សូមអត់,..... ។

**ខមនីយ** គុ. [ខម+អនីយ] គឺ...គប្បីអត់បាន, គឺ...អត់ធន់បាន, វិ. **ខមិតព្វន្តិ**> **ខមនីយំ** ។

**ខមន** បុំ. អ្នកអត់ធន់ (ដូច **ខន្តិមា**)។

**ខមន្តិ** កិ. [ខម + អ + អន្តិ-វ.] គួរ, អត់, អត់ឱន ។

**ខមន** នបុំ. ការអត់ធន់ (ដូច **តិតិក្ខា**)។

**ខមា** ឥ. ការអត់ធន់ (ដូច **ខន្តិ**),ផែនដី (ដូច **ភូ**) ។

**ខមាបនុបាយ** បុំ. [ខមាបន + ឧបាយ] ឧបាយជាគ្រឿងញុំាង....ឲ្យអត់, -ឲ្យអត់ទោស ។

**ខមាបិត** គុ. [ខម + ណាបេ + ឥ-អា. + ត] គឺ....ឲ្យអត់ហើយ, -ឲ្យអត់ទោសហើយ, វិ. **ខមាបិយិត្ថាតិ** >**ខមាបិតោ** ។ - **កាល** បុំ. កាលនៃ....គឺ....ឲ្យអត់ហើយ, -ឲ្យអត់ទោសហើយ ។

**ខមាបិយមាន** គុ. [ខម + ណាបេ + ឥ-អា. + យ + មាន] គឺ....កាលឲ្យអត់,.... ។

**ខមាបេតិ** កិ. [ខម + ណាបេ + តិ-វ.] ញុំាង....ឲ្យអត់ ។

**ខមាបេតុំ** អ. [ខម + ណាបេ + តុំ] ដើម្បីញុំាង....ឲ្យអត់,..... ។

**ខមាបេត្វា** អ. [ខម + ណាបេ + ត្វា] ញុំាង....ឲ្យអត់ហើយ,... ។

**ខមាបេថ** កិ. [ខម + ណាបេ + ថ-ប.] ចូរញុំាង....ឲ្យអត់,.... ។

**ខមាបេយ្យ** កិ. [ខម + ណាបេ + ឯយ្យ-ស.] គប្បីញុំាង....ឲ្យអត់, .... ។

**ខមាបេសិ** កិ. [ខម + ណាបេ + ឥំ-អជ្ជ., ចុះស-អា.] ញុំាង....ឲ្យអត់ហើយ ។

**ខមាបេសុំ** កិ. [ខម+ណាបេ+ឧំ-អជ្ជ. ចុះស-អា.] ញុំាង.....ឲ្យអត់ហើយ,..... ។

**ខមាបេស្សាមិ** កិ. [ខម + ណាបេ + ស្សាមិ-ភ.] នឹងញុំាង...ឲ្យអត់,........ ។

**ខមាបេហិ** កិ. [ខម + ណាបេ + ហិ-ប.] ចូរញុំាង...ឲ្យអត់ , .... ។

**ខមាមិ** កិ. [ខម + អ + មិ-វ.] អត់, អត់ទោស,....... ។

**ខមាយិ** ធា. **វិធុននេ ខមាយតិ ខមាតោ ខមាតវា** "រលាស់, អង្រួន, បក, ពន្លាត់,..." ភូ.។

**ខមិស្សតិ** កិ. [ខម + អ + ឥ-អា.+ ស្សតិ-ភ.] នឹងអត់,.... ។

**ខម្ប** ធា. **ខន្តិយំ ខម្បេតិ ខម្បយតិ** "អត់ធន់, ទ្រាំ, ស៊ូ" ចុ. ។

**ខមិ** ធា. **សហនេ ខមតិ ខមោ ខន្តិ ខមនំ ខន្តា ខមិតា** "អត់ធន់, អត់ធ្មត់, ទ្រាំ, ស៊ូទ្រាំ,..." ភូ. ។ អា. **ខមោ ហោតិ សីតស្សបិ ឧណ្ហស្សបិ** "ជាអ្នកស៊ូទ្រាំ ចំពោះត្រជាក់និងក្តៅ" ស. ។

**ខយ** បុំ. [ខិ + អ] កិ.អស់, ការអស់ទៅ សាបសូន្យទៅ (ដូច **អបចយ**), វិ. **ខយនំ** >**ខយោ** ។ -**ប្បត្ត** គុ. ដល់ហើយនូវកិ.អស់ទៅ ។ -**វយធម្ម** គុ. មានកិ.អស់ទៅនិងកិ.សូន្យទៅជាធម្មតា, វិ. **ខយ-វយោ ធម្មោ យស្ស តំ** >**ខយវយធម្មំ** ។ - **វយ** បុំ. កិ.អស់ទៅនិងកិ.សូន្យទៅ ។ -**សង្ខាត** គុ. ពោលគឺកិ.អស់ទៅ, គឺបណ្ឌិតរាប់ព្រមហើយថាកិ.អស់ទៅ ។ ផ្ទះ (ដូច **មន្ទិរ**, **ឧក**), អស់ទៅ, សាបសូន្យទៅ (ដូច **អបចយ**), រោគរីងរៃ (ដូច **សោស**), ។

**ខរ** គុ. រឹង, គ្រោតគ្រាត (ដូច **ទុប្ផស្ស**), មុត, ក្លា (ដូច **តិខិណ**),កាច (ដូច **ចណ្ឌ**) បុំ. សត្វលា (ដូច **គទ្រភ**),រណារ (ដូច **កកច**), ក្រចកសេះ (ដូច **សផ**) ។

**ខរតរ** គុ. [ខរ + តរ] ក្លាជាង, ខ្លាំងជាង, រឹងជាង ។

**ខរមន្តី** គុ. [ខរ + មន្តី] មានសេចក្តីគិតដ៏ក្លា, មានគំនិតមោះមុត, មានគំនិតអង់អាច, មានគំនិតវាងវៃ ។

**ខរិ** ធា. **ខយេ ខរតិ ខរណំ**"អស់, សូន្យ" ភូ. ។ **អក្ខរ** នបុំ. "អក្សរ" មិនចេះអស់, វិ. **នក្ខរន្តិ នក្ខីយន្តីតិ អក្ខរានិ** (**អ**+**ខរិ**)**ស**.។ **នក្ខត្តំ** នបុំ. "ផ្កាយនក្ខឫក្ស" មិនចេះអស់, មិនសូន្យ, វិ. **នក្ខរន្តិ ន នស្សន្តីតិ នក្ខត្តានិ** (**ន**+**ខរិ**) -ស. (ន័យផ្សេងទៀត) **នក្ខត្តំ ជោតិ សិក្ខំ តំ** ទាំង ៤ សព្ទនេះជាឈ្មោះផ្កាយនក្សត្រ, **ឧឡុ តារា តារកា** ៣ សព្ទនេះ, ជាឈ្មោះផ្កាយ ធម្មតា, **ឱសធី** ជាឈ្មោះផ្កាយវិសេស -ស. ។

**ខល** នបុំ. [ខល + អ] ទីដែលគេគប្បីសម្អាត (លាន) ។ -**កាល** បុំ. កាលជាទីធ្វើនូវលាន ។ -**អគ្គ** គុ. ទានដ៏ប្រសើរគឺបុគ្គលគប្បីឲ្យក្នុងកាលជាទីនាំមកកាន់លាន, ទានដ៏លើសគឺបុគ្គលគប្បីឲ្យក្នុងកាលជាទីធ្វើនូវលាន ។ -**ភណ្ឌកាល** បុំ. កាលជាទីធ្វើនូវកិ.បញ្ចាន់ក្នុងលាន, កាលជាទីធ្វើនូវកិ.រោយក្នុងលាន ។ -**ភណ្ឌគ្គ** គុ. ទានដ៏ថ្មោងគឺបុគ្គលគប្បីឲ្យក្នុងកាលជាទីបញ្ចប់ក្នុងលាន ។ -**មណ្ឌលមត្ត** គុ. មានមណ្ឌលនៃលានជាប្រមាណ, ប៉ុនមណ្ឌលនៃលាន ។ -**មណ្ឌ-លសទិស** គុ. ប្រាកដស្មើដោយមណ្ឌលនៃលាន ។ លានស្រូវ (ដូច **ធញ្ញករណ**), លំអិតសម្រាប់ងូត (ដូច **កក្ក**)។ បុំ. ជនថោក

ទាប (ដូច **នីច**),អ្នកខូចកាច, ខិលខូច (ដូច **សឋ**) ។

**ខលិត** គុ. [ខល + ឥ-អា. + ត] ដែល.....ភ្លាំងភ្លាត់ហើយ, ...ភ្លាត់ហើយ, ។ ន. សេចក្ដីភ្លាំងភ្លាត់ សព្ទនេះជាអត្ថនៃ**ខលសព្ទ** ។

**ខលិត្វា** អ. [ខល + ឥ-អា. + ត្វា] ភ្លាត់ហើយ ។

**ខលីន** បុំ. បង្ហៀរសេះ (ដូច **មុខាធាន**)។

**ខលុ** និ. ឮថា, បានឮថា, គេឮថា, សេចក្ដីតំណាលថា ។ និបាតប្រាប់អត្ថ គឺ **និសេធ** ហាម, ឃាត់, ឧ. **ខលុបច្ឆាភត្តិកោ** ភិក្ខុសមាទាន ធុតង្គវត្តម្យ៉ាង ឃាត់នូវ បច្ឆាភត្ត កាលបើហាមភត្តហើយ ទុកជាមានភិក្ខុផងគ្នាធ្វើវិនយកម្មឲ្យ ក៏មិនទទួលបច្ឆាភត្តនោះដែរ, ចូរមើលខលុបច្ឆាភត្តិកធុតង្គនិងបឋមបវារណាសិក្ខាបទ, **វាក្យាលង្ការ** ប្រដាប់ពាក្យ ប្រែថា ក៏, **អវធារណ** ប្រែថា ដោយពិត, មែនពិត, **បសិទ្ធិ** សម្រេច ។

**ខលុង្ក** បុំ. សេះថោកទាប, សេះសាមញ្ញ (ដូច **ឃោដក**)។

**ខល** បុំ. ឆ្នាំង (ដូច **ឧក្ខលិ**) ។

**ខល្លាដ** បុំ. មនុស្សក្បាលទំពែក (ដូច **និក្ខេសសីស**)។

**ខល្លាតសីស** នបុំ. [ខល្លាត + សីស] ក្បាលនៃបុគ្គលទំពែក, សីសៈទំពែក (ខល្លាត <ខ + លា + ត = អ្នកកាន់យកនូវសីសៈទទេ (ទំពែក), វិ. **ខំ តុច្ឆំ សីសំ លាតីតិ** >**ខល្លាតោ** ។

**ខលិ** ធា. ១-**សញ្ចិននេ ខលតិ**"រួបរួម, ប្រមូល, សន្សំ" ភូ. ។ **ខល** បុំ. "លានស្រូវ, លានបោកបែនស្រូវ" ។
២- **ចលនេ ខលតិ**"ភ្លាត់, ខុស" ភូ. ។ **ខល** បុំ. "អ្នកខុស, អ្នកភ្លាត់" =**ទុជ្ជនោ** -ស. ។
៣- **សោចេយ្យេ ខាលេតិ ខាលយតិ បក្ខាលេតិ វិក្ខាលេតិ**" សម្អាត, ជម្រះ, ខ្ពុរមាត់" ចុ. ។

**ខឡ** បុំ. លានស្រូវ (ដូច **ធញ្ញករណ**)។

**ខឡិ** ធា. **ភេទេ ខឡេតិ ខឡយតិ**"បំបែក, ទម្លាយ" ចុ. ។

**ខា, ខ្យា** ធា. **បកថនេ ខាតិ សង្ខាតិ អក្ខាតិ អាខ្យាតិ សង្ខាតោ អក្ខាតោ សង្ខាតា អក្ខាតា ស្វាក្ខាតោ** កម្ម. **អក្ខាយតិ សង្ខាយតិ** "ពោល, ថ្លែង, សម្ដែង, ប្រកាស, ទេសន៍" ភូ. ។ ទីណាដែលមាន **អ**នៅខាងដើម គឺ អាបុព្វទរស្សៈ ជា អ -ស.។ អា. **អក្ខាសិ បុរិសុត្តមោ** "ព្រះពុទ្ធជាបុរសដ៏ឧត្តម ទ្រង់សម្ដែងហើយ" ។ **អក្ខាតារោ តថាគតា** "ព្រះតថាគតទ. គ្រាន់តែជាអ្នកពោលប្រាប់" (អា+ខា+តុ) ។ **សង្ខាតាសព្វធម្មានំ វិធុរោ** "វិធុរបណ្ឌិតជាអ្នកសម្ដែងនូវធម៌ទាំងអស់ទ." (សំ+ខា+តុ) **ធម្មោ សង្ខាយតិ**

| | | |
|---|---|---|
| | | "ធម៌ដែលព្រះពុទ្ធទ្រង់សម្តែង" ។ **ស្វាក្ខាតោ ភគវតា ធម្មោ** "ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងល្អហើយ" -ស. ។ **សង្ខា** ឥ. (សំ+ខា) ប្រែបានច្រើនយ៉ាង ៖ |
| | | ១/ ដឹង, ពិចារណា =**ញាណំ** បាលីថា **សង្ខាយេកំ បដិសេវតិ** (**សង្ខាយ+ឯកំ**)។ |
| | | ២/ ចំណែក, ផ្នែក= **កោដ្ឋាសោ**, បាលីថា **បបញ្ចសង្ខា សមុ-ទាចរន្តិ** ។ |
| | | ៣/ បញ្ញត្ត តែងតាំង =**បញ្ញត្តិ** បាលីថា **តេសំ តេសំ ធម្មានំ សង្ខាសមញ្ញា**។ |
| | | ៤/ រាប់, ពាក្យរាប់ =**គណនា** បាលីថា **ន សុករំ សង្ខាតុំ** ស.។ **អាខ្យាតំ** នបុំ. "អាខ្យាត ពោល ឬប្រាប់នូវកិរិយាសព្ទ" វិ. **កិរិយំ អាខ្យាតិ កថេតីតិ អាខ្យាតំ** (**អា+ខ្យា+ត**) ស. ។ |
| **ខាណុ** | នបុំ. | ដង្គត់ (ដូច **សំកុ**) ។ |
| **ខាណុ**, **ខានុក** | បុំ., ន បុំ. | ដង្គត់, បង្គោល ។ -**សញ្ញី** បុំ. អ្នកមានសេចក្តីសម្គាល់ថាដង្គត់ ។ -**មត្ត** គុ. ត្រឹមតែដង្គត់, មានដង្គត់ជាប្រមាណ ។ - **មត្ថក** បុំ. ទីបំផុតនៃដង្គត់, ចុងនៃដង្គត់, ក្បាលនៃដង្គត់ ។ |
| **ខាត** | នបុំ. | ត្រពាំងទឹក, ស្រះ (ដូច **បោក្ខរណី**)។ |
| **ខាទតិ** | កិ. | [ខាទ + អ + តិ-វ.] ស៊ី, ទំពាស៊ី ។ |
| **ខាទន** | នបុំ. | [ខាទ + យុ] កិ.ស៊ី, កិ.ទំពាស៊ី, វិ. **ខាទយតេតិ** >**ខាទនំ** ។ - **បិវនសមត្ថ** គុ. អាចក្នុងកិ.ទំពាស៊ី និងកិ.ផឹក ។ -**វស** បុំ. អំណាចនៃកិ.ទំពាស៊ី ។ - **សមត្ថ** គុ. អាចក្នុងកិ.ទំពាស៊ី ។ |
| **ខាទនីយ** | គុ. | [ខាទ+អនីយ] វត្ថុគឺបុគ្គលគប្បីទំពាស៊ី (បង្អែម, ចំណី), វិ. **ខាទិតព្វន្តិ** > **ខាទនីយំ** ។ - **ភោជនីយសយន** នបុំ. វត្ថុគឺបុគ្គលគប្បីទំពាស៊ី និងវត្ថុគឺបុគ្គលគប្បីបរិភោគ និងទីជាទីដេក ។ -**អាទិ-ទានឱបម្ម** នបុំ. ភាវៈនៃវាចាជាគ្រឿងប្រៀបដោយកិ.ឲ្យនូវវត្ថុមានវត្ថុគឺបុគ្គលគប្បីទំពាស៊ីជាដើម (**ឧបមាយ ភាវោ** > **ឱបម្មំ**)។ |
| **ខាទន្ត** | គុ. | [ខាទ + អ + អន្ត] កាលទំពាស៊ី ។ |
| **ខាទន្តិ** | កិ. | [ខាទ + អ + អន្តិ-វ.] ស៊ី, ទំពាស៊ី ។ |
| **ខាទមាន** | គុ. | [ខាទ + អ + មាន] កាលទំពាស៊ី ។ |
| **ខាទសិ** | កិ. | [ខាទ + អ + សិ-វ.] ស៊ី, ទំពាស៊ី ។ |
| **ខាទាបេសិ** | កិ. | [ខាទ+ណាបេ+ឦ-អជ្ជ., ចុះស-អា.] ញុំាង.....ឲ្យទំពាស៊ីហើយ ។ |
| **ខាទាបេស្សាមិ** | កិ. | [ខាទ + ណាបេ + ស្សាមិ-ភ. ] នឹងញុំាង....ឲ្យទំពាស៊ី ។ |

**ខាទាម** កិ. [ខាទ + អ + ម-ប. ឬស្សាម-ភ.] ចូរទំពាស៊ី, នឹងទំពាស៊ី ។

**ខាទាហិ** កិ. [ខាទ + អ + ហិ-ប.] ចូរទំពាស៊ី ។

**ខាទិ** កិ. [ខាទ + អ + ឦ-អជ្ជ.] ទំពាស៊ីហើយ ។

**ខាទិត** គុ. [ខាទ + ឥ-អា. + ត] គឺ....ទំពាស៊ីហើយ, ស៊ីហើយ, លេបហើយ (ដូច **គិលិត**)។ -**បីតនច្ចគីតវាទិតាទិ** គុ. វត្ថុគឺ....ទំពាស៊ី និងវត្ថុគឺ....ផឹក និងគ្រឿងតន្ត្រីមានកិ.រាំ និងកិ.ច្រៀង និងកិ.ប្រគំជាដើម ។ -**បុព្វ** គុ. គឺ...ធ្លាប់ទំពាស៊ីហើយ, គឺ...ទំពាស៊ីហើយក្នុងកាលមុន ។ -**មំស** នបុំ. សាច់គឺ....ទំពាស៊ីហើយ ។

**ខាទិតុំ** អ. [ខាទ + ឥ-អា. + តុំ] ដើម្បីទំពាស៊ី ។

**ខាទិត្ថ** កិ. [ខាទ + អ + ឥ-អា. + ត្ថ-ហី.] ទំពាស៊ីហើយ ។

**ខាទិត្វា** អ. [ខាទ + ឥ-អា. + ត្វា] ទំពាស៊ីហើយ ។

**ខាទិយមាន** គុ. [ខាទ + ឥ-អា. + យ + មាន ] គឺ...កាលទំពាស៊ី, គឺ...កាលស៊ី ។

**ខាទិស្សាមិ** កិ. [ខាទ + អ + ឥ-អា. +ស្សាមិ-ភ.] នឹងទំពាស៊ី ។

**ខាទេយ្យ** កិ. [ខាទ + អ + ឯយ្យ-ស.] គប្បីទំពាស៊ី ។

**ខាទិ** ធា. ១-**ភក្ខនេ ខាទតិ ខាទិកា ខាទនំ**"ទំពា, ខាំ, កកេរ" ភូ.។ កម្ម. **ខជ្ជតិ** ។ អា. **អញ្ញមញ្ញំ ខាទិកា**"អ្នកខាំកកេរស៊ីគ្នាឯង" **បុប្ផផលខាទិកា** "អ្នកខាំស៊ីនូវផ្កានិងផ្លែ" ស.។ **ខជ្ជំ** នបុំ. = **បូវោ** នំ ខាំកាត់ស៊ី ស.។ **ខាទនីយ** កិ.គុ. "របស់ដែលគួរខាំទំពា មាននំនិងមើមជាដើម" -ស. ។ **ខន្ធ** បុំ. "ខន្ធ, រូបរាងកាយគឺជាតិជរា ជាដើមកកេរខាំ គឺថាបៀតបៀន" -ស. ។

២- **បរិយាតេ** (**សមន្តតោ ហននេ**) **ខន្ធតិ** "បៀតបៀន" រុ. ។

**ខានុកោណ្ឌញ្ញ** អ.ន. ព្រះថេរៈឈ្មោះខានុកោណ្ឌញ្ញៈ ។ -**ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះ **ខានុកោណ្ឌញ្ញៈ** ។

**ខាយតិ** កិ. [ខា + យ + តិ-វ.] ប្រាកដ, ជាក់ស្តែង ។

**ខាយិ** កិ. [ខា + យ + ឦ-អជ្ជ.] ប្រាកដហើយ, ជាក់ស្តែងហើយ ។

**ខាយឹសុ** កិ. [ខា + យ + ឧំ-អជ្ជ.] ប្រាកដហើយ ។

**ខារ** បុំ. ដីប្រៃ (ដូច **ឧស**), ក្បុង, ផេះ (ដូច **ភស្ម**)។

**ខារក** បុំ. ផ្កាក្តោប, ផ្កាក្រពុំ (ដូច **មុកុល**),រសប្រៃ, រសខារ, ឈើដែលមានផ្កានិងផ្លែជាប្រក្រតី (ដូច **ជាលក**), ដើមពោនស្វា (ដូច **ឥន្ទ-សាល**)។

**ខារបរិសេក** បុំ. [ខារ + បរិ + សិច + ណ] កិ.ស្រោចដោយទឹកដ៏ផ្សា ។

**ខារិ** ឥ. អម្រែកប្រមាណ ៩ **មាណិកា** ។

**ខារិក** គុ. [ខារ + ណិក] មានរសខារ ។

**ខារិភណ្ឌក** នបុំ. [ខារិ+ភណ្ឌក] ភណ្ឌៈគឺគ្រឿងបរិក្ខារ, ភណ្ឌៈសម្រាប់នាំនូវបរិក្ខារ (តាមទម្លាប់ថា «ភណ្ឌៈគឺអម្រែក») ភណ្ឌៈមានខារិជាប្រមាណ ។

**ខិ** ធា. **គតិយំ ខិណោតិ**"ទៅ, ដល់, ប្រព្រឹត្តទៅ" កី. ។ ទី ដែលជាណ គឺផ្លាស់ន ជា ណ ដោយអនុវត្តតាមសំស្រ្កឹត ។ **អតិខិណ** គុ. "មុត, ស្រួច" ៖ ទៅក្រៃលែង, រហ័ស =**អតិគតោ** អា. **អតិខិណោ សរោ** ស.។ **ខំ** នបុំ. "សូគិ ស្ថានសួគ៌" =**សគ្គោ**, ស.។

**ខិជី** ធា. **អព្យត្តសទ្ទេ ខិជតិ**"ចេញសំឡេងមិនច្បាស់" ភូ. ។

**ខិដ្ឋ** បុំ. អ្នកលំបាក, នឿយហត់, សព្ទនេះជាអត្ថនៃ**សន្ត**សព្ទ ។

**ខិដី** ធា. **ឧត្តាសនេ ខេដតិ អាខេដោ ខេដោ ឧក្ខេដិតោ សមុក្ខេដិ-តោ** "ខ្លាច, ស្លុត, រន្ធត់" ភូ. ។

**ខិឌ្ឌា** ឥ. ល្បែង, ការលេង (ដូច **ខឌ**)។

**ខិឌ្ឌាបសុតតា** ឥ. [ខិឌ្ឌាបសុត + តា] ភាវៈនៃ...ជាអ្នកខ្វល់ខ្វាយក្នុងកិ.លេង, វិ. **ខិឌ្ឌាបសុតស្ស តាភាវោ** >**ខិឌ្ឌាបសុតតា** ។

**ខិណិ** ធា. **ហឹសាយំ ខិណោតិ**"បៀតបៀន" ត. ។

**ខិត្ត** គុ. [ខិប + ត] គឺ...បោះទៅហើយ, -ចោលទៅហើយ,-គ្រវែងទៅហើយ,-បាញ់ទៅហើយ(ដូច **អាខិត្ត**) ។ -**កាល** បុំ. កាលនៃ...គឺ ...បោះទៅហើយ, ... ។

**ខិទិ** ធា. ១-**អវយវេ ខិន្ទតិ**"ញែកចេញជាផ្នែកៗ" រុ. ។
២- **ទីនិយេ** (**ទីនភាវេ**) **ខិជ្ជតិ ខិន្នោ ខេទោ**"ហត់, នឿយ, លំបាក, ជាទុក្ខ, (អស់កម្លាំង)" ទិ. ។ អា. **អខិន្នា មតិ**"មតិ ឬយោបល់មិនចេះហត់," **ខេទំ គតោ លោកហិតាយ នាថោ** -ស.។

**ខិប** កិ. [ខិប + អ + ហិ-ប., លុបហិ ] ចូរបោះទៅ, ចូរចោលទៅ, ចូរគ្រវែងទៅ ។

**ខិបតិ** កិ. [ខិប + អ + តិ-វ.] បោះទៅ, ចោលទៅ, គ្រវែងទៅ ។

**ខិបតុ** កិ. [ខិប + អ + តុ-ប.] ចូរបោះទៅ,...។

**ខិបន្ត** គុ. [ខិប + អ + អន្ត] កាលបោះទៅ , .... ។

**ខិបន** នបុំ. ការបោះទៅ, ចោលទៅ, បាញ់ទៅ, សព្ទនេះជាអត្ថនៃ **អសន** សព្ទ ។

**ខិបមាន** គុ. [ខិប + អ + មាន] កាលបោះទៅ , ... ។

**ខិបាបេសិ** កិ. [ខិប + ណាបេ + ឦ-អជ្ជ. ចុះស-អា. ] ញុំាង...ឲ្យបោះទៅហើយ, -ឲ្យគ្រវែងទៅហើយ ។

**ខិបិ** កិ. [ខិប + អ + ឦ-អជ្ជ.] បោះទៅហើយ, ផ្ចាត់ទៅហើយ ។

**ខិបិត** គុ. [ខិប + ឥ-អា. + ត] គឺ...កណ្តាស់ហើយ, គឺ...បោះទៅហើយ ។ -**ភាសាទិ** គុ. មានរោគកណ្តាស់ និងរោគក្អកជាដើម ។ -**រោគ** បុំ. រោគកណ្តាស់, រោគគឺកិ.កណ្តាស់ ។ - **សទ្ទ** បុំ. សំឡេងកណ្តាស់, សូរគឺកិ.កណ្តាស់, សូរនៃកិ.កណ្តាស់, សូរគឺ....បោះទៅហើយ ។

**ខិបិតុំ** អ. [ខិប + ឥ-អា. + តុំ] ដើម្បីបោះទៅ, វីកិ.បោះទៅ ។

**ខិបិត្វា** អ. [ខិប + ឥ-អា. + ត្វា] កណ្តាស់ហើយ, បោះទៅហើយ ។

**ខិបិយមាន** គុ. [ខិប + ឥ-អា. + យ + មាន] គឺ....កាលបោះទៅ ។

**ខិបីសុ** កិ. [ខិប + អ + ឥំ-អជ្ជ.] បោះទៅហើយ ។

**ខិបេយ្យុំ** កិ. [ខិប + អ + ឯយ្យុំ-ស.] គប្បីបោះទៅ ។

**ខិប្បតរ** គុ. [ខិប្ប + តរ] ឆាប់ជាង, រហ័សជាង ។

**ខិប្បាភិញ្ញាណ** គុ. [ខិប្ប + អភិញ្ញាណ] អ្នកមានអភិញ្ញាណដ៏ឆាប់, អ្នកមានគុណជាតជាគ្រឿងចំពោះដ៏រហ័ស ។

**ខិប្បំ** កិ.វិ. ឆាប់, ឆាប់ៗ, ប្រញាប់, រហ័ស, រួសរាន់, ទាន់ហាន់(ដូច **សីឃំ**)។

**ខិប** ធា. ១-**ឆឌ្ឌនេ ខិបតិ**"បោះទៅ, ចោល, ទម្លាក់ចោល,..." ភូ. ។ ធាតុនេះ កាលណាមានឧបសគ្គនាំមុខ មានអត្ថន័យ ផ្សេងៗដូចតទៅនេះ ៖

១/ **ឧក្ខិបតិ**"លើកឡើង, ទូល (លើកទោស),..." ។ រូបដទៃ **ឧក្ខិត្តោ ឧក្ខិបិត្វា ឧក្ខេបកោ ឧក្ខេបនំ** (**ឧ**+**ខិប**)។

២/ **វិក្ខិបតិ**"រវើរវាយ, រាយមាយ, រសេមរសាម,..." រូបដទៃ **វិក្ខិត្តោ វិក្ខេបោ វិក្ខេបនំ** (**វិ**+**ខិប**)។

៣/ **អវក្ខិបតិ**"ដាក់ចុះ, ទម្លាក់ចុះ,..." រូបដទៃ **អវក្ខិត្តោ ឱក្ខិត្តោ អវក្ខេបោ** (**អវ**+**ខិប** ។

៤/ **សង្ខិបតិ**"បំប្រួញ, ធ្វើឲ្យខ្លី, សង្ខេប,..." រូបដទៃ **សង្ខិត្តោ សង្ខិបិត្វា សង្ខេបោ** (**សំ**+**ខិប**)។

៥/ **បក្ខិបតិ** "ដាក់ចុះ, ទម្លាក់ចុះ, ..." រូបដទៃ **បក្ខិត្តោ បក្ខិបិត្វា បក្ខិបិតុំ** (**ប**+**ខិប**) ។

៦/ **និក្ខិបតិ**"ដាក់ចុះ, តាំងទុក, លះបង់, ទុក, បញ្ញើ" រូបដទៃ **និក្ខិត្តោ និក្ខិបិត្វា និក្ខេបនំ** (**និ**+**ខិប**)។

២-**បេរណេ**(**ចុណ្ណីករណេ**) **ខិបតិ ខេបកោ**"ធ្វើឲ្យល្អិត, ..." ភូ. ។

៣- **អព្យត្តសទ្ទេ ខិបតិ**"ក្អក, គ្រហែម" ភូ. ។ អា. **យថា ច ធម្មំ ទេសេន្តោ ខិបិ លោកគ្គនាយកោ** ព្រះអគ្គនាយកាលសម្តែងព្រះធម៌ទេសនា ទ្រង់គ្រហែម -ស. ។ **ខិបិតសទ្ទ** បុំ. "សូរ

គ្រហែម -ស. ។
៤- **បេរណេ ខិបតិ ខិប្បំ**"ធ្វើឲ្យល្អិត, កិន" ភូ. ។ **ខិប្បំ** អព្យ. "ឆាប់, រហ័ស, លឿន" ប្រើជាកិរិយាវិសេសន៍ ។
៥- **ខេបេ ខិបុណាតិ**"បោះទៅ, បង់ទៅ" សុ. ។ **ខិប** នបុំ. "អង្រុត" =**មច្ឆបញ្ជរោ** ស.។
៦- **បេរណេ ខេបេតិ ខេបយតិ**"ធ្វើឲ្យល្អិត, បុក, កិន" ចុ. ។
៧- **គតិយំ ខិម្បតិ**"ទៅ, ដល់, ប្រព្រឹត្តទៅ" រុ. ។

**ខិទ** ធា. **និទស្សនេ ខេទតិ, ខិព្ទតិ**"អាងដល់, ចង្អុលតួយ៉ាង" ភូ. ទិ. ។

**ខី** ធា. ១-**ខយេ ខីយតិ ខិយ្យតិ ខីណា ខីយនំ**"អស់, សូន្យ" ទិ. ។ **ខយ** បុំ. "ក្ស័យ អស់, សូន្យ ជាឈ្មោះនៃរោគកើតខាងក្នុង (រោគរីងរៃ), ឈ្មោះមគ្គផលនិព្វាន" ដូចបាលីថា **រាគក្ខយោ** ស.។ **ខំ** នបុំ. "ទទេ, សូន្យ, អាកាស" =**តុច្ឆំ** =**សុញ្ញំ**=**វិត្តំ**=**រិត្តំ**= **អាកាសោ** ស.។ **ខីណា** (<**ខី**+**ត**>**ណា**)។
២-**និវាសេ ខីយតិ ខិយ្យតិ**"នៅ, អាស្រ័យ" ទិ. ។ **ខយំ** នបុំ. = **និវេសនំ**"និវេសន៍, ទីនៅ, លំនៅ, ទីអាស្រ័យ" អា. **រាជក្ខយំ**" ព្រះរាជនិវេសន៍," **យមក្ខយំ**"លំនៅនៃយមរាជ" ស. ។ **ខំ** នបុំ. "ឥន្ទ្រិយមានចក្ខុជាដើម, ជាទីអាស្រ័យនៃចក្ខុវិញ្ញាណជាដើម" ស. ។
៣- **និវាសកោធហឹសាសុ ខីយតិ-ខិយ្យតិ**"នៅ, ក្រោធ, បៀតបៀន" ទិ. ។ អា. **នាគនាគេន ខីយន្តិ**"ប្រជាជនទ. ក្រេវក្រោធព្រោះតែឲ្យដំរី ន័យមួយទៀតថា រមែងបៀតបៀន" -ស. ។
៤- **ខយេ ខីណោតិ ខីណាតិ ខីណោ សង្ខយោ**"អស់, សូន្យ" សុ. ។ អា. **ខីណា ជាតិ** "អស់ជាតិ, អស់កំណើត" ។ **អយោគា ត្វរីសង្ខយោ** "ប្រាជ្ញាសាបសូន្យទៅ ព្រោះតែការមិនប្រកប (មិនមានព្យាយាម)" -ស. ។

**ខីណ** គុ. [ខិ + ត, ត >ល្យណ] អស់ហើយ, ។ -**ត្ត** នបុំ. ភាវៈនៃ...ជា....អស់ហើយ ។ -**តា** ឥ. ភាវៈនៃ....ជា...អស់ហើយ ។ -**បត្ត** គុ. មានស្លាបអស់ហើយ ។ -**បាថេយ្យ** គុ. មានវត្ថុជាប្រយោជន៍ក្នុងផ្លូវអស់ហើយ, មានស្បៀងអស់ហើយ, វិ. **បថេ ហិតំ** >**បាថេយ្យំ**, **ខីណំ បាថេយ្យំ យេសំ តេ** >**ខីណបាថេយ្យា** ។ -**ភាវ** បុំ. ភាវៈនៃ...ជា...អស់ហើយ ។ -**មច្ឆ** គុ. មានត្រីអស់ហើយ ។ -**សំយោជន** គុ. អ្នកមានសំយោជនៈអស់ហើយ, អ្នកមានធម៌ជាគ្រឿងញុំាងសត្វឲ្យប្រកបព្រមអស់ហើយ ។

**ខីណាសវ** គុ., បុំ. [ខីណ + អាសវ] អ្នកមានអាសវៈអស់ហើយ, ព្រះខីណាស្រព, ព្រះអរហន្ត (ដូច **អសេក្ខ**)។ -**ឧសភ** បុំ. ព្រះខីណាស្រពដូចជាគោឧសភ, ព្រះខីណាស្រពអ្នកប្រសើរ, ព្រះខីណាស្រពអ្នកអង់អាច ។ -**ព្រាហ្មណ** បុំ. ព្រាហ្មណ៍ជាព្រះខីណាស្រព, ព្រាហ្មណ៍មានអាសវៈអស់ហើយ ។ -**ភាវ** បុំ. ភាវៈនៃ...ជាអ្នកមានអាសវៈអស់ហើយ ។ -**សហស្ស** នបុំ. ពាន់នៃព្រះខីណាស្រព ។ -**សាមណេរ** បុំ. សាមណេរជាព្រះខីណាស្រព ។ - **សីស** នបុំ. សីសៈ(ក្បាល) នៃព្រះខីណាស្រព ។

**ខីយតិ** កិ. [ខិ + ល្បយ + តិ-វ.] អស់, អស់ទៅ ។

**ខីយន្ត** គុ. [ខី + អ + អន្ត, ផ្លាស់ ល្បនៃធាតុជា ល្បយ ] កាលតិះដៀល ។

**ខីយមាន** គុ. [ខី + ណ + មាន] កាលតិះដៀល ។

**ខីយមាន** គុ. [ខិ + ល្បយ + ឬណាយ + មាន ] កាលអស់ទៅ, កាលឲ្យអស់ទៅ ។

**ខីយិត្វា** អ. [ខី + ឥ-អា. + ត្វា ] តិះដៀលហើយ ។

**ខីយេ** កិ. [ខិ + ល្បយ + ឯយ្យ-ស.] គប្បីអស់ទៅ ។

**ខីរ** នបុំ. [ខិ+ល្បរ] ធម្មជាតអស់ទៅដោយកិ.រឹត (ទឹកដោះ, ទឹកដោះស្រស់ដូច **ទុទ្ធ**), វិ. **ខីយតិ ឧហណោនាតិ** >**ខីរំ** ។ - **បក** គុ. អ្នកបៅនូវទឹកដោះ, កំពុងបៅទឹកដោះ, វិ. **ខីរំ បិវតីតិ** >**ខីរបកោ** ។ -**មុខ** គុ. មានទឹកដោះក្នុងមាត់, មានមាត់កំពុងផឹកនូវទឹកដោះ ។ -**មូល** នបុំ. តម្លៃនៃទឹកដោះ ។ -**យាគុ** ឥ. បបរគឺបុគ្គលចម្អិនហើយដោយទឹកដោះ, បបរលាយដោយទឹកដោះ ។ -**សទិស** គុ. ប្រាកដស្មើដោយទឹកដោះ ។ -**សប្បិមធុផាណិត** នបុំ. ទឹកដោះស្រស់ និងទឹកដោះថ្លា និងទឹកឃ្មុំ និងទឹកអំពៅ ។

**ខីរណ្ណវ** បុំ. សមុទ្រទឹកដោះ ។

**ខីរិកា** ឥ. ដើមកែស, ឥន្ទនេល (ដូច **រាជាយតន**) ។

**ខីរោទក** នបុំ. [ខីរ + ឧទក] ទឹកដ៏លាយហើយដោយទឹកដោះស្រស់, វិ. **ខីរេន សំសដ្ឋំ ឧទកំ** >**ខីរោទកំ** ។

**ខីលជាត** គុ. [ខីល+ជាត] ជាអ្នកដូចជាសសរខឿនកើតហើយ, ជាអ្នករឹងត្អឹង, (**ជាត** ទុកជាសកត្ថៈ មិនបាច់ប្រែក៏បាន) ។

**ខីល** ធា. **បដិត្ថម្ភេ ខីលតិ**"ពង្រឹងចំពោះ, គាំទ្រ,..." ភូ. ។ **ខីល** បុំ. "ចម្រឹង, បង្គោល..." អា. **តិត្តិខីលោ**"ចម្រឹងជញ្ជាំង (របា) ជញ្ជាំង, "**ឥន្ទ-ខីល** បុំ. "សសរគោល សសរ ឬបង្គោលដ៏ធំ," ។ **បាទខីល** បុំ. "ដំបៅលេច" អា... **បាទខីលាពាធោ វា ឱបាហនំ ធារេតុំ**

"ភិក្ខុមានរោគដំបៅលេចត្រង់បាតជើងក្តីអនុញ្ញាតឲ្យពាក់ស្បែកជើងបាន" (មហាវគ្គ ៧/១៨៣) ។

**ខីវិ** ធា. **មទេ ខីវតិ**"ស្រវឹង, ប្រមាទ" ភូ. ។

**ខុ** ធា. **សទ្ទេ ខោតិ ខវតិ**"ស្រែក, ពោល, ចេញសំឡេង" ភូ. ។

**ខុជ្ជ** គុ. [កុ >ខុ+វជ+ណ, លុបវ] អ្នកដើរទៅដែលគេគួរខ្ពើម, ឬអ្នកដល់នូវដំណើរដែលគេគួរខ្ពើម (គម),វិ. **កុច្ឆិតំ វជ្ជតីតិ** >**ខុជ្ជោ** ។ -**ធាតុក** គុ. មានធាតុនៃបុគ្គលគម, មានធាតុគម ។ -**ឧត្តរា** អ.ន ភិក្ខុនីឈ្មោះខុជ្ជុត្តរា ។ បុំ. មនុស្សគម (ដូច **គណ្ឌុល**) ។

**ខុជិ** ធា. **ថេយ្យករណេ ខោជតិ** "លួច, លាក់, ប្លន់" ភូ. ។

**ខុណិ** ធា. **ហឹសាយំ ខុណោតិ** "បៀតបៀន" ត. ។

**ខុទា** ឥ. សេចក្តីឃ្លាន (ដូច **ជិឃច្ឆា**) ។

**ខុទិត** គុ. អ្នកឃ្លាន (ដូច **ឆាត**)។

**ខុទ្ទក** គុ. [ខុទ្ទ + ក-ស.] តូច ។ - **គាមភោជក** បុំ. អ្នកបរិភោគនូវស្វយក្នុងស្រុកតូច (មេស្រុក), វិ. **ខុទ្ទកគាមំ ភុញ្ជតីតិ** >**ខុទ្ទកគាមភោជកោ** ។ -**មហន្ត** គុ. ទាំងតូចទាំងធំ ។ -**មហល្លកទារក** បុំ. ទារកតូចនិងទារកធំ, ក្មេងតូចនិងក្មេងអ្នកកាន់យកនូវភារៈនៃខ្លួនជាមនុស្សធំ ។ -**វត្ថលិយ** បុ. ប្រចៀវតូច ។ -**សាខា** ឥ. មែកតូច ។ -**សាខាភញ្ជន** នបុំ. កិ.កាច់នូវមែកតូច, កិ.បំបាក់នូវមែកតូច ។ -**សោណ្ឌី** ឥ. ត្រពាំងទឹកតូច ។ -**ច្ឆិទ្ទកវាតបាន** នបុំ. បង្អួចមានប្រហោងតូច ។

**ខុទ្ទឃណ្ឌិកា** ឥ. កណ្តឹង, ចង្រ្កង់ (ដូច **កីកិណី**)។

**ខុទ្ទសំខ** បុំ. ខ្យងតូច, ខ្ចៅ, លៀស (ដូច **សំខនខ**) ។

**ខុទ្ទានុខុទ្ទក** គុ. [ខុទ្ទ + អនុខុទ្ទក] តូចនិងតូចដោយលំដាប់, តូចនិងតូចតាមលំដាប់ ។ -**អាបត្តិអាបជ្ជន** នបុំ. កិ.ត្រូវនូវអាបត្តិតូចនិងតូចដោយលំដាប់ ។

**ខុទ្ទាភិភូត** គុ. [ខុទ្ទ+អភិភូត] គឺសេចក្តីឃ្លានគ្របសង្កត់ហើយ, គឺសេចក្តីលំបាកគ្របសង្កត់ហើយ ។

**ខុទ្ទ** ន.គុ. [ខុ ឬខុទ + ទ] បុំ.សេចក្តីឃ្លាន, សេចក្តីលំបាក, អ្នកមានសេចក្តីកំណាញ់រឹង (ដូច**ថទ្ធមច្ឆរី**), អ្នកថោកទាប (ដូច **អធម**) , អ្នកកម្សត់ (ដូច **កបណា**),សត្វរុយ(ដូច**មក្ខិកា**),នបុំ. ទឹកឃ្មុំ (ដូច **មធុ**)។ គុ. តូច (ដូច**សុខុម**,**អប្បក**), ច្រើន (ដូច **ពហុ**)។ -**ពូវ** បុំ. នំតូច ។

**ខុទិ** ធា. ១-**កីឡាយំ ខោទតិ** "លេង, លេងកីឡា" ភូ. ។

២- **អាបចវនេ ខុន្ទតិ**"ជម្រះ, ធ្វើឲ្យស្អាត" ភូ. ។

**ខុប្បិបាសា** ឥ. [ខុទ្ទ+បិបាស] សេចក្តីប្រាថ្នាដើម្បីស៊ី និងសេចក្តីប្រាថ្នាដើម្បីផឹក, សេចក្តីឃ្លាននិងសេចក្តីស្រេក ។ -**បីឡិត** គុ. គឺសេចក្តីឃ្លាន និងសេចក្តីស្រេកបៀតបៀនហើយ ។

**ខុភតិ** កិ. [ខុភ + អ + តិ-វ.] កម្រើក, រញ្ជួយ, ញាប់ញ័រ ។

**ខុភិ** ធា. **សញ្ចលនេ ខោភតិ សង្ខោភតិ ខុព្ភតិ សង្ខុព្ភតិ ខោភោ សង្ខោភោ**"កម្រើក, រញ្ជួយ, ជ្រួលជ្រើម, ឆោឡោ, កម្រើកព្រម" ភូ. ទិ. ។ ការិត. **ខោភេតិ ខោភយតិ** ។ អា. **ហត្ថិនាគេ បទិន្នម្ហិ ខុព្ភិត្ថ នគរំ តទា**"កាលដែលទ្រង់ប្រទានដំរីហើយ ក្រុង (អ្នកក្រុង) ឆោឡោឡើងហើយក្នុងកាលនោះ" -ស.។

**ខុរ** បុំ., នបុំ. [ខុរ + អ] កាំបិតកោរ, ក្រចក ។ -**អគ្គ** គុ. ចុងនៃកាំបិតកោរ, កាលជាទីបំផុតនៃកម្មគឺបុគ្គលគប្បីធ្វើដោយកាំបិតកោរ ។ -**ធារា** ឥ. មុខនៃកាំបិតកោរ ។ ធម្មជាតជាគ្រឿងកាត់នូវផែនដី (ក្រចក), វិ. **ខុរតិ ឆិន្ទតិ បឋវឹ អនេនាតិ** > **ខុរំ** ។

**ខុរក** បុំ. ដើមទ្រមូច (ដូច **តិលក**)។

**ខុរប្ប** បុំ. កូនសរ (ដូច **តេជន**)។

**ខុរិ** ធា. **ឆេទនវិលេខនេសុ ខុរតិ**"កាត់, ចៀរ, គូស, សរសេរ, ធ្វើឲ្យមានស្នាម" ភូ.។ **ខុរ** បុំ. "កាំបិតកោរ, របស់ដែលមុត, កាត់, ក្រចក (សត្វ) -ស. ។

**ខុឡិ** ធា. **ពាល្យេ ឃសនេ ច ខុឡតិ**"ល្ងង់, ខ្លៅ, ស៊ី, បរិភោគ" ភូ. ។

**ខុំសិត** គុ. [ខុស + ឥ-អា. + ត, ចុះនិ-អា.] គឺ...ជេរហើយ, -ប្រទេចហើយ ។

**ខុំសេន្ត** គុ. [ខុស + អ + អន្ត, ចុះនិ-អា.] កាលជេរ, កាលប្រទេច ។

**ខុំសិ** ធា. **អក្កោសនេ ខុំសេតិ ខុំសយតិ ខុំសេន្តោ**"ជេរប្រទេច" ចុ. ។

**ខេ** ធា. ១-**ខាទនសត្តាសុ ខាយតិ បក្ខាយតិ ខាយិតំ**"កកេរ, ខាំស៊ី, ជា, ប្រាកដ,..."។ អា. **ឧន្ទូរា ខាយន្តិ** "កណ្តុរទ. កកេរស៊ី" ។ **គោខាយិត** នបុំ. ឬ គុ. "ស្មៅដែលគោស៊ី" ។ **អស្សិរី វិយ ខាយតិ**" ប្រាកដដូចជាគ្មានសិរី" ។ **ទិសាបិ មេ ន បក្ខាយន្តិ** "សូម្បីតែទិសទ. លែងប្រាកដដល់ខ្ញុំ" -ស. ។ **ខាយិតកំ** នបុំ. ឬ គុ "របស់ដែលសត្វខាំស៊ី" ។

២- **ខយេ ខាយតិ**"អស់, សូន្យ" ភូ. ។

**ខេដក** នបុំ. ខែល (ដូច **ចម្ម**)។

**ខេដិ** ធា. **ភក្ខនេ ខេដេតិ ខេដយតិ**"ស៊ី, បរិភោគ" ចុ. ។ **ខេដក** នបុំ" ខែល ក្តារ ឬ ស្បែកសម្រាប់ការពារអាវុធ" (សូចិ) ។

**ខេត្ត** នបុំ. [ខិប + ត] ទីដែលជនព្រោះនូវពូជ ឬទីជាទីព្រោះនូវពូជ(ស្រែ,